- សារលិខិតជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារ
ពលករ និងឆ្មាំទាំងអស់នៃអាជ្ញាធរជាតិអប្សរា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៥..............៤០៩

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែកក្កដា

ក្រុមការងារសហគមន៍ បន្តចុះពិនិត្យសំណើពលរដ្ឋ នៅក្នុងរមណីយដ្ឋានអង្គរ បានចំនួន ៦០ករណី និងសម្រេចអនុញ្ញាតបានចំនួន៥៤ករណី

ផ្សាយនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៤

ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងរមណីយដ្ឋានអង្គរ ត្រូវបានទទួលនូវការយកចិត្តទុកដាក់អំពីសំណាក់អាជ្ញាធរជាតិអប្សរា ដោយមានការអនុគ្រោះក្នុងការជួសជុលតូចតាចនូវលំនៅឋានក៏ដូចជាសំណង់ឧប្បសម្ព័ន្ធមាន របង ដំបូល ជញ្ជាំង សសរពុក បង្គន់អនាម័យ រោងគោ ទ្រុងមាន់ និងទ្រុងជ្រូកជាដើម នៅលើទីតាំងកំពុងរស់នៅផ្ទាល់តែម្តង តាមរយៈការចុះពិនិត្យ និងសម្រេចជាប្រចាំដោយក្រុមការងារសហគមន៍នាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា។ ជាក់ស្តែងក្នុងសប្តាហ៍ទី៣ (ទី១៧ដល់ទី២១) នៃខែមិថុនា ក្រុមការងារសហគមន៍បានចុះពិនិត្យសំណើបានចំនួន ៦០ករណី និងសម្រេចអនុញ្ញាតបានចំនួន ៥៤ករណី ទៅតាមបណ្តាលស្រុក/ក្រុងទាំង៥ ដូចខាងក្រោមៈ

- ស្រុកបន្ទាយស្រីអនុញ្ញាតបាន ២៣ករណី
- ក្រុងសៀមរាបអនុញ្ញាតបាន ១៩ករណី
- ស្រុកប្រាសាទបាគងអនុញ្ញាតបាន ២ករណី
- ស្រុកអង្គរធំអនុញ្ញាតបាន ៤ករណី
- ស្រុកពួកអនុញ្ញាតបាន ៦ករណី

សូមជម្រាបថា រាល់ការដាក់ពាក្យស្នើសុំច្បាប់ និងការអនុញ្ញាត គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ។ ជាមួយគ្នានេះ ក្រុមការងារសង្កេតឃើញថា ក៏មានអ្នកដែលទទួលបានការអនុញ្ញាតហើយ ប៉ុន្តែពុំបានអនុវត្តត្រឹមត្រូវស្របនឹងការអនុញ្ញាតនោះឡើយ។

ដូច្នេះអាជ្ញាធរជាតិអប្សរា សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតឱ្យជួសជុលលំនៅឋានត្រូវអនុវត្តឲ្យស្របតាមចំណុចបច្ចេកទេសដែលមានការទទួលដឹងឮពីអាជ្ញាធរមូលដ្ឋាននិងទទួលស្គាល់ដោយអាជ្ញាធរជាតិអប្សរា៕

អាជ្ញាធរជាតិអប្សរា សហការជាមួយអង្គការ IDE និងអង្គការ FAO បន្តដាំកូនឈើ ក្នុងបរិវេណរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៤

ក្នុងយុទ្ធនាការដាំដើមឈើ ដើម្បីអភិរក្សរមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោក កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ ថ្នាក់ដឹកនាំ និងបុគ្គលិករបស់អង្គការ IDE ប្រចាំខេត្តសៀមរាប ចំនួន២០នាក់ បានសហការជាមួយ អាជ្ញាធរជាតិអប្សរា ចូលរួមដាំកូនឈើចម្រុះចំនួន១០០ដើម នៅខាងកើតដងស្ទឹងសៀមរាប ស្ថិតនៅខាងជើងស្ពាន បច្ចេកទេស(ស្ពានរ៉ោករ៉ាក)នៃឧទ្យានអង្គរ។

នៅថ្ងៃដដែលនោះ ឆ្លៀតឱកាសកម្មវិធីសិក្ខាសាលា ថ្នាក់ដឹកនាំ បុគ្គលិករបស់អង្គការ FAO រួមជាមួយ សិក្ខាកាមចំនួន១២០នាក់ ក៏បានចូលរួមដាំកូនឈើចម្រុះ ចំនួន៦០០ដើម នៅខាងលិចដងស្ទឹងសៀមរាបនៃឧទ្យាន អង្គរ ដើម្បីបន្សល់ទុកជាស្នាដៃសម្រាប់ការងារសង្គម និង ទុកជាអនុស្សាវរីយ៍នៃការចងចាំក្នុងរមណីយដ្ឋានអង្គរផង។

កូរ៉េប្រគល់សម្ភារបរិក្ខារមួយចំនួនក្នុងគម្រោងអភិរក្ស និងជួសជុលក្រុមប្រាសាទព្រះពិធូរក្នុងជំហានទី២

ផ្សាយនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៤ អាជ្ញាធរជាតិអប្សរា និងមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េ នៃទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) បានរៀបចំពិធីប្រគល់សម្ភារបរិក្ខារមួយចំនួន ដើម្បីអនុវត្តន៍គម្រោងជួសជុលក្រុមប្រាសាទព្រះពិធូរជំហានទី២ និងព្រះលានជល់ដំរី។

លោក Song Youngjun នាយករងនៃទីភ្នាក់ងារ KOICA បានថ្លែងថា កម្ពុជា និងកូរ៉េ មានកិច្ចសហប្រតិបត្តិការលើវិស័យអភិរក្ស និងជួសជុលបេតិកភណ្ឌវប្បធម៌ ជាពិសេសគម្រោងក្នុងតំបន់រមណីយដ្ឋានអង្គរ រយៈពេលជិត១០ឆ្នាំមកហើយ រាប់ចាប់ពីឆ្នាំ២០១៥មក ដែលភាគីទាំងពីរបានចុះហត្ថលេខាលើកដំបូង ក្នុងកិច្ចពិភាក្សាគម្រោងដំណាក់កាលទី១ លើគម្រោងអភិរក្ស និងជួសជុលប្រាសាទព្រះពិធូរ។ ជិត១០ឆ្នាំមកនេះ មានសមិទ្ធផលផ្លែផ្កាជាច្រើន ក្នុងនោះភាពជាដៃគូដ៏រឹងមាំ និងស្និតរមួតរវាង KOICA និងអាជ្ញាធរជាតិអប្សរា ក៏បានក្លាយជាសមិទ្ធផលដ៏សំខាន់ និងលេចធ្លោបំផុត។

ចំពោះសម្ភារបរិក្ខារដែលប្រគល់ជូនដល់អាជ្ញាធរជាតិអប្សរា សរុប១១មុខផ្សេងគ្នា រួមមានម៉ាស៊ីនស្កេន 3D, រ៉ាដាពិនិត្យក្រោមដី និងកម្មវិធីវិភាគ និងបកស្រាយទិន្នន័យពីឧបករណ៍ទាំងនោះ រួមនិងសម្ភារមួយចំនួនទៀត។ លោក Song Youngjun បញ្ជាក់ថា ចាប់ពីគម្រោងទី១ រហូតមកដល់បច្ចុប្បន្ននេះ ឧបករណ៍ និងសម្ភារសរុប៩១មុខហើយ ដែលជាជំនួយផ្ទាល់របស់ KOICA ជូនទៅអាជ្ញាធរជាតិអប្សរា។ មន្ត្រីរូបនេះរំពឹងថា ការទទួលបានសម្ភារប្រើប្រាស់ខាងលើនេះ នឹងផ្ដល់អត្ថប្រយោជន៍ច្រើនដល់ការងារអភិរក្ស ក៏ដូចជាការស្រាវជ្រាវថ្មីៗបន្ថែមទៀតនៅតំបន់រមណីយដ្ឋានអង្គរ។

នាឱកាសនោះ **ឯកឧត្តម គឹម សុធិន** អគ្គនាយករងអាជ្ញាធរជាតិអប្សរា បានរំឭកថា មន្ទីរពិសោធន៍នេះបានក្លាយជាមន្ទីរពិសោធន៍ទី១នៅតំបន់អង្គរដែលបានបំពាក់ទៅដោយគ្រឿងបរិក្ខារតាមបែបវិទ្យាសាស្ត្រជាច្រើន ដែលអាចផ្ដល់ឱ្យអ្នកសិក្សាស្រាវជ្រាវ អាចសិក្សាវិភាគ និងស្រង់ទិន្នន័យផ្នែកស្ថាបត្យកម្មសិក្សាអំពីថ្មចាស់ ថ្មថ្មី និងលោហៈដែលបានមកពីបណ្ដាប្រាសាទនានា ដែលបានក្នុងតំបន់រមណីយដ្ឋានអង្គរ។

មន្ត្រីស្ថាប័នចម្រុះចូលរួមសិក្ខាស្ដីពី « ច្បាប់ និងបេតិកភណ្ឌវប្បធម៌ »

ផ្សាយនៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៤

មន្ត្រីអាជ្ញាធរជាតិអប្សរា អាជ្ញាធរជាតិព្រះវិហារ អាជ្ញាធរសំបូរព្រៃគុក អគ្គនាយកដ្ឋានបេតិកភណ្ឌ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មន្ទីរវប្បធម៌ខេត្តសៀមរាប អាជ្ញាធរដែនដីទាំង៥ស្រុក/ក្រុងក្នុងរមណីយដ្ឋានអង្គរ មន្ទីររៀបចំដែនដីខេត្តសៀមរាប តំណាងរដ្ឋបាល និងក្រុមប្រឹក្សាខេត្តសៀមរាប សហភាពសហព័ន្ធយុវជនកម្ពុជាខេត្តសៀមរាប និងអាជ្ញាធរដែនដីពាក់ព័ន្ធប្រមាណ៤៥រូប បានចូលរួមសិក្ខាសាលាស្ដីពី«ច្បាប់ និងកិច្ចការពារបេតិកភណ្ឌ» ដែលរៀបចំឡើងដោយអាជ្ញាធរជាតិអប្សរា រយៈពេលបីថ្ងៃ ចាប់ពីថ្ងៃទី២រហូតដល់ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៤។

សិក្ខាសាលានេះ មានការអញ្ជើញចូលរួមក្រោមអធិបតីភាព **ឯកឧត្តម ឡុង កុសល** អគ្គនាយករង ដែលតំណាងឱ្យ**ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា និងឧទ្ទេសនាមដោយលោក Etienne Clement មេធាវីអន្តរជាតិ ឯកទេសខាងបេតិកភណ្ឌវប្បធម៌ គឺធ្វើឡើងក្នុងគោលបំណង ឱ្យយល់ដឹងពីសម្បត្តិបេតិកភណ្ឌវប្បធម៌ ពីការប៉ះពាល់នានា ព្រមទាំងការប្រើច្បាប់ជាតិ អន្តរជាតិ ដើម្បីការពារសម្បត្តិបេតិកភណ្ឌទាំងនោះ ពីការបំផ្លាញដោយមនុស្ស ដោយអាយុកាល និងដោយគ្រោះធម្មជាតិជាដើម។

កម្មវិធីនេះ ជាវេទិកាសម្រាប់ការចែករំលែកបទពិសោធន៍ ការផ្ដល់ឱ្យសិក្ខាកាម ថ្នាក់ដឹកនាំមកពីស្ថាប័នគ្រប់គ្រងបេតិកភណ្ឌ ដើម្បីស្វែងយល់ពីគោលបំណង មាតិកា និងការបន្ថែមនូវអនុសញ្ញាអន្តរជាតិសំខាន់ៗ រួមនឹងគោលការណ៍ច្បាប់ជាតិ ដែលជាទម្រង់ស្របច្បាប់សម្រាប់កិច្ចការពារសម្បត្តិបេតិកភណ្ឌក្នុងប្រទេសកម្ពុជា។ សិក្ខាកាមនឹងទទួលបាននូវចំណេះដឹងថ្មីៗក្នុងទម្រង់ច្បាប់ការពារបេតិកភណ្ឌ ដែលឆ្លើយតបទៅនឹងតួនាទី និងភារកិច្ចរបស់ខ្លួនក្នុងនាមជាអ្នកអភិរក្ស និងគ្រប់គ្រងបេតិកភណ្ឌ៕

សោភ័ណភាពប្រាសាទតុបខាងលិច ក្រោយពេលជួសជុល

ផ្សាយនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៤

ប្រាសាទតុបខាងលិច កសាងនៅសតវត្សរ៍ទី១០ និងកសាងបន្ថែមនៅសតវត្សរ៍ទី១៣ ដល់សតវត្សរ៍ទី១៧ ដោយខឿនដើមសង់ពីថ្មបាយក្រៀម ត្រូវបានរៀបថ្មភក់មួយជាន់ពីលើ។ តួប៉មកណ្តាលក៏កែកុនដែរដោយរក្សាទុកនូវផ្នែកចម្លាក់លម្អផ្សេងៗ ដូចជា ផ្តែរ និងសសរធ្វើពីថ្មភក់ពណ៌ផ្កាឈូក ព្រមទាំងសង់បន្ថែមតួប៉មចំនួនពីរនៅសងខាងបន្ថែមទៀត។ តួប៉មទាំងអស់នោះសុទ្ធតែមានចម្លាក់រូបព្រះពុទ្ធសាសនា។ នៅសម័យកណ្តាល សាងខឿនទ្រវែងមួយ តពីខឿនចាស់មកខាងកើត។ នៅចុងខាងលិចនៃ ខឿនលយថ្មីនេះ គេឃើញសំណល់បល្ល័ង្កព្រះធំមួយ។

ដោយសារអាយុកាល កត្តាធម្មជាតិ និងការកង្វះការថែទាំរយៈពេលយូរ បានធ្វើឱ្យប្រាសាទនេះរងការខូចខាតស្ទើរតែទាំងស្រុង។ ពេលបច្ចុប្បនេះ ក្រោយចំណាយពេលជួសជុលអស់ជាច្រើនឆ្នាំ ក្រោមកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា ជាមួយវិទ្យាស្ថានជាតិណារ៉ាប្រទេសជប៉ុន ប្រាសាទតុបលិច បានឈររឹងមាំឡើងវិញ បង្ហាញនូវសោភ័ណភាព សម្រាប់ជាទីគោរពបូជា និងទស្សនាស្វែងយល់ពីស្ថាបត្យកម្ម និងក្បាច់ចម្លាក់ផ្សេងៗ។ ត្បិតប្រាសាទតូចមួយនេះ មានភាពស្រស់ស្អាត និងគួរជាទីចាប់អារម្មណ៍ទាំងប្រាសាទ និងធម្មជាតិជុំវិញ ដែលទេសចរមិនត្រូវរំលង។

សូមបញ្ជាក់ថា ប្រាសាទតុបខាងលិច ស្ថិតនៅក្នុងរាជធានីអង្គរធំ ឬនៅខាងលិចប្រាសាទបាយ័ន ចន្លោះប្រាសាទបាយ័ន និងខ្លោងទ្វារតាការ។ បើធ្វើដំណើរចេញពីប្រាសាទបាយ័នស្ថិតនៅខាងឆ្វេងដៃមានចម្ងាយ៧០០ម៉ែត្រ និងពីខ្លោងទ្វារតាការខាងស្តាំដៃ មានចម្ងាយ៨០០ម៉ែត្រ៕

កូនឈើចម្រុះចំនួន៦,១៥០ដើម ត្រូវបានអាជ្ញាធរជាតិអប្សរាចែកចាយ ពីថ្ងៃទី២៤ ខែមិថុនា ដល់ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៤

- ផ្តល់កូនឈើចម្រុះជូនតំណាងកងពលធំអន្តរាគមន៍លេខ២ ចំនួន៣,០០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណទីបញ្ជាការ ស្ថិតនៅភូមិស្រះខ្វាវ ឃុំត្បែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន ធ្នង់៥០០ដើម បេង៥០០ដើម គ្រញូង៥០០ដើម ដើមយាង៥០០ដើម គគីរ៥០០ដើម និងកកោះ៥០០ដើម។

- ផ្តល់កូនឈើចម្រុះជូនអ្នកស្រី សាញ់ សោភ័ណ្ឌ ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន៨០ដើម ដើម្បីយកទៅដាំតាមដងផ្លូវ នៅភូមិពួក ឃុំពួក ស្រុកពួក ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន ដើមយាង១៥ដើម ធ្នង់១៥ដើម បេង២០ដើម និងគ្រញូង៣០ដើម។

- ផ្តល់កូនឈើចម្រុះជូនលោក ប្រាង គីមស៊ីន ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន១,២០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណវត្តអារាម ស្ថិតនៅភូមិត្រពាំងថ្ម ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។ កូនឈើទាំងនោះរួមមាន គ្រញូង៣០០ដើម ធ្នង់២០០ដើម បេង២០០ដើម ត្រាច២០០ដើម គគីរ២០០ និងក្រោក១០០ដើម។

- ផ្តល់កូនឈើចម្រុះជូនលោក ប៉េង ពិសិដ្ឋ បម្រើការងារនៅក្រុមហ៊ុនតូតាល់អេនើជី(ខេមបូឌា)ឯ.ក ចំនួន២៥ដើម ដើម្បីយកទៅដាំនៅរាជធានីភ្នំពេញ។ កូនឈើទាំងនោះរួមមាន គ្រញូង៥ដើម ធ្នង់៥ដើម បេង៥ដើម និងក្រោក១០ដើម។

- ប្រគេនកូនឈើចម្រុះជូនព្រះអង្គ រតនសារោ ទិត្យ ដារ៉ា ចំនួន៩០០ដើម ដើម្បីយកទៅដាំលំអក្នុងបរិវេណវត្តមេណីយារាម ស្ថិតក្នុងសង្កាត់ពញាពន់ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។ កូនឈើទាំងនោះរួមមាន គ្រញូង៣០០ដើម បេង២០០ដើម ធ្នង់២០០ដើម និងច្រេស២០០ដើម។

- ផ្តល់កូនឈើចម្រុះជូនអង្គការ IDE ចំនួន១០០ដើម ដើម្បីយកទៅដាំតាមមាត់ស្ទឹងសៀមរាប ស្ថិតនៅខាងជើងស្ពានរ៉ាក់រ៉ាកនៃរមណីយដ្ឋានអង្គរ។ កូនឈើទាំងនោះរួមមាន ធ្នង់២០ដើម បេង២០ដើម ច្រេស២០ដើម រំដួល២០ដើម និងឥន្ទនេល២០ដើម។

- ផ្តល់កូនឈើចម្រុះជូនអង្គការ FAO ចំនួន៦០០ដើម ដើម្បីយកទៅដាំតាមមាត់ស្ទឹងសៀមរាប ស្ថិតនៅខាងជើងស្ពានរ៉ាក់រ៉ាកនៃរមណីយដ្ឋានអង្គរ។ កូនឈើទាំងនោះរួមមាន ធ្នង់១០០ដើម បេង១០០ដើម ច្រេស១០០ដើម គគីរ១០០ដើម រំដួល៥០ដើម ពុល៥០ដើម ក្រោក៥០ដើម និងឥន្ទនេល៥០ដើម។

- ផ្តល់កូនឈើចម្រុះជូនលោក ឡុង សុជាតិ ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន៧៥ដើម ដើម្បីយកទៅដាំអមតាមផ្លូវ នៅក្នុងសង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន ដើមយាង ៥០ដើម និងធ្នង់២៥ដើម។

- ផ្តល់កូនឈើចម្រុះជូនលោក ម៉ៅ រតនា ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន២០ដើម ដើម្បីយកទៅដាំដីផ្ទាល់ខ្លួន នៅជើងភ្នំគូលែន។ កូនឈើទាំងនោះរួមមាន ធ្នង់១៦ដើម និងបេង៤ដើម។

- ផ្តល់កូនគ្រញូងជូនលោក សួម វីរៈ ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន១៥០ដើម ដើម្បីយកទៅដាំដីផ្ទាល់ខ្លួន និងតាមផ្លូវជាតិលេខ៥ ស្ថិតនៅស្ថិតនៅភូមិដំនីក ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង។

អាជ្ញាធរជាតិអប្សរាចូលរួមកិច្ចប្រជុំក្រុមការងារ ដឹកនាំគម្រោង Angkor Water Resilience

ផ្សាយនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៤

នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៤ ក្រុមការងារដឹកនាំគម្រោង Angkor Water Resilience ដែលមានអាជ្ញាធរជាតិអប្សរា និងក្រសួងការបរទេស និងពាណិជ្ជកម្មនៃប្រទេសនូវែលសេឡង់ បានជួបប្រជុំគ្នា ដើម្បីពិនិត្យវាយតម្លៃការអនុវត្តការងារកន្លងមក និងផ្ដល់អនុសាសន៍ដល់ក្រុមការងារបច្ចេកទេសសម្រាប់អនុវត្តការងារបន្តទៀត៕

សប្តាហ៍ទី៤នៃខែមិថុនា ឆ្នាំ២០២៤នេះ ក្រុមការងារសហគមន៍ បន្តចុះពិនិត្យសំណើពលរដ្ឋនៅក្នុងរមណីយដ្ឋានអង្គរ បានចំនួន៥៤ករណី និងសម្រេចអនុញ្ញាតបានចំនួន ៤៤ករណី

ផ្សាយនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៤

ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងរមណីយដ្ឋានអង្គរ ត្រូវបានទទួលនូវការយកចិត្តទុកដាក់អំពីសំណាក់អាជ្ញាធរជាតិអប្សរា ដោយមានការអនុគ្រោះក្នុងការជួសជុលតូចតាចនូវលំនៅដ្ឋានក៏ដូចជាសំណង់ឧប្បសម្ព័ន្ធមាន របង ដំបូល ជញ្ជាំង សសរពុកមួយចំនួន បង្គន់អនាម័យ រោងគោ ទ្រុងមាន់ និងទ្រុងជ្រូកជាដើម នៅលើទីតាំងកំពុងរស់នៅផ្ទាល់តែម្តងតាមរយៈការចុះពិនិត្យ និងសម្រេចជាប្រចាំដោយក្រុមការងារសហគមន៍ នាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍នៃអាជ្ញាធរជាតិអប្សរា។ ជាក់ស្តែងក្នុងសប្តាហ៍ទី៤ (ទី២៤ដល់ទី២៨) នៃខែមិថុនា ក្រុមការងារសហគមន៍បានចុះពិនិត្យសំណើបានចំនួន ៥៤ករណី និងសម្រេចអនុញ្ញាតបានចំនួន ៤៤ករណី ទៅតាមបណ្តាលស្រុក/ក្រុងទាំង៥ ដូចខាងក្រោម៖

- ស្រុកបន្ទាយស្រីអនុញ្ញាតបាន ៨ករណី
- ស្រុកប្រាសាទបាគងអនុញ្ញាតបាន ៣ករណី
- ក្រុងសៀមរាបអនុញ្ញាតបាន ២៧ករណី
- ស្រុកពួកអនុញ្ញាតបាន ៣ករណី
- ស្រុកអង្គរធំអនុញ្ញាតបាន ៣ករណី

សូមជម្រាបថា រាល់ការដាក់ពាក្យស្នើសុំច្បាប់ និងការអនុញ្ញាត គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ។ ជាមួយគ្នានេះ ក្រុមការងារសង្កេតឃើញថា ក៏មានអ្នកដែលទទួលបានការអនុញ្ញាតហើយ ប៉ុន្តែពុំបានអនុវត្តត្រឹមត្រូវ ស្របនឹងការអនុញ្ញាតនោះឡើយ។

ដូច្នេះអាជ្ញាធរជាតិអប្សរា សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតឱ្យជួសជុលលំនៅដ្ឋានត្រូវអនុវត្តឲ្យស្របតាមចំណុចបច្ចេកទេសដែលមានការទទួលដឹងឮ ពីអាជ្ញាធរមូលដ្ឋាន និងទទួលស្គាល់ដោយអាជ្ញាធរជាតិអប្សរា៕

ទិដ្ឋភាពភ្ញៀវទេសចរនៅប្រាសាទអង្គរវត្ត ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៤

ប្រាសាទអង្គរវត្ត ជាទីទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិ ចូលមកទស្សនា និងថតផ្តិតរូបភាពជាពិសេសសម្រស់ព្រះអាទិត្យរះនៅពេលព្រឹកព្រលឹម។

ទិដ្ឋភាពភ្ញៀវទេសចរចម្រុះជាតិសាសន៍ ទស្សនាប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៤

ភ្ញៀវទេសចរចម្រុះជាតិសាសន៍ ទស្សនាប្រាសាទអង្គរវត្ត មានជាឯកជន គ្រួសារ មិត្តភក្តិ និងខ្លះមានមគ្គុទ្ទេសក៍អធិប្បាយរឿងរ៉ាវប្រវត្តិសាស្ត្រ ប្រវត្តិសិល្បៈ ស្ថាបត្យកម្ម និងថតផ្តិតរូបភាពផង មុននឹងបន្តដំណើរទៅទស្សនានៅតាមប្រាង្គប្រាសាទ និងគោលដៅទេសចរណ៍សំខាន់ៗជាច្រើនទៀត។

សូមភ្ញៀវទេសចរជាតិ និងអន្តរជាតិគោរពក្រមប្រតិបត្តិអង្គរ និងចូលរួមថែរក្សាបរិស្ថាននៅក្នុងរមណីយដ្ឋានអង្គរទាំងអស់គ្នា៕



ទិដ្ឋភាពភ្ញៀវទេសចរ ចូលទស្សនាប្រាសាទតាព្រហ្ម នាថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៤

សិក្ខាសាលាស្តីពី «ច្បាប់ និងបេតិកភណ្ឌវប្បធម៌» បានបញ្ចប់ដោយជោគជ័យ

ផ្សាយនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៤

សិក្ខាសាលាបណ្តុះបណ្តាលសមត្ថភាពស្តីពី«ច្បាប់ និងបេតិកភណ្ឌវប្បធម៌»រយៈពេល៣ថ្ងៃ ដែលឧទ្ទេសនាមដោយមេធាវីអន្តរជាតិ ជាអ្នកឯកទេសខាងបេតិកភណ្ឌវប្បធម៌ លោក Etienne Clement បានបញ្ចប់ដោយជោគជ័យ នៅរសៀលថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៤។

សិក្ខាសាលារៀបចំធ្វើ តាំងពីថ្ងៃទី២ ខែកក្កដានោះ មានគោលបំណងបង្កើនសមត្ថភាពមន្ត្រីចម្រុះ មកពីអាជ្ញាធរជាតិអប្សរា អាជ្ញាធរជាតិព្រះវិហារ អាជ្ញាធរសំបូរព្រៃគុក អគ្គនាយកដ្ឋានបេតិកភណ្ឌនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មន្ទីរវប្បធម៌ខេត្តសៀមរាប មន្ទីររៀបចំដែនដីខេត្តសៀមរាប អាជ្ញាធរដែនដីទាំង៥ស្រុក/ក្រុងក្នុងរមណីយដ្ឋានអង្គរ និងសហភាពសហព័ន្ធយុវជនកម្ពុជាខេត្តសៀមរាប ឱ្យយល់ដឹងពីគោលការណ៍ច្បាប់ទាំងក្របខណ្ឌជាតិ និងអន្តរជាតិ ដើម្បីលើកតម្លៃ និងថែរក្សាសម្បត្តិបេតិកភណ្ឌវប្បធម៌។

សិក្ខាសាលាដែលបានពន្យល់ជាច្រើន ដែលទាក់ទងនឹងអនុសញ្ញាអន្តរជាតិសំខាន់ៗពាក់ព័ន្ធនឹងការគ្រប់គ្រងថែរក្សាបេតិកភណ្ឌវប្បធម៌ឱ្យកានតែមានប្រសិទ្ធភាពខ្ពស់៕

ការងារកាត់សម្អាតស្មៅ និងកូនរុក្ខជាតិនានា នៅក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៤

ក្រុមការងារសម្អាតបរិស្ថានរបស់អាជ្ញាធរជាតិអប្សរា បានបន្តសម្អាតកាត់ស្មៅ និងកូនរុក្ខជាតិនៅតាមគោលដៅរបស់ខ្លួន នៅក្នុងតំបន់រមណីយដ្ឋានអង្គរ ដើម្បីរក្សាបាននូវសោភ័ណភាពស្រស់ស្អាតជាប្រចាំ។ ជាពិសេសនៅរដូវវស្សា ខណៈមានភ្លៀងញឹកញាប់ ក្រុមការងារតាមគោលដៅនីមួយៗកាន់តែពន្លឿនសកម្មភាពការងារដើម្បីឱ្យទាន់សភាពការណ៍៕

ខ្លោងទ្វារទន្លេអុំ ជាទីដ៏ទាក់ទាញសម្រាប់ភ្ញៀវទេសចរថតយករូបភាព

ផ្សាយនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៤

ខ្លោងទ្វារទន្លេអុំ ជាទីដ៏ទាក់ទាញសម្រាប់ទេសចរថតរូបអនុស្សាវរីយ៍ជាមួយសម្រស់ស្រស់ស្អាត និងទាក់ទាញនូវរូបចម្លាក់យក្ស និងទេវតាទាញព្រ័ត្រ។

ទិដ្ឋភាពភ្ញៀវទេសចរ ចូលទស្សនាប្រាសាទនាគព័ន្ធ នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរាតែងតែយកចិត្តទុកដាក់ចំពោះទេសចរគ្រប់រូប ដែលមកទស្សនានៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៤

ក្រុមការងារភ្នាក់ងារទេសចរ និងភ្នាក់ងារសណ្តាប់ធ្នាប់របស់អាជ្ញាធរជាតិអប្សរា ដែលប្រចាំការនៅទីតាំងប្រាសាទសំខាន់ៗ និងទេសចរចូលទស្សនាច្រើន តែងតែជួយសម្រួលចរាចរណ៍ មើលការខុសត្រូវចំពោះយានយន្តគ្រប់ប្រភេទឱ្យចូលចតនៅចំណតបានត្រឹមត្រូវ រក្សាបាននូវសណ្តាប់ធ្នាប់ល្អ និងសុវត្ថិភាពដល់ភ្ញៀវទេសចរ។

អាជ្ញាធរជាតិអប្សរា សូមអំពាវនាវដល់អ្នកបើកបរយានយន្តគ្រប់ប្រភេទ បើកបរដោយប្រុងប្រយ័ត្នខ្ពស់ និងគោរពច្បាប់ចរាចរណ៍នៅក្នុងរមណីយដ្ឋានអង្គរ ដើម្បីសុវត្ថិភាពទាំងអស់គ្នា ព្រោះនៅតាមទីតាំងទស្សនាមួយចំនួននៅកៀកនិងផ្លូវហើយមានភ្ញៀវទេសចរដើរឆ្លងកាត់ទស្សនា និងថតរូបជាប្រចាំ៕

រូបភាពប្រចាំសប្តាហ៍៖
ប្រាសាទបាលិលេយ្យ
ហាក់បីដូចកំបាំងភ្នែកទេសចរ
កម្របានទៅដល់ ប៉ុន្តែប្រាសាទនេះ
ជាទីពេញនិយមសម្រាប់ការថតរូប
អនុស្សាវរីយ៍មុនរៀបអាពាហ៍ពិពាហ៍
ជាដើម

ត្បិតតែ រចនាសម្ព័ន្ធប្រាសាទ
រងការខូចខាតច្រើនអន្លើក្តី
តែក៏ជាទីទាក់ទាញមួយ
ជាមួយសំណង់ស្លាបត្បកម្ម
ដើមឈើ និងព្រៃឈើស្រស់ស្អាត
ខុសប្លែកពីប្រាសាទផ្សេងៗ

ផ្សាយនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៤

ថ្ងៃលិចលើភ្នំបាខែង នៅតែជាជម្រើសពិសេសសម្រាប់ទេសចរ

ផ្សាយនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៤

មិនថាពេលណាជាពេលនោះទេ ការទស្សនាថ្ងៃលិចនៅលើកំពូលប្រាសាទភ្នំបាខែង គឺជាជម្រើសដ៏ពិសេសសម្រាប់ភ្ញៀវទេសចរ នៅពេលដែលពួកគេមកកម្សាន្តនៅរមណីយដ្ឋានអង្គរ។ ពន្លឺពណ៌មាសចែងចាំងលើកំពូលប្រាសាទមួយនេះ ជាផ្ទាំងទស្សនីយភាពដ៏អស្ចារ្យបំផុតសម្រាប់ទេសចរ៕

សកម្មភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិ ចូលទស្សនាប្រាសាទបាយ័ន ព្រឹកថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៤

សកម្មភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិ ទស្សនា និងថតផ្តិតរូបភាពនៅខ្លោងទ្វារទន្លេអុំ ព្រឹកថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា សហការជាមួយវិទ្យាស្ថានខេមអេដ បន្តដាំកូនឈើនៅបរិវេណខាងមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៤

នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៤ ឆ្លៀតឱកាសក្នុងកម្មវិធីទស្សនកិច្ចប្រចាំឆ្នាំ និងជិះកង់កម្សាន្តក្នុងរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ក្រុមនិស្សិតនៃវិទ្យាស្ថានខេមអេដ (CamEd Business School) ចំនួន១៩១នាក់ បានសហការជាមួយអាជ្ញាធរជាតិអប្សរា ដាំកូនឈើចម្រុះចំនួន២០០ដើម និងស្មៅចំនួន១០០ម៉ែត្រការ៉េ នៅបរិវេណអតីតផ្សារយាងធំ ស្ថិតនៅខាងជើងឆៀងខាងលិចប្រាសាទអង្គរវត្ត ដើម្បីចូលរួមក្នុងយុទ្ធនាការដាំដើមឈើ និងស្មៅ។ ការងារនេះ ដើម្បីអភិរក្សរមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោក សម្រាប់បន្សល់ទុកជាស្នាដៃការងារសង្គម និងជាអនុស្សាវរីយ៍នៃការចងចាំក្នុងរមណីយដ្ឋានអង្គរផង៕

រូបភាពប្រចាំសប្តាហ៍៖ ទិដ្ឋភាពប្រាសាទបាគង ពីលើអាកាសនាពេលព្រឹកព្រលឹម

ផ្សាយនៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៤

ភ្នាក់ងារទេសចរនៃអាជ្ញាធរជាតិអប្សរា ប្រគល់សម្ភារៈជូនភ្ញៀវទេសចរដែលភ្លេច នៅរមណីយដ្ឋានអង្គរ ចំនួន២ករណី

ផ្សាយនៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៤

ក្រុមការងារភ្នាក់ងារទេសចរ និងភ្នាក់ងារសណ្តាប់ធ្នាប់ប្រចាំគោលដៅអតីតក្រុងអង្គរធំបាន បានសហការជាមួយនគរបាលទេសចរណ៍ និងនគរបាលការពារបេតិកភណ្ឌ ប្រគល់កាបូបស្ពាយចំនួនមួយ ដល់ភ្ញៀវទេសចរជនជាតិចិនជាម្ចាស់ដើមដែលបានភ្លេចនៅរួតទីពីរទិសខាងលិចធៀងខាងជើងនៃប្រាសាទបាយ័ន ក្រោយពីទេសចរខ្មែរម្នាក់រើសបាន និងយកមកប្រគល់មកក្រុមការងារដើម្បីរក្សា និងប្រគគល់ជូនម្ចាស់ដើមវិញ។

ករណីដូចគ្នានេះដែរ ក្រុមភ្នាក់ងារទេសចរគោលដៅប្រាសាទប្រែរូប បានប្រទះឃើញទូរស័ព្ទចំនួនមួយគ្រឿង នៅបរិវេណច្រកចូលខាងកើតនៃប្រាសាទប្រែរូប និងបានសហការជាមួយភ្នាក់ងារសណ្តាប់ធ្នាប់ នគរបាលទេសចរណ៍ និងនគរបាលការពារបេតិកភណ្ឌ ប្រគល់ជូនម្ចាស់ដើមដែលជាទេសចរមកពីប្រទេសអ៊ីស្រាអែល ក្រោយពីពិនិត្យឃើញថា ពិតជារបស់គាត់ពិតមែន៕

ដាំកូនឈើ១,០០០ដើមនៅរមណីយដ្ឋានអង្គរ ដើម្បីអបអរសាទរខួបរុក្ខទិវាជាតិ ៩កក្កដា ២០២៤

ផ្សាយនៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៤ កាកបាទក្រហមកម្ពុជាសហការជាមួយអាជ្ញាធរជាតិអប្សរា បានប្រារព្ធ យុទ្ធនាការដាំដើមឈើ ចំនួន១,០០០ដើម អបអរសាទរខួប រុក្ខទិវាជាតិ៩កក្កដា ២០២៤ ក្រោមប្រធានបទ " ព្រៃឈើ ដើម្បីប្រជាជន និងការអភិវឌ្ឍដោយចីរភាព" នៅតាមបណ្តោយវិថីព្រះនរោត្តមសីហមុនី ស្ថិតនៅភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប។

អញ្ជើញជាអធិបតីនាឱកាសនោះមាន **ឯកឧត្តម ពិត ចំណាន** សមាជិកគណៈកម្មាធិការកណ្តាលកាកបាទក្រហមកម្ពុជា **ឯកឧត្តម យូ ឡាណា** អគ្គលេខាធិការរងកាកបាទក្រហមកម្ពុជា **លោកជំទាវ ទុយ ជិ ប្រាក់ សោភ័ណ** អនុប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមកម្ពុជា ខេត្តសៀមរាប **ឯកឧត្តម ឡុង កុសល** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់**ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា ព្រមទាំងវត្តមានលោក លោកស្រី ប្រធានឬតំណាងអង្គភាពមន្ទីរជំនាញពាក់ព័ន្ធជុំវិញខេត្ត ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិកអាជ្ញាធរជាតិអប្សរា និងសមាជិក សមាជិកានៃគណៈកម្មាធិការកាកបាទក្រហមកម្ពុជា មកពីសាខា ខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ កំពង់ធំ និងព្រះវិហារផងដែរ។

ឯកឧត្តម ឡុង កុសល អគ្គនាយករងអាជ្ញាធរជាតិអប្សរាមានប្រសាសន៍នាឱកាសនោះថា អាជ្ញាធរជាតិអប្សរាមានសេចក្តីសោមនស្សរីករាយក្នុងការផ្តល់នូវកិច្ចសហការ និងការរៀបចំទីតាំង ព្រមទាំងកូនឈើក្នុងព្រឹត្តិការណ៍នេះ។ ព្រៃឈើ និងធម្មជាតិនៅជុំវិញគឺជាផ្នែកមួយដែលពុំអាចកាត់ផ្តាច់បានពីប្រាសាទ ដូចនេះ ការការពារ ការថែរក្សា និងការបង្កើនឡើងវិញនូវព្រៃឈើគឺជាអទិភាពមួយក្នុងចំណោមអទិភាពជាច្រើន។ ជាក់ស្តែង តាំងពីឆ្នាំ២០០៤មក ដល់បច្ចុប្បន្នអាជ្ញាធរជាតិអប្សរា បានដាំកូនឈើឡើងវិញបានចំនួនប្រមាណ២លានដើមរួចមកហើយ។ ទន្ទឹមនេះ ក៏មានការចែកជូនកូនឈើ ដោយមិនគិតថ្លៃ ទៅដល់ស្ថាប័នរដ្ឋ វិស័យឯកជន និងប្រជាពលរដ្ឋទូទៅយកទៅដាំដុះបន្ត ក្នុងន័យដើម្បីពង្រីកនូវគម្របព្រៃឈើបន្ថែមក្នុងទូទាំងប្រទេសកម្ពុជា។

ឯកឧត្តម ពិត ចំណាន សមាជិកគណៈកម្មាធិការកណ្តាលកាកបាទក្រហមកម្ពុជាមានប្រសាសន៍ថា យុទ្ធនាការដាំកូនឈើ១,០០០ដើម អបអរសាទរខួបលើកទី៧២ រុក្ខទិវា៩កក្កដា ២០២៤ ក្រោមប្រធានបទ " ព្រៃឈើ ដើម្បីប្រជាជន និងការអភិវឌ្ឍដោយចីរភាព" បានសបញ្ជាក់ពីសេចក្តីស្រឡាញ់ ឆន្ទៈ និងស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការចូលរួមថែរក្សាបរិស្ថាន ព្រៃឈើឱ្យបានគង់វង្ស ដើម្បីសុខុមាលភាពរបស់មនុស្សជាតិ។ ឯកឧត្តមថា យុទ្ធនាការនេះ មិនមែនជាលើកទីមួយឡើយ កន្លងមកកាកបាទក្រហមកម្ពុជា បានដាំដើមឈើជាបន្តបន្ទាប់ ក្នុងនោះឧទ្យានសហសវត្សរ៍របស់កាកបាទក្រហមកម្ពុជា មានដើមឈើតូចធំជាច្រើន បានក្លាយជាគម្របធម្មជាតិ និងជាផ្នែកមួយក្នុងការការពារបរិស្ថានក្នុងតំបន់រមណីយដ្ឋានអង្គរផងដែរ។

ជាមួយគ្នានេះ ឯកឧត្តមក៏បានថ្លែងអំណរគុណ អាជ្ញាធរជាតិអប្សរា និងស្ថាប័នពាក់ព័ន្ធចំពោះកិច្ចការសម្របសម្រួលផ្តល់ទីតាំង ក៏ដូចជាកូនឈើសម្រាប់ដាំ នៅក្នុងយុទ្ធនាការដាំកូនឡើងវិញ អបអរសាទរខួបលើកទី៧២ រុក្ខទិវា៩កក្កដា ២០២៤៕

កូនឈើចម្រុះចំនួន៩,២២៥ដើម ត្រូវបានអាជ្ញាធរជាតិអប្សរាចែកចាយ ពីថ្ងៃទី០៣ដល់ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២៤

កូនឈើដែលបានចែកចាយទាំងនោះរួមមានៈ

- ប្រគេនកូនឈើចម្រុះជូនព្រះភិក្ខុ សមថវិរិយោ សារឿន វ៉ាន់ឌី ព្រះចៅអធិការវត្តសុវណ្ណគិរី ចំនួន២,៥០០ដើម ដើម្បីយកទៅដាំលំអក្នុងបរិវេណវត្ត និងសាលារៀន ស្ថិតក្នុងភូមិស្រះលិច ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ កូនឈើទាំងនោះរួមមាន គ្រញូង៥០០ដើម បេង៣០០ដើម ធ្នង់៣០០ដើម ប្រេស២០០ដើម គគីរ៥០០ដើម ឈើទាល៥០០ដើម និងរំដួល២០០ដើម។
- ផ្តល់កូនឈើចម្រុះជូនតំណាងលោក នួន ពុទ្ធារ៉ា អភិបាលក្រុងសៀមរាប ចំនួន៥,០០០ដើម ដើម្បីយកទៅដាំលម្អសោភណភាព ក្នុងយុទ្ធនាការដាំកូនឈើតាមដងផ្លូវក្នុងក្រុងសៀមរាប។ កូនឈើទាំងនោះរួមមាន លឿងរាជ១,២០០ដើម ត្របែកព្រៃ៦០០ដើម ក្រោក៦០០ដើម ចាមរី៤០០ដើម ធ្នង់៦០០ដើម ឈើទាល៤០០ដើម គគីរ៦០០ដើម និងរំដួល៦០០ដើម។
- ផ្តល់កូនឈើចម្រុះជូនតំណាងក្រុមហ៊ុនHCC Angkor ចំនួន៣៦៥ដើម ដើម្បីយកទៅដាំលម្អតាមដងស្ទឹងសៀមរាប ខាងជើងស្ពានរ៉ាក់រ៉ាក ស្ថិតនៅភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាបនៃរមណីយដ្ឋានអង្គរ។ កូនឈើទាំងនោះរួមមាន ធ្នង់១០០ដើម ប្រេស១០០ដើម បេង៥០ដើម គ្រញូង៤០ដើម រំដួល៥០ដើម និងក្រោក២៥ដើម ។

- ផ្តល់កូនឈើចម្រុះជូនលោក ម៉ា វណ្ណៈ ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន១០ដើម ដើម្បីយកទៅដាំលើដីផ្ទាល់ខ្លួន ស្ថិតនៅភូមិគោកស្រុក ឃុំរលួស ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន អំពិល២ដើម រាំងទឹក៥ដើម និងរំដួល៣ដើម។
- ផ្តល់កូនឈើចម្រុះជូនលោក ថោង បញ្ញាវ័ន្ត ប្រធានស្ដីទីមន្ទីរពេទ្យបង្អែកប៊ុនរ៉ានី ហ៊ុនសែនរុនតាឯក ចំនួន១៥០ដើម ដើម្បីយកទៅដាំលម្អក្នុងបរិវេណមន្ទីរពេទ្យ និងតាមដងផ្លូវជុំវិញមន្ទីរពេទ្យ ស្ថិតក្នុងក្រុងរុនតាឯក តេជោសែន។ កូនឈើទាំងនោះរួមមាន ត្របែកព្រៃ៥០ដើម ក្រោក៥០ដើម ចាមរី២០ដើម និងរំដួល៣០ដើម។
- ផ្តល់កូនឈើចម្រុះជូនវិទ្យាស្ថានខេមអេដ (CamEd Business School) ចំនួន២០០ដើម ដើម្បីយកទៅដាំនៅបរិវេណខាងជើងអតីតផ្សារយាងធំនៃរមណីយដ្ឋានអង្គរ។ កូនឈើទាំងនោះរួមមាន ធ្នង់១០០ដើម ឈើទាល៥០ដើម រំដួល២៥ដើម និងឥន្ទនេល២៥ដើម។
- ផ្តល់កូនឈើចម្រុះជូនកាកបាទក្រហមកម្ពុជា ចំនួន១,០០០ដើម ដើម្បីយកទៅដាំតាមវិថីព្រះនរោត្តមសីហមុនីនៃរមណីយដ្ឋានអង្គរ ស្ថិតក្នុងភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន គគីរ១០០ដើម ឈើទាល២០០ដើម ធ្នង់២០០ដើម បេង១០០ដើម ប្រេស២០០ដើម គ្រញូង១០០ដើម និងរំដួល១០០ដើម។

ទិដ្ឋភាពភ្ញៀវទេសចរ
ទស្សនានៅប្រាសាទបេងមាលា
ផ្សាយនៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២៤

ក្រុមការងារពិនិត្យ និងតាមដាន ការសាងសង់ក្រោយទទួលបាន ការអនុញ្ញាតកន្លងមកចំនួន ៦២ករណី និងការជួសជុលតូចតាច ដោយក្រុមការងារសហគមន៍ ចំនួន ១៧៣ករណី

ផ្សាយនៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២៤

ប្រជាពលរដ្ឋដែលរស់នៅក្នុងឧទ្យានអង្គរពីយូរមកហើយ ត្រូវបានទទួលការអនុញ្ញាតសាងសង់សំណង់នានា ស្របតាមគោលការណ៍ច្បាប់ និងការងារជួសជុលតូចតាច (ដោយក្រុមការងារសហគមន៍)។ រាល់សំណង់នានា ដែលនៅមានសុពលភាព ត្រូវបាននាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា បានចុះទៅពិនិត្យ និងផ្តល់នូវលក្ខណៈបច្ចេកទេស ដោយពុំគិតប្រាក់កម្រៃជាប្រចាំ រហូតសំណង់ទាំង នោះ សង់រួចរាល់មួយរយភាគរយ។

ជាក់ស្តែងក្នុងសប្តាហ៍ទី៤ នៃខែមិថុនា ឆ្នាំ២០២៤ នេះ មន្ត្រី-បុគ្គលិកជំនាញ បានចុះពិនិត្យ និងផ្តល់លក្ខណៈបច្ចេកទេសនូវសំណង់ដែលបានការអនុញ្ញាត កន្លងមក ចំនួន ៦២ករណី និងការជួសជុលតូចតាចដោយក្រុមការងារសហគមន៍ ចំនួន១៧៣ករណី ដែលស្ថិតក្នុងភូមិសាស្ត្រ ដូចខាងក្រោម៖

១. ក្រុងសៀមរាបចំនួន ៦៩ករណី
២. ស្រុកប្រាសាទបាគង ២៨ករណី
៣. ស្រុកបន្ទាយស្រីចំនួន ៦៥ករណី
៤. ស្រុកពួកចំនួន ៥៩ករណី
៥. ស្រុកអង្គរធំចំនួន ១៤ករណី

សូមបញ្ជាក់ជូនផងដែរថា ក្នុងចំណោម ២៣៥ករណី មាន ១៨៩ករណី កំពុងតែសាងសង់ ជួសជុលត្រឹមត្រូវតាមការអនុញ្ញាត មាន ៤៥ករណី មិនទាន់សាងសង់ និងសាងសង់ពុំត្រឹមត្រូវតាមការអនុញ្ញាត ០១ករណី នៅភូមិមមាញ ឃុំរលួស ស្រុកប្រាសាទបាគង។

ករណីដែលប្រជាពលរដ្ឋសាងសង់ពុំត្រឹមត្រូវតាមការអនុញ្ញាតក្រុមការងារបានសម្របសម្រួលឱ្យពួកគាត់កែប្រែឡើងវិញ ឬ ត្រូវបញ្ឈប់ការសាងសង់តែម្តង។

ក្រុមការងារបច្ចេកទេស និងបន្តតាមដានការសាងសង់ និងជួសជុលរហូតដល់ការ អនុញ្ញាតផុតសុពលភាព និងការសាងសង់ រួចរាល់មួយរយភាគរយ៕

អាជ្ញាធរជាតិអប្សរា
កែលម្អទីតាំងដីសឹករិចរិល និងដីទំនេរ
កែប្រែជាទេសភាពបៃតង

ផ្សាយនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា ខិតខំកែលម្អទីតាំងដីមួយចំនួនដែលសឹករិចរិល ឬដីទំនេរ និងបរិវេណនៅតាមដងផ្លូវ កែប្រែទៅជាទេសភាពបៃតងខ្ចបប្រាំងវស្សា ដោយដាំស្មៅ និងដើមឈើកាន់តែច្រើនឡើងជាបន្តបន្ទាប់ ហើយមើលថែជាប្រចាំ រួមទាំងថែទាំដើមឈើដែលមានស្រាប់កាន់តែល្អប្រសើរ។

ព្រៃឈើ ជាផ្នែកមួយរួមចំណែកយ៉ាងសំខាន់ក្នុងការលើកម្ពស់សោភ័ណភាពតំបន់រមណីយដ្ឋានអង្គរ និងភពផែនដីរបស់យើង។ សូមចូលរួមថែរក្សាការពារព្រៃឈើ និងបរិស្ថាននៅក្នុងរមណីយដ្ឋានអង្គរទាំងអស់គ្នា៕

ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិ ចូលមកទស្សនាព្រះអាទិត្យរះ នាព្រឹកព្រលឹមនៅប្រាសាទអង្គរវត្ត ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២៤

ភ្នាក់ងារទេសចរបានជួយសង្គ្រោះបឋមដល់ភ្ញៀវទេសចរ ដែលរងរបួស ខណៈពេលកំពុងដើរទស្សនាប្រាសាទ

ផ្សាយនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២៤

នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២៤ វេលាម៉ោង ១០:២៦ នាទីព្រឹក ក្រុមភ្នាក់ងារទេសចរប្រចាំគោលដៅរាជធានីក្រុងអង្គរធំ ប្រាសាទបាភួន និងខ្លោងទ្វារតាការ បានជួយសង្គ្រោះបឋមដល់ភ្ញៀវទេសចរ ជនជាតិ អេស្ប៉ាញ ភេទប្រុស អាយុ៤៨ឆ្នាំ ដែលមានរបួស ខណៈដើរទស្សនាប្រាសាទ។ បន្ទាប់ពីនោះ ភ្ញៀវទេសចរខាងលើក៏បន្តដើរទស្សនាប្រាសាទដទៃទៀត៕

សកម្មភាពក្រុមភ្នាក់ងារទេសចរ ធ្វើការសម្អាតនៅតាមប្រាសាទនានា

ផ្សាយនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២៤

ក្រៅពីមានតួនាទីជួយសម្របសម្រួល និងទទួលបដិសណ្ឋាកិច្ច ចំពោះភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដែលចូលមកទស្សនាតាមប្រាសាទនានាហើយនោះ ក្រុមភ្នាក់ងារទេសចរ ក៏បានជួយធ្វើការបោសសម្អាតជាប្រចាំនៅតាមទីតាំងប្រាសាទនានា ជាគោលដៅប្រចាំការរបស់ពួកគាត់។ គោលដៅចម្បងរួមគ្នាតែមួយនោះគឺ ធ្វើយ៉ាងណាឱ្យរមណីយដ្ឋានអង្គរ មានភាពស្រស់ស្អាត ជាទីគយគន់របស់ទេសចរ៕

អាជ្ញាធរជាតិអប្សរា និងភាគីអាល្លឺម៉ង់ ចុះអនុស្សរណៈនៃការយោគយល់គ្នា(Mou) ដើម្បីបន្តកិច្ចសហការ ក្នុងវិស័យជួសជុលអភិរក្សប្រាសាទ

ផ្សាយនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤

នៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៤ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានអញ្ជើញចុះអនុស្សរណៈនៃការយោគយល់គ្នា រវាងអាជ្ញាធរជាតិអប្សរា ជាមួយភាគីអាល្លឺម៉ង់ នៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា។

ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា(Mou)ខាងលើក្នុងគោលបំណង ដើម្បីបន្តកិច្ចសហការ ក្នុងវិស័យជួសជុលអភិរក្សប្រាសាទក្នុងរមណីយដ្ឋានអង្គរ និងរមណីយដ្ឋានប្រវត្តិសាស្ត្រផ្សេងៗទៀត ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា៕





ទិដ្ឋភាព៣៦០ដឺក្រេ ដែលភ្ញៀវទេសចរជាតិ និងអន្តរជាតិ អាចមើលឃើញពីកំពូលភ្នំប្រាសាទភ្នំបាខែង

ផ្សាយនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤

ខ្លោងទ្វារទន្លេអុំ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤ សកម្មភាពសណ្តាប់ធ្នាប់រៀបរយល្អក្នុងការចតយានយន្តបានត្រឹមត្រូវ រក្សាបាននូវសុវត្ថិភាព និងសណ្តាប់ធ្នាប់ល្អនៅក្នុងរមណីយដ្ឋានអង្គរ

សូមបន្តរក្សាសណ្តាប់ធ្នាប់ និងអនាម័យល្អនៅតាមទីតាំងចំណតនីមួយៗ ដើម្បីភាពទាក់ទាញបន្ថែមទៀត

ផ្សាយនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤

សួនរុក្ខជាតិអង្គរ ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា ត្រូវបាន TripAdvisor ផ្តល់នូវ Travellers´ Choice Awards ក្នុងឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤

ក្រុមការងារក្រុមហ៊ុន មេនូឡាយហ្វ៍ បន្តដាំកូនឈើនៅតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៤ ក្រុមការងារនៃក្រុមហ៊ុនមេនូឡាយហ្វ៍ បានសហការជាមួយអាជ្ញាធរជាតិអប្សរា ដែលមានអ្នកចូលរួមសរុប១០០នាក់បន្តចូលរួមដាំកូនឈើ នៅក្នុងឧទ្យានសហគមន៍អង្គរ-មេនូឡាយហ្វ៍ ក្នុងបំណងដើម្បីបង្កើនគម្របព្រៃឈើបន្ថែមក្នុងតំបន់រមណីយដ្ឋានអង្គរ។

ដើមឈើដែលបានដាំនៅពេលនោះសរុប ១១០០ដើម ដែលរួមមាន ដើមច្រេស ២៥០, ដើមបេង ២២៥, គ្រញូង ២៥ដើម,ដើមយាង ឬឈើទាល ២០០,ដើមធ្នង់២០០ និងគគីរ ២០០ដើម៕

ស្នាមញញឹមខ្លោងទ្វារតាកាវ ស្វាគមន៍ភ្ញៀវទេសចរ មកទស្សនា និងថតផ្តិតរូបភាពដ៏ស្រស់ស្អាត ពីព្រឹកព្រលឹម រហូតដល់ថ្ងៃលិច

ផ្សាយនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៤

អនាម័យបរិស្ថានស្រស់ស្អាត ជាចំណែកមួយក្នុងការទាក់ទាញភ្ញៀវទេសចរ ឱ្យមកទស្សនារមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា បានយកចិត្តចំពោះការងារបោសសម្អាតថែទាំ អនាម័យបរិស្ថាននៅតាមប្រាសាទ និងបរិវេណជុំវិញនោះ ធ្វើយ៉ាងណាឱ្យតំបន់រមណីយដ្ឋានអង្គរ មានភាពស្រស់ស្អាតជារៀងរាល់ថ្ងៃ ព្រោះទាំងនេះក៏ជាផ្នែកមួយយ៉ាងសំខាន់ ដើម្បីទាក់ទាញទេសចរជាតិនិងអន្តរជាតិឱ្យចូលមកទស្សនាបានផងដែរ។

ជាមួយគ្នានេះ អាជ្ញាធរជាតិអប្សរា សូមថ្លែងអំណរគុណចំពោះក្រុមការងារផ្នែកសម្អាតបរិស្ថាន ដែលជារៀងរាល់ថ្ងៃ បើទោះបីស្ថិតក្នុងអាកាសក្តៅ ត្រជាក់ឬភ្លៀងរលឹមយ៉ាងណា ក៏នៅតែបន្តសកម្មភាពដ៏មមាញឹក ក្នុងការងារបោសសម្អាត កាត់សម្អាតស្មៅកូនឈើនិងស្តារវុក្ខជាតិតូចៗតែងតែដុះ នៅតាមប្រាសាទ ឬក្នុងទឹកនាបរិវេណរមណីយដ្ឋានអង្គរ។

អាជ្ញាធរជាតិអប្សរា ចូលរួមពិព័រណ៌ផ្សព្វផ្សាយ និងចែកកូនឈើ ក្រោមមូលបទ "ពន្លកបៃតង" និងវេទិកាកេសរកូលជាតិលើកទី៤

ផ្សាយនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៤

នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៤ អាជ្ញាធរជាតិអប្សរាចូលរួមពិព័រណ៌ផ្សព្វផ្សាយ និងចែកកូនឈើ ក្រោមមូលបទ "ពន្លកបៃតង" និងវេទិកាកេសរកូលជាតិលើកទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ហ៊ុន ម៉ានី** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនៅទីស្តីការក្រសួងបរិស្ថាន។

ក្នុងឱកាសនោះ អាជ្ញាធរជាតិអប្សរា ក៏បាននាំយកកូនឈើចម្រុះចំនួន២៩ប្រភេទ សរុបចំនួន១,៧០០ដើម ដើម្បីតាំងបង្ហាញផ្សព្វផ្សាយ និងចែកចាយជូនសាធារណជនទូទៅដោយឥតគិតថ្លៃផងដែរ៕

ទិដ្ឋភាពភ្ញៀវទេសចរ ជិះទូកកម្សាន្ត នៅបារាយណ៍ជយតាដាក ឬបារាយណ៍នាគព័ន្ធ

ផ្សាយនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤

ទិដ្ឋភាពភ្ញៀវទេសចរ ជិះទូកកម្សាន្តនៅបារាយណ៍ជយតាដាក ឬបារាយណ៍នាគព័ន្ធ តាមរយៈសេវាកម្មបម្រើជិះទូកកម្សាន្តរបស់សហគមន៍សាមគ្គីដើម្បីអភិវឌ្ឍន៍ទេសចរណ៍ ដែលទេសចរអាចផ្លាស់ប្តូរបរិយាកាសដោយចូលទស្សនាប្រាសាទនាគព័ន្ធស្ថិតនៅលើកោះ អាចគយគន់ទេសភាពព្រៃប្រឹក្សាជុំវិញ រុក្ខវារីជាតិ មច្ឆជាតិ បក្សាបក្សី និងទស្សនាថ្ងៃលិចផង។ ការគាំទ្រជិះទូករបស់សហគមន៍ ជាការលើកកម្ពស់វិស័យទេសចរណ៍ធម្មជាតិបែបប្រវត្តិសាស្ត្រ និងផ្តល់ការងារដល់ប្រជាជនក្នុងសហគមន៍ជុំវិញបារាយណ៍ប្រវត្តិសាស្ត្រមួយនេះដែរ។

សូមជម្រាបជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដែលមានបំណងចង់ជិះទូកកម្សាន្តនៅបារាយណ៍ជយតដាក នេះ អាចទាក់ទងជាវសំបុត្រតាមរយៈលេខទូរសព្ទ ០៨៩ ២១១ ៧៣៧ សូមអរគុណ៕

ប្រាសាទព្រះគោ និងទេសភាពបរិស្ថានជុំវិញនៅដើមរដូវវស្សា

រួមគ្នាថែរក្សាបរិស្ថានស្អាត នៅក្នុងរមណីយដ្ឋានអង្គរទាំងអស់គ្នា

ផ្សាយនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរាដាក់របាសុវត្ថិភាព ភ្ញៀវទេសចរនៅប្រាសាទប្រែរូប

ផ្សាយនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា បានផ្តោតការយកចិត្តទុកដាក់ខ្ពស់ទៅលើសុវត្ថិភាពភ្ញៀវទេសចរគ្រប់រូបជាចាំបាច់។ ដោយសារ ការយកចិត្តទុកដាក់នេះ អាជ្ញាធរជាតិអប្សរា បានធ្វើរបាសុវត្ថិភាពសម្រាប់ភ្ញៀវ នៅលើប្រាសាទប្រែរូប ដើម្បីធានាបានសុវត្ថិភាពខ្ពស់ដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដែលតែងតែទៅទស្សនាប្រាសាទ និងទិដ្ឋភាពថ្ងៃរៀបលិច ដូចនៅប្រាសាទភ្នំបាខែង និងប្រាសាទភ្នំក្រោមដែរ៕

រូបភាពប្រចាំសប្តាហ៍៖ ទិដ្ឋភាពប្រាសាទបាយ័ន ដែលមានចម្លាក់ព្រហ្មមុខ៤ ញញឹមស្វាគមន៍ភ្ញៀវទេសចរចម្រុះជាតិសាសន៍ មកពីគ្រប់ទិសទី

ផ្សាយនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៤

សូមចូលរួមថែរក្សា និងលើកកម្ពស់បរិស្ថានស្អាត នៅក្នុងរមណីយដ្ឋានអង្គរទាំងអស់គ្នា

ផ្សាយនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៤

ក្រៅពីមើលការខុសត្រូវផ្សេងៗតាមតួនាទីរបស់ខ្លួន ក្រុមការងារភ្នាក់ងារទេសចរ ប្រចាំគោលដៅប្រាសាទបាយ័ន បានម្ចាតស្មៅ និងរុក្ខជាតិតូចៗដែលដុះទៅតាមប្រាសាទជាប្រចាំ ដែលក្រុមការងារតែងតែទុកប្រាសាទប្រៀបបានជាផ្ទះត្រូវតែថែទាំ ដើម្បីភាពស្រស់ស្អាតជាប្រចាំ។

អាជ្ញាធរជាតិអប្សរា ធ្វើបទបង្ហាញស្តីពីការអភិរក្ស និងអភិវឌ្ឍបេតិកភណ្ឌតំបន់អង្គរ ជូនដល់និស្សិតមកពីសាកលវិទ្យាល័យជាតិបាត់ដំបង

ផ្សាយនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៤

ក្រោមការសម្របសម្រួលរបស់អាជ្ញាធរជាតិអប្សរា និស្សិតជំនាញស្ថាបត្យកម្ម ឆ្នាំទី៣ ចំនួន២០រូប មកពីសាកលវិទ្យាល័យជាតិបាត់ដំបង ខេត្តបាត់ដំបង បានចុះទស្សនសិក្សានៅក្នុងតំបន់អង្គរ ក្នុងគោលបំណងសិក្សាស្វែងយល់អំពីការងារជួសជុល អភិរក្សថែទាំប្រាសាទ រួមទាំងប្រវត្តិសាស្ត្រ ប្រវត្តិសិល្បៈ ស្ថាបត្យកម្មប្រាសាទបុរាណនៅក្នុងតំបន់អង្គរ រយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី១៣ ដល់ទី១៥ ខែកក្កដា ឆ្នាំ២០២៤។

ក្នុងឱកាសនេះដែរ មន្ត្រីជំនាញរបស់អាជ្ញាធរជាតិអប្សរា បានធ្វើបទបង្ហាញស្តីពីការអភិរក្ស និងអភិវឌ្ឍបេតិកភណ្ឌតំបន់អង្គរ រួមទាំងវិធីសាស្ត្រក្នុងការធ្វើផែនទីហានិភ័យប្រាសាទ និងសម្រង់ប្រាសាទ។លើសពីនេះ ក្រុមនិស្សិតទាំងចំនួន២០រូប ក៏នឹងអនុវត្តការងារសម្រង់ប្រាសាទ (ស្រាវជ្រាវប្រមូលព័ត៌មានលក្ខណៈស្ថាបត្យកម្ម លក្ខណៈបច្ចេកទេស ការស្រាវជ្រាវអំពីមុខងារ និងលំហរូបភាពនៃគ្រាទស្សន៍នៅតាមទីតាំងប្រាសាទដោយផ្ទាល់ជាក់ស្តែងផង)៕

រូបភាពប្រចាំសប្តាហ៍៖ សម្រស់ប្រាសាទប្រែរូប អមដោយធម្មជាតិបៃតង ស្រស់បំព្រងនារដូវវស្សា

ផ្សាយនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៤

ប្រាសាទក្រវ៉ាន់ដែលសាងសង់ពីឥដ្ឋ បង្ហាញខ្លួនយ៉ាងស្រស់ស្អាត នៅបណ្តោយផ្លូវវង់តូច ទាក់ទាញភ្ញៀវទេសចរ ចូលមកទស្សនាជាប្រចាំ

ផ្សាយនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៤

ទិដ្ឋភាពភ្ញៀវទេសចរ ចូលមកទស្សនាប្រាសាទអង្គរវត្ត នាព្រឹកថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤

ក្រុមការងារខ្មែរនិងអាមេរិក កំពុងជួសជុលជណ្ដើរ៥ថ្នាក់និងចម្លាក់តោ នៅទិសខាងត្បូងនៃប្រាសាទភ្នំបាខែង

ផ្សាយនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤

ក្រោមកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា ជាមួយអង្គការមូលនិធិប្រាសាទពិភពលោក (World Monument Fund) របស់សហរដ្ឋអាមេរិក កំពុងជួសជុលរចនាសម្ពន្ធជណ្ដើរទាំង៥ថ្នាក់ទិសខាងត្បូងនៃប្រាសាទភ្នំបាខែង មកដល់ពាក់កណ្ដាលឆ្នាំ២០២៤នេះ ជួសជុលសម្រេចបានជណ្ដើរចំនួន៤ថ្នាក់ ចម្លាក់តោអមសងខាងជណ្ដើរចំនួន៥ ហើយបន្តជួសជុលរចនាសម្ពន្ធជណ្ដើរចំនួន១ថ្នាក់ទៀត។

ប្រធានការដ្ឋានជួសជុលនៅប្រាសាទភ្នំបាខែង លោក វ៉ាន វ៉ា ឱ្យដឹងថា ការងារជួសជុលកាំជណ្ដើរចំនួន៥ថ្នាក់ របស់ប្រាសាទភ្នំបាខែងទិសខាងត្បូងសម្រេចបាន ៨០%ហើយនៅសល់តែចំនួន១ថ្នាក់ទៀតក្នុងចំណោម រចនាសម្ពន្ធជណ្ដើរចំនួន៥ថ្នាក់ ដែលត្រូវនឹងប្រើពេលវេលាប្រមាណជា៥ខែទៀត។

ចំណែកចម្លាក់តោអមសងខាងជណ្ដើរទិសខាងត្បូងនេះ ប្រធានការដ្ឋានរូបនេះបញ្ជាក់ថា នៅសេសសល់តែតោចំនួន៥ ក្នុងចំណោមតោទាំង១២ ត្រូវបានក្រុមការងារជួសជុលរួចរាល់ហើយដែរ ព្រោះថាតោនីមួយៗខ្លះបាក់បែកផ្នែកជើងទម្រជើង ឬដងខ្លួន និងក្បាលជាដើម។

ចម្លាក់តោទាំងនោះ ក៏ធ្លាប់មានការជួសជុលម្ដងមកហើយនៅសម័យអាណាព្យាបាលបារាំង។ ក្រៅពីនេះគេឃើញមានបំណែកតោមួយចំនួនទៀត ដែលរងការខូចខាតធ្ងន់ធ្ងរ មិនអាចកំណត់អត្តសញ្ញាណ និងផ្គុំឡើងវិញបានទេ៕

អាជ្ញាធរជាតិអប្សរា សូមប្រកាសស្វែងរកម្ចាស់កាបូបទេសចរជ្រុះ ឬភ្លេចនៅចំណុចផ្លូវកង់ខាងទីតាំងត្រួតពិនិត្យសំបុត្រចូលទស្សនាប្រាសាទក្នុងតំបន់រមណីយដ្ឋានអង្គរ កែងផ្លូវសម្តេចវិបុលបញ្ញាសុខ អាន (ផ្លូវ៦០ម៉ែត្រ)

ផ្សាយនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤ សិស្សសាលាបឋមសិក្សាក្រវ៉ាន់ រើសបានកាបូបដៃចំនួនមួយរបស់ភ្ញៀវទេសចរបរទេស ដែលបានជ្រុះ ឬភ្លេចនៅចំណុចផ្លូវជិះកង់ចម្ងាយប្រហែល២០០ម៉ែត្រខាងកើតទីតាំងត្រួតពិនិត្យសំបុត្រចូលទស្សនាប្រាសាទក្នុងតំបន់រមណីយដ្ឋានអង្គរ កែងផ្លូវសម្តេចវិបុលបញ្ញាសុខ អាន (ផ្លូវ៦០ម៉ែត្រ) ឬកែងផ្លូវអេក្សT។

ក្រោយពីរើសបាន សិស្សក៏យកមកប្រគល់ជូនលោកគ្រូអ្នកគ្រូ ហើយថ្នាក់ដឹកនាំសាលាបឋមសិក្សាក្រវ៉ាន់ រាយការណ៍មកអាជ្ញាធរជាតិអប្សរា ដើម្បីស្វែងរក និងប្រគល់ជូនម្ចាស់ដើមវិញ៕

ម្ចាស់កាបូប ឬអ្នកមានទំនាក់ម្ចាស់ខាងលើ អាចទាក់ទងតាមលេខទូរសព្ទ 012 247 525។ សូមអរគុណ

ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិ ចូលមកទស្សនាព្រះអាទិត្យរះ នាព្រឹកព្រលឹមនៅប្រាសាទអង្គរវត្ត ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា ជួសជុលពង្រឹងខឿនជណ្តើរ និងបង្កាន់នាគផ្នែកខាងលិច នៃជណ្តើរកណ្តាល ខាងត្បូងប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤

ការងារជួសជុលខឿនជណ្តើរ និងបង្កាន់ដៃនាគផ្នែកខាងលិចជាន់ផ្ទាល់ដីនៃជណ្តើរកណ្តាលនៅទិសខាងត្បូងប្រាសាទអង្គរវត្ត ដែលបានដំណើរការតាំងតែពីពាក់កណ្តាលខែឧសភា ឆ្នាំ២០២៤ មកដល់ពេលនេះ ក្រុមការងារអាជ្ញាធរជាតិអប្សរា ជួសជុលគ្រឹះខឿនស្រុត និងថ្មក្រៀកហែកបានរួចរាល់ ហើយបន្តជួសជុលខឿនទ្របង្កាន់ដៃនាគស្រទាប់ខាងលើដែលរអិលចេញពីគន្លងដើម ដើម្បីរៀបបង្កាន់នាគឱ្យត្រូវតាមទីតាំងដើម។

ផ្លូវកង់ជាជម្រើសទស្សនាទេសភាពដ៏ស្រស់ស្អាត ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤

ទេសចរជាតិ និងអន្តរជាតិ មកទស្សនារមណីយដ្ឋានអង្គរ ក្រៅពីការធ្វើដំណើរដោយរថយន្ត ម៉ូតូ ឬមធ្យោបាយផ្សេងៗនៅលើផ្លូវកៅស៊ូធំទូលាយ និងភាពស្រស់ស្អាតហើយនោះក៏មាន ជាផ្លូវកង់សម្រាប់ភ្ញៀវទេសចរអាចជិះបានទាំងវង់តូច និងវង់ធំ មានប្រវែងជាង៤០គីឡូម៉ែត្រ ដែលអាជ្ញាធរជាតិអប្សរាបានបង្កើតឡើងសម្រាប់ទេសចរជិះកង់ទស្សនារមណីយដ្ឋានអង្គរផង។

ក្រោយការបង្កើតឱ្យមានជាផ្លូវកង់ នាអំឡុងឆ្នាំ២០២០មកដល់បច្ចុប្បន្ន ផ្លូវកង់ នៅតែមានភាពទាក់ទាញ និងពេញនិយមយ៉ាងខ្លាំង ពីសំណាក់ទេសចរ ដែលចង់ផ្លាស់ប្តូរបរិយាកាសពីការធ្វើដំណើរដោយយានយន្ត ដែលមានសំឡេងរំខាន ឬផ្សែងបំពុលបរិស្ថាន អាចធ្វើដំណើរកម្សាន្តតាមរយៈផ្លូវទស្សនាប្រាសាទ។

មិនថា នាថ្ងៃសម្រាកចុងសប្តាហ៍ ឬថ្ងៃធ្វើការធម្មតាឡើយ ការធ្វើដំណើរដោយជិះកង់ តាមវង់ទស្សនាដែលអាជ្ញាធរជាតិអប្សរាបានរៀបចំ មិនត្រឹមតែមានសុខសុវត្ថិភាព និងសុខភាពល្អប៉ុណ្ណោះទេ អ្នកទេសចរក៏អាចគយគន់ទេសភាពព្រៃព្រឹក្សា ខ្យល់អាកាសល្អបរិសុទ្ធ វាលស្រែ ទស្សនាជីវភាពរស់នៅប្រចាំថ្ងៃ និងភូមិឋានបងប្អូនអ្នកស្រុកអង្គរយ៉ាងសប្បាយរីករាយ៕

ប្រាសាទសួរព្រ័ត៌ឈរបញ្ចូតសម្រស់ដ៏ទាក់ទាញនារដូវវស្សា

ផ្សាយនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤

ភ្នាក់ងារទេសចរ សហការជាមួយនគរបាលការពារបេតិកភណ្ឌ ប្រគល់ទូរស័ព្ទ១គ្រឿង ម៉ាក iPhone១៣ ជូនភ្ញៀវទេសចរដែលភ្លេចបន្សល់ទុក

ផ្សាយនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤

វេលាម៉ោង១:២៦នាទី ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤ ភ្នាក់ងារទេសចរ ប្រចាំគោលដៅរាជធានីក្រុងអង្គរធំ បានប្រទះឃើញទូរស័ព្ទដៃ ១គ្រឿង ម៉ាក iPhone១៣ នៅច្រកខាងកើតប្រាសាទបាយ័ន លុះប្រហែល៥នាទីក្រោយមក មានភ្ញៀវទេសចរ ជនជាតិភីលីពិន ភេទស្រី អាយុ ៥០ឆ្នាំ បានត្រឡប់មករកវិញ ដោយពិនិត្យឃើញថាពិតជារបស់គាត់ពិតប្រាកដមែន ក្រុមការងារទេសចរ សហការនគរបាលការពារបេតិកភណ្ឌ និង ធ្វើការប្រគល់ជូនគាត់វិញ។

អាជ្ញាធរជាតិអប្សរា ដកទំនប់ការពារ ចេញពីការដ្ឋានរបស់ស្ពានហាលខាងលិច ប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤

ក្រុមអ្នកជំនាញនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា បានចាប់ផ្តើមដកទំនប់ការពារ ដែលទប់ធ្វើជាទំនប់ទឹក ក្នុងអំឡុងពេលជួសជុលស្ពានហាលខាងលិចប្រាសាទអង្គរវត្តនោះចេញវិញហើយ ដើម្បីគ្រប់គ្រងរំហូរទឹក ឱ្យមានសភាពដូចដើមឡើងវិញ។

ការដកទំនប់ការពារ ដែលទប់ធ្វើជាទំនប់ទឹកបណ្តោះអាសន្ននេះ បន្ទាប់ពីស្ពានហាលខាងលិចប្រាសាទអង្គរវត្ត បានជួសជុលរួចរាល់ជាស្ថាពរ។ អ្នកស្រី អួន ស៊ីណាង មន្ត្រីបច្ចេកទេស និងជាអ្នកទទួលបន្ទុកដកទំនប់ការពារ មានប្រសាសន៍ថា គម្រោងជួសជុលស្ពានហានខាងលិចប្រាសាទអង្គរវត្ត បានបញ្ចប់កាលពីចុងឆ្នាំ២០២៣ ហើយការងារដែលនៅសេសសល់ គឺការដកទំនប់ការពារដែលទប់ទឹកមិនឱ្យចូលការដ្ឋានកាលណោះចេញវិញ។

ទំនប់ដី ដែលធ្វើការពារទឹកបណ្តោះអាសន្ន ក្នុងពេលជួសជុលស្ពានហាលខាងលិចប្រាសាទអង្គរវត្តនោះ មានបណ្តោយប្រវែង២៣០ម៉ែត្រ ទទឹង៤ម៉ែត្តន្លះ និងកម្ពស់២ម៉ែត្រកន្លះ។ ការដកទំនប់ការពារនេះ មិនត្រឹមតែបើករំហូរទឹក ឱ្យមានសភាពដូចដើមវិញប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជួយបង្កើនភាពស្រស់ស្រាយសោភ័ណភាពរបស់ស្ពាន ដើម្បីឱ្យភ្ញៀវទេសចរអាចអង្គុយមើលពីប្រាំងកសិន្ធុ ឃើញពីភាពរឹងមាំនៃរចនាសម្ពន្ធស្ពានដែលទើបតែជួសជុលរួចមានភាពរឹងមាំផងដែរ។

អ្នកស្រី អួន ស៊ីណាង ឱ្យដឹងទៀតថា ការដកទំនប់ការពារចេញពីរបាំងស្ពានហាលនេះ គឺមានការពិបាកខ្លាំង ដោយត្រូវប្រើបច្ចេកទេសជ្រមុជទឹកកាយយកអាចម៍ដី និងលើកចេញពីក្នុងទឹកមកប្រកក្នុងការ៉ុង រួចដាក់លើក្បូនហើយត្រូវទាញក្បូនជញ្ជូនមករក្សាទុកនៅលើគោកជាដើម៕

ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិ ចូលទស្សនាប្រាសាទអង្គរវត្ត ខណៈមានភ្លៀងធ្លាក់ ដែលជាទេសភាពមួយមានសោភ័ណភាពយ៉ាងទាក់ទាញ

ទេសចរអាចនិងប្លែកអារម្មណ៍ចង់ឃើញទិដ្ឋភាពភ្លៀងធ្លាក់នៅប្រាសាទបុរាណជាមួយគ្នានេះ អាជ្ញាធរជាតិអប្សរា សូមឱ្យភ្ញៀវទេសចរដើរដោយប្រុងប្រយ័ត្ន ចៀសវាងគ្រោះថ្នាក់ដោយប្រការផ្សេងៗ

ផ្សាយនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៤

ទិដ្ឋភាពភ្ញៀវទេសចរ ទស្សនាខ្លោងទ្វារទន្លេអុំ ពេលភ្លៀងធ្លាក់

ផ្សាយនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៤

កូនឈើចម្រុះចំនួន៩,៨១៨ដើម ត្រូវបានអាជ្ញាធរជាតិអប្សរាចែកចាយ ពីថ្ងៃទី០៨ ដល់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៤

កូនឈើចម្រុះសរុប៩៨១៨ដើមបន្ថែមទៀត ត្រូវបានអាជ្ញាធរជាតិអប្សរា បានចែកចាយដល់ព្រះសង្ឃ សាធារណជនទូទៅ ចាប់ពីថ្ងៃទី៨ ដល់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤ ដើម្បីយកទៅដាំទៅតាមតំបន់ផ្សេងៗ។

អាជ្ញាធរជាតិអប្សរា មានកិត្តិយសគោរពអញ្ជើញ ឯកឧត្តម លោកជំទាវ លោក លោកស្រី សាធារណជនចូលរួមស្តាប់បាឋកថា ក្រោមប្រធានបទ «របត់សង្គមសម័យកណ្តាលតាមរយៈតស្តុតាងបុរាណវិទ្យាថ្មីៗ ក្នុងក្រុងសៀមរាប»

ផ្សាយនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៤

បាឋកថានេះ នឹងប្រារព្ធនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៤ វេលាម៉ោង៨កន្លះព្រឹក នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ នៃទីស្នាក់ការអាជ្ញាធរជាតិអប្សរា ស្ថិតនៅភូមិបង្គោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប។

អាជ្ញាធរជាតិអប្សរាបើកយុទ្ធនាការចែកកូនឈើ ដល់ពលរដ្ឋរស់នៅក្នុងក្រុងរុនតាឯក តេជោសែន

ផ្សាយនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៤

កូនឈើជាង១០ប្រភេទ រួមមាន៖ ឈើបេង ក្រញូង ធ្នឹក សុក្រម ដើមឈើមានផ្កាលម្អ និងដើមឈើអាចអាស្រ័យផលបាន ចំនួន៥,០០០ដើម ត្រូវបានមន្ត្រីជំនាញអាជ្ញាធរជាតិអប្សរា បើកយុទ្ធនាការចែកជូនពលរដ្ឋរស់នៅក្រុងរុនតាឯក តេជោសែន ដើម្បីបង្កើនគម្របបៃតង ផ្តល់ជាម្លប់ និងការពារការប្រែប្រួលអាកាសធាតុជាដើម។

លោក ស៊ុន កែវពិសី អនុប្រធានប្រចាំការនៅអង្គភាពគ្រប់គ្រងភូមិធម្មជាតិរុនតាឯក បានឱ្យដឹងថា អនុវត្តតាមការណែនាំរបស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ក្រុមការងារបានបើកយុទ្ធនាការចែកជូនកូនឈើដោយមិនគិតថ្លៃ ដល់បងប្អូនប្រជាពលរដ្ឋរស់នៅក្នុងក្រុងរុនតាឯក តេជោសែន ខណៈជំហានដំបូងកូនឈើដែលបានត្រៀមសម្រាប់ចែកជូន មានចំនួនប្រមាណ ៥,០០០ដើម ដែលយុទ្ធនាការ និងចាប់ផ្តើមពីដើមរដូវវស្សានេះ រហូតដល់ចុងបញ្ចប់នៃរដូវវស្សាក្នុងឆ្នាំនេះ។

អ៊ំស្រី លាន សុភ័ក្រ ប្រជាពលរដ្ឋរស់នៅភូមិតានី ក្រុងរុនតាឯក តេជោសែន មកទទួលកូនឈើយកទៅដាំដុះនៅគេហដ្ឋានរបស់ខ្លួន បានបង្ហាញអារម្មណ៍សប្បាយរីករាយ នៅពេលអាជ្ញាធរជាតិអប្សរា ចែកជូនកូនឈើចម្រុះ ដល់ពលរដ្ឋអាចយកទៅដាំដុះនៅក្បែរផ្ទះ ដើម្បីផ្តល់ជាម្លប់ បង្កើនសោភ័ណ្ឌភាពបៃតងស្រស់ស្អាត និងអាចពឹងអាស្រ័យផល បាននៅពេលដើមឈើទាំងនោះធំលូតលាស់ក្នុងពេល២ឬ៣ឆ្នាំខាងមុខ។

ចំណែកអ៊ំស្រី សាំង សារឿន ពលរដ្ឋរស់នៅក្នុងក្រុងរុនតាឯក តេជោសែន មានប្រសាសន៍ថា ការផ្តល់ជូនកូនឈើរបស់អាជ្ញាធរជាតិអប្សរានាពេលនេះ គឺស្របនិងការចង់បានរបស់ពលរដ្ឋក្នុងសហគមន៍ ព្រោះថាពលរដ្ឋខ្លះទើបតែចូលមករស់នៅថ្មីៗ ត្រូវការដើមឈើ យកទៅដាំដើម្បីផ្តល់ជាប្រយោជន៍ក្នុងពេលខាងមុខ។ អ៊ំស្រី បានថ្លែងអំណរគុណ អាជ្ញាធរជាតិអប្សរា ចំពោះការគិតគូរអំពីសោភ័ណ្ឌភាព បរិស្ថាន ដើម្បីផ្តល់ភាពងាយស្រួលសម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋ៕

រូបភាពប្រចាំសប្តាហ៍៖
ក្រោយភ្លៀងធ្លាក់ រុក្ខជាតិតូចធំរីកលូតលាស់ស្រស់បំព្រង ជាមួយនិងវាលស្មៅបៃតងខ្ចីនៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៤

ការបង្ហោះផ្សាយរបស់ក្រុមឧទ្ទាម The Cambodia Daily ថាមន្ត្រីអាជ្ញាធរជាតិអប្សរាម្នាក់ទម្លាយថាកម្ពុជា កំពុងក្លាយជាទីតាំងប្រព្រឹត្តអំពើចោរកម្ម ដ៏គួរឱ្យភ័យខ្លាចលើភ្ញៀវទេសចរ គឺជាព័ត៌មានក្លែងក្លាយ!

ផ្សាយនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៤

ក្រុមអ្នកជំនាញបញ្ចប់ការងារជួសជុលសំណង់ព្រះវិហារបុរាណវត្តព្រះឥន្ទកោសីយ៍

ផ្សាយនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៤

រូបភាពមុនពេលជួសជុល

រូបភាពក្រោយពេលជួសជុល

ក្រុមការងារផ្នែកអភិរក្ស និងជួសជុលសំណង់ព្រះវិហារបុរាណ នៃនាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ របស់អាជ្ញាធរជាតិអប្សរា បានបញ្ចប់ការងារជួសជុលទាំងស្រុង នូវសំណង់ព្រះវិហារបុរាណមួយនៅបរិវេណវត្តព្រះឥន្ទកោសីយ៍។

រូបភាពមុនពេលជួសជុល

រូបភាពក្រោយពេលជួសជុល

លោក ស៊ឹម ប៊ុនធឿន អនុប្រធាននាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ សំណង់ព្រះវិហារបុរាណនៅវត្តព្រះឥន្ទកោសីយ៍ ដែលបានបញ្ចប់ការជួសជុលទាំងស្រុងហើយនៅពាក់កណ្ដាលខែ កក្កដានេះ បន្ទាប់ពីចាប់ផ្ដើមពីដើមឆ្នាំ២០២៤មក។ លោកបន្តថា ព្រះវិហារដែលមានរាងតូចច្រឡឹងមួយនេះ ខូចខាតខ្លាំងនៅផ្នែកដំបូល ដែលពេលជួសជុលត្រូវប្រើសម្ភារថ្មីច្រើន តែជាសម្ភារដូចរបស់ដើម ចំណែកផ្នែកផ្សេងទៀតដែលមានការខូចខាត ស្ថិតក្នុងកម្រិតនៃការជួសជុលបាន ហើយក្រុមការងាររបស់អាជ្ញាធរជាតិអប្សរា បានជួសជុល និងអភិរក្សឡើងវិញ ដោយរក្សានូវទម្រង់ដើមទាំងស្រុង។

ចំពោះគុណតម្លៃនៃសំណង់ព្រះវិហារខាងលើនេះ លោក ស៊ឹម ប៊ុនធឿន ពន្យល់ថា វាមានតម្លៃមិនអាចកាត់ថ្លៃបាន។ ជាគុណតម្លៃរួម សំណង់វិហារនេះបានបង្ហាញពីប្រវត្តិសាស្ត្រ និងសិល្បៈដ៏យូរលង់របស់ខ្មែរដែលមានអាយុជិត១០០ឆ្នាំ ហើយដែលបុព្វការីជនអ្នកមានជំនឿក្នុងព្រះពុទ្ធសាសនានៅពេលនោះ មានសទ្ធាសាងសង់ព្រះវិហារនេះឡើងដើម្បីទុកជាមរតកសម្រាប់អ្នកជំនាន់ក្រោយថែរក្សា។ ចំណែកតម្លៃជារូបរាងវិញ ព្រះវិហារនេះសង់លើខឿនខ្ពស់ពីដីបន្តិច មានរាងតូចត្រឡឹងមិនធំពេក និងមិនតូចពេក ងាយស្រួលការគោរព និងថែទាំអភិរក្ស។ សម្រាប់លោក ស៊ឹម ប៊ុនធឿន សំណង់នេះបង្ហាញពីស្ថាបត្យកម្មជំនាន់នោះដែលគិតគូរវែងឆ្ងាយទៅអនាគត បើសំណង់ខ្ពស់ពេក ធ្វើឱ្យបាត់បង់សោភ័ណភាពនៅផ្នែកណាមួយមិនខាន។

ជាអ្នកស្រឡាញ់ និងអភិរក្សសំណង់បុរាណមួយរូប លោក ស៊ឹម ប៊ុនធឿន ស្នើឱ្យតាមវត្តអារាមទាំងអស់ ត្រូវចូលរួមថែរក្សាព្រះវិហារបុរាណ កុំព្យាយាមរុះរើសំណង់ចាស់ចោល សង់សំណង់ថ្មី ព្រោះសំណង់ទាំងបង្ហាញពីប្រវត្តិ សិល្បៈ និងវប្បធម៌ដ៏ផូរផង់របស់ជាតិខ្មែរទាំងមូល។

គ្រូសូត្រឆ្វេងវត្តព្រះឥន្ទកោសីយ៍ ព្រះអង្គ សន វាសនា មានសង្ឃដីកាថ្លែងអំណរគុណដល់ក្រុមការងារអាជ្ញាធរជាតិអប្សរា ដែលខិតខំជួសជុលព្រះវិហារបុរាណខាងលើបានដោគជ័យជាស្ថាពរ។ ព្រះអង្គក៏បានផ្តាំផ្ញើទៅពុទ្ធបរិស័ទ និងព្រះសង្ឃទាំងអស់ក្នុងវត្តដែលមានវិហារចាស់ៗ ឬថ្មីៗ សូមជួយអភិរក្ស ថែរក្សាជារឿយៗ ដើម្បីបង្ការកុំឱ្យសំណង់ទាំងនោះខូចខាតខ្លាំង។ សម្រាប់ព្រះអង្គ សន វាសនា ព្រះវិហារជាចំណុចសំខាន់ ឬជាបេះដូងនៃទីសក្ការៈបូជារបស់សាសនា ហើយព្រះអង្គសុំឱ្យព្រះសង្ឃទាំងអស់ កុំចង់បានរបស់ថ្មីដោយវាយសំណង់ចាស់ចោលផ្ទុយទៅវិញសំណង់បុរាណទាំងនោះមានគុណតម្លៃផ្នែកបេតិកភណ្ឌជាតិជាច្រើន៕

ភ្នាក់ងារទេសចរស ង្គ្រោះបឋមភ្ញៀវទេសចរ មានអាការៈមិនស្រួលខ្លួន ពេលទស្សនានៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៤

ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៤ ក្រុមការងារភ្នាក់ងារទេសចររបស់អាជ្ញាធរជាតិអប្សរា ប្រចាំការគោលដៅប្រាសាទអង្គរវត្ត បានជួយសង្គ្រោះបឋមដល់ភ្ញៀវជនជាតិអង់គ្លេសម្នាក់ ដែលមានអាការៈមិនស្រួលខ្លួនអំឡុងពេលដើរទស្សនានៅចំណុចរួតព្រះពាន់នៃប្រាសាទអង្គរវត្ត។ បន្ទាប់ពីគាត់បានធូរស្បើយ ក្រុមការងារសហការជាមួយក្រុមការងារសណ្ដាប់ធ្នាប់សម្រួលឱ្យរ៉ឺម៉កកង់បីចូលមកយកគាត់ទៅសម្រាកនៅសណ្ឋាគារដែលគាត់ស្នាក់នៅ៕

សេចក្ដីប្រកាសព័ត៌មាន ទាក់ទងនឹងការចោទប្រកាន់ របស់ឧបករណ៍ឃោសនានយោបាយជ្រុលនិយម The Cambodia Daily ដែលបានចុះផ្សាយថា "មន្ត្រីអាជ្ញាធរជាតិអប្សរាម្នាក់បានទម្លាយថា កម្ពុជាកំពុងក្លាយជាទីតាំងប្រព្រឹត្តអំពើចោរកម្មដ៏គួរឱ្យភ័យខ្លាចលើភ្ញៀវទេសចរ" អមដោយខ្លឹមសារបំភ្លៃការពិត និងគ្មានមូលដ្ឋានមួយចំនួន

ពាក់ព័ន្ធនឹងករណីនេះ អាជ្ញាធរជាតិអប្សរា សូមបញ្ជាក់ជូនសាធារណជនទាំងអស់ មេត្តាជ្រាបដូចខាងក្រោម៖

ផ្សាយនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៤



អាជ្ញាធរជាតិអប្សរា ប្រារព្ធពិធីប្រុងពលីបើកការដ្ឋាន ជួសជុលស្ពានហាលខាងកើត នៃប្រាសាទបេងមាលា

ផ្សាយនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា ប្រារព្ធពិធីប្រុងពលីបើកការដ្ឋាន ជួសជុលស្ពានហាលខាងកើត នៃប្រាសាទបេងមាលា ក្រោមជំនួយថវិកាពីមូលនិធិពិសេសមេគង្គ-ឡានឆាង នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៤។

ក្នុងពិធីប្រុងពលីបើកការដ្ឋានជួសជុល មានការអញ្ជើញក្រោមអធិបតីភាព**ឯកឧត្តម គីម សុធិន** អគ្គនាយករងអាជ្ញាធរជាតិអប្សរា ឯកឧត្តម Lu Qizhi អគ្គកុងស៊ុល នៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំខេត្តសៀមរាប ប្រតិភូនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ប្រតិភូក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អភិបាលនៃគណៈអភិបាលស្រុកស្វាយលើ ប្រធាននាយកដ្ឋាន អនុប្រធាន អាជ្ញាធរមូលដ្ឋាន លោក លោកស្រី និងមន្ត្រី បុគ្គលិកនៃអាជ្ញាធរជាតិអប្សរា។

ឯកឧត្តម គឹម សុធិន អគ្គនាយករងអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ថា ស្ថានភាពស្ពានហាលខាងកើតនេះ បានខូចខាតស្ទើរទាំងស្រុង ដោយសារកត្តាមនុស្សអាយុកាល ធម្មជាតិ។ ជញ្ជាំងស្ពានស្រុត ប្រេះហែកទ្រេត និងរលុះធ្លាក់មួយចំនួន ចំណែកឯ បង្កាន់ដៃនាគរលំដួលទាំងស្រុង ថ្មបែកបាក់ជាច្រើនកំណាត់ កម្រាលស្ពានស្រុតហែកចេញជាច្រើនផ្នែក ថ្មប្រេះបែក និងពុកផុយ ហើយសសរម្ទូលទ្របង្កាន់ដៃនាគក៏ដួលរលំស្ទើរទាំងស្រុងដែរ។

ឯកឧត្តមបន្តទៀតថា គម្រោងជួសជុលស្ពានហាលខាងកើតដែលជាច្រកចូលសំខាន់របស់ប្រាសាទនេះ មានទទឹង១៣ម៉ែត្រ បណ្តោយរួមទាំងរចនាសម្ពន្ធស្ពានហាលប្រវែង១០០ម៉ែត្រ។ ការងារសិក្សាស្រាវជ្រាវបានចាប់ផ្តើមតាំងពីខែមេសា ឆ្នាំ២០២៤ ហើយការងារជួសជុលគ្រោងនឹងបញ្ចប់នៅខែកក្កដា ឆ្នាំ២០២៥ខាងមុខ។

ឯកឧត្តម Lu Qizhi មានប្រសាសន៍ថា ប្រាសាទបេងមាលា គឺជាផ្នែកមួយដ៏សំខាន់នៃរមណីយដ្ឋានអង្គរដែលបង្ហាញយ៉ាងពេញលេញអំពីប្រវត្តិសាស្ត្រដ៏យូរលង់របស់ប្រទេសកម្ពុជា និងបេតិកភណ្ឌវប្បធម៌ដ៏ជ្រាលជ្រៅ។ ការអនុវត្តគម្រោង អភិរក្ស និងការជួសជុលក្រោមក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងនឹងមិនត្រឹមតែលើកកម្ពស់ការបង្ហាញ និងការប្រើប្រាស់ទីតាំងប្រាសាទបេងមាលាប៉ុណ្ណោះទេ។ ប៉ុន្តែ ថែមទាំងផ្តល់នូវបទពិសោធន៍និងឯកសារយោងសំខាន់ៗសម្រាប់ការការពារបេតិកភណ្ឌវប្បធម៌ដ៏មានតម្លៃជាច្រើនរបស់កម្ពុជា។

ឆ្នាំនេះ គឺជាឆ្នាំនៃការផ្លាស់ប្តូរប្រជាជនរវាងប្រទេសចិននិងកម្ពុជាដែលបានកំណត់ រួមគ្នាដោយថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ។ ទាំងប្រទេសចិន និងកម្ពុជាមានប្រវត្តិសាស្ត្រដ៏យូរលង់ និងវប្បធម៌ដ៏វិសេសវិសាល ភាពបើកចំហ ការរួមបញ្ចូលនិងការរៀនសូត្រគ្នាទៅវិញទៅមក គឺជាកម្លាំងជំរុញសម្រាប់ការរីកចម្រើននៃអរិយធម៌៕

រូបភាពប្រចាំសប្តាហ៍៖ ខ្លោងទ្វារដីឆ្នាំងពេលភ្លៀងធ្លាក់

ផ្សាយនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៤

ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិ ចូលមកទស្សនាព្រះអាទិត្យរះ នាព្រឹកព្រលឹមនៅប្រាសាទអង្គរវត្ត ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៤

ភ្នាក់ងារទេសចរ សង្គ្រោះបឋមភ្ញៀវទេសចរ ដែលមានបញ្ហាសុខភាពពេលដើរទស្សនានៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៤

ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៣ ក្រុមការងារភ្នាក់ងារទេសចររបស់អាជ្ញាធរជាតិ ប្រចាំនៅគោលដៅប្រាសាទអង្គរវត្ត និងភ្នំបាខែង ជួយសង្គ្រោះភ្ញៀវទេសចរជាតិម្នាក់ រអិលដួលនៅចំណុចរានហាលនៃប្រាសាទអង្គរវត្ត និងបានសហការជាមួយក្រុមភ្នាក់ងារសណ្តាប់ធ្នាប់សម្រួលឱ្យរថយន្តចូលមកយកទៅមន្ទីរពេទ្យបន្តទៀត។

ចំណែកករណីដូចគ្នានេះដែរ ក្រុមការងារភ្នាក់ងារទេសចរបានធ្វើការជួយសង្គ្រោះបឋមដល់ភ្ញៀវជាជនជាតិឥណ្ឌាម្នាក់ ដែលមានអាការៈខ្យល់គរ នៅចំណុចព្រះពាន់ប្រាសាទអង្គរវត្ត និងបានធូរស្បើយអាចបន្តដើរទស្សនាទៀត។

ដូចគ្នានេះដែរ ក្រុមការងារជួយសង្គ្រោះបឋមដល់ភ្ញៀវទេសចរខ្មែរ ដែលមានអាការៈខ្យល់គរ ចំនួនមួយករណីទៀត និងបានសហការជាមួយក្រុមការងារភ្នាក់ងារសណ្តាប់ធ្នាប់សម្រួលឱ្យរថយន្តមកយកដើម្បីទៅព្យាបាលនៅមន្ទីរពេទ្យជាបន្តទៀត៕

លោកជំទាវបណ្ឌិត សភាចារ្យ ភឿង សកុណា អញ្ជើញដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំលើកទី៤៦ នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក នៅប្រទេសឥណ្ឌា

ផ្សាយនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៤

នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិតសភាចារ្យ** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានអញ្ជើញដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំលើកទី៤៦ នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក នៅប្រទេសឥណ្ឌា ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២១ រហូតដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤។

នៅក្នុងកំឡុងពេល នៃការចូលរួមកិច្ចប្រជុំដ៏មានសារសំខាន់លើផ្នែកវប្បធម៌នេះ **លោកជំទាវបណ្ឌិត សភាចារ្យ** ក៏នឹងមានការជួបសម្ដែងការគួរសម ព្រមទាំងពិភាក្សានូវការងារមួយចំនួនជាមួយដៃគូនៃប្រទេសជាមិត្ត និងបណ្ដាស្ថាប័ននានាមួយចំនួន ស្ដីពី ការអភិរក្ស និងអភិវឌ្ឍនៅរមណីយដ្ឋានបេតិកភណ្ឌពិភពលោកក្នុងប្រទេសកម្ពុជា៕

សេចក្ដីជូនដំណឹង ស្ដីពីការដកហូតដើមឈើ និងកាត់ក្រីមែកឈើ មានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
A P S A R A

លេខ: ៤២២ /ប.ស៨៣

សេចក្ដីជូនដំណឹង
ស្ដីពី
ការកាត់ដកហូតដើមឈើនិងកាត់ក្រីមែកឈើ
មានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់មន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ និងសមាគមបន្តុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន ក៏ដូចជាដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវ និងតាមបរិវេណប្រាសាទក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា អាជ្ញាធរជាតិអប្សរានឹងកាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើ នៅតាមទីតាំងនានាដូចខាងក្រោម៖

- កាត់ក្រីមែកឈើចំនួន០៥ដើម (ដើមឈើទាល៣ដើម ដើមស្លែង១ដើម ដើមស្ពង់១ដើម) ស្ថិតនៅបរិវេណប្រាសាទព្រះបាលិលេយ្យ
- កាត់ដកហូត និងកាត់ក្រីដើមឈើចំនួន០៦ដើម (កាត់ដកហូតដើមម្កាក់១ដើម កាត់ក្រីដើមត្រសេក២ដើម ដើមត្នោត១ដើម ដើមឫស្សី១ដើម ដើមអង្គោល១ដើម) ស្ថិតនៅបរិវេណប្រាសាទមេបុណ្យ
- កាត់ដកហូតដើមស្គួលងាប់១ដើម មានហានិភ័យស្ថិតនៅបរិវេណខ្លោងទ្វារខ្មោចខាងត្បូង
- កាត់ដកហូត និងកាត់ក្រីដើមឈើចំនួន១៤ដើម (កាត់ដកហូតដើមពព្លា២ដើម ដើមសង្កែ៥ដើម ដើមត្រសេក២ដើម ដើមឆ្កៀសំពោច១ដើម កាត់ក្រីដើមកំបោបាយ១ដើម ដើមសង្កែ១ដើម និងដើមស្រឡៅ២ដើម) ដែលមានហានិភ័យស្ថិតនៅបរិវេណប្រាសាទបេងមាលា
- កាត់ដកហូតដើមឈើទាលចំនួន១ដើមស្ថិតនៅភូមិស្ពានថ្មែក ឃុំកណ្ដែក ស្រុកប្រាសាទបាគង
- កាត់ដកហូតដើមឈើទាល០១ដើម ស្ថិតនៅភូមិស្រះស្រង់ ខាងជើង សង្កាត់នគរធំ ក្រុងសៀមរាប
- កាត់ដកហូត និងកាត់ក្រីដើមឈើចំនួន១៣ដើម (កាត់ដកហូតដើមគគី២ដើម កាត់ក្រីដើមឈើទាល៤ដើម ដើមត្រសេក០១ដើម ដើមទឹកដោះ០១ដើម ដើមគគី០១ដើម ដើមខ្នុរ១ដើម ដើមសំរោង១ដើម ដើមអង្គាញ់១ដើម ដើមត្នោត១ដើម) ស្ថិតនៅបរិវេណប្រាសាទលលៃ និងប្រាសាទព្រះគោ
- កាត់ដកហូត និងកាត់ក្រីដើមឈើចំនួន១១ដើម (កាត់ដកហូតដើមឈើទាល២ដើម ដើមកកោះ១ដើម ដើមក្រសាំង១ដើម កាត់ក្រីដើមឈើ៧ដើម) ស្ថិតនៅបរិវេណប្រាសាទបាគង និងព្រៃមន្ទីរ។
- កាត់ដកហូតដើមឈើចំនួន០២ដើម (ដើមឈើទាល០១ដើម ដើមក្រឡាញ់០១ដើម) ស្ថិតនៅប្រាសាទបាគង ខាងកើតប្រាសាទឥដ្ឋ។

ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា នឹងចាប់ផ្ដើមអនុវត្តការងារខាងលើចាប់ពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤ តទៅរហូតដល់ចប់ការកិច្ច។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមមន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ អន្តរជាតិ និងសមាគមបន្តុទ្ទេសក៍ ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ ចន្ទ ២ រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
សៀមរាប ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០២៤
អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្កោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប
អាជ្ញាធរអភិវឌ្ឍន៍ការគ្រប់គ្រងរមណីយដ្ឋាន និងតំបន់អង្គរ
Website: apsaraauthority.gov.kh　Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576
APSARA National Authority
Address: Bang Koeng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

កូនឈើចម្រុះចំនួន១០,៨៣០ដើម ត្រូវបានអាជ្ញាធរជាតិអប្សរា ចែកចាយពីថ្ងៃទី១៧ ដល់ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤

កូនឈើចម្រុះសរុប ១០,៨៣០ដើម បន្ថែមទៀត ត្រូវបានអាជ្ញាធរជាតិអប្សរា បន្តចែកចាយដល់ព្រះសង្ឃ ស្ថាប័នរដ្ឋ ឯកជន ព្រមទាំងសាធារណជននានា ចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៤



ក្រុមស្រាវជ្រាវបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា ធ្វើកំណាយស្រាវជ្រាវ នៅស្ថានីយស្លដែកបុរាណភ្នំបូក

ផ្សាយនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤

ក្រុមអ្នកបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរាធ្វើកំណាយស្រាវជ្រាវ នៅស្ថានីយស្លដែកបុរាណមួយកន្លែង នៅក្នុងភូមិស្រែចង្ហូត សង្កាត់រុនតាឯក ក្រុងរុនតាឯកតេជោសែន ជិតជើងភ្នំបូក។

បុរាណវិទូនៃអាជ្ញាធរជាតិអប្សរាលោកសួម សុភា ឱ្យដឹងថា ការធ្វើកំណាយស្រាវជ្រាវ នៅស្ថានីយស្លដែកសម័យបុរាណ ក្នុងតំបន់អតីតរាជធានីអង្គរនេះ គឺបំណង ដើម្បីសិក្សាឱ្យស៊ីជម្រៅពីឧស្សាហកម្មស្លដែក ការផលិតដែក ព្រមទាំងចង់ដឹងពីរចនាសម្ពន្ធនៃចង្ក្រានស្លដែករបស់ខ្មែរបុរាណកាលពីសម័យអង្គរផង ព្រមទាំងជួយបណ្តុះបណ្តាលយុវជនខ្មែរជំនាន់ក្រោយ ឱ្យយល់ដឹងពីជំនាញទាំងនោះផង។

ក្នុងការធ្វើកំណាយ នៅស្ថានីយស្លដែកសម័យបុរាណនោះ គឺមានយុវជនមកពីវិទ្យាល័យស្រុកប្រាសាទបាគងចំនួនជាង២០នាក់ ចូលរួមទស្សនាស្វែងយល់ និងសិស្សមកពីសាលាអន្តរជាតិ JPA ចំនួន៤នាក់ទៀត បានចូលរួមហ្វឹកហាត់ផងដែរ។

លោក សួម សុភា បញ្ជាក់ទៀតថា ក្នុងការធ្វើកំណាយស្រាវជ្រាវស្ថានីយស្លដែកបុរាណនោះ ក្រុមការងារបានជីករណ្តៅទំហំ៣ម៉ែត្រ គុណនិង៤ម៉ែត្រ។ នៅក្នុងរណ្តៅកំណាយគេបានប្រទះឃើញរ៉ែដែកតូចៗ បំណែកអាចម៍ដែក បំណែកចង្ក្រាន្ត និងបំណែកកុលាលភាជន៍ផ្សេងៗជាដើម។ ជាលទ្ធផល ក្រុមអ្នកបុរាណវិទ្យាបានសន្និដ្ឋានថា ស្ថានីយស្លដែកបុរាណ នៅក្នុងអតីតរាជធានីអង្គរ ដែលគេបានធ្វើកំណាយស្រាវជ្រាវនេះ បានដំណើរការនៅសម័យអង្គរ។ អ្នកស្រាវជ្រាវយល់ថា ឧស្សាហកម្មស្លដែកសម័យអង្គរ គឺជាវិស័យយ៉ាងសំខាន់មួយ ដែលបានផលិតដែកធ្វើជាឧបករណ៍ប្រើប្រាស់សម្រាប់កសិកម្ម គ្រឿងសាស្ត្រាវុធ ព្រមទាំងបម្រើការឱ្យវិស័យស្ថាបត្យកម្មជាដើម ដែលជួយឱ្យចក្រភពខ្មែរសម័យនោះ មានការរីកចម្រើនជឿនលឿន និងជាកត្តាមួយដែលជំរុញអារ្យធម៌អង្គរថ្កុំថ្កើន។

សូមបញ្ជាក់ថា មុនពេលដែលក្រុមអ្នកបុរាណវិទ្យា បើកកំណាយស្រាវជ្រាវស្ថានីយស្លដែកបុរាណនៅភ្នំបូកនោះ គឺអ្នកស្រាវជ្រាវបានសិក្សាតាមវិធីវាស់ស្ទង់ ប្រើឧបករណ៍ Gradiometer ដោយបានជំនួយពីសកលវិទ្យាល័យ FlindersUniversity,Australia ជាមុនដើម្បីសិក្សាបឋមពីវត្តមាននៃទីតាំងចង្ក្រាន នៅលើស្ថានីយនេះ៕

អាជ្ញាធរជាតិអប្សរា រៀបចំធ្វើបទបង្ហាញ ក្រោមប្រធានបទ «របត់សង្គមសម័យកណ្តាល តាមរយៈភស្តុតាងបុរាណវិទ្យាថ្មីៗ ក្នុងក្រុងសៀមរាប

ផ្សាយនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤

កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៤ នាមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ នៃទីស្នាក់ការអាជ្ញាធរជាតិអប្សរា ស្ថិតនៅភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប អាជ្ញាធរជាតិអប្សរាបានអញ្ជើញវាគ្មិនដែលជាដៃគូសហការណ៍ស្រាវជ្រាវ ធ្វើបាឋកថាអំពីលទ្ធផលស្រាវជ្រាវដែលបានធ្វើកន្លងមក ជូនមន្ត្រីបុគ្គលិក និងសាធារណជនស្តាប់ និងទស្សនា ក្រោមប្រធានបទ «របត់សង្គមសម័យកណ្តាលតាមរយៈភស្តុតាងបុរាណវិទ្យាថ្មីៗ ក្នុងក្រុងសៀមរាប»។

លោក អ៊ឹម សុខរិទ្ធី បុរាណវិទូ និងជាប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ អញ្ជើញចូលរួមបើកធ្វើបាឋកថានោះ ព្រមទាំងមានលោក លោកស្រីជាមន្ត្រី បុគលិកអាជ្ញាធរជាតិអប្សរា ព្រមទាំងសាធារណជនបានអញ្ជើញចូលរួមផងដែរ។ ទន្ទឹមនឹងនេះអាជ្ញាធរជាតិអប្សរាក៏បានផ្សាយបន្តផ្ទាល់តាមហ្វេកបុកផេករបស់ខ្លួន ដើម្បីឲ្យមជ្ឈដ្ឋានអ្នកស្រេវជ្រាវ និងសាធារណជនដទៃទៀត ដែលពុំមានពេលមកចូលរួមផ្ទាល់បាន។

វាគ្មិនជំនាញលោក បណ្ឌិត ហេង ពិភាល់ អ្នកស្រាវជ្រាវនៃបុរាណវិទ្យាCotsen(សាកលវិទ្យាល័យកាលីហ្វ័រញ៉ានៅឡូសអិនជីលេសUCLA) និងជាសាស្ត្រាចារ្យសាកលវិទ្យាល័យហាវ៉ៃសហរដ្ឋអាមេរិក ខ្លឹមសារសំខាន់ៗក្នុងបាឋកថានោះរួមមាន៖

- ការស្រាវជ្រាវបុរាណវិទ្យាថ្មីៗអំពីរបត់សង្គម និងការប្រែប្រួលនៃអារ្យធម៌អង្គរ
- តួនាទីរបស់បុរាណវិទ្យាប្រវត្តិសាស្ត្រ (Historical Arhaeology) ក្នុងការបំពេញ និងពង្រីកចំណេះដឹងប្រវត្តិសាស្ត្រដោយប្រើវិធីសាស្ត្រស្រាវជ្រាវចម្រុះ
- ការផ្លាស់ប្តូរនៅចុងសម័យអង្គរ
- វិស័យសេដ្ឋកិច្ចនៅសម័យក្រោយអង្គរ
- ការផ្លាស់ប្តូរសាសនា
- បេតិកភណ្ឌ និងការចងចាំ

បាឋកថាខាងលើបានបញ្ចប់ដោយជោគជ័យ ដោយសិក្ខាម និងសាធារណជន បានយកចិត្តទុកដាក់ ស្តាប់ និងមានសំណួរជជែកយ៉ាងផុសផុលជាមួយវាគ្មិនជំនាញ៕

សកម្មភាពលោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា ប្រធានគណៈប្រតិភូកម្ពុជា ក្នុងកិច្ចប្រជុំលើកទី៤៦នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក

ផ្សាយនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤

ក្នុងឱកាសដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមប្រជុំកិច្ចប្រជុំគណៈកម្មាធិការបេតិកភណ្ឌពិភពលោកលើកទី៤៦ នាទីក្រុងញូវដេលី ប្រទេសឥណ្ឌា នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានប្រតិភូ បានជួបសម្តែងការគួរសមជាមួយលោកជំទាវ Audrey AZOULAY អគ្គនាយិកា អង្គការយូណេស្កូ និងថ្នាក់ដឹកនាំដ៏ទៃទៀតនៃស្ថាប័នពាក់ព័ន្ធ ព្រមទាំងបណ្តាគណៈប្រតិភូប្រទេសជាមិត្តមួយចំនួនទៀត។

នាឱកាសនោះ លោកជំទាវបណ្ឌិតសភាចារ្យ បានជម្រាបជូនដល់លោកជំទាវអគ្គនាយិកានៃអង្គការយូណេស្កូ និងបណ្តាគណៈប្រតិភូទាំងនោះនូវកិច្ចខិតខំរបស់កម្ពុជាក្នុងនាមជារដ្ឋភាគីលើកិច្ចការអភិរក្សនិងអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃរមណីយដ្ឋានបេតិកភណ្ឌពិភពលោកដែលមាននៅកម្ពុជា៕

អាជ្ញាធរជាតិអប្សរា មានសេចក្តីរន្ធត់និងសោកស្តាយជាពន់ពេក ដោយនៅវេលាម៉ោងប្រមាណ៥:៣០នាទីល្ងាចថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤ មានឧបទ្ទវហេតុនូវការដួលរលំដើមឈើមួយដើម នៅខាងមុខខ្លោងទ្វារទន្លេអុំ នៃក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤

ក្នុងពេលបច្ចុប្បន្ន ក្រុមការងារជំនាញមកពីគ្រប់ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ កំពុងតែធ្វើការដកចេញនូវដើមឈើដែលបានដួលរលំនេះ

អាស្រ័យហេតុនេះ សូមសាធារណជនដែលមានភាពចាំបាច់ក្នុងការធ្វើដំណើរឆ្លងកាត់តាមគន្លងផ្លូវនេះ សូមមេត្តាធ្វើការបង្វៀងទៅប្រើប្រាស់ផ្លូវផ្សេងជំនួសវិញ។ អាជ្ញាធរជាតិអប្សរានឹងជូនដំណឹងជាថ្មី នៅពេលការងាររួចរាល់

អាជ្ញាធរជាតិអប្សរា
សូមជម្រាបជូនសាធារណជនទាំងអស់មេត្តាជ្រាបថា
នៅវេលាម៉ោង00:១៥នាទី ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤
ដើមឈើដែលបានដួលរលំនៅខ្លោងទ្វារទន្លេអុំ
ត្រូវបានដកចេញរួចរាល់

ការធ្វើដំណើរឆ្លងកាត់តាមគន្លងផ្លូវនេះ
អាចធ្វើចរាចរណ៍ឡើងវិញចាប់ពីពេលនេះតទៅ

ផ្សាយនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤

ក្រុមការងារសហគមន៍ បន្តចុះពិនិត្យសំណើពលរដ្ឋ នៅក្នុងរមណីយដ្ឋានអង្គរ បានចំនួន៣៩ករណី និងសម្រេចអនុញ្ញាតបានចំនួន២៧ករណី

ផ្សាយនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤

ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងរមណីដ្ឋានអង្គរត្រូវបានទទួលនូវការយកចិត្តទុកដាក់អំពីសំណាក់អាជ្ញាធរជាតិអប្សរាដោយមានការអនុគ្រោះក្នុងការជួសជុលតូចតាចនូវលំនៅដ្ឋានក៏ដូចជាសំណង់ឧបសម្ព័ន្ធមាន របង ដំបូល ជញ្ជាំង សសរពុកផុយ បង្គន់អនាម័យ រោងគោ ទ្រុងមាន់ និងទ្រុងជ្រូកជាដើម ហើយរាល់ការអនុញ្ញាតជួសជុលមានសុពលភាពត្រឹមពីរខែ នៅលើទីតាំងកំពុងរស់នៅផ្ទាល់តែម្តងតាមរយៈការចុះពិនិត្យ និងសម្រេចជាប្រចាំដោយក្រុមការងារសហគមន៍នាយកដ្ឋានគ្រប់គ្រង់ដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា។ជាក់ស្តែងក្នុងសប្តាហ៍ទី២(ទី៨ដល់ទី១២) នៃខែកក្កដា ក្រុមការងារសហគមន៍បានចុះ ពិនិត្យសំណើបានចំនួន ៣៩ករណី និងសម្រេចអនុញ្ញាតបានចំនួន ២៧ករណី ទៅតាមបណ្តាលស្រុក/ក្រុងទាំង៦ ដូចខាងក្រោម៖

- ក្រុងសៀមរាបអនុញ្ញាតបាន ១៣ករណី
- ស្រុកបន្ទាយស្រីអនុញ្ញាតបាន ៤ករណី
- ស្រុកអង្គរធំអនុញ្ញាតបាន ៩ករណី
- ស្រុកពួកអនុញ្ញាតបាន ១ករណី

សូមជម្រាបថា រាល់ការដាក់ពាក្យស្នើសុំច្បាប់ និងការអនុញ្ញាតគឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ។ ជាមួយគ្នានេះក្រុមការងារសង្កេតឃើញថា ក៏មានអ្នកដែលទទួលបានការអនុញ្ញាតហើយ ប៉ុន្តែពុំបានអនុវត្តត្រឹមត្រូវ ស្របនឹងការអនុញ្ញាតនោះឡើយ។

ដូច្នេះអាជ្ញាធរជាតិអប្សរា សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតឱ្យជួសជុលលំនៅដ្ឋានត្រូវអនុវត្តឲ្យស្របតាមចំណុចបច្ចេកទេសដែលមានការទទួលដឹងលឺ ពីអាជ្ញាធរមូលដ្ឋាន និងទទួលស្គាល់ដោយអាជ្ញាធរជាតិអប្សរា៕

អ្នកជួសជុលប្រាសាទបុរាណជំនាន់ថ្មី ចង់ឱ្យស្នាដៃដូនតានៅគង់វង្សគ្រប់ជំនាន់

ផ្សាយនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤

ក្នុងនាមជាអ្នកជួសជុលប្រាសាទបុរាណនៅជំនាន់ថ្មីនេះ បានខិតខំអស់ពីកម្លាំងកាយចិត្ត និងដោយក្តីស្រឡាញ់មរតកដូនតាដែលមានអាយុកាលរាប់រយឆ្នាំ រួចផុតពីការខូចខាតទៅតាមអាយុកាល និងធម្មជាតិឡើយ នៅគង់វង្សយូរអង្វែងសម្រាប់កូនខ្មែរគ្រប់ជំនាន់។

លោក ឃឹម សុផល អាយុ៤៥ឆ្នាំ ជាអ្នកភូមិស្រះស្រង់ខាងជើង សង្កាត់នគរធំ គឺជាកម្មករជំនាញជួសជុលប្រាសាទបុរាណក្នុងតំបន់អង្គរជាង២០ឆ្នាំ ជាមួយស្ថាប័នអាជ្ញាធរជាតិអប្សរា ដែលបច្ចុប្បន្ន រូបលោកកំពុងបន្តការងារជួសជុលខឿនជណ្តើរ និងបង្កាន់នាគផ្នែកខាងលិចនៃជណ្តើរកណ្តាលភាគខាងត្បូងនៃប្រាសាទអង្គរវត្ត។ លោក សុផល យល់ថា ការងារជួសជុល អភិរក្សប្រាសាទបុរាណ គឺមានតម្លៃធំធេងមិនអាចកាត់ថ្លៃបាន។ ចិត្តស្រឡាញ់ប្រាសាទបុរាណ លោក សុផល ចង់ឱ្យកេរដំណែលដូនតាខ្មែរគង់វង្សយូរអង្វែង ទុកសម្រាប់កូនខ្មែរជំនាន់ក្រោយឃើញ និងថែរក្សាបន្តទៀត។

ដូចគ្នានេះ លោក ធ្លក សុខ អាយុ៤៩ឆ្នាំ ជាអ្នកភូមិស្រះស្រង់ខាងជើងដែរ បានបង្ហាញការសប្បាយចិត្ត ដែលរូបគាត់ចូលបម្រើការងារជួសជុលប្រាសាទបុរាណប្រមាណជិត១០ឆ្នាំមកនេះ ព្រោះជឿតក្តីប្រាថ្នាចង់ឃើញប្រាសាទបុរាណមានភាពរឹងមាំជារៀងរហូត ហើយក្រុមការងារតែងតែខិតខំរួមគ្នាអស់ពីកម្លាំងកាយចិត្ត ដើម្បីឱ្យការងារនេះបានជោគជ័យ៕

ក្រុមយុវជនអ្នកវិទ្យាសាស្ត្រវ័យក្មេង១៣ប្រទេស ចូលរួមដាំកូនឈើជានិមិត្តរូប នៅតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤ ក្រុមយុវជនជាអ្នកវិទ្យាសាស្ត្រវ័យក្មេងមកពី១៣ប្រទេស ដែលចូលរួមក្នុងកិច្ចប្រជុំ «អាស៊ានបូកបី-វិថីនៃអ្នកវិទ្យាសាស្ត្រវ័យក្មេង (ASEAN Plus Three Junior Science Odyssey_ATP JSO) លើកទី១០ បានចូលរួមដាំកូនឈើសរុបចំនួន ២៤ដើម ជានិមិត្តរូបនៅក្នុងរមណីយដ្ឋានអង្គរ។ សូមបញ្ជាក់ថា កូនឈើដែលបានដាំ ជាប្រភេទកូនឈើធ្នង់ ត្រូវបានរៀបចំដាំនៅបរិវេណខាងត្បូងកសិន្ធុអង្គរវត្ត៕

អាជ្ញាធរជាតិអប្សរា ជួសជុលពង្រឹងតួប៉ម A នៃប្រាសាទគោកពោធិ៍

ផ្សាយនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤

បើទោះបីជាក្រុមប្រាសាទខ្លះមានទីតាំងនៅតំបន់ឆ្ងាយៗយ៉ាងណា ក៏អាជ្ញាធរជាតិអប្សរា តែងតែយកចិត្តទុកដាក់ថែទាំ និងជួសជុលប្រាសាទបុរាណទាំងនោះ។ ជាក់ស្តែង ក្រុមអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរា កំពុងជួសជុលពង្រឹងតួប៉ A នៃប្រាសាទគោកពោធិ៍ ដែលសាងសង់ពីឥដ្ឋលាយជាមួយថ្មភក់ ធ្វើជាគ្រឿងលម្អ មានអាយុកាលជាង១ពាន់ឆ្នាំ ដើម្បីបន្តភាពរឹងមាំនៃប្រាសាទនេះឡើងវិញ បន្ទាប់ពីពិនិត្យឃើញថា បានរងការខូចខាតខ្លាំងទាមទារឱ្យជួសជុលសង្គ្រោះជាបន្ទាន់។

លោក ហួរ សុធន បុរាណវិទូ នាយកដ្ឋានអភិរក្សប្រាសាទនៃអាជ្ញាធរជាតិអប្សរា និងជាអ្នកទទួលខុសត្រូវនៅការដ្ឋានជួសជុលប្រាសាទគោកពោធិ៍ ឱ្យដឹងថា ក្រុមប្រាសាទគោកពោធិ៍ មានតួប៉មចំនួន៤ កំណត់ជាតួប៉មA B C និងD តែមិនស្ថិតនៅក្នុងខ្សែបន្ទាត់តែមួយឡើយ ព្រោះសាងសង់ក្នុងសម័យកាលខុសគ្នា និងក្នុងរាជ្យនៃព្រះមហាក្សត្រផ្សេងៗគ្នា។ កត្តាអាយុកាលធម្មជាតិ និងកង្វះការថែទាំយូរអង្វែង ជាពិសេសដើមឈើ ធ្វើឱ្យរចនាសម្ពន្ធប្រាសាទរងការបំផ្លាញ ហើយតួប្រាង្គចំនួន២ តួប្រាង្គC និងD បានរលំដួលទាំងស្រុង នៅតែប្រាង្គ A សេសសល់ជញ្ជាំងជុំវិញ និងB នៅសល់តែខឿន និងជញ្ជាំងផ្នែកខាងត្បូង។

ក្នុងជំហានទីមួយ អាជ្ញាធរជាតិអប្សរា ជួសជុលពង្រឹងតួប៉មA ដោយក្រុមការងារបានសម្អាតរុក្ខជាតិ សម្រង់ប្លង់ ថតរូបរៀបចំឯកសារសម្អាតកំណកដី ជួសជុលពង្រឹងគ្រឹះខឿន និងជញ្ជាំង។ ប្រាសាទនេះធ្លាប់បានសម្អាត និងជួសជុលនៅសម័យបារាំងម្តងរួចមកហើយ។ ចំណែកការងារជួសជុលនេះ គ្រោងចំណាយពេលវេលា៦ខែ ចាប់ផ្តើមពីពាក់កណ្តាលខែមិថុនា ឆ្នាំ២០២៤។ អ្នកជំនាញរំពឹងថា ក្រោយការងារជួសជុលរួចរាល់ នឹងធ្វើឱ្យតួប៉មនៃប្រាសាទគោកពោធិ៍ មានភាពរឹងមាំឡើងវិញ ជាមរតកដល់អ្នកភូមិជុំវិញគោរពបូជា តាមជំនឿរហូតមក និងសម្រាប់កូនចៅជំនាន់ក្រោយ។

សូមជម្រាបថា ប្រាសាទគោកពោធិ៍ ជាក្រុមប្រាសាទមួយ មានទីតាំងស្ថិតនៅខាងជើងបារាយណ៍ទឹកថ្លា ប្រមាណជា២គីឡូម៉ែត្រ ស្ថិតក្នុងភូមិគោកពោធិ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប។ ក្រុមប្រាសាទនេះកសាងឡើងនៅចុងសតវត្សរ៍ទី៨ និងទី៩៕

ញត្តិគាំទ្ររបស់ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំនៃអាជ្ញាធរជាតិអប្សរា ចំពោះសារពិសេសរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា លើការអនុវត្តកម្មវិធី និងគម្រោងក្រោមក្របខណ្ឌនៃតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម (CLV-DTA)

ផ្សាយនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ៖......✓.......

ញត្តិគាំទ្រ

សារពិសេសរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា
លើការអនុវត្តកម្មវិធី និងគម្រោងក្នុងក្របខ័ណ្ឌនៃតំបន់ត្រីកោណអភិវឌ្ឍន៍
កម្ពុជា-ឡាវ-វៀតណាម (CLV-DTA)

យើងខ្ញុំជាថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំនៃអាជ្ញាធរជាតិអប្សរា សូមប្រកាសគាំទ្រយ៉ាងពេញទំហឹងចំពោះសារពិសេសរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** ពាក់ព័ន្ធការអនុវត្តកម្មវិធី និងគម្រោងក្រោមក្របខ័ណ្ឌតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម (CLV-DTA) ជាគំនិតផ្តួចផ្តើមដំបូងរបស់កម្ពុជានៅឆ្នាំ១៩៩៩ ក្នុងគោលដៅយុទ្ធសាស្ត្រជំរុញវឌ្ឍនភាពខេត្តជាប់ព្រំដែននៃប្រទេសទាំងបី ប្រែក្លាយទៅជាតំបន់ព្រំដែនមិត្តភាព សាមគ្គីភាព និងការអភិវឌ្ឍ។

គោលការណ៍គ្រឹះសំខាន់នៃកិច្ចសហប្រតិបត្តិការនេះ គឺដើម្បីលើកកម្ពស់ការគោរព និងការជឿទុកចិត្តគ្នាទៅវិញទៅមក សម្រាប់ផលប្រយោជន៍រួម ការការពារបូរណភាពទឹកដី និងការដោះស្រាយបញ្ហានានាអនុលោមតាមទំនាក់ទំនងការទូត និងលិខិតបទដ្ឋានគតិយុត្តអន្តរជាតិពាក់ព័ន្ធ។ គម្រោងនេះក៏បានគិតគូរដល់ផលប្រយោជន៍រួមគ្នាផ្សេងទៀតដូចជា ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការកាត់បន្ថយការជួញដូរមនុស្ស គ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន ការកាប់បំផ្លាញព្រៃឈើខុសច្បាប់ ការសម្រួលពាណិជ្ជកម្ម ការបង្កើនទំនាក់ទំនងប្រជាជន និងប្រជាជន ការលើកកម្ពស់វិស័យទេសចរណ៍ និងការអភិវឌ្ឍវិស័យកសិកម្ម ដែលមិនត្រឹមតែបានរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍតំបន់ត្រីកោណរបស់យើង ធ្វើឱ្យតំបន់នេះលែងជាតំបន់ដាច់ស្រយាលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានលើកកម្ពស់សេដ្ឋកិច្ចក្នុងតំបន់ពោរពេញដោយសក្តានុពល និងមានភាពទាក់ទាញក្នុងការរស់នៅ និងការវិនិយោគទៀតផង។

យើងខ្ញុំទាំងអស់គ្នា សូមប្រកាសថ្កោលទោស និងគាំទ្រយ៉ាងពេញទំហឹងចំពោះការអនុវត្តវិធានការច្បាប់ប្រឆាំងជនទាំងឡាយណា ដែលញុះញង់បង្កចលាចល សំដៅបំផ្លាញសមិទ្ធផល និងដំណើរការអភិវឌ្ឍនៃតំបន់ត្រីកោណអភិវឌ្ឍន៍ និងសូមអំពាវនាវដល់បងប្អូនជនរួមជាតិទាំងអស់ សូមបន្តគាំទ្រលើការអនុវត្តកម្មវិធី និងគម្រោងអភិវឌ្ឍន៍តំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម (CLV-DTA) របស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា ដែលមាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** ក្នុងការបន្តបេសកកម្មដ៏ឧត្តុង្គឧត្តមនេះ ដើម្បីឧត្តមប្រយោជន៍ជាតិមាតុភូមិ និងប្រជាជាតិយើង។

ថ្ងៃសុក្រ ៦ កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
សៀមរាប ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤
អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបន្ទាយ ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប
អាជ្ញាធរជាតិអប្សរាសហការគ្រប់រដ្ឋាន និងរៀបចំតំបន់ផ្សេ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576
APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

កិច្ចប្រជុំនៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោកកាន់តែមានភាពមមាញឹក

ផ្សាយនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤

នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រុមការងារបានអញ្ជើញចូលរួមក្នុងដំណើរការនៃកិច្ចប្រជុំគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ដែលកាន់តែមានសភាពមមាញឹកនៅក្នុងកាលៈទេសៈនៃការសម្រេចបញ្ចូលសម្បត្តិបេតិកភណ្ឌរបស់បណ្ដាប្រទេសផ្សេងៗទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

រូបភាពប្រចាំសប្តាហ៍៖ ទិដ្ឋភាពប្រាសាទភ្នំបាខែង ពីលើអាកាសមុនថ្ងៃរៀបលិច

ផ្សាយនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៤

សកម្មភាពកាត់ក្រី និងដកហូតដើមឈើ មានហានិភ័យនៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៤

ក្រុមការងារនាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និង ហេដ្ឋារចនាសម្ព័ន្ធ នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និង អនុវត្តវិធានការបន្ទាន់ចំពោះដើមឈើមួយចំនួនដែលមាន ហានិភ័យនៅរមណីយដ្ឋានអង្គរ ដើម្បីធានាសុវត្ថិភាពជូន ភ្ញៀវទេសចរ ចៀសវាងគ្រោះថ្នាក់ផ្សេងៗ៕

អាជ្ញាធរជាតិអប្សរា សហការជាមួយអង្គការដៃគូប្រឹក្សាកម្ពុជា ដាំដើមឈើចំនួន២៥០ដើម ក្នុងបរិវេណរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៤នេះ អាជ្ញាធរជាតិអប្សរា រួមជាមួយព្រះសង្ឃ ថ្នាក់ដឹកនាំ និងសិស្សានុសិស្ស នៃអង្គការដៃគូប្រឹក្សាកម្ពុជា(Mentors Cambodia) ចំនួន៧០អង្គ/នាក់រួមគ្នាដាំដើមឈើចម្រុះចំនួន២៥០ដើម និងស្មៅឡើងវិញ បរិវេណខាងមុខប្រាសាទអង្គរវត្ត ក្នុងភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ក្នុងគោលបំណងដើម្បីអភិរក្សរមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោក៕

រូបភាពប្រចាំសប្តាហ៍៖ គយគន់សម្រស់ប្រាសាទអង្គរវត្ត ពីលើអាកាសនារដូវវស្សា

ផ្សាយនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៤

សោភ័ណភាពក្រោយជួសជុលខ្លោងទ្វារខាងលិចប្រាសាទបន្ទាយក្តី

ផ្សាយនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៤

ខ្លោងទ្វារខាងលិច ក្នុងចំណោមខ្លោងទ្វារទាំង៤របស់ប្រាសាទបន្ទាយក្តី ដែលបានបញ្ចប់ការងារជួសជុលអភិរក្ស តាមបច្ចេកទេសអាណាស្ទីឡូ (Anastylosis) នៅចុងឆ្នាំ២០២៣កន្លងមក រួចផុតពីស្ថានភាពខូចខាតទ្រុឌទ្រោម ដោយពង្រឹងនូវគ្រឹះ ជួសជុលតួខ្លោងទ្វារដែលស្រុត ជញ្ជាំងហែក ហើយថ្មនៃរចនាសម្ពន្ធមួយចំនួនដែលរលុះធ្លាក់ត្រូវបានរៀបផ្គុំនៅទីតាំងដើម ផ្នែកខ្លះទៀតចាំបាច់ក៏ត្រូវប្រើថ្មថ្មីជំនួសដើម្បីភាពរឹងមាំឡើងវិញ។

បច្ចុប្បន្ននេះខ្លោងទ្វារខាងលិចនៃប្រាសាទបន្ទាយក្តី មានភាពរឹងមាំ និងសោភ័ណភាព ដែលរង់កក្រ្គកំពូលខ្លោងទ្វារញ ញឹមសារ ជា ថ្មី ដោយ ស្នាដៃ កូន ខ្មែរ ជំនាន់ ថ្មី ក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា។ សុវត្ថិភាពទាំងសំណង់ប្រាសាទបុរាណ និងភ្ញៀវទេសចរ៕

សកម្មភាពក្រុមការងារឆ្លាក់ងារទេសចរប្រចាំគោលដៅប្រាសាទបាគង រៀបចំចាក់បំពេញដីនៅទីតាំងផ្លូវចូលទស្សនាប្រាសាទបាគង ដើម្បីរក្សាបានសោភ័ណភាពល្អ និងភ្ញៀវទេសចរដើរឆ្លងកាត់ដោយមានសុវត្ថិភាព ពិសេសនៅក្នុងរដូវវស្សា

ផ្សាយនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៤

សប្តាហ៍ទី៣នៃខែកក្កដា ឆ្នាំ២០២៤នេះ ក្រុមការងារពិនិត្យ និងតាមដានការសាងសង់ ក្រោយទទួលបានការអនុញ្ញាត នាពេលកន្លងមករបស់ពលរដ្ឋរស់នៅក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៤

ប្រជាពលរដ្ឋដែលរស់នៅក្នុងរមណីយដ្ឋានអង្គរពីយូរមកហើយត្រូវបានទទួលការអនុញ្ញាតសាងសង់សំណង់នានាស្របតាមគោលការណ៍ច្បាប់ និងការងារជួសជុលតូចតាច (ដោយក្រុមការងារសហគមន៍)។ រាល់សំណង់នានា ដែលនៅមានសុពលភាព ត្រូវបាននាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា បានចុះទៅពិនិត្យ និងផ្តល់នូវលក្ខណៈបច្ចេកទេស ដោយពុំគិតប្រាក់កម្រៃជាប្រចាំរហូតសំណង់ទាំង នោះសង់រួចរាល់មួយរយភាគរយ។

ជាក់ស្តែងក្នុងសប្តាហ៍ទី៣ នៃខែកក្កដា ឆ្នាំ២០២៤ នេះ មន្ត្រី-បុគ្គលិកជំនាញ បានចុះពិនិត្យ និងផ្តល់លក្ខណៈបច្ចេកទេសនូវសំណង់ដែលបានការអនុញ្ញាត កន្លងមកចំនួន ៧០ករណី និងការជួសជុលតូចតាចដោយក្រុមការងារសហគមន៍ចំនួន ១៥៦ករណី ដែលស្ថិតក្នុងភូមិសាស្រ្ត ដូចខាងក្រោម៖

១. ក្រុងសៀមរាបចំនួន ៥៤ករណី
២. ស្រុកប្រាសាទបាគង ២៨ករណី
៣. ស្រុកបន្ទាយស្រីចំនួន ៥៩ករណី
៤. ស្រុកពួកចំនួន ៥០ករណី
៥. ស្រុកអង្គរធំចំនួន ២៩ករណី
៦. ស្រុកស្វាយលើ ០៦ករណី

សូមបញ្ជាក់ជូនផងដែរថា សំណង់ដែលទទួលបានការអនុញ្ញាតចំនួន ២២៦ករណី នេះមាន ១៧៤ករណី កំពុងតែសាងសង់ ជួសជុលត្រឹមត្រូវតាមការអនុញ្ញាត និងមាន ៥២ករណី មិនទាន់សាងសង់។ ហើយក្នុងចំណោមសំណង់ទាំង ១៧៤ករណី ដែលកំពុងតែសាងសង់ និងជួសជុលតត្រឹមត្រូវ មានសំណង់ដែលបាន សង់រួចរាល់ជាស្ថាបពរចំនួន ៥០ករណី និងសំណង់ដែលសង់ពុំទាន់រួចរាល់ តែហួសសុពលភាពមានចំនួន ១៧ករណី។

ក្រុមការងារបច្ចេកទេស និងបន្តតាមដានការសាងសង់ និងជួសជុលរហូតដល់ការ អនុញ្ញាតផុតសុពលភាព និងការសាងសង់រួចរាល់មួយរយភាគរយ៕

អាជ្ញាធរជាតិអប្សរា
កំពុងជួសជុលប្រាសាទត្រពាំងផុង
ផ្នែកខាងកើតខាងត្បូង និងខាងជើង

ផ្សាយនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤

ប្រាសាទត្រពាំងផុង គឺជាប្រាសាទទោល ដែលកសាងឡើងអំពីឥដ្ឋ ស្ថិតនៅភាគខាងត្បូង នៃក្រុងរលួស ក្នុងភូមិគោកស្រុក ឃុំរលួស ដែលមានចម្ងាយ៣គីឡូម៉ែត្រពីប្រាសាទបាគង។

បច្ចុប្បន្នដោយសារកត្តាអាកាសធាតុ អាយុកាល និងកត្តាមនុស្ស ធ្វើឱ្យប្រាសាទបុរាណមួយនេះ មានសភាពទ្រុឌទ្រោមជាខ្លាំង ជាហេតុធ្វើឱ្យក្រុមអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរា ត្រូវរៀបចំជួសជុលក្នុងដំណាក់កាលទី២ នៅផ្នែកខាងកើត ខាងត្បូង និងខាងជើង។ លោក សារាយ គឹមហួល ប្រធានអភិរក្សតំបន់រលួស នៃអាជ្ញាធរជាតិអប្សរាបានឱ្យដឹងថា ក្រុមការងារត្រូវតែជួយសង្គ្រោះប្រាសាទត្រពាំងផុងជាបន្ទាន់ ដោយចាប់ផ្តើមជួសជុលតាំងពីគ្រឹះរហូតដល់កំពូលប្រាសាទ។

លោក សារាយ គឹមហួល មានប្រសាសន៍ទៀតថា ការជួសជុលមាន២ដំណាក់កាល គឺដំណាក់កាលទី១ ជួសជុលផ្នែកខាងលិច ហើយដំណាក់កាលទី២ គឺជួសជុលផ្នែកខាងកើត ខាងត្បូងនិងខាងជើង។ ប្រាសាទត្រពាំងផុង កសាងឡើងពីឥដ្ឋបូកជាមួយកំបោរបាយអពីលើ ដោយមានការតុបតែងលម្អផ្តែរ ជណ្តើរ ស៊ុមទ្វារធ្វើពីថ្មភក់។ ប្រាសាទនេះ មានតួប្រាង្គ៥ មានបណ្ណាល័យ ហើយមានកសិន្ធុទឹកព័ទ្ធជុំវិញ។

បច្ចុប្បន្នដោយសារប្រាសាទត្រពាំងផុង មានសភាពទ្រុឌទ្រោមខ្លាំងដូចជាឥដ្ឋមួយចំនួនបានពុកផុយផ្តែរមុខនៅផ្នែកខាងកើតបានបាត់ ទើបក្រុមអភិរក្សនៃអាជ្ញាធរជាតិអប្សរា ចាប់ផ្តើមជួសជុល និងជួយសង្គ្រោះឡើងវិញដោយយកចិត្តទុកដាក់ខ្ពស់បំផុត៕

ទិដ្ឋភាពភ្ញៀវទេសចរទស្សនានៅប្រាសាទអង្គរវត្ត ព្រឹកថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤



**មានប្រជាពលរដ្ឋមួយចំនួនចោទសួរថា
ហេតុអ្វីត្រូវដកហូតដើមឈើយាងមួយដើមនេះ?
មូលហេតុចម្បងនោះគឺដើមឈើយាងមួយដើមនេះ
មានពុកគល់ និងប្រហោងក្នុង**

**ការដកហូតនៅពេលនេះគឺធ្វើតាមការវាយតម្លៃជាក់ស្តែង
ស្របតាមបច្ចេកទេស ដើមឈើនេះអាចដួលមកពេលណាមួយ
ជាយថាហេតុនៅពេលភ្លៀងនិងខ្យល់ខ្លាំង
រហូតដល់ពេលនេះអាជ្ញាធរជាតិអប្សរា
ដកហូតតែមួយដើមនេះប៉ុណ្ណោះ**

ផ្សាយនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា ជួសជុលប្រាង្គបណ្ណាល័យសង់ពីឥដ្ឋនៅជ្រុងឦសាន ប្រាសាទភ្នំក្រោម

ផ្សាយនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា កំពុងជួសជុលប្រាង្គបណ្ណាល័យសង់ពីឥដ្ឋនៅជ្រុងឦសានរបស់ប្រាសាទភ្នំក្រោមដើម្បីទប់ស្កាត់ការខូចខាត និងពង្រឹងភាពរឹងមាំឱ្យគង់វង្សយូរអង្វែងបន្តទៀត។

លោក រស់ វិសុទ្ធ មន្ត្រីអភិរក្សប្រាសាទនៃអាជ្ញាធរជាតិអប្សរា ឱ្យដឹងថា ដោយសាររចនាសម្ពន្ធសំណង់ប្រាសាទភ្នំក្រោមរងនូវអាកាសធាតុក្ដៅសើមសម្ពាធខ្យល់ពីបឹងទន្លេសាបជាប្រចាំ ក្នុងនោះសំណង់បណ្ណាល័យដែលសង់ពីឥដ្ឋស្ថិតនៅទិសឦសាន បាត់បង់អស់នូវកំបោរបាយអសឺករិចរិលខឿនជើងជញ្ជាំង រួមទាំងគ្រឿងបង្គុំទ្វារថ្មភក់ជើងក្រោមផង។ ជញ្ជាំងជ្រុងពាយ័ព្យហែកក្រៀក កំពូលប្រាសាទខូចខាតជ្រាបទឹកពេលភ្លៀងជាដើម។

មន្ត្រីអភិរក្សរូបនេះបន្តថា អាជ្ញាធរជាតិអប្សរា បានយកចិត្តទុកដាក់ជួសជុលពង្រឹងខឿនជើងជញ្ជាំងជុំវិញ។ ជួសជុលជ្រុងនិរតី និងជ្រុងឦសានរហូតដល់ក្បាំងជញ្ជាំងខាងលើ និងពង្រឹងរចនាសម្ពន្ធកំពូលប្រាសាទការពារជម្រាបទឹក និងសត្វល្អិតដើម្បីឱ្យប្រាសាទនេះរឹងមាំដោយគោរពទៅតាមធម្មនុញ្ញអង្គរ។

សូមបញ្ជាក់ថា ប្រាសាទភ្នំក្រោម ស្ថិតនៅភូមិភ្នំក្រោម សង្កាត់សៀមរាប ក្រុងសៀមរាប។ ប្រាសាទនេះកសាងនៅចុងសតវត្សរ៍ទី៩ ដើមសតវត្សរ៍ទី១០ សង់ពីឥដ្ឋ ថ្មភក់ និងថ្មបាយក្រៀម លើភ្នំកម្ពស់១៤០ម៉ែត្រ ជាភ្នំនៅទំនាបមាត់បឹងទន្លេសាបខាងត្បូងក្រុងសៀមរាប ក្នុងចម្ងាយ១២គីឡូម៉ែត្រ៕

ស្ពានភាពភ្ញៀវទេសចរចម្រុះជាតិសាសន៍ដើរទស្សនាប្រាសាទបាយ័ន នាថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែសីហា

នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០២៤ ក្រុមការងារផ្លាក់ងារទេសចរ ប្រចាំគោលដៅប្រាសាទតាព្រហ្ម ប្រទះឃើញកាបូបស្ពាយចំហៀងមួយ នៅចំណុចផ្លូវខាងត្បូងនៃប្រាសាទ ហើយបានសហការជាមួយនគរបាលការពារបេតិកភណ្ឌប្រគល់ជូនទៅម្ចាស់ដើមវិញ

ផ្សាយនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា
យកចិត្តទុកដាក់ក្នុងការរក្សានូវបរិស្ថាន
និងសោភ័ណភាពល្អក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤

កូនឈើចម្រុះចំនួន១០,១២៤ដើម បន្ថែមទៀតត្រូវបានអាជ្ញាធរជាតិអប្សរាចែកចាយ ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា បានបន្តចែកចាយកូនឈើសរុប ១០,១២៥ ដើមបន្ថែមទៀត ទៅស្ថាប័នរដ្ឋ ឯកជន វត្តអារាម និងប្រជាពលរដ្ឋក្នុងមូលដ្ឋានទាំងក្នុង និងក្រៅខេត្តសៀមរាប។ ដើមឈើទាំងនោះរួមមាន៖

- ប្រគេនកូនឈើចម្រុះជូនព្រះគ្រូសិរីរតនានុបាល ធុយ ធុល ព្រះគ្រូចៅអធិការវត្តជយមុនីនារាម(វត្តជយោ) ចំនួន៧០០ដើម
- ប្រគេនកូនឈើចម្រុះជូនព្រះគ្រូមុនីសន្តិបាល មល់ ប្រុស ព្រះគ្រូចៅអធិការវត្តពោធិវនារាម(វត្តស្លី) ចំនួន៧០០ដើម
- ផ្តល់កូនឈើចម្រុះជូនតំណាងឧត្តមសេនីយ៍ឯក ពៅ ហេង មេបញ្ជាការយោធភូមិភាគទី៤នៃកងទ័ពជើងគោក ចំនួន៣,០០០ដើម
- ផ្តល់កូនឈើចម្រុះចំនួន២,០០០ដើម ដើម្បីយកទៅចែកជូនប្រជាពលរដ្ឋរស់នៅក្រុងរុនតាឯក តេជោសែន
- ផ្តល់កូនឈើចម្រុះ ចំនួន៦៥០ដើម ដើម្បីយកទៅដាំបន្ថែមក្នុងភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប
- ផ្តល់កូនឈើចម្រុះជូនតំណាងលោក ឡាច សឿន ប្រធានក្រុមប្រឹក្សាឃុំសំរោងយា ចំនួន១,២០០ដើម ដើម្បីយកទៅដាំតាមដីទំនេរក្នុងបរិវេណវត្ត សាលារៀន សាលាឆទាន និងដីសហគមន៍ ក្នុងឃុំសំរោងយា ស្រុកពួក ខេត្តសៀមរាប

- ផ្តល់កូនឈើចម្រុះជូនលោក រំ រ៉ែន នាយកសាលាបឋមសិក្សា ថៃស្ស ចំនួន៨០០ដើម ដើម្បីយកទៅដាំបន្ថែមក្នុងបរិវេណ និងសងខាងផ្លូវចូលសាលារៀន ស្ថិតនៅសង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប
- ផ្តល់កូនឈើចម្រុះជូនកម្មវិធី អាស៊ានបូកបី វិថីនៃអ្នកវិទ្យាសាស្ត្រវ័យក្មេង លើកទី១០ និងអង្គការ Mentors Cambodia ចំនួន២៧៤ដើម ដើម្បីយកទៅដាំនៅបរិវេណខាងត្បូងកសិន្ទប្រាសាទអង្គរវត្តនៃរមណីយដ្ឋានអង្គរ
- ផ្តល់កូនឈើចម្រុះជូនលោក ណា សុភ័ក្រ ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន៣០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណវត្តអូរជា ស្ថិតនៅភូមិអូរជា ឃុំផ្លូវមាស ស្រុករតនមណ្ឌល ខេត្តបាត់ដំបង
- ផ្តល់កូនឈើចម្រុះជូនលោក សោម វុត្ថា ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន៥០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណដីបន្ទាយទាហានរថក្រោះ ស្ថិតនៅភូមិព្រៃខ្មុំ ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប

សេចក្តីប្រកាសព័ត៌មាន
ស្តីពីលទ្ធផលនៃកិច្ចប្រជុំគណៈកម្មាធិការ
បេតិកភណ្ឌពិភពលោកលើកទី៤៦
នៅទីក្រុងញូវដេលី សាធារណរដ្ឋឥណ្ឌា

ផ្សាយនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

សេចក្តីប្រកាសព័ត៌មាន
ស្តីពី
លទ្ធផលនៃកិច្ចប្រជុំគណៈកម្មាធិការបេតិកភណ្ឌពិភពលោកលើកទី៤៦
នៅទីក្រុងញូវដេលី នៃសាធារណរដ្ឋឥណ្ឌា

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈមានកិត្តិយសសូមជម្រាបជូនសារព័ត៌មានជាតិ និងអន្តរជាតិ ព្រមទាំងសាធារណជនមេត្តាជ្រាបថា ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីរាជរដ្ឋាភិបាលកម្ពុជា **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** បានដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំគណៈកម្មាធិការបេតិកភណ្ឌពិភពលោកលើកទី៤៦ ចាប់ពីថ្ងៃទី២១ រហូតដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៤ នាទីក្រុងញូវដេលី សាធារណរដ្ឋឥណ្ឌា។ កិច្ចប្រជុំនេះត្រូវបានអញ្ជើញចូលរួមបើកជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម Narendra Modi នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋឥណ្ឌា និងលោកជំទាវ Audrey Azoulay អគ្គនាយិកានៃអង្គការយូណេស្កូ**។ នាឱកាសក្នុងការចូលរួមកិច្ចប្រជុំដ៏មានសារៈសំខាន់នេះ **លោកជំទាវបណ្ឌិតសភាចារ្យ** បានជួបសម្តែងការគួរសមនិងពិភាក្សាការងារជាមួយឥស្សរជនមួយចំនួននៃស្ថាប័នទទួលបន្ទុកថែរក្សាការពារសម្បត្តិបេតិកភណ្ឌពិភពលោកក្នុងក្របខណ្ឌសន្ធិសញ្ញាឆ្នាំ១៩៧២។ លោកជំទាវប្រធានគណៈប្រតិភូក៏បានលើកឡើងពីការងាររបស់កម្ពុជាក្នុងភាពតួកិច្ចជារដ្ឋភាគីក្នុងការថែរក្សាការពារសម្បត្តិបេតិកភណ្ឌពិភពលោកនានាដែលកម្ពុជាបានចុះបញ្ជីកន្លងមក។

លទ្ធផលដែលទទួលបានរួមមាន៖

១. គណៈកម្មាធិការបេតិកភណ្ឌពិភពលោកបានពិនិត្យលើរបាយការណ៍ នៃសម្បត្តិបេតិកភណ្ឌពិភពលោកដែលស្ថិតក្នុងបញ្ជីគ្រោះថ្នាក់ចំនួន៥៦ បានឯកភាពដកចេញវាកាលបរិច្ឆេទឆ្នាំជាសកលដោយសារការសាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្មីៗ និងការស្នើសុំកែសម្រួលតំបន់ការពារ។ ជាមួយគ្នានោះដែរ គណៈកម្មាធិការក៏បានពិនិត្យលើរបាយការណ៍ដែលផ្តល់ដោយរដ្ឋភាគីសរុបចំនួន១៣៧ ក្នុងនោះរបាយការណ៍ចំនួន១៣ ត្រូវបានលើកមកពិភាក្សា និងចំនួន៥៤ផ្សេងទៀតត្រូវអនុម័តដោយមិនលើកមកពិភាក្សា។

២. គណៈកម្មាធិការបេតិកភណ្ឌពិភពលោក បានទទួលយករបាយការណ៍ដែលរៀបចំដោយអាជ្ញាធរជាតិអប្សរាដែលរួមមាន ការអភិរក្សនិងអភិវឌ្ឍយូរអង្វែង ក៏ដូចជាការរៀបចំគម្របរឹយកម្មនៅរមណីយដ្ឋានអង្គរនិងព្រះខ័ន។

១

ទូរស័ព្ទ / ទូរសារៈ 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

៣. គណៈកម្មាធិការបេតិកភណ្ឌពិភពលោកបានផ្តល់អនុសាសន៍ដល់កម្ពុជា ក្នុងនាមជារដ្ឋភាគី អញ្ជើញអ្នកជំនាញពីមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោក ស្ថាប័ន ICOMOS និង ICCROM ដើម្បីសិក្សាឲ្យបានស៊ីជម្រៅពីស្ថានភាពចុះទៅនៃកិច្ចការអភិរក្ស និងអភិវឌ្ឍនៅក្នុងបរិបទថ្មីដែលជាការរួមបញ្ចូលនៃកិច្ចការពារបេតិកភណ្ឌរូបី និងអរូបីនៃប្រជាពលរដ្ឋមូលដ្ឋានក្នុងរមណីយដ្ឋានអង្គរ ក៏ដូចជាការរៀបចំគម្របរឹយកម្មថ្មីនៅទីក្រុងអង្គរធំជាពិសេស។

៤. គណៈប្រតិភូក៏បានដកស្រង់និងទទួលយកនូវបទពិសោធន៍ ព្រមទាំងយន្តការថ្មីៗផ្សេងទៀតក្នុងការថែរក្សា ការពារសម្បត្តិបេតិកភណ្ឌពិភពលោកនាពេលបច្ចុប្បន្នដែលពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ ការរួមចំណែករបស់សហគមន៍ កិច្ចការពារបេតិកភណ្ឌពិភពលោកក្នុងករណីមានជម្លោះប្រដាប់អាវុធ និងការគ្រប់គ្រងទេសចរណ៍ប្រកបដោយចីរភាព។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសារព័ត៌មានជាតិ និងអន្តរជាតិ ព្រមទាំងសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤

២

ក្រុមការងារសហគមន៍ បន្តចុះពិនិត្យសំណើពលរដ្ឋនៅក្នុងរមណីយដ្ឋានអង្គរ បានចំនួន៦៩ករណី និងសម្រេចអនុញ្ញាតបានចំនួន៥៩ករណី

ផ្សាយនៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៤

ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងរមណីដ្ឋានអង្គរ ត្រូវបានទទួលនូវការយកចិត្តទុកដាក់អំពីសំណាក់អាជ្ញាធរជាតិអប្សរា ដោយមានការអនុគ្រោះក្នុងការជួសជុលតូចតាចនូវលំនៅដ្ឋានក៏ដូចជាសំណង់ឧបរសម្ព័ន្ធមាន របង ដំបូល ជញ្ជាំង សសរពុកផុយ បង្គន់អនាម័យ រោងគោ ទ្រុងមាន់ និងទ្រុងជ្រូកជាដើម ហើយរាល់ការអនុញ្ញាតជួសជុលមានសុពលភាពត្រឹមពីរខែ នៅលើទីតាំងកំពុងរស់នៅផ្ទាល់តែម្តងតាមរយៈការចុះពិនិត្យ និងសម្រេចជាប្រចាំដោយក្រុមការងារសហគមន៍នាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា។ជាក់ស្តែងក្នុងសប្តាហ៍ទី៤(ទី២២ដល់ទី២៨) នៃខែកក្កដា ក្រុមការងារសហគមន៍បានចុះ ពិនិត្យសំណើបានចំនួន៦៩ករណី និងសម្រេចអនុញ្ញាតបានចំនួន៥៩ករណី ទៅតាមបណ្តាលស្រុក/ក្រុងទាំង៦ ដូចខាងក្រោម៖

- ស្រុកបន្ទាយស្រីអនុញ្ញាតបាន ១៥ករណី
- ក្រុងសៀមរាបអនុញ្ញាតបាន ២៨ករណី
- ស្រុកស្វាយលើអនុញ្ញាតបាន ២ករណី
- ស្រុកពួកអនុញ្ញាតបាន ៦ករណី
- ស្រុកអង្គរធំអនុញ្ញាតបាន ៥ករណី
- ស្រុកប្រាសាទបាគងអនុញ្ញាតបាន ៣ករណី

ថ្នាក់ដឹកនាំ ព្រះមន្ត្រីសង្ឃ មន្ត្រីរាជការ និងសមណនិស្សិត និស្សិតនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ និមន្ត/ធ្វើដំណើរទស្សនកិច្ចក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៤

ថ្នាក់ដឹកនាំព្រះមន្ត្រីសង្ឃ មន្ត្រីរាជការ និងសមណនិស្សិត និស្សិត ចំនួន៣៩០អង្គ/នាក់ និមន្ត/អញ្ជើញពីរាជធានីភ្នំពេញ ខេត្តកំពង់ឆ្នាំង និងខេត្តបាត់ដំបង និមន្ត/ធ្វើដំណើរទស្សនកិច្ចក្នុងតំបន់រមណីយដ្ឋានអង្គរ រយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៤។

គោលបំណង នៃដំណើរទស្សនកិច្ច សិក្សាឈ្វេងយល់ និងផ្តិតយករូបភាពនានាតាមប្រាសាទ ព្រមទាំងបានជាប្រយោជន៍ដល់ការរៀបចំឯកសារ សម្រាប់បំពេញនូវលក្ខខណ្ឌនៃការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤។

អាជ្ញាធរជាតិអប្សរា ក៏បានជួយសម្របសម្រួល និងធ្វើបទបង្ហាញតាមប្រធានបទមួយចំនួន ជូនថ្នាក់ដឹកនាំ ព្រះមន្ត្រីសង្ឃ មន្ត្រីរាជការ និងសមណនិស្សិត និស្សិត ក្នុងដំណើរទស្សនកិច្ចខាងលើ ទទួលបានជោគជ័យ៕

អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជម្រាបជូនសាធារណជន ភ្ញៀវជាតិនិងអន្តរជាតិ ព្រមទាំងប្រតិបត្តិករក្នុងវិស័យទេសចរណ៍ទាំងអស់បានជ្រាបថា ក្នុងគោលដៅបង្កភាពងាយស្រួលក្នុងការថតវីដេអូ ឬរូបភាពសន្លឹកក្នុងរមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរាសូមជម្រាបជូនអំពីការកែសម្រួលនូវលក្ខខណ្ឌតម្លៃថ្មីពាក់ព័ន្ធ ដូចខាងក្រោម៖

ផ្សាយនៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៤



ភ្ញៀវទេសចរជាតិនិងអន្តរជាតិ បង្ហាញភាពស្ញប់ស្ញែងពេលមកទស្សនាប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៤

គ្រប់ពេលវេលាទាំងអស់ ភ្ញៀវទេសចរ ចម្រុះជាតិសាសន៍ ពេលមកដល់ខេត្តសៀមរាប តែងតែងចង់មកមើលប្រាសាទអង្គរវត្ត ជាគោលដៅទី១មុនគេ។ ភាពល្បីល្បាញរបស់ប្រាសាទអង្គរវត្ត ក្រៅពីមានសំណង់ប្រវត្តិសាស្ត្រដ៏អស្ចារ្យគ្មានពីរនៅលើលោក ក៏មានព្រៃឈើធម្មជាតិនិងបរិស្ថាន ជាចំណុចទាក់ទាញភ្ញៀវទេសចរបន្ថែមទៀត ធ្វើឱ្យភ្ញៀវទេសចរគ្រប់រូប បានធូរស្បើយពីទុក្ខកង្វល់ ដោយសារតែឃើញកសិន្ធុទឹកថ្លាយង់ដ៏ធំល្វឹងល្វើយ វាលស្មៅពណ៌បៃតងខ្ចី ហាក់បីដូចជាខ្លួនគេកំពុងស្ថិតនៅក្នុងឋានដ៏ពិសិដ្ឋមួយ។

លោក ផល វណ្ណៈ ដែលមកកម្សាន្តប្រាសាទអង្គរវត្ត ជាមួយក្រុមការងារច្រើននាក់ទៀតកាលពីថ្ងៃទី១ខែសីហា បានបង្ហាញអារម្មណ៍រីករាយ និងស្រស់ស្រាយ។ លោក វណ្ណៈ ឱ្យដឹងថា អង្គរវត្តពិតជាអស្ចារ្យ ហើយវារិតតែពិសេសទៅទៀត នៅពេលដែលមគ្គុទ្ទេសក៍ទេសចរណ៍បានរៀបរាប់ពីរឿងរ៉ាវនានានៅតាមប្រាសាទឱ្យលោកស្តាប់។ បុរសអ្នកភ្នំពេញរូបនេះ បានចាត់ទុកអង្គរវត្តគឺជាសំណង់ដ៏ល្អឯក ដែលមានចម្លាក់នៅតាមផ្ទាំងថ្មជាច្រើនដ៏រស់រវើក ព្រមទាំងមានធម្មជាតិ ដ៏ស្រស់ស្អាតនៅជុំវិញបរិវេណផង គឺកាន់តែធ្វើឱ្យរូបលោកមិនស្ទើចសរសើរមិនបាន។

ចំណែកអ្នកស្រី សាម សេត ដែលជាអ្នកទេសចរ មកដល់អង្គរវត្តជាលើកដំបូងក៏មានចិត្តសប្បាយរីករាយដែរ។ អ្នកស្រីបានប្រាប់ថា ពេលដែលគាត់បានឃើញកំពូលប្រាសាទអង្គរវត្ត កសិន្ធុទឹក និងវាលស្មៅបៃតងស្រស់ស្អាតភ្លាម គឺមានអារម្មណ៍រីករាយ រំភើបនិងស្បើយពីកង្វល់នានាភ្លាម។

មិនត្រឹមតែភ្ញៀវទេសចរជាតិប៉ុណ្ណោះទេដែលស្ងើចសសើរអំពីភាពអច្ឆរិយៈនៃប្រាសាទអង្គរវត្តនិងទេសភាពដ៏ស្រស់ស្អាតនោះ សូម្បីតែភ្ញៀវទេសចរបរទេស ក៏បង្ហាញអារម្មណ៍ដូចគ្នានេះដែរ។

បុរសជនជាតិអេស្ប៉ាញ ដែលបាននាំភរិយានិងកូន២នាក់ទៀតមកទស្សនាអង្គរវត្ត បានបង្ហាញអារម្មណ៍ស្ញប់ស្ញែងជាមួយសំណង់ស្ថាបត្យកម្មដែលមានអាយុជិតមួយពាន់ឆ្នាំនេះដែរ។ លោកមានប្រសាសន៍ថា វាពិតជាមានភាពអស្ចារ្យបំផុត ដែលធ្វើឱ្យលោកនិងក្រុមគ្រួសារបានឃើញជាលើកដំបូង។

បុរសដដែលបញ្ជាក់ថា បានជាប់ចិត្តជាមួយប្រាសាទបុរាណនៅទីនេះយ៉ាងខ្លាំង ហើយលោកនឹងបន្តនាំភរិយានិងកូនដើរទស្សនាក្រុងអង្គរធំ ព្រមទាំងប្រាសាទតាព្រហ្មថែមទៀត៕

សកម្មភាពនៃការសម្អាតបរិស្ថាន និងអនាម័យនៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៤

សកម្មភាពនៃការសម្អាតបរិស្ថាន និងអនាម័យនៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ: ៥៧៨៦/២៤ ខ.ប.សរ.ពា

សារលិខិតគោរពជូនពរ

សូមគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា
នៃព្រះរាជាណាចក្រកម្ពុជា

សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់!

ក្នុងឱកាសដ៏មហានក្ខត្តឫក្សថ្លៃថ្លានៃថ្ងៃចម្រើនជន្មាយុគម្រប់ ៧២ឆ្នាំ ឈានចូល ៧៣ឆ្នាំ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា** ដែលនឹងចូលមកដល់នៅថ្ងៃចន្ទ ១កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤ ខាងមុខនេះ តាងនាមថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងផ្ទាំនៃអាជ្ញាធរជាតិអប្សរា និងក្នុងនាមខ្លួនខ្ញុំបាទផ្ទាល់ យើងខ្ញុំសូមសម្តែងនូវមនោសញ្ចេតនារីករាយឥតឧបមា និងសេចក្តីគោរពស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត ព្រមទាំងសូមគោរពជូនពរបវរមហាប្រសើរជូន **សម្តេចអគ្គមហាសេនាបតីតេជោ ប្រធានព្រឹទ្ធសភា** ជាទីគោរពដ៏ខ្ពង់ខ្ពស់ សូមមានជន្មាយុយឺនយូរ សុខមាលភាពល្អបរិបូរណ៍ បញ្ញាញាណភ្លឺថ្លា ដើម្បីដឹកនាំព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៥ ទទួលបានជោគជ័យដ៏ត្រចះត្រចង់ថ្មីៗបន្ថែមទៀត។

ឆ្លៀតក្នុងឱកាសនេះផងដែរ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវការគោរពដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ** មហាវីរបុរសជាតិរបស់កម្ពុជា ស្ថិតក្នុងបេះដូងប្រជាជនគ្រប់ស្រទាប់ដែលនាពេលកន្លងមក និងមកទល់បច្ចុប្បន្ន បាន ហើយនឹងបន្តយកអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី និងបទពិសោធន៍ប្រកបដោយគុណវិភាពក្នុងការបង្កើតនូវស្នាដៃ និងសមិទ្ធផលជូនជាតិគួរជាទីមោទនៈ ដែលនាំមកនូវកិត្យានុភាពជាតិល្បីសុះសាយលើឆាកអន្តរជាតិ និងទទួលបានការគាំទ្រពីប្រជាពលរដ្ឋខ្មែរគ្រប់មជ្ឈដ្ឋាន។

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងផ្ទាំនៃអាជ្ញាធរជាតិអប្សរា និងក្នុងនាមខ្លួនខ្ញុំបាទផ្ទាល់ យើងខ្ញុំសូមសម្តែងនូវកតញ្ញុតាធម៌ សូមលំឱនកាយបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតារក្សាព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយបីបាច់ថែរក្សា អភិបាលប្រោះព្រំសព្វសាធុការពរ បវរសួស្តី សិរីមង្គល វិបុលសុខមហាប្រសើរជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ប្រធានព្រឹទ្ធសភា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ព្រមទាំងក្រុមគ្រួសារ សូមបានប្រកបដោយពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ។

ថ្ងៃ សុក្រ ១៣រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
សៀមរាប ថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០២៤
អគ្គនាយក

ហង់ ពៅ

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្គោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

ក្រុមការងារអាជ្ញាធរជាតិអប្សរា បោសសម្អាតដី ប្រមូលសំរាម ស្លឹកឈើ និងរៀបចំអនាម័យបរិស្ថាន ដើម្បីលើកកម្ពស់សោភ័ណភាព អនាម័យ បរិស្ថាន និងសុខុមាលភាព របស់ភ្ញៀវទេសចរដែលមកកម្សាន្ត នៅប្រាសាទ

ផ្សាយនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២៤

ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ចូលរួមទិវារត់ប្រណាំងម៉ារ៉ាតុន ចក្រភពអង្គរលើកទី៩

ផ្សាយនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៤នេះ **ឯកឧត្តម ឡុង កុសល** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានចូលរួមក្នុងពិធីបើកទិវារត់ប្រណាំងម៉ារ៉ាតុនចក្រភពអង្គរលើកទី៩ ដែលប្រារព្ធឡើងនៅខាងមុខប្រាសាទអង្គរវត្ត។ ពិធីនេះមានការចូលរួមជាអធិបតីភាពពី**ឯកឧត្តម ថោង ខុន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណៈកម្មាធិការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តសៀមរាប រួមទាំងអាជ្ញាធរពាក់ព័ន្ធ ក្រុមអត្តពលិកជាតិ និងអន្តរជាតិយ៉ាងច្រើនកុះករ។

នៅក្នុងទិវារត់ប្រណាំងម៉ារ៉ាតុនចក្រភពអង្គរទី៩នេះ មានការចូលរួមពីអត្តពលិកចូលរួមចំនួន៣,០២១នាក់មកពីបណ្តាប្រទេសចំនួន៥១។ទិវារត់ប្រណាំងម៉ារ៉ាតុនចក្រភពអង្គរ ត្រូវបានរៀបចំធ្វើជារៀងរាល់ឆ្នាំនៅខេត្តសៀមរាប ហើយព្រឹត្តិការណ៍នៅឆ្នាំនេះ គឺធ្វើឡើងដើម្បីស្វែងរកមូលនិធិជួយដល់មន្ទីរពេទ្យគន្ធបុប្ផា ក៏ដូចជាដើម្បីទាក់ទាញភ្ញៀវទេសចរឱ្យមកទស្សនាតំបន់ទេសចរណ៍កម្ពុជា ពិសេសខេត្តសៀមរាបតែម្តង។ ជាមួយគ្នានេះ ទិវានេះក៏ធ្វើឡើងក្នុងគោលបំណងកិច្ចការពារបរិស្ថានបៃតងក្នុងរមណីយដ្ឋានអង្គរ៕

សិស្សានុសិស្សសាលាអន្តរជាតិសន្តិភាព ENH ចំនួន៣០០នាក់ មកទស្សនាស្វែងយល់នៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ

ផ្សាយនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២៤

កាលពីថ្ងៃទី៣ ខែសីហា ឆ្នាំ២០២៤ សិស្សានុសិស្សសាលាអន្តរជាតិសន្តិភាព ENH ចំនួន៣០០នាក់ បានមកទស្សនាស្វែងយល់នៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ក្នុងគោលបំណងស្វែងយល់ពីតួនាទីរបស់សារមន្ទីរ និងវត្ថុសិល្បៈនានា បានមកពីការស្រាវជ្រាវរបស់អាជ្ញាធរជាតិអប្សរា និងអង្គការស្ថាប័នអន្តរជាតិ ក្នុងកិច្ចការជួសជុល អភិរក្ស ស្រាវជ្រាវនៅក្នុងតំបន់អង្គរ៕

អាជ្ញាធរជាតិអប្សរា ប្រកាសស្វែងរកម្ចាស់ទូរស័ព្ទដែលជ្រុះ ឬភ្លេចនៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា សូមប្រកាសស្វែងរកម្ចាស់ទូរស័ព្ទម៉ាកiPhone7ពណ៌ទឹកមាសចំនួន១គ្រឿងដែលបានជ្រុះ ឬភ្លេច ពេលមកទស្សនានៅប្រាសាទអង្គរវត្ត។

បច្ចុប្បន្នក្រុមការងារភ្នាក់ងារទេសចរប្រចាំគោលដៅប្រាសាទអង្គរវត្ត បានសហការប្រគល់ជូនទៅនគរបាលទេសចរណ៍រក្សាទុករង់ចាំម្ចាស់ត្រឡប់មកទទួលយកវិញ។ សូមម្ចាស់ទូរស័ព្ទខាងលើអាចទំនាក់ទំនងដោយផ្ទាល់ជាមួយភ្នាក់ងារទេសចរ ឬនគរបាលទេសចរណ៍ប្រចាំការនៅប្រាសាទអង្គរវត្ត៕

អាជ្ញាធរជាតិអប្សរា សហការជាមួយសាលាគណរាជធានីភ្នំពេញ និងគ្រឹះស្ថានសិក្សានានា រួមជាមួយ ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី បន្តដាំកូនឈើក្នុងបរិវេណរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២៤

នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២៤ ដើម្បីចូលរួមពិធី «យុទ្ធនាការដាំដើមឈើ និងស្មៅ ដើម្បីអភិរក្សរមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោក» អាជ្ញាធរជាតិអប្សរា បានសហការជាមួយព្រះសង្ឃ ថ្នាក់ដឹកនាំ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត មន្ត្រី បុគ្គលិក និងពលករ ចំនួន ៣១១អង្គ/នាក់នៃសាលាគណរាជធានីភ្នំពេញ សមាគមសម្ព័ន្ធសារព័ត៌មានឯករាជ្យ(IPA) និងគ្រឹះស្ថានសិក្សានានាដូចជា ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ពុទ្ធិកសាកលវិទ្យាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន(ព.ស.ហ.ស) សាកលវិទ្យាល័យឯកទេសនៃកម្ពុជា (CUS) វិទ្យាស្ថានខ្មែរជំនាន់ថ្មី វិទ្យាស្ថានអាស៊ីកម្ពុជា តំណាងកាកបាទក្រហមកម្ពុជា តំណាងសហភាពសហព័ន្ធយុវជនកម្ពុជានៃវិទ្យាល័យបាគង និងវិទ្យាល័យបាយ័ន បានដាំកូនឈើចម្រុះចំនួន១,០៤០ដើម និងស្មៅចំនួន ១,០០០ម៉ែត្រការ៉េ នៅបរិវេណខាងជើងច្រមុះជ្រូកតាមវិថីព្រះនរោត្តម សីហមុនី (ខាងមុខប្រាសាទអង្គរវត្ត)។

នៅថ្ងៃដដែលនោះ ឆ្លៀតឱកាសក្នុងកម្មវិធីទស្សនកិច្ចនៅខេត្តសៀមរាប ដើម្បីអបអរសាទរខួបលើកទី៣២ឆ្នាំរបស់ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី ថ្នាក់ដឹកនាំបុគ្គលិកចំនួន៥០នាក់ ក៏បានចូលរួមដាំកូនឈើ(ធ្នង់) ចំនួន៥០ដើម នៅខាងកើតដងស្ទឹងសៀមរាបនៃរមណីយដ្ឋានអង្គរ ដើម្បីលើកកម្ពស់ស្មារតីចូលរួមថែរក្សាព្រៃឈើ បន្សល់ទុកជាស្នាដៃសម្រាប់ការងារសង្គម និងទុកជាអនុស្សាវរីយ៍នៃការចងចាំក្នុងតំបន់រមណីយដ្ឋានអង្គរផង។

អាជ្ញាធរជាតិអប្សរា អបអរសាទរការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ

ផ្សាយនៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២៤

ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំនៃអាជ្ញាធរជាតិអប្សរាចូលរួមវាយគង ទូងស្គរ នៅថ្ងៃចន្ទ ១កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹងទី៥ ខែសីហា ឆ្នាំ២០២៤ នាស្ពានហាលខាងលិចប្រាសាទអង្គរវត្ត ដើម្បីអបអរសាទរការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ។

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូនសាធារណជនទាំងអស់ ជ្រាបអំពីការផ្សព្វផ្សាយ និងការពិភាក្សានៅតាមបណ្តាញសង្គមមួយចំនួន ពាក់ព័ន្ធនឹងតម្លៃសេវាថតវីដេអូ និងរូបភាពរបស់អាជ្ញាធរជាតិអប្សរា ដោយបានលើកឡើងថាមានតម្លៃថ្លៃជាដើម

ករណីនេះ អាជ្ញាធរជាតិអប្សរាសូមបញ្ជាក់ជូនសាធារណជន មេត្តាជ្រាបដូចខាងក្រោម៖

ផ្សាយនៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៖ ៦០៤/២៤ អជអ.រដ្ឋបាល

សេចក្តីប្រកាសព័ត៌មាន

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូនសាធារណជនទាំងអស់ មេត្តាជ្រាបថា៖ ថ្មីៗនេះ មានការចុះផ្សាយ ក៏ដូចជាការពិភាក្សាគ្នានៅតាមបណ្តាញសង្គមមួយចំនួនពាក់ព័ន្ធនឹងតម្លៃសេវាកម្មថតវីដេអូ និងរូបភាពរបស់អាជ្ញាធរជាតិអប្សរា ដោយបានលើកឡើងថា មានតម្លៃថ្លៃជាដើម។ ពាក់ព័ន្ធនឹងករណីនេះ អាជ្ញាធរជាតិអប្សរា សូមបញ្ជាក់ជូនសាធារណជនទាំងអស់ មេត្តាជ្រាបដូចខាងក្រោម៖

១- តម្លៃសេវាសម្រាប់ប្រភេទអាជីវកម្ម ដែលបានកំណត់ក្នុងសេចក្តីជូនដំណឹងកាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៤ គឺជាតម្លៃនៃសេវាកម្មដែលបានអនុវត្តតាំងពីអំឡុងឆ្នាំ២០១២ មកម្ល៉េះ និងពុំមានការតម្លើងតម្លៃណាមួយឡើយ។ ក្នុងនោះតម្លៃមួយចំនួនទៀតសោតក៏ត្រូវបានកែសម្រួលបន្ថយផងដែរ។

២- តម្លៃសេវាសម្រាប់ប្រភេទអាជីវកម្មនានាដែលដាក់ឱ្យអនុវត្តមានចំនួន៤ជម្រើស។ អ្នកត្រូវការប្រើប្រាស់សេវាអាចជ្រើសរើសយកជម្រើសណាមួយតាមតម្លៃសមរម្យ ដែលចង់បាន (សូមអានតារាងតម្លៃសេវាសាធារណៈផ្លូវការ ដែលមានក្នុងគេហទំព័រហ្វេសប៊ុកផេកផ្លូវការរបស់អាជ្ញាធរជាតិអប្សរា)។

៣- រាល់តម្លៃសេវាទាំងអស់ ត្រូវបង់ផ្ទាល់ទៅក្នុងធនាគារជាតិសាខាខេត្តសៀមរាប។

៤- អាជ្ញាធរជាតិអប្សរា សូមអំពាវនាវដល់សាធារណជនទាំងអស់ បញ្ឈប់ការចែករំលែកព័ត៌មានដែលផ្ទុយពីការពិត និងចូលរួមចែករំលែកនូវព័ត៌មានពិតដែលមានប្រភពច្បាស់លាស់ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ២កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
សៀមរាប ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២៤
អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្គោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576
APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

អាជ្ញាធរជាតិអប្សរា ចាប់ផ្ដើមជួសជុលរចនាសម្ព័ន្ធ បណ្ណាល័យខាងត្បូង នៅរួតទី២របស់ប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា ចាប់ផ្តើមជួសជុលរចនាសម្ពន្ធ បណ្ណាល័យខាងត្បូង នៅរួតទី២របស់ប្រាសាទអង្គរវត្ត ដែលមានភាពខូចខាតធ្ងន់ធ្ងរ។

លោក ឃាម មុនី ប្រធានក្រុមការងារជួសជុលបណ្ណាល័យខាងត្បូងនេះ បញ្ជាក់ថា បច្ចុប្បន្ន បណ្ណាល័យខាងត្បូង នៅរួតទី២របស់ប្រាសាទអង្គរវត្ត មានសភាពទ្រុឌទ្រោម ខ្លាំងដូចជា សសរថ្មនៅផ្នែកខាងត្បូង ធៀងខាងកើតបានពុក និងប្រេះបែកតាំងពីលើរហូតដល់ក្រោម។ តួយ៉ាងហោជាង និងជញ្ជាំងរបស់បណ្ណាល័យហែកចេញពីគ្នា ដំបូលមួយចំនួនត្រូវបានបាត់បង់ ធ្នឹមរងនូវសំណឹក និងសសរមានសភាពពុកផុយជាដើម៕

កូនឈើចម្រុះចំនួន១០,៩២០ដើម ត្រូវបានអាជ្ញាធរជាតិអប្សរាចែកចាយ ពីថ្ងៃទី៣០ ខែកក្កដា ដល់ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៤

- ប្រគេនកូនឈើចម្រុះជូនព្រះភិក្ខុ អប្បគញ្ញោ ម៉ាក ចន្ទ ព្រះគ្រូចៅអធិការវត្តជម្ពូធិបតីសុវណ្ណោព្រីងកោង ចំនួន១,៥០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណវត្ត ស្ថិតក្នុងឃុំបុស្សរ៍ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ កូនឈើទាំងនោះរួមមាន គ្រញូង៤០០ដើម បេង២០០ដើម ធ្នង់២០០ដើម គគីរ៣០០ដើម ឈើយាង (ឈើទាល) ៣០០ដើម ព្លុល៥០ដើម ដើងគោ៣០ដើម និង រាំងទឹក២០ដើម។

- ប្រគេនកូនឈើចម្រុះជូនព្រះអង្គ ឆោម សារិន គង់នៅវត្តសុវណ្ណារាម ចំនួន៩០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណវត្ត ស្ថិតក្នុងភូមិតាម៉ូតមានជ័យ ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។កូនឈើទាំងនោះរួមមានគគីរ៣០០ដើម ផ្ចឹក៣០០ដើម និងឈើទាល៣០០ដើម។

- ផ្តល់កូនឈើចម្រុះជូនក្រុមហ៊ុនតូតាល់ អេនើជី ម៉ាឃីធីង (ខេមបូឌា) ឯ.ក ចំនួន១,៥០០ដើម ដើម្បីប្រារព្ធ យុទ្ធនាការដាំដើមឈើ ដើម្បីពិភពលោកបៃតង។ កូនឈើទាំងនោះរួមមាន ធ្នង់៣០០ដើម បេង៣០០ដើម គ្រញូង៣០០ដើម ព្លុល៣០០ដើម និងរំដួល៣០០ដើម។

- ផ្តល់កូនឈើចម្រុះជូនតំណាងលោក នួន ពុទ្ធារ៉ា អភិបាលក្រុងសៀមរាប ចំនួន២,២០០ដើម ដើម្បីយកទៅដាំលម្អសោភណភាព ក្នុងយុទ្ធនាការដាំកូនឈើតាមដងផ្លូវក្នុងក្រុងសៀមរាប។ កូនឈើទាំងនោះរួមមាន ត្របែកព្រៃ៤០០ដើម អំពិល១០០ដើម ធ្នង់១,០០០ដើម និងរំដួល៧០០ដើម។

- ផ្តល់កូនឈើចម្រុះជូនតំណាងលោក ទី មេង ប្រធានក្រុមប្រឹក្សាឃុំឬស្សីលក ចំនួន១,២០០ដើម ដើម្បីយកទៅដាំតាមដីទំនេរក្នុងបរិវេណសាលារៀន ទីសាធារណៈ និងតាមដងផ្លូវ ក្នុងឃុំឬស្សីលក ស្រុកជីក្រែង ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន គ្រញូង២០០ដើម បេង១០០ដើម ធ្នង់១០០ដើម ប្រេស១០០ដើម លឿងរាជ១០០ដើម ជើងគោ២៥ដើម ពុល២៥ដើម ឥន្ទនេល៥០ដើម ស្តៅ១០០ដើម រំដួល១០០ដើម កកោះ១០០ដើម គគីរ១០០ដើម និងផ្ចៀក១០០ដើម។

- ផ្តល់កូនឈើចម្រុះជូនលោក ឈួន នី តំណាងសហគ្រាសខ្មែរទំនើប ចំនួន១,៥០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណដីផ្ទាល់ខ្លួន និងតាមដងផ្លូវ ស្ថិតនៅភូមិគោកធ្លក ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន គ្រញូង២០០ដើម ធ្នង់២០០ដើម បេង២០០ដើម ឈើទាល២០០ដើម កកោះ២០០ដើម រំដួល១០០ដើម ក្រៅកតូច១០០ដើម ចាមរី១០០ដើម និងលឿងរាជ២០០ដើម។

- ផ្តល់កូនឈើចម្រុះជូនអ្នកស្រី សន រ័ត្ន ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន៥០០ដើម ដើម្បីយកទៅដាំលើដីផ្ទាល់ខ្លួន ស្ថិតនៅភូមិក្បាលអូរ ឃុំព្រះស្រែ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។ កូនឈើទាំងនោះរួមមាន គ្រញូង១០០ដើម ធ្នង់១០០ដើម គគីរ១០០ដើម កកោះ១០០ដើម ឈើទាល៥០ដើម និងរំដួល៥០ដើម។

- ផ្តល់កូនឈើចម្រុះជូនលោក នេត វាសនា ប្រជាពលរដ្ឋរស់នៅខេត្តឧត្តរមានជ័យ ចំនួន១២០ដើម ដើម្បីយកទៅដាំក្នុងបរិវេណដីផ្ទាល់ខ្លួន ស្ថិតនៅភូមិស៊ីលៀម ឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។ កូនឈើទាំងនោះរួមមាន គ្រញូង៥០ដើម និងធ្នង់៧០ដើម។

- ផ្តល់កូនឈើចម្រុះជូនលោក ចាន់ រដ្ឋា ប្រជាពលរដ្ឋរស់នៅរាជធានីភ្នំពេញ ចំនួន១,៥០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណដីផ្ទាល់ខ្លួន ស្ថិតនៅភូមិយាង ឃុំឬស្សីលក ស្រុកជីក្រែង ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន ធ្នង់១,០០០ដើម បេង២៥០ដើម និងកកោះ២៥០ដើម៕

ទិដ្ឋភាពភ្ញៀវទេសចរ ទស្សនាខ្លោងទ្វារទន្លេអុំ ព្រឹកថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៤

ក្រុមការងារឆ្លាក់ងារទេសចរគោលដៅប្រាសាទតាព្រហ្ម បានជួយសម្រួលឱ្យរ៉ឺម៉ក់កង់បីចូលយកភ្ញៀវជនជាតិអេស្ប៉ាញម្នាក់ មានបញ្ហាសុខភាពពេលកំពុងទស្សនា ដើម្បីត្រលប់ទៅសម្រាក

ផ្សាយនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៤

លោកជំទាវ ប្រធានក្រុមប្រឹក្សាភិបាល នៃអាជ្ញាធរជាតិអប្សរាចូលរួមកិច្ចពិគ្រោះយោបល់ ស្តីពីការគ្រប់គ្រងតំបន់រមណីយដ្ឋានបេតិកភណ្ឌពិភពលោក អង្គរ

ផ្សាយនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៤

លោក ជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិអប្សរា ព្រមទាំង **ឯកឧត្តម ហង់ ពៅ** អគ្គនាយក និងថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរាជាច្រើនរូបទៀត បានចូលរួមក្នុងកិច្ចពិគ្រោះយោបល់ស្តីពីការគ្រប់គ្រងតំបន់រមណីយដ្ឋានបេតិកភណ្ឌពិភពលោក អង្គរ នៅថ្ងៃទី១២ និងថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤។ កិច្ចពិគ្រោះយោបល់ រៀបចំឡើងដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រោមវត្តមាន**ឯកឧត្តម សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់៕

អាជ្ញាធរជាតិអប្សរា សហការជាមួយ សភាយុវពាណិជ្ជករអន្តរជាតិកម្ពុជា ខេត្តសៀមរាប បន្តដាំកូនឈើ នៅបរិវេណខាងមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៤

កាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៤ ឆ្លៀតឱកាសក្នុងកម្មវិធី វនយាត្រា(Forest Walk) សម្រាប់កុមារចំនួន២០នាក់ ដែលរៀបចំដោយ សភាយុវពាណិជ្ជករអន្តរជាតិកម្ពុជា ខេត្តសៀមរាប (JCI Siem Reap) បានសហការជាមួយអាជ្ញាធរជាតិអប្សរា ដាំកូនឈើផ្ចង់ចំនួន៥០ដើម នៅបរិវេណខាងត្បូងឆៀងខាងលិចកសិន្ធុប្រាសាទអង្គរវត្ត ដើម្បីចូលរួមក្នុងយុទ្ធនាការដាំដើមឈើដើម្បីអភិរក្សរមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោកក៏ដូចជាផ្តល់ជូនកុមារទាំងអស់បានស្វែងយល់ពីសារៈសំខាន់នៃព្រៃឈើ និងវប្បធម៌ប្រវត្តិសាស្ត្រ សម្រាប់បន្សល់ទុកជាស្នាដៃការងារសង្គម និងជាអនុស្សាវរីយ៍នៃការចងចាំក្នុងរមណីយដ្ឋានអង្គរផងៗ

ក្រុមការងារសហគមន៍បន្តចុះពិនិត្យសំណើពលរដ្ឋ នៅក្នុងរមណីយដ្ឋានអង្គរ បានចំនួន៤0ករណី និងសម្រេចអនុញ្ញាតបានចំនួន៣៧ករណី

ផ្សាយនៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤

ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងរមណីដ្ឋានអង្គរ ត្រូវបានទទួលនូវការយកចិត្តទុកដាក់អំពីសំណាក់ អាជ្ញាធរជាតិអប្សរា ដោយមានការអនុគ្រោះក្នុងការជួសជុល តូចតាចនូវលំនៅដ្ឋានក៏ដូចជាសំណង់ឧបួសម្ព័ន្ធ មានរបង ដំបូល ជញ្ជាំង សសរពុកផុយ បង្គន់អនាម័យ រោងគោ ទ្រុងមាន់ និងទ្រុងជ្រូកជាដើម ហើយរាល់ការអនុញ្ញាត ជួសជុលមានសុពលភាពត្រឹមពីរខែ នៅលើទីតាំងកំពុង រស់នៅផ្ទាល់តែម្តងតាមរយៈការចុះពិនិត្យ និងសម្រេច ជាប្រចាំដោយក្រុមការងារសហគមន៍នាយកដ្ឋានគ្រប់គ្រង ដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិ អប្សរា។ជាក់ស្តែងក្នុងសប្តាហ៍ទី១នៃខែសីហា(គិតចាប់ពី ថ្ងៃទី២៩ ខែកក្កដា រហូតដល់ថ្ងៃទី២ ខែសីហា) ក្រុមការងារ សហគមន៍បានចុះ ពិនិត្យសំណើបានចំនួន៤០ករណី និង សម្រេចអនុញ្ញាតបានចំនួន ៣៧ករណី ទៅតាមបណ្តាល ស្រុក/ក្រុងទាំង៦ ដូចខាងក្រោម៖

- ស្រុកបន្ទាយស្រីអនុញ្ញាតបាន ៨ករណី
- ក្រុងសៀមរាបអនុញ្ញាតបាន១៧ ករណី
- ស្រុកអង្គរធំអនុញ្ញាតបាន ៨ករណី
- ស្រុកពួកអនុញ្ញាតបាន ៤ករណី

សូមជម្រាបថា រាល់ការដាក់ពាក្យស្នើសុំច្បាប់ និងការ អនុញ្ញាត គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ។ ជាមួយគ្នានេះ ក្រុមការងារសង្កេតឃើញថា ក៏មានអ្នក ដែលទទួលបានការអនុញ្ញាតហើយ ប៉ុន្តែពុំបានអនុវត្ត ត្រឹមត្រូវ ស្របនឹងការអនុញ្ញាតនោះឡើយ។

ដូច្នេះអាជ្ញាធរជាតិអប្សរា សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋ ដែលទទួលបានការអនុញ្ញាតឱ្យជួសជុលលំនៅដ្ឋានត្រូវ អនុវត្តឲ្យស្របតាមចំណុចបច្ចេកទេសដែលមានការ ទទួលដឹងលឺ ពីអាជ្ញាធរមូលដ្ឋាន និងទទួលស្គាល់ដោយ អាជ្ញាធរជាតិអប្សរា៕

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ឆ្មាំ និងពលករនៃអាជ្ញាធរជាតិអប្សរា សូមប្រកាសគាំទ្រយ៉ាងពេញទំហឹងចំពោះសារសំឡេងពិសេសរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលបានថ្លែងពន្យល់បន្ថែមអំពី «កិច្ចសហប្រតិបត្តិការតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម (CLV-DTA)» នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៤ ដែលមានខ្លឹមសារពោរពេញទៅដោយឧត្តមគតិស្នេហាជាតិមាតុភូមិពិតប្រាកដ និងទស្សនវិស័យវែងឆ្ងាយប្រកបដោយគតិបណ្ឌិត ដើម្បីការពារសុខសន្តិភាព ស្ថិរភាព និងអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមជាតិ សំដៅបំរើផលប្រយោជន៍ពលរដ្ឋគ្រប់រូប

ផ្សាយនៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ៖.........

ញត្តិគាំទ្រ

យើងខ្ញុំជាថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ឆ្មាំ និងពលករទាំងអស់ នៃអាជ្ញាធរជាតិអប្សរា សូមប្រកាសគាំទ្រយ៉ាងពេញទំហឹងចំពោះសារសំឡេងពិសេសរបស់ **សម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** ថ្លែងពន្យល់បន្ថែមអំពី "កិច្ចសហប្រតិបត្តិការតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម (CLV-DTA)" នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៤ ដែលមានខ្លឹមសារពោរពេញទៅដោយឧត្តមគតិស្នេហាជាតិមាតុភូមិពិតប្រាកដ និងទស្សនវិស័យវែងឆ្ងាយប្រកបដោយគតិបណ្ឌិត ដើម្បីការពារសុខសន្តិភាព ស្ថិរភាព និងអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមជាតិ សំដៅបំរើផលប្រយោជន៍ប្រជាពលរដ្ឋគ្រប់ៗរូប។

តាមរយៈនេះ យើងខ្ញុំទាំងអស់គ្នា សូមប្រកាសថ្កោលទោសយ៉ាងដាច់អហង្ការ និងសូមគាំទ្រនូវរាល់ការចាត់វិធានការនានា ប្រឆាំងរាល់ការផ្សព្វផ្សាយព័ត៌មានមិនពិត សកម្មភាពអុជអាល ញុះញង់ បំបែកបំបាក់សង្គមជាតិ និងនូវរាល់សកម្មភាពប៉ុនប៉ងបំផ្លិចបំផ្លាញសាមគ្គីភាព ឯកភាពជាតិ សន្តិភាព ស្ថិរភាព និងការអភិវឌ្ឍប្រទេសនៅគ្រប់វិស័យ។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នាសូមប្រកាសគាំទ្រយ៉ាងពេញទំហឹងចំពោះសារសំឡេងពិសេសពន្យល់បន្ថែមរបស់ **សម្តេចតេជោ** និងសូមអំពាវនាវដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ សូមរួបរួមគ្នាជាមហាសាមគ្គី ឯកភាពជាតិជាធ្លុងមួយ ជឿជាក់លើការដឹកនាំដ៏ត្រឹមត្រូវ និងស្វាហាប់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងការដឹកនាំប្រកបដោយគតិបណ្ឌិតវាងវៃបំផុតរបស់ **សម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** ស្ថាបនិកសន្តិភាពដ៏ឆ្នើមគ្មានពីរ ក្នុងការការពារជាតិមាតុភូមិ បន្តវឌ្ឍនភាពសេដ្ឋកិច្ច-សង្គម និងភាពសម្បូរុងរឿងសម្រាប់ជាតិយើង។

ថ្ងៃអង្គារ ៩កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
សៀមរាប ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤
អាជ្ញាធរជាតិអប្សរា

APSARA National Authority
Address: Bang Kong Village, Ampil Commune, Prasat Bakong District, Siem Reap Province
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

អាជ្ញាធរជាតិអប្សរា សហការចូលរួមជាមួយសមាគមសិល្បករខ្មែរ ក្នុងការរៀបចំកម្មវិធី «ស្នាមញញឹមនៃកម្ពុជា» ដើម្បីផ្សព្វផ្សាយវប្បធម៌ដល់ទេសចរណ៍

ផ្សាយនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរាសហការចូលរួមជាមួយសមាគមសិល្បករខ្មែរក្នុងការរៀបចំកម្មវិធី«ស្នាមញញឹមនៃកម្ពុជា» ដើម្បីផ្សព្វផ្សាយវប្បធម៌ដល់ទេសចរណ៍ និងជាទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិមកទស្សនារមណីយដ្ឋានអង្គរ និងរមណីយដ្ឋានសំខាន់ៗទូទាំងប្រទេស។ ពិធីនេះនឹងរៀបចំនៅអតីតទីស្នាក់ការអង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំរមណីយដ្ឋានអង្គរ នាថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤។

ស្នាមញញឹមនៃកម្ពុជា
THE SMILE OF CAMBODIA
• គោលបំណង ៖ ផ្សព្វផ្សាយអំពីទេសចរណ៍-វប្បធម៌
• គោលដៅ ៖ ភ្ញៀវទេសចរជាតិ-អន្តរជាតិ
• ទីតាំង ៖ រមណីយដ្ឋានអង្គរវត្ត និងតំបន់រមណីយដ្ឋានសំខាន់ៗទូទាំងប្រទេស
• សកម្មភាព ៖
១ ការផលិតមាតិកាខ្លីៗ
២ ការបង្កើតសកម្មភាពកម្សាន្តសម្រាប់ផ្តល់ឱកាសដល់ភ្ញៀវទេសចរចូលរួម
៣ ការបង្ហាញពីមុខម្ហូបខ្មែរ
៤ ការរួមចំណែកបង្កើតស្នាដៃផ្សព្វផ្សាយពីវប្បធម៌

• រៀបចំដោយ ៖
- សមាគមសិល្បករខ្មែរ
• សហការគាំទ្រដោយ ៖
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងទេសចរណ៍
- ក្រសួងកិច្ចការនារី
- រដ្ឋបាលខេត្តសៀមរាប
- អាជ្ញាធរជាតិអប្សរា
- សហព័ន្ធទេសចរណ៍កម្ពុជា
• ស្នើរការគាំទ្រ ៖
- CAMBODIA TOURISM BOARD (CTB)
- សមាគមទេសចរណ៍
- សភាពាណិជ្ជកម្មកម្ពុជា
- សមាគមសណ្ឋាគារខេត្តសៀមរាប

ស្នាមញញឹមរបស់កូនខ្មែរគ្រប់ៗរូប ជាស្នាមញញឹមដ៏ស្រស់ស្រាយ រាក់ទាក់ ទាក់ទាញ ដែលពិភពលោកទទួលស្គាល់ និងប្រសិទ្ធនាមថា«ស្នាមញញឹមខ្មែរ»

ផ្សាយនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤

នាព្រឹកថ្ងៃព្រហស្បតិ៍ ១១កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤ ព្រឹត្តិការណ៍«ស្នាមញញឹមនៃកម្ពុជា»ត្រូវបានប្រកាសបើកជាផ្លូវការ ស្ថិតនៅបរិវេណ ខាងមុខប្រាសាទអង្គរវត្តនៃខេត្តសៀមរាប។ ព្រឹត្តិការណ៍នេះ បានការអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា **លោកជំទាវ បណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា ឯកឧត្តម អគ្គនាយក អគ្គនាយករងអាជ្ញាធរជាតិអប្សរា ប្រធានសមាគមសិល្បករខ្មែរ តំណាងរដ្ឋបាលខេត្តសៀមរាប លោក លោកស្រីតំណាងអង្គភាព មន្ទីរពាក់ព័ន្ធជុំវិញខេត្ត សិល្បករ សិល្បការិនី អ្នកផលិតមាតិការម្ហូបអាហារ អាជីវករ រួមទាំងភ្ញៀវទេសចរជាតិ និងអន្តរជាតិយ៉ាងច្រើនកុះករ។

សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា មានប្រសាសន៍ថា ព្រឹត្តិការណ៍«ស្នាមញញឹមនៃកម្ពុជា»មានគោលបំណងធ្វើការផ្សព្វផ្សាយសិល្បៈវប្បធម៌ ដើម្បីទេសចរណ៍លើទឹកដីប្រវត្តិសាស្ត្រអង្គរដ៏រុងរឿង នៃព្រះរាជាណាចក្រកម្ពុជា។ សម្តេចមានប្រសាសន៍ថា ព្រឹត្តិការណ៍«ស្នាមញញឹមនៃកម្ពុជា»ជាសក្ខីភាពមួយ ដែលបង្ហាញអំពីស្នាមញញឹមនៃប្រជាពលរដ្ឋខ្មែរទៅកាន់ពិភពលោក ក៏ដូចជា សម្រស់ដ៏ស្រស់ត្រកាលនៃប្រាង្គប្រាសាទខ្មែរ ជាតំណាងនៃអរិយធម៌ដ៏រុងរឿងនៃបុព្វបុរសខ្មែរដ៏សម្បូរបែប រួមទាំងទំនាក់ទំនងដ៏ស៊ីជម្រៅជាមួយសីលធម៌សង្គម ដែលជានិមិត្តរូបនៃស្មារតីឯកភាពជាតិយូរអង្វែងបន្តពីដូនតាមក។

សម្តេចកិត្តិសង្គហបណ្ឌិត មានប្រសាសន៍បន្តថា ព្រឹត្តិការណ៍ «ស្នាមញញឹមនៃកម្ពុជា»ក៏ជាផ្នែកមួយនៃគោលនយោបាយ និងទិសដៅទស្សនាខេត្តសៀមរាបឆ្នាំ២០២៤ ដែលបានដាក់ចេញដោយ**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជំរុញវិស័យទេសចរណ៍នៅខេត្តសៀមរាបឱ្យបានងើបឡើងវិញ បន្ទាប់បានរងផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ១៩។

សូមជម្រាបថា ព្រឹត្តិការណ៍«ស្នាមញញឹមនៃកម្ពុជា»ត្រូវបានរៀបចំឡើងរយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី១២-១៦ ខែសីហា ឆ្នាំ២០២៤ ដោយសមាគមសិល្បករខ្មែរ ក្រោមកិច្ចសហការគាំទ្រពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងទេសចរណ៍ ក្រសួងកិច្ចការនារី រដ្ឋបាលខេត្តសៀមរាប អាជ្ញាធរជាតិអប្សរា និងសហព័ន្ធទេសចរណ៍។ សកម្មភាពមួយចំនួនក្នុងព្រឹត្តិការណ៍ខាងលើរួមមាន៖ កម្មវិធីកម្សាន្តការបង្ហាញពិព័រណ៍ខ្នាតតូចនៃមុខម្ហូបខ្មែរ បង្កើតនូវស្នាដៃផ្សព្វផ្សាយពីវប្បធម៌ បង្កបរិយាកាស និងកម្មវិធីផ្សេងៗមួយចំនួនទៀត ដើម្បីជាស្នាមញញឹមដល់ភ្ញៀវទេសចរដែលបានមកចូលរួម៕

អាជ្ញាធរជាតិអប្សរាសូមធ្វើការអំពាវនាវដល់អ្នកដំណើរ ភ្ញៀវទេសចរទាំងអស់ និងបងប្អូនប្រជាពលរដ្ឋ ដែលរស់នៅក្នុងរមណីយដ្ឋានអង្គរ មេត្តាកុំបោះសំរាម និងចូលរួមកាត់បន្ថយការប្រើប្រាស់រាល់សារធាតុប្លាស្ទិក ទុកដាក់សំរាម ដែលនាំឱ្យប៉ះពាល់ដល់សោភ័ណភាពបរិស្ថាន និងអនាម័យនៃរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤

កូនឈើចម្រុះចំនួន១០,៩៨៥ដើម ត្រូវបានអាជ្ញាធរជាតិអប្សរាចែកចាយ ពីថ្ងៃទី០៧ ដល់ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤

- ប្រគេនកូនឈើចម្រុះជូនព្រះអង្គ យ៉យ ឧត្តម ព្រះគ្រូចៅអធិការស្តីទី វត្តសុធម្មាជ្រលួ ចំនួន១,០០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណទីធ្លាវត្ត ស្ថិតនៅភូមិជ្រលួ ឃុំចក ស្រុកអូររាំងឪ ខេត្តកំពង់ចាម។ កូនឈើទាំងនោះរួមមាន គ្រញូង បេង ធ្នង់ ផ្ចឹកនិងកកោះ។

- ប្រគេនកូនឈើចម្រុះជូនតំណាងព្រះអង្គ តាត មហាទី ព្រះគ្រូចៅអធិការវត្តឥន្ទបត្តបុរី ហៅវត្តអង្គរខាងជើង ចំនួន៤០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណវត្តសុវណ្ណគិរីឫទ្ធិសិលា ហៅវត្តសសី ស្ថិតនៅភូមិថ្មដល់ ឃុំត្បែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន គ្រញូង ធ្នង់ បេង និងគគីរ។

- ផ្តល់កូនឈើចម្រុះជូនតំណាងឯកឧត្តម ហេង រតនា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ចំនួន៦,០០០ដើម ដើម្បីយកទៅដាំលម្អសោភណភាពក្នុងទីធ្លាវិទ្យាស្ថានបច្ចេកទេសសកម្មភាពកំចាត់មីនខេត្តកំពង់ឆ្នាំង និងនៅសារមន្ទីរតេជោសន្តិភាពខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន គ្រញូងបេង ធ្នង់ ប្រេស គគីរ ឈើទាលកកោះ៥០០ដើម និងផ្ចឹក។

- ផ្តល់កូនឈើចម្រុះជូនលោកស្រី ហេង ស៊ីថា នាយិកាវិទ្យាល័យក្រឡាញ់ ចំនួន៨០០ដើម ដើម្បីយកទៅដាំបន្ថែមក្នុងបរិវេណ និងសងខាងផ្លូវចូលសាលារៀន ស្ថិតនៅស្រុកក្រឡាញ់ ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន បេង ធ្នង់ ប្រេស កកោះ គគីរ ផ្ចឹក ពពេល ធ្លក ត្រយឹង ក្របៅ ឈើទាល ស្លង់ មៀនព្រៃ ខ្នុរព្រៃ ពុល សេដា រាំងទឹក រាំងភ្នំ វិដ្ឋូល និងឥន្ទនេល។

- ផ្តល់កូនឈើចម្រុះ ចំនួន១,៦៤៥ដើម ដើម្បីយកទៅដាំបន្ថែមក្នុងសួនរុក្ខជាតិអង្គរ និងភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន ធ្នង់ ប្រេស ត្រដក់ សារ៉ាម៉ាវព្រៃ សិរមាន់ អុញម៉ុញ ត្របៀកដំរី សុរភី ផ្កាក្ងោក សេដា ផ្កាស្រឡៅជូរ ផ្កាស្រឡៅ និងផ្កាត្របែកព្រៃ ។

- ផ្តល់កូនឈើធ្នង់ចំនួន៥០ដើម ជូនថ្នាក់ដឹកនាំ បុគ្គលិកចំនួន៥០នាក់របស់ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី យកទៅដាំនៅខាងកើតដងស្ទឹងសៀមរាបនៃមេណីយដ្ឋានអង្គរ។

- ផ្តល់កូនឈើចម្រុះជូនព្រះសង្ឃ ថ្នាក់ដឹកនាំ លោកគ្រូអ្នកគ្រូ សិស្ស និស្សិត មន្ត្រី បុគ្គលិក ចំនួន៣១១អង្គ/នាក់នៃសាលាគណរាជធានីភ្នំពេញ សមាគមសម្ព័ន្ធសារព័ត៌មានឯករាជ្យ(IPA) និងគ្រឹះស្ថានសិក្សានានា ចំនួន១,០៤០ដើម ដើម្បីយកទៅដាំនៅបរិវេណខាងជើងប្រម៉ុះជ្រូកតាមវិថីព្រះនរោត្តម សីហមុនី(ខាងមុខប្រាសាទអង្គរវត្ត) នៃរមេណីយដ្ឋានអង្គរ។ កូនឈើទាំងនោះរួមមាន ធ្នង់ ប្រេស គ្រញូង បេង ឈើទាល គគីរ កកោះ ផ្ចឹក ចំបក់ ធ្លក ស្រឡៅ ពពេល ត្រសេក តាត្រាវ សុក្រំ ខ្នុរព្រៃ មៀនព្រៃ ត្បែង ក្របៅ វិដ្ឋូល ពុល ក្ងោករលួស និងប្រាំងជំរឿង។

ថ្នាក់ដឹកនាំ អាជ្ញាធរជាតិអប្សរា ជួបសំណេះសំណាលជាមួយមន្ត្រីរាជការ

ផ្សាយនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤

នៅរសៀល ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា អគ្គនាយករង ថ្នាក់ដឹកនាំបានជួបសំណេះសំណាលជាមួយមន្ត្រីរាជការ របស់អាជ្ញាធរជាតិអប្សរា ដើម្បីពន្យល់អំពីកិច្ចសហប្រតិបត្តិការតំបន់អភិវឌ្ឍន៍ត្រីកោណ កម្ពុជា ឡាវ វៀតណាម (CLV-DTA)។

ក្នុងឱកាសនេះ ឯកឧត្តមអគ្គនាយក បានធ្វើការពន្យល់ទៅលើសេចក្តីថ្លែងការណ៍របស់អ្នកនាំពាក្យរាជរដ្ឋាភិបាល ដូចជា៖

ទី១. គ្មានការកាត់ទឹកដី ៤ខេត្ត ជូនប្រទេសវៀតណាមដូចការចោទប្រកាន់មូលបង្កាច់ពីក្រុមជ្រុលនិយមមួយចំនួនតូចនោះឡើយ។

ទី២. គ្មានការយកខេត្តទាំង៤ របស់កម្ពុជា ទៅដាក់ហ៊ុនជាមួយប្រទេសជិតខាង ដើម្បីបញ្ចូលគ្នាជាដែនដីតែមួយ ដូចការលើកឡើងដោយបំភាន់ ឬដោយការភាន់ច្រឡំមួយចំនួននោះឡើយ។

ទី៣. គ្មានការដាក់ហ៊ុនធនធានធម្មជាតិ ដូចជាធនធានរ៉ែ និងធនធានព្រៃឈើជាដើម របស់ខេត្តទាំង៤ ដើម្បីវិនិយោគរួមគ្នាដូចការលើកឡើងនោះឡើយ។

ទី៤. គ្មានការអនុញ្ញាតឱ្យប្រជាពលរដ្ឋប្រទេសនីមួយៗ ចេញចូលដោយសេរី ក្នុងទឹកដីតំបន់អភិវឌ្ឍន៍ ត្រីកោណនោះឡើយ។

ពោលគឺ ប្រទេសនីមួយៗនៅតែគ្រប់គ្រង និងរក្សាឯករាជ្យភាព អធិបតេយ្យភាពជាតិ និងបូរណភាពទឹកដីរបស់ខ្លួនស្របតាមច្បាប់ជាធរមាន ដោយគ្មានការបង្កើតដែនដីថ្មីរួមគ្នាណាមួយដូចការលើកឡើងនោះឡើយ។

ជាមួយគ្នានោះដែរ ថ្នាក់ដឹកនាំ មន្ត្រីរាជការទាំងអស់នៃអាជ្ញាធរជាតិអប្សរា បានសម្តែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅចំពោះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា ដែលបានផ្តួចផ្តើមគំនិតអំពីគម្រោងកិច្ចសហប្រតិបត្តិការតំបន់អភិវឌ្ឍន៍ត្រីកោណ កម្ពុជា ឡាវ វៀតណាម (CLV-DTA) និងប្តេជ្ញាចូលរួមគាំទ្រពេញទំហឹង ព្រមទាំងសម្តែងការគោរពចំពោះឆន្ទះដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមានសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ជាប្រមុខ ជាពិសេសគាំទ្រនិងប្តេជ្ញាអនុវត្តនូវយុទ្ធសាស្ត្របញ្ចកោណដើម្បីសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ ក្លាយជាប្រទេសមានចំណូលខ្ពស់៕

គណៈប្រតិភូបណ្ដាប្រទេសអាស៊ីប៉ាស៊ីហ្វិក រួមគ្នាដាំដើមឈើនៅមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៤នេះ អាជ្ញាធរជាតិអប្សរា បានរៀបចំទីតាំងសម្រាប់ដាំកូនឈើ ជូនគណៈប្រតិភូបណ្ដាប្រទេសអាស៊ីប៉ាស៊ីហ្វិក ដែលបានអញ្ជើញចូលរួមកិច្ចប្រជុំសហភាពប្រៃសណីយ៍អាស៊ីប៉ាស៊ីហ្វិក នៅខេត្តសៀមរាប ចាប់ពីថ្ងៃទី១២ ដល់១៧ ខែសីហា ឆ្នាំ២០២៤មក។

លោក ជូ រ៉ាឌីណា អនុប្រធាននាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ នៃអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា អាជ្ញាធរជាតិអប្សរា បានរៀបចំទីតាំងនៅបរិវេណខាងត្បូងកសិន្ធុ នៃប្រាសាទអង្គរវត្ត ដើម្បីទុកជាអនុស្សាវរីយ៍ បន្ទាប់ពីបានចូលរួមកិច្ចប្រជុំខាងលើ និងបន្តទស្សនាប្រាសាទអង្គរវត្ត ដែលជាដួងព្រលឹងរបស់កម្ពុជា។ ដើមឈើដែលបានដាំមានចំនួន៤២ដើម ក្នុងនោះមួយដើម គឺជាដើមផ្កាថ្កុល តំណាងឱ្យកិច្ចប្រជុំសហភាពប្រៃសណីយ៍អាស៊ីប៉ាស៊ីហ្វិក។

អាជ្ញាធរជាតិអប្សរា មានសេចក្ដីសោមនស្សជាពន់ពេក ចំពោះវត្តមានគណៈប្រតិភូបណ្ដាប្រទេសអាស៊ីប៉ាស៊ីហ្វិក ក៏ដូចជាស្ថាប័នពាក់ព័ន្ធ អង្គការសង្គមស៊ីវិល បងប្អូនប្រជាពលរដ្ឋ ដែលបានចូលរួមចំណែកជាមួយអាជ្ញាធរជាតិអប្សរា ដើម្បីកិច្ចការងារអភិរក្សរមណីយដ្ឋានអង្គរឱ្យមានទេសភាពបៃតងស្អាតគ្រប់រដូវកាល៕

អ្នកជំនាញអាជ្ញាធរជាតិអប្សរា កំពុងរៀបចំជួសជុលរចនាសម្ព័ន្ធ ប្រព័ន្ធចង្អូរបង្ហូរទឹក ចម្លាក់ក្បាលមករ

ផ្សាយនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤

ប្រព័ន្ធបង្ហូរទឹកបុរាណ ដែលមានចម្លាក់រូបក្បាលមករ នៅទំនប់(ទឹកមុជ)ដែលជាទំនប់ទឹកបុរាណ ស្ថិតនៅជ្រុងនិរតីចម្ងាយប្រមាណ៣គីឡូម៉ែត្រពីប្រាសាទបេងមាលា ក្នុងភូមិទឹកលិច ឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប កំពុងរងការខូចខាតយ៉ាងខ្លាំង។

ក្រុមជំនាញរបស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា កំពុងរៀបចំចាប់ផ្តើមជួសជុលប្រព័ន្ធបង្ហូរទឹកនេះ ដើម្បីឱ្យមានភាពប្រសើរឡើងវិញ។

បុព្វបុរសខ្មែរសម័យមុន បានធ្វើចង្អូរបង្ហូរទឹកចម្លាក់មករនេះ សម្រាប់ប្រមូលទឹកពីតំបន់ភ្នំគូលែនបញ្ចេញមកក្រោមតាមទ រួចហើយឱ្យហូរចេញតាមមាត់សត្វមករធ្លាក់ចូលទៅក្នុងអូរថ្មដាប់ បន្តទៅបំពេញនៅកសិន្ធុប្រាសាទបេងមាលា និងបន្តហូរចាក់ចូលទៅអាងរក្សាទឹកធំមួយ នៅភាគខាងកើតរបស់ប្រាសាទបេងមាលា ដែលគេហៅថាវាលផ្ទី៕

សកម្មភាព ក្រុមការងារពិនិត្យ និងតាមដានការសាងសង់ ក្រោយទទួលបានការអនុញ្ញាត ក្នុងសប្តាហ៍ទី២ នៃខែសីហា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៤

ប្រជាពលរដ្ឋដែលរស់នៅក្នុងឧទ្យានអង្គរពីយូរមកហើយត្រូវបានទទួលការអនុញ្ញាតសាងសង់សំណង់នានាស្របតាមគោលការណ៍ច្បាប់ និងការងារជួសជុលតូចតាច (ដោយក្រុមការងារសហគមន៍)។ រាល់សំណង់នានា ដែលនៅមានសុពលភាព ត្រូវបាននាយកដ្ឋានគ្រប់ គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា បានចុះទៅពិនិត្យ និងផ្តល់នូវលក្ខណៈបច្ចេកទេស ដោយពុំគិតប្រាក់កម្រៃជាប្រចាំ រហូតសំណង់ទាំង នោះសង់រួចរាល់មួយរយភាគរយ។

ជាក់ស្តែងក្នុងសប្តាហ៍ទី២ នៃខែសីហា ឆ្នាំ២០២៤ នេះ មន្ត្រី-បុគ្គលិកជំនាញ បានចុះពិនិត្យ និងផ្តល់លក្ខណៈបច្ចេកទេសនូវសំណង់ដែលបានការអនុញ្ញាត កន្លងមក ចំនួន ៥៩ករណី និងការជួសជុលតូចតាចដោយក្រុមការងារសហគមន៍ ចំនួន ១២១ករណី ដែលស្ថិតក្នុងភូមិសាស្ត្រ ដូចខាងក្រោម៖

១. ក្រុងសៀមរាបចំនួន ៦១ករណី
២. ស្រុកប្រាសាទបាគង ១៤ករណី
៣. ស្រុកបន្ទាយស្រីចំនួន ៥២ករណី
៤. ស្រុកពួកចំនួន ២៨ករណី
៥. ស្រុកអង្គរធំចំនួន ២៥ករណី

សូមបញ្ជាក់ជូនផងដែរថា សំណង់ដែលទទួលបានការអនុញ្ញាតចំនួន ១៨០ករណី នេះមាន ១៤១ករណី កំពុងតែសាងសង់ជួសជុលត្រឹមត្រូវតាមការអនុញ្ញាត និងមាន ៣៩ករណី មិនទាន់សាងសង់។

ក្នុងចំណោមសំណង់ទាំង ១៤១ករណី ដែលកំពុងតែសាងសង់ និងជួសជុលត្រឹមត្រូវ មានសំណង់ដែលបាន សង់រួចរាល់ជាស្ថាពរចំនួន ៣៩ករណី និងសំណង់ដែលសង់ពុំទាន់រួចរាល់ តែហួសសុពលភាពមានចំនួន ១៤ករណី។

ក្រុមការងារបច្ចេកទេសនិងបន្តតាមដានការសាងសង់និងជួសជុលរហូតដល់ការអនុញ្ញាតផុតសុពលភាពនិងការសាងសង់រួចរាល់មួយរយភាគរយ៕



អាជ្ញាធរជាតិអប្សរា ជួសជុលពង្រឹងតួប៉មឥដ្ឋ G15 នៃប្រាសាទភ្នំបាខែង

ផ្សាយនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៤

លោកស្រី ឈុន រតនា មន្ត្រីនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា ឱ្យដឹងថា បច្ចុប្បន្ននេះ ប៉មឥដ្ឋ G15 នៃប្រាសាទភ្នំបាខែង ទ្រុឌទ្រោម ដោយសារអាយុកាលនៃសំណង់ កង្វះការថែទាំយូរអង្វែង ព្រមទាំងធម្មជាតិផង ធ្វើឱ្យប្រាសាទឥដ្ឋនេះ រងការខូចខាតទាំងស្រុង ចាប់តាំងពីក្បាំងជញ្ជាំងឡើងលើ។ ក្រៅពីនេះ ចំណុចហានិភ័យនៃប៉មឥដ្ឋ G15 មានដូចជា ខូចខាតខឿន និងរលុះប្រេះហែករចនាសម្ពន្ធនៃជញ្ជាំងជ្រាបទឹកចូលនៅក្នុងរដូវវស្សា។

លោក ស្រី ឈុន រតនា បញ្ជាក់ថា ដើម្បីថែរក្សាស្ថិរភាពប្រាសាទនេះឱ្យមានលំនឹងបន្តទៀត អ្នកជំនាញនៃអាជ្ញាធរជាតិអប្សរា កំពុងដំណើរការជួសជុលពង្រឹងជញ្ជាំងឥដ្ឋផ្នែកខាងក្នុង ព្រមទាំងជួសជុលពង្រឹងជញ្ជាំងឥដ្ឋផ្នែកខាងក្រៅនាទិសខាងកើត ទិសខាងលិច ទិសខាងជើង និងទិសខាងត្បូងឡើងវិញ។ ជួសជុលពង្រឹងខឿន សសរផ្តោប និងសសរពេជ្រ បិទភ្ជិតស្នាមប្រេះការពារជម្រាបទឹក គឺដើម្បីឱ្យតួប៉ម G15 នៃប្រាសាទភ្នំបាខែងរឹងមាំឡើងវិញនៅគង់វង្សយូរអង្វែងបន្តទៀត៕

ចម្លាក់បដិមាទ្វារបាលចំនួន១ រកឃើញនៅខ្លោងទ្វារខាងកើត ប្រាសាទបន្ទាយប្រី

ផ្សាយនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤

ចម្លាក់បដិមាទ្វារបាល(យក្ស)ចំនួន១ ធ្វើពីថ្មភក់ ត្រូវបានប្រទះឃើញនៅទិសខាងកើតរបស់ខ្លោងទ្វារទី២ នៃប្រាសាទបន្ទាយប្រី ខណៈពេលដែលក្រុមការងារនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា រៀបចំគំនរថ្មរាយប៉ាយ និងសម្អាតកំណកដី។

បុរាណវិទូ លោក ជា សារិទ្ធ បានឱ្យដឹងថា បដិមាទ្វារបាល ដែលប្រទះឃើញនេះ គឺស្ថិតនៅខាងស្តាំដៃរបស់ផ្លូវចូលទិសខាងកើតខ្លោងទ្វារទី២ នៃប្រាសាទបន្ទាយប្រី កប់ក្រោមគំនរថ្ម និងកំណកដីប្រមាណជា៨តឹក។ តាមការសន្និដ្ឋានរបស់លោក សារិទ្ធ ការដួលរលំនេះ អាចបណ្តាលមកពីការដួលរលំរបស់រចនាសម្ពន្ធខាងលើនៃខ្លោងទ្វារនេះ។ ទោះបីយ៉ាងណាក៏បដិមានេះ នៅតែរក្សាបាននូវរូបរាងល្អស្ទើរតែពេញលេញ។

លោក ជា សារិទ្ធ បញ្ជាក់ថា ស្ថានភាពនៃបដិមាទ្វារបាលនេះ ដួលដេកក្បាលទៅទិសខាងលិច ហើយដងខ្លួននៃបដិមានេះបាក់ជា៦បំណែក ដែលបាក់នៅត្រង់ក ដើមដៃផ្នែកខាងឆ្វេង ចង្កេះ និងក្រោមជង្គង់នៃជើងទាំង២ និងផ្នែកដែលបាត់បង់ គឺដំបង។ ចម្លាក់បដិមាទ្វារបាលនេះ គឺស្ថិតក្នុងរចនាប័ទ្មបាយ័ន មានកម្ពស់ប្រមាណ១,៦០ម៉ែត្រ៕

ក្រុមការងារសហគមន៍ បន្តចុះពិនិត្យសំណើពលរដ្ឋ នៅក្នុងរមណីយដ្ឋានអង្គរ បានចំនួន៤២ករណី និងសម្រេចអនុញ្ញាត បានចំនួន៣២ករណី

ផ្សាយនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៤

ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងរមណីយដ្ឋានអង្គរ ត្រូវបានទទួលនូវការយកចិត្តទុកដាក់អំពីសំណាក់អាជ្ញាធរជាតិអប្សរា ដោយមានការអនុគ្រោះក្នុងការជួសជុលតូចតាចនូវលំនៅដ្ឋានក៏ដូចជាសំណង់ឧបសម្ព័ន្ធមាន របង ជំបូល ជញ្ជាំង សសរពុកផុយ បង្គន់អនាម័យ រោងគោ ទ្រុងមាន់ និងទ្រុងជ្រូកជាដើម ហើយរាល់ការអនុញ្ញាតជួសជុលមានសុពលភាពត្រឹមពីរខែ នៅលើទីតាំងកំពុងរស់នៅផ្ទាល់តែម្ដងតាមរយៈការចុះពិនិត្យ និងសម្រេចជាប្រចាំដោយក្រុមការងារសហគមន៍ នាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍នៃអាជ្ញាធរជាតិអប្សរា។ជាក់ស្ដែងក្នុងសប្ដាហ៍ទី២នៃខែសីហា (ចាប់ពីថ្ងៃទី៦ រហូតដល់ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៤) ក្រុមការងារសហគមន៍បានចុះ ពិនិត្យសំណើបានចំនួន៤២ករណី និងសម្រេចអនុញ្ញាតបានចំនួន ៣២ករណី ទៅតាមបណ្ដាលស្រុក/ក្រុងទាំង៦ ដូចខាងក្រោម៖

- ស្រុកបន្ទាយស្រីអនុញ្ញាតបាន ១២ករណី
- ក្រុងរុនតាឯក អនុញ្ញាតបាន១ករណី
- ស្រុកប្រាសាទបាគងអនុញ្ញាតបាន ២ករណី
- ក្រុងសៀមរាបអនុញ្ញាតបាន ១៥ករណី
- ស្រុកអង្គរធំអនុញ្ញាតបាន ២ករណី

សូមជម្រាបថា រាល់ការដាក់ពាក្យស្នើសុំច្បាប់ និងការអនុញ្ញាត គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ។ ជាមួយគ្នានេះ ក្រុមការងារសង្កេតឃើញថា ក៏មានអ្នកដែលទទួលបានការអនុញ្ញាតហើយ ប៉ុន្តែពុំបានអនុវត្តត្រឹមត្រូវ ស្របនឹងការអនុញ្ញាតនោះឡើយ។

ដូច្នេះអាជ្ញាធរជាតិអប្សរា សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតឱ្យជួសជុលលំនៅដ្ឋានត្រូវអនុវត្តឲ្យស្របតាមចំណុចបច្ចេកទេសដែលមានការទទួលដឹងលឺ ពីអាជ្ញាធរមូលដ្ឋាន និងទទួលស្គាល់ដោយអាជ្ញាធរជាតិអប្សរា៕

អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជម្រាបជូនសាធារណជន ភ្ញៀវជាតិនិងអន្តរជាតិ ព្រមទាំងប្រតិបត្តិករក្នុងវិស័យទេសចរណ៍ទាំងអស់មេត្តាជ្រាបថា ក្នុងគោលដៅសម្រួលដល់ការទស្សនារបស់ភ្ញៀវជាតិ និងអន្តរជាតិឱ្យទទួលបានបទពិសោធន៍ទស្សនាមួយកម្រិតថែមទៀត ព្រមទាំងរក្សាបានទាំងសុវត្ថិភាពប្រាសាទ និងភ្ញៀវទេសចរផងនោះ អាជ្ញាធរជាតិអប្សរាសូមកែសម្រួលនូវគោលការណ៍ដូចខាងក្រោម៖

ផ្សាយនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ: ៦៣៧/២៤ អប.សជណ

សេចក្តីជូនដំណឹង
ស្តីពី
ការកែសម្រួលពេលវេលាបើក-បិទនៃការចូលទស្សនាប្រាសាទក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីសម្រួលដល់ការទស្សនារបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិឱ្យទទួលបាននូវបទពិសោធន៍ទស្សនាមួយកម្រិតថែមទៀត ព្រមទាំងរក្សាបានទាំងសុវត្ថិភាពប្រាសាទ និងភ្ញៀវទេសចរផងនោះ អាជ្ញាធរជាតិអប្សរាសូមកែសម្រួលនូវគោលការណ៍ដូចខាងក្រោម៖

១- ប្រាសាទដែលភ្ញៀវទេសចរនិយមទស្សនាថ្ងៃរះ
ប្រាសាទអង្គរវត្ត បើកម៉ោង ០៥៖០០នាទីព្រឹក និងបិទម៉ោង ១៨៖០០នាទីល្ងាច។ ក្រោយម៉ោង ១៨៖០០នាទី ភ្ញៀវទេសចរនឹងពុំអនុញ្ញាតឱ្យចូលក្នុងបរិវេណប្រាសាទទៀតឡើយ ប៉ុន្តែភ្ញៀវទេសចរដែលកំពុងទស្សនាក្នុងប្រាសាទអាចបន្តការទស្សនារហូតដល់ម៉ោង ១៨៖៣០នាទីល្ងាច។

២- ប្រាសាទដែលភ្ញៀវទេសចរនិយមទស្សនាថ្ងៃលិច
ប្រាសាទប្រែរូប ប្រាសាទភ្នំបាខែង និងប្រាសាទភ្នំក្រោម បើកម៉ោង ០៦៖០០នាទីព្រឹក និងបិទម៉ោង ១៩៖០០នាទីល្ងាច។ ក្រោយម៉ោង ១៩៖០០នាទី ភ្ញៀវទេសចរនឹងពុំអនុញ្ញាតឱ្យចូលក្នុងបរិវេណប្រាសាទទៀតឡើយ ប៉ុន្តែភ្ញៀវទេសចរដែលកំពុងទស្សនាក្នុងប្រាសាទអាចបន្តការទស្សនារហូតដល់ម៉ោង ១៩៖៣០នាទីល្ងាច។

៣- ប្រាសាទដទៃៗទៀត
បើកម៉ោង ០៦៖០០នាទីព្រឹក និងបិទម៉ោង ១៨៖៣០នាទីល្ងាច។ ក្រោយម៉ោង ១៨៖៣០នាទី ភ្ញៀវទេសចរនឹងពុំអនុញ្ញាតឱ្យចូលក្នុងបរិវេណប្រាសាទទៀតឡើយ ប៉ុន្តែភ្ញៀវទេសចរដែលកំពុងទស្សនាក្នុងប្រាសាទអាចបន្តការទស្សនារហូតដល់ម៉ោង ១៩៖០០នាទីល្ងាច។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន និងមេត្តាចូលរួមអនុវត្តជាមួយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃសុក្រ ៤រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
សៀមរាប ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៤
អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្កោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពារតំបន់ និងរៀបចំដែនអង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

កិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យសូហ្វីយ៉ា ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស សម្រាប់និស្សិតមហាវិទ្យា បុរាណវិទ្យា

ផ្សាយនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៤

មនុស្សផ្នែកកំណាយស្រាវជ្រាវបុរាណវិទ្យា ដើម្បីចែករំលែកចំណេះដឹង និងជាការបន្តវេនដល់មនុស្សជំនាន់ក្រោយ។

ក្នុងកិច្ចសហប្រតិបត្តិការបណ្តុះបណ្តាលធនធានមនុស្សផ្នែកកំណាយស្រាវជ្រាវនេះ គឺអាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យសូហ្វីយ៉ា បានធ្វើកំណាយស្រាវជ្រាវរួមគ្នានៅខាងក្នុងកំពែងរបស់ប្រាសាទបន្ទាយក្តី លើទួលបុរាណ សិក្សាអំពីរចនាសម្ពន្ធរបស់ទួល និងទំនាក់ទំនងជាមួយកំពែងប្រាសាទ។ កំណាយស្រាវជ្រាវបុរាណវិទ្យានេះ ចាប់ផ្តើមនៅខែសីហា ឆ្នាំ២០២៤។

និស្សិតមហាវិទ្យាល័យបុរាណវិទ្យា ឆ្នាំទី៣នៃសាកលវិទ្យាល័យភូមិន្ទ វិចិត្រសិល្បៈ កញ្ញា កែវ ឈន់លីលី ដែលបានចូលរួមធ្វើកំណាយ បានឱ្យដឹងថា នេះជាឆ្នាំទី២ហើយ ដែលមានឱកាសចូលរួមធ្វើកំណាយស្រាវជ្រាវនៅតំបន់អង្គរ។ និស្សិតដដែលបញ្ជាក់ថា ការចូលរួមធ្វើកំណាយស្រាវជ្រាវ គឺពិតជាមានសារសំខាន់ណាស់បានផ្តល់នូវចំណេះដឹង និងបទពិសោធន៍ជាច្រើនបន្ថែមពីលើការសិក្សាទ្រឹស្តីនៅក្នុងសាលា។

ចំណែកនិស្សិតបុរាណវិទ្យាឆ្នាំទី២ មួយរូបទៀត លោក ឡាំ យសោធរ ឱ្យដឹងថា នេះជាលើកដំបូងសម្រាប់រូបគាត់ដែលបានចុះអនុវត្តមកធ្វើកំណាយស្រាវជ្រាវនៅតំបន់អង្គរ។ និស្សិតរូបនេះ បញ្ជាក់ថា ការចុះមកអនុវត្តផ្ទាល់នៅការដ្ឋានកំណាយបានធ្វើឱ្យរូបលោក បានយល់ដឹងពីរបៀបបែងចែករណ្តៅកំណាយ ការដៅចំណុចរណ្តៅនីមួយៗ របៀបកំណាយ ការកត់ត្រា ការបែកចែកស្រទាប់ដី និងរៀបចំឯកសារជាដើម។ បង្កើនការយល់ដឹងផ្នែកស្រាវជ្រាវបុរាណវិទ្យា ទទួលបាននូវបទពិសោធន៍ ចំណេះដឹងថ្មីៗក្នុងការពង្រឹងសមត្ថភាពលើការសិក្សា និងទៅថ្ងៃអនាគត៕

អាជ្ញាធរជាតិអប្សរារៀបចំកម្រាលផ្លូវដើរ សម្រាប់ភ្ញៀវទេសចរដើរទស្សនា និងថតរូបនៅស្រះទឹក ខាងមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៤

ក្រុមការងារត្រួតពិនិត្យសេវាកម្មទេសចរណ៍ នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ នៃអាជ្ញាធរជាតិអប្សរា កំពុងដំណើរការរៀបចំធ្វើកម្រាលផ្លូវដើរ សម្រាប់ភ្ញៀវទេសចរដើរទស្សនា និងថតរូបនៅស្រះទឹកខាងមុខប្រាសាទអង្គរវត្ត។ គោលដៅចម្បង នៃការរៀបចំកម្រាលខាងលើ ដើម្បីសម្រួលដល់ទេសចរធ្វើដំណើរមកថតរូបនៅបរិវេណស្រះទឹកនៃប្រាសាទអង្គរកាន់ងាយស្រួល រក្សាបាននូវសោភណ្ឌភាព ជាពិសេសរដូវវស្សាមានភ្លៀងធ្លាក់ញឹកញាប់ ការពារកំណាកដីឬភក់ប្រឡាក់ជាប់ស្បែកជើងនាំទៅដល់ស្ពានហាល និងកាត់បន្ថយភាពសឹករិចរឹលរបស់ថ្មជាដើម។

លោក នូ វុទ្ធី ក្រុមការងារត្រួតពិនិត្យសេវាកម្មទេសចរណ៍ នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ នៃអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ថា នេះជាដំណាក់កាលទី៤ហើយ ដែលអាជ្ញាធរជាតិអប្សរា បានរៀបចំកម្រាលផ្លូវដើរ សម្រួលដល់ទេសចរធ្វើដំណើរចូលមកទស្សនាប្រាសាទអង្គរវត្ត។ កម្រាលផ្លូវដើរនេះ ពេលរៀបចំរួចរាល់ ធ្វើឱ្យភ្ញៀវងាយស្រួលដើរទស្សនាប្រាសាទ កាត់បន្ថយការនាំយកកំណាកដីជាប់ជាមួយស្បែកជើងឡើងទៅខាងលើនៃស្ពានហាលនិងប្រាសាទ។ ម្យ៉ាងទៀតក៏ដើម្បីគ្រប់គ្រងលំហូររបស់ភ្ញៀវទេសចរឱ្យសមរម្យ ចៀសវាងភ្ញៀវដើរនៅលើស្មៅ និងលើដី រក្សាបានរបៀបរៀបរយ និងរួមចំណែកលើកកម្ពស់សោភណ្ឌភាពប្រាសាទអង្គរវត្ត ឱ្យមានភាពបៃតងគ្រប់រដូវកាល៕

សិស្សថ្នាក់ទី១១នៃវិទ្យាល័យនគរធំ ចុះទស្សនកិច្ចសិក្សានៅការដ្ឋានកំណាយស្រាវជ្រាវនៅប្រាសាទបន្ទាយក្ដី

ផ្សាយនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៤

ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៤ អាជ្ញាធរជាតិអប្សរា ដែលសហការជាមួយសាកលវិទ្យាល័យសូហ្វីយ៉ានៃប្រទេសជប៉ុន បានដឹកនាំសិស្សានុសិស្សថ្នាក់ទី១១ មកពីវិទ្យាល័យនគរធំ ចំនួន៤៥នាក់ ចុះធ្វើទស្សនកិច្ចសិក្សានៅស្ពានហាលប្រាសាទអង្គរវត្ត និងការដ្ឋានកំណាយស្រាវជ្រាវនៅខាងក្នុងកំពែងរបស់ប្រាសាទបន្ទាយក្ដី ក្នុងគោលបំណងឱ្យពួកគេដែលរស់នៅជិតប្រាសាទ និងជាអ្នកបន្តវេនផងសិក្សាស្វែងយល់ពីកិច្ចការជួសជុលអភិរក្ស ប្រវត្តិសិល្បៈសំណង់ស្ថាបត្យកម្មនិងកំណាយស្រាវជ្រាវបុរាណវិទ្យាថ្មីៗ ព្រមទាំងយល់ដឹងពីតម្លៃមរតកដូនតា តម្លៃបេតិកភណ្ឌ បណ្ដុះគំនិតស្រឡាញ់ គោរព និងចូលរួមថែរក្សាការពារតទៅអនាគត៕

ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៤ ក្រុមឆ្មាំការសណ្តាប់ធ្នាប់ប្រចាំគោលដៅក្រុងអង្គរធំ និងបារាយណ៍ទឹកថ្លា បានសហការជាមួយឆ្មាំការទេសចរនគរបាលបេតិកភណ្ឌ និងនគរបាលទេសចរណ៍ប្រចាំតំបន់អង្គរ ជួយសង្គ្រោះបឋមករណីភ្ញៀវជនជាតិហូឡង់ម្នាក់ បានរអិលដួល នៅត្រង់ចំណុចរូចទី១ផ្នែកខាងជើងនៃប្រាសាទបាយ័ន

បន្ទាប់ពីបានធូរស្រាល ក្រុមការងារបានទាក់ទង Pass App របស់គាត់ ឱ្យមកយកគាត់ទៅសម្រាកជាបន្តទៀត

ផ្សាយនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរាបញ្ចប់ការងារជួសជុល ពង្រឹងខឿនជណ្តើរ និងបង្កាន់ដៃនាគ ផ្នែកខាងលិចនៃជណ្តើរកណ្តាល ខាងត្បូងប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៤

នៅក្នុងខែសីហា នេះ អាជ្ញាធរជាតិអប្សរា បានបញ្ចប់ការងារជួសជុលការពង្រឹងខឿនជណ្តើរ និងបង្កាន់ដៃនាគ ផ្នែកខាងលិចនៃជណ្តើរកណ្តាល ខាងត្បូងប្រាសាទអង្គរវត្តហើយ បន្ទាប់ពីចាប់ផ្តើមជួសជុលពីខែ ឧសភា មក។

លោក សយ សុភារិទ្ធ បានរំឭកថា ចំពោះទីតាំងនេះ មុនពេលជួសជុល គឺខឿនជណ្តើរនាគស្រុត ថ្មហែកញែកចេញពីគ្នា ធ្វើឱ្យនាគមានជំហមិននឹងជាដើម។ ដំណាក់កាលដំបូង ក្រុមការងារអាជ្ញាធរជាតិអប្សរា បានជួសជុលពង្រឹងខឿនឡើងវិញ បន្ទាប់មកបានជួសជុលនាគឱ្យមានជំហ និងលំនឹងដូចដើមវិញ។

តាមការបញ្ជាក់ពីលោក សយ សុភារិទ្ធ ការងារខាងលើនេះបានចាប់ផ្តើមពីថ្ងៃទី១៥ ខែឧសភា និងបញ្ចប់ទាំងស្រុងនៅថ្ងៃទី១៥ ខែសីហា គឺប្រើពេល៣ខែ។ បុរាណវិទូរូបនេះរំពឹងថា ទីតាំងនេះនឹងមានភាពរឹងមាំ និងសម្រួលដល់ការទស្សនារបស់ភ្ញៀវទេសចរតទៅអនាគត ដោយមិនបារម្ភពីហានិភ័យនៃការដួលរលំចម្លាក់នាគបន្តទៀតទេ ព្រោះការជួសជុលអ្នកជំនាញបាន ប្រើបច្ចេកទេសត្រឹមត្រូវ បិទពង្រឹងដងខ្លួននាគ ក៏ដូចជាជើងទម្រឱ្យរឹងមាំដូចសភាពដើមវិញហើយ។ ក្រៅពីទីតាំងខាងលើនេះ អាជ្ញាធរជាតិអប្សរា កំពុងសិក្សានៅតាមចំណុចផ្សេងៗទៀតដើម្បីលើកគម្រោង ជួសជុលទៅអនាគត សំដៅធ្វើយ៉ាងណាអភិរក្ស ជួសជុលបុរាណវត្ថុនានាឱ្យល្អប្រសើរឡើងវិញ៕

ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ជួបពិភាក្សាការងារ ជាមួយគណៈប្រតិភូខេត្ត Central Java នៃសាធារណរដ្ឋឥណ្ឌូនេស៊ី

ផ្សាយនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៤នេះ **ឯកឧត្តម ឡុង កុសល** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានជួបពិភាក្សាការងារជាមួយគណៈប្រតិភូខេត្ត Central Java នៃសាធារណរដ្ឋឥណ្ឌូនេស៊ី ដែលដឹកនាំដោយ លោក ស្រី Muhammad Isnaeni ប្រធានក្រុមគណៈប្រតិភូ នៃខេត្តCentral Java នៃសាធារណរដ្ឋឥណ្ឌូនេស៊ី។ក្នុងជំនួបពិភាក្សាបានផ្តោតសំខាន់ អំពីការបន្តកិច្ចសហប្រតិបត្តិការ ការងារអភិរក្ស និងថែរក្សាមេណីយដ្ឋានអង្គរ នៃព្រះរាជាណាចក្រកម្ពុជា និងប្រាសាទបូរ៉ូប៊ូឌួ(Borobudur)នៃសាធារណរដ្ឋឥណ្ឌូនេស៊ី៕

កូនឈើចម្រុះចំនួន៤,១៧២ដើមបន្ថែមទៀត ត្រូវបានអាជ្ញាធរជាតិអប្សរាចែកចាយ ពីថ្ងៃទី១៤ ដល់ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៤

- ផ្តល់កូនឈើចម្រុះជូនលោក អ៊ឹម យើន នាយកសាលាបឋមសិក្សាក្លាំងហាយ ចំនួន៦១០ដើម ដើម្បីយកទៅដាំបន្ថែមក្នុងបរិវេណ និងសងខាងផ្លូវចូលសាលារៀន ស្ថិតនៅភូមិក្លាំងហាយ ស្រុកស្រីស្នំ ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន បេង១០០ដើម ធ្នង់១០០ដើម ប្រេស១០០ដើម កកោះ១០០ដើម រំដួល៥០ដើម ក្រាក៥០ដើម ពុល១០ដើម ជើងគោ៥០ដើម និងស្តៅ៥០ដើម។
- ផ្តល់កូនឈើចម្រុះជូនតំណាងលោក ស៊ុំ សំអន នាយកសាខាកាកបាទក្រហមខេត្តសៀមរាប ចំនួន១០០ដើម ដើម្បីយកទៅដាំលម្អសោភ័ណភាពក្នុងទីធ្លាសាខាកាកបាទក្រហម។ កូនឈើទាំងនោះរួមមាន ធ្នង់៥០ដើម និងរំដួល៥០ដើម។
- ផ្តល់កូនឈើចម្រុះជូនលោក ងួន វុទ្ធី ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន៤០០ដើម ដើម្បីយកទៅដាំលើដីផ្ទាល់ខ្លួន ស្ថិតនៅភូមិទឹកថ្លា សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន។ កូនឈើទាំងនោះរួមមាន គ្រញូង១០០ដើម ធ្នង់២០០ដើម ឈើទាល៥០ដើម ពុល២០ និងរំដួល៣០ដើម។
- ផ្តល់កូនគគីរជូនលោក អ៊ឹម ញ៉យ ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន៣០០ដើម ដើម្បីយកទៅប្រគេនតាមវត្តអារាមនៅរាជធានីភ្នំពេញ។
- ផ្តល់កូនឈើចម្រុះចំនួន៤០០ដើម ដើម្បីយកទៅចែកជូនប្រជាពលរដ្ឋរស់នៅក្រុងរុនតាឯក តេជោសែន។ កូនឈើទាំងនោះរួមមាន គ្រញូង១០០ដើម និងស្តៅ៣០០ដើម។
- ផ្តល់កូនឈើចម្រុះ ចំនួន១,៥៥០ដើម ដើម្បីយកទៅដាំបន្ថែមនៅសួនរុក្ខជាតិអង្គរ ខាងជើងសួនក្រវ៉ាន់ និងភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន ធ្នង់៥០០ដើម ប្រេស៤៥០ដើម បេង៥០ដើម ឈើទាល១០០ដើម គគីរ១០០ដើម កកោះ១០០ដើម រំដួល៥០ដើម កណ្តក់១០០ដើម និងធ្លក១០០ដើម ។

- ផ្តល់កូនឈើចម្រុះជូនលោក ម៉ក់ សុខា ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន២០០ដើម ដើម្បីយកទៅដាំនៅបរិវេណវត្តស្រះបុទុមស្រមោច និងសាលាបឋមសិក្សាស្រមោច ស្ថិតនៅភូមិស្រមោច ឃុំដូនប្រែង ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ កូនឈើទាំងនោះរួមមាន គ្រញូង២០ដើម ធ្នង់៥០ដើម បេង៣០ដើម ត្របែកព្រៃ១០ដើម ពុល១០ដើម ជើងគោ១០ដើម ក្រៅកតូច១០ដើម ស្តៅ២០ដើម រាំងភ្នំ៣០ដើម និងរំដួល១០ដើម។
- ផ្តល់កូនឈើចម្រុះជូនថ្នាក់ដឹកនាំក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងគណៈប្រតិភូក្រុមប្រឹក្សាប្រតិបត្តិសហភាពប្រៃសណីយ៍អាស៊ីប៉ាស៊ីហ្វិក ចំនួន៤២ដើម យកទៅដាំនៅខាងត្បូងកសិន្ធុប្រាសាទអង្គរវត្តនៃរមណីយដ្ឋានអង្គរ។ កូនឈើទាំងនោះរួមមាន នាងនួន៥ដើម ធ្លក៣ដើម ពុល១៧ដើម និងរំដួល១៧ដើម។
- ផ្តល់កូនឈើចម្រុះជូនតំណាងក្រុមហ៊ុនមេរ៉ុ ខមម្យូនីសេន(ខេមបូឌា) ឯ.ក ចំនួន៣៧០ដើម យកទៅដាំនៅខាងត្បូងកសិន្ធុប្រាសាទអង្គរវត្តនៃរមណីយដ្ឋានអង្គរ។ កូនឈើទាំងនោះរួមមាន ធ្នង់១០០ដើម បេង៥០ដើម កកោះ៥០ដើម គគីរ៣០ដើម រំដួល៥០ដើម ក្រៅក២០ដើម ពុល៣០ដើម ស្រឡៅ២០ដើម និងស្រឡៅជូរ២០ដើម។
- ផ្តល់កូនឈើចម្រុះជូនក្រុមហ៊ុនមេនូឡាយហ្វ៍ ខេមបូឌា ភីអិលស៊ី ចំនួន២០០ដើម ដើម្បីយកទៅដាំនៅបរិវេណឧទ្យានសហគមន៍អង្គរ មេនូឡាយហ្វ៍នៃរមណីយដ្ឋានអង្គរ។ កូនឈើទាំងនោះរួមមាន ដើមយាង ឬឈើទាល១៥០ដើម និងប្រេស៥០ដើម។

ក្រុមការងារសហគមន៍ បន្តចុះពិនិត្យសំណើពលរដ្ឋ នៅក្នុងរមណីយដ្ឋានអង្គរ បានចំនួន៤៦ករណី និងសម្រេចអនុញ្ញាតបានចំនួន៣៦ករណី

ផ្សាយនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៤

ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងរមណីយដ្ឋានអង្គរ ត្រូវបានទទួលនូវការយកចិត្តទុកដាក់អំពីសំណាក់អាជ្ញាធរជាតិអប្សរា ដោយមានការអនុគ្រោះក្នុងការជួសជុលតូចតាចនូវលំនៅដ្ឋានក៏ដូចជាសំណង់ឧប្បសម្ព័ន្ធមាន របង ដំបូល ជញ្ជាំង សសរពុកផុយ បង្គន់អនាម័យ រោងគោ ទ្រុងមាន់ និងទ្រុងជ្រូកជាដើម ហើយរាល់ការអនុញ្ញាតជួសជុលមានសុពលភាពត្រឹមពីរខែ នៅលើទីតាំងកំពុងរស់នៅផ្ទាល់តែម្តងតាមរយៈការចុះពិនិត្យ និងសម្រេចជាប្រចាំដោយក្រុមការងារសហគមន៍នាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា។ជាក់ស្តែងក្នុងសប្តាហ៍ទី៣ នៃខែសីហា ក្រុមការងារសហគមន៍បានចុះ ពិនិត្យសំណើបានចំនួន៤៦ករណី និងសម្រេចអនុញ្ញាតបានចំនួន ៣៦ករណី ទៅតាមបណ្តាលស្រុក/ក្រុងទាំង៧ ដូចខាងក្រោម៖

- ស្រុកប្រាសាទបាគងអនុញ្ញាតបាន ១ករណី
- ក្រុងសៀមរាបអនុញ្ញាតបាន ២៣ករណី
- ស្រុកបន្ទាយស្រីអនុញ្ញាតបាន ៧ករណី
- ស្រុកអង្គរធំអនុញ្ញាតបាន ២ករណី
- ស្រុកពួកនុញ្ញាតបាន ២ករណី
- ក្រុងរុនតាឯកតេជោសែននុញ្ញាតបាន ១ករណី

សូមជម្រាបថា រាល់ការដាក់ពាក្យស្នើសុំច្បាប់ និងការអនុញ្ញាត គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ។ ជាមួយគ្នានេះ ក្រុមការងារសង្កេតឃើញថា ក៏មានអ្នកដែលទទួលបានការអនុញ្ញាតហើយ ប៉ុន្តែពុំបានអនុវត្តត្រឹមត្រូវស្របនឹងការអនុញ្ញាតនោះឡើយ។ ដូច្នេះអាជ្ញាធរជាតិអប្សរាសង្ឃឹមថាបងប្អូនប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតឱ្យជួសជុលលំនៅដ្ឋានត្រូវអនុវត្តឲ្យស្របតាមចំណុចបច្ចេកទេសដែលមានការទទួលដឹងលឺ ពីអាជ្ញាធរមូលដ្ឋាន និងទទួលស្គាល់ដោយអាជ្ញាធរជាតិអប្សរា៕

ភ្ញៀវទេសចរជាច្រើន ទស្សនាថ្ងៃរះដ៏ស្រស់ស្អាតនៅប្រាសាទអង្គរ

ផ្សាយនៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤

នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤ នេះ ភ្ញៀវទេសចរជាតិ និងអន្តរជាតិជាច្រើន បានចូលទស្សនាថ្ងៃរះនៅប្រាសាទអង្គរវត្ត។ ថ្ងៃរះនៅអង្គរវត្ត ជាទស្សនីយភាពដ៏ទាក់ទាញ និងអស្ចារ្យសម្រាប់ភ្ញៀវទេសចរ ដែលតែងមកទស្សនា កំឡុងពេលពួកគេមកដល់ខេត្តសៀមរាប៕

កិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យសូហ្វីយ៉ាក្នុងការធ្វើកំណាយស្រាវជ្រាវបុរាណវិទ្យានៅប្រាសាទបន្ទាយក្តី

ផ្សាយនៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤

នៅដើមខែសីហា ឆ្នាំ២០២៤នេះ អាជ្ញាធរជាតិអប្សរា និង សាកលវិទ្យាល័យសូហ្វីយ៉ា បានធ្វើកំណាយស្រាវជ្រាវទួលបុរាណនៅភាគអាគ្នេយ៍ក្នុងកំពែងនៃប្រាសាទបន្ទាយក្តី ដើម្បីឈ្វេងយល់អំពីទំនាក់ទំនងរវាងកំពែង និងទួល ព្រមទាំងរចនាសម្ពន្ធរបស់ទួល។ លើសពីនេះទៀត គឺចង់ដឹងអំពីការរស់នៅរបស់មនុស្សនាសម័យនោះ ពោល គឺចាប់ពីពេលមុនសាងសង់ប្រាសាទរហូតដល់សម័យកណ្តាល។

លោក ញឹម សុធារិទ្ធ អ្នកស្រាវជ្រាវ និងជាសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យសូហ្វីយ៉ា ប្រទេសជប៉ុន បានលើកឡើងថា ការជ្រើសរើសយកទីតាំងនៅអាគ្នេយ៍នៃប្រាសាទបន្ទាយក្តី សម្រាប់កិច្ចការស្រាវជ្រាវ ដោយហេតុថា នៅទីតាំងនេះ មើលតាមរូបថត lidar ឃើញមានទួលជាច្រើន ដូចជា នៅប្រាសាទអង្គរវត្ត និងប្រាសាទតាព្រហ្មជាដើម។ ដូច្នេះហើយ នៅក្នុងកំណាយស្រាវជ្រាវ ពោល គឺសិក្សាអំពីលំនៅឋាន និងការតាំងទីរស់នៅរបស់មនុស្សនាសម័យមុន។ ម្យ៉ាងទៀត កិច្ចការសំខាន់ គឺការបណ្តុះបណ្តាលធនធានមនុស្ស ដែលសាកលវិទ្យាល័យសូហ្វីយ៉ា បានអនុវត្តតាំងពីឆ្នាំ១៩៩១មកម្ល៉េះ។ ឆ្នាំនេះ សាកលវិទ្យាល័យសូហ្វីយ៉ាបានជ្រើសរើសនិស្សិតមកពីមហាវិទ្យាល័យបុរាណវិទ្យានៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ឆ្នាំទី២ និងទី៣ ចំនួន៣នាក់ ដើម្បីមកចូលរួមសិក្សាអំពីការធ្វើកំណាយបែបបុរាណវិទ្យា។

ចំណែកបុរាណវិទូ នៃអាជ្ញាធរជាតិអប្សរា លោក វិទូ ភារម្យ បានឱ្យដឹងថា កំណាយនេះ បានបើកចំនួនបីរណ្តៅ ក្នុងជម្រៅ ២ម៉ែត្រគុណ២ម៉ែត្រ មាន២រណ្តៅ និង២ម៉ែត្រគុណ១.៥០ម៉ែត្រ ១រណ្តៅ ដោយរណ្តៅនីមួយៗ បែងចែកជា៤ស្រទាប់សំខាន់ៗ។ តាមការសន្និដ្ឋានរបស់លោក ការសាងសង់ទួលនៅក្នុងកំពែង មាន៣ដំណាក់កាលធំៗ គឺដំណាក់ទី១ អាចមានពលករមករៀបចំស្នាក់នៅ ដើម្បីត្រៀមរៀបចំការសាងសង់ប្រាសាទនៅលើទួលដែលមានស្រាប់។ ដំណាក់កាលទី២ ពេលកំពុងសាងសង់ប្រាសាទ គឺមនុស្សបន្តរៀបចំទួលនេះ ដោយចាក់ដីបន្ថែម និងយកកម្ទេច និងបំណែកថ្មភក់ រៀបចំជាគ្រឹះនៅជាប់ជើងទួល។ ដំណាក់កាលទី៣ ក្រោយពេលសាងសង់ប្រាសាទរួចរាល់ អាចមានមនុស្សមករស់នៅថែរក្សាប្រាសាទ មានព្រាហ្មណ៍ មានខ្ញុំប្រាសាទជាដើម បន្តរស់នៅគឺនៅស្រទាប់ទី៣នេះ។

ក្រៅពីនេះ នៅស្រទាប់ទី៣ ក៏បានរកឃើញបំណែកកុលាលភាជន៍ខ្មែរ និងចិននៅចុងសតវត្សរ៍ទី១២ និងដើមសតវត្សរ៍ទី១៣មួយចំនួន។ ជាជំហានដំបូង ទិន្នន័យនៃការធ្វើកំណាយនេះ បានធ្វើឱ្យអ្នកស្រាវជ្រាវយល់ដឹងអំពីសកម្មភាពរបស់មនុស្ស ក្រៅពីប្រាសាទ អ្នកដែលចូលរួម អ្នករស់នៅក្បែរកំពែងនៅក្នុងប្រាសាទ ជាផ្នែកមួយរបស់ប្រាសាទ តាមរយៈទួលមួយនេះ យើងឃើញមានសកម្មភាពដែលមនុស្សមករស់នៅ អាចយកជាភស្តុតាងបំពេញបន្ថែមទៅលើឯកសារសរសេរជាសិលាចារឹក ចម្លាក់ដែលឃើញមាននៅតាមប្រាសាទ ពោលគឺនៅកន្លែងនេះ តឹកតាងបុរាណវិទ្យា អាចឱ្យយើងដឹងអំពីសកម្មភាពរបស់មនុស្ស និងទំនាក់ទំនងជាមួយប្រាសាទ៕

អាជ្ញាធរជាតិអប្សរា សហការជាមួយអគ្គនាយកដ្ឋានកីឡា នៃក្រសួងអប់រំ យុវជននិងកីឡា និងសមាគមក្លឹបទេសចរណ៍ខេត្តសៀមរាប រៀបចំទស្សនកិច្ចគុនខ្មែរនៅតំបន់អង្គរ

ផ្សាយនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៤

ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៤ កិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា ជាមួយអគ្គនាយកដ្ឋានកីឡានៃក្រសួងអប់រំ យុវជន និងកីឡា និងសមាគមក្លឹបទេសចរណ៍ខេត្តសៀមរាប រៀបចំទស្សនកិច្ចគុនខ្មែរនៅតំបន់អង្គរ ។

ទស្សនកិច្ចកីឡាករគុនខ្មែរមកកាន់តំបន់ប្រវត្តិសាស្ត្រអង្គរ បានដឹកនាំកីឡាករកីឡាការិនីលំដាប់ជួរមុខក្នុងប្រទេសកម្ពុជាទទួលបានមេដាយពីព្រឹត្តិការណ៍ស៊ីហ្គេម២០២៣ ដើម្បីឱ្យពួកគាត់បានឈ្វេងយល់ពីចម្លាក់គុនខ្មែរនៅតាមផ្ទាំងសិលានៅតាមប្រាសាទសំខាន់ៗ មានប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន ប្រាសាទតាព្រហ្ម ប្រាសាទព្រះខ័ន។ល។ ជាសាវតារនៃគុនខ្មែរតាមរយៈចម្លាក់នៅតាមប្រាសាទនានា មានជាយូរលង់ណាស់មកហើយ។ បណ្តុះគំនិតស្មារតីស្រឡាញ់ និងបង្កើនឆន្ទៈថែរក្សាការពារ រួមគ្នាចូលរួមផ្សព្វផ្សាយទៅកាន់ពិភពលោក។ ក្នុងដំណើរទស្សនកិច្ចនេះដែរ មានបុរាណវិទូរបស់អាជ្ញាធរជាតិអប្សរា បានធ្វើបទបង្ហាញនៅតាមចម្លាក់នៅតាមប្រាសាទនីមួយៗផង៕

អាជ្ញាធរជាតិអប្សរា បន្តការងារជួសជុលទបង្ហូរទឹក នៅផ្នែកខាងជើង នៃប្រាសាទនាគព័ន្ធ បន្ទាប់ពីបញ្ចប់ការជួសជុលទបង្ហូរទឹក ផ្នែកខាងកើតរួចមក

ផ្សាយនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៤

កាលពីពាក់កណ្តាលខែមិថុនា ឆ្នាំ២០២៤ អាជ្ញាធរជាតិអប្សរា បានធ្វើការជួសជុលទបង្ហូរទឹក ផ្នែកខាងកើត ប្រាសាទនាគព័ន្ធ ក្នុងរយៈពេលជិត២ខែកន្លងមក កិច្ចការងារនេះបានបញ្ចប់ដោយជោគជ័យ និងកំពុងបន្តការងារជួសជុលទបង្ហូរទឹក ផ្នែកខាងជើងវិញម្តង។

លោក អ៊ិច ស្រេង ស្ថាបត្យករនៃអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា ចាប់ផ្តើមពីដើមខែសីហា ឆ្នាំ២០២៤មក ក្រុមការងារជំនាញ បានបន្តការជួសជុលទបង្ហូរទឹក នៅផ្នែកខាងជើងនៃប្រាសាទនាគព័ន្ធ ដើម្បីពង្រឹងរចនាសម្ពន្ធនៃទបង្ហូរទឹក ដែលប្រឈមនិងគ្រោះថ្នាក់ ឱ្យវារឹងមាំគង់វង្សយូរអង្វែងទៅមុខទៀត។

លោកថា មុននឹងចាប់ផ្តើមការជួសជុល អភិរក្ស ទបង្ហូរទឹកទាំងនោះ អ្នកជំនាញបានសិក្សាអំពីស្ថានភាពគ្រឹះសម្រង់ប្លង់គោល របស់ទបង្ហូរទឹកនីមួយៗ ដើម្បីចង់ដឹងអំពីទំហំនៃភាពខូចខាត ទើបចាប់ផ្តើមជួសជុលដោយយកតាមលំនាំពីបុរាណ រក្សាអ្វីជាភាពដើមនៃសំណង់ ជ្រើសយកថ្មី មកជំនួសថ្មចាស់ ក្នុងកម្រិតទាបបំផុត រួចចាប់ផ្តើមជួសជុលពង្រឹងគ្រឹះខាងក្រោមនៃទបង្ហូរទឹកជាមុន ដោយសារមានសភាពទ្រុឌទ្រោមខ្លាំង ទើបបន្តទៅជួសជុលនៅផ្នែកជណ្តើរវិញម្តង។ ជាជំហានបន្ទាប់ ក្រុមការងារនឹងបន្តទៅជួសជុលទបង្ហូរទឹក ផ្នែកខាងលិច នៃប្រាសាទនាគព័ន្ធនេះ ដើម្បីធ្វើយ៉ាងណាឱ្យរចនាសម្ពន្ធរបស់ទបង្ហូរទឹក និងជណ្តើរ រួចផុតពីហានិភ័យ។

សូមជម្រាបថា អាជ្ញាធរជាតិអប្សរា បានធ្វើការជួសជុលពង្រឹងជណ្តើរខាងលិចនៃស្រះខាងកើត និងកម្រាលជុំវិញដំបូលទបង្ហូរទឹកខាងកើត ជួសជុលជណ្តើរខាងត្បូងនៃស្រះខាងជើង និងកម្រាលជុំវិញដំបូលទបង្ហូរទឹកខាងជើង ជួសជុលជណ្តើរខាងកើតនៃស្រះខាងលិច និងកម្រាលជុំវិញដំបូលទបង្ហូរទឹកខាងលិច នៃប្រាសាទនាគព័ន្ធដោយបចាប់ផ្តើមជួសជុលតាំងពីដើមខែឧសភា ឆ្នាំ២០២៤មក៕

អាជ្ញាធរជាតិអប្សរា បើកធ្វើសិក្ខាសាលាផ្ទៃក្នុងស្តីពី "ដំណើរការអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងបរិស្ថានដើម្បីតំបន់អង្គរ"

ផ្សាយនៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤

នាព្រឹកថ្ងៃ ២៩ ខែសីហា ឆ្នាំ២០២៤នេះ នៅសាលសន្និសីទអង្គរ ស្នាក់ការកណ្តាលអាជ្ញាធរជាតិអប្សរា មានបើកធ្វើសិក្ខាសាលាផ្ទៃក្នុងស្តីពី "ដំណើរការអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងបរិស្ថានដើម្បីតំបន់អង្គរ" ក្រោមអធិបតីភាព **ឯកឧត្តម សុខ លក្ខិណា** តំណាង**ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា និងជាប្រធានប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ ព្រមទាំងសិក្ខាកាមមកពីតាមបណ្តានាយកដ្ឋានចំណុះទាំង៨របស់អាជ្ញាធរជាតិអប្សរាដ៏ច្រើនកុះករ។

អង្គសិក្ខាសាលា ដែលរៀបចំឡើងដោយអង្គភាពគ្រប់គ្រងបរិស្ថាន-អង្គរ នៃអាជ្ញាធរជាតិអប្សរានេះ ក្នុងគោលបំណងដើម្បី៖ ផ្សព្វផ្សាយ និងណែនាំពីការប្រើប្រាស់សៀវភៅប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ បញ្ជ្រាបការយល់ដឹងពីសកម្មភាពគ្រប់គ្រងបរិស្ថានរបស់នាយកដ្ឋាននីមួយៗ ព្រមទាំងលទ្ធភាពក្នុងការចូលរួមការពារបរិស្ថានក្នុងតំបន់អង្គរ។ ដោយផ្តោតទៅលើប្រធានបទសំខាន់ៗមួយចំនួនដូចជា អង្គរនិងបរិស្ថាន តួនាទីនិងភារកិច្ចនៃភ្នាក់ងារសណ្តាប់ធ្នាប់ប្រាសាទដែលកំពុងអនុវត្ត កិច្ចការសាងសង់ និងជួសជុលសំណង់ក្នុងរមណីយដ្ឋានអង្គរជាដើម។

ឯកឧត្តម សុខ លក្ខិណា បានបញ្ជាក់ថា ប្រព័ន្ធគ្រប់គ្រងបរិស្ថានបែបស្តង់ដាអន្តរជាតិISO14001 ដែលអាជ្ញាធរជាតិអប្សរាយកមកអនុវត្តតាំងពីឆ្នាំ2003នេះ មានសារៈសំខាន់ណាស់ សម្រាប់កិច្ចការអភិរក្សនិងលើកតម្លៃរមណីយដ្ឋាន-អង្គរ។ មិនចំពោះតែផ្ទៃក្នុងអាជ្ញាធរជាតិអប្សរាប៉ុណ្ណោះទេ យើងក៏នៅបានផ្សព្វផ្សាយដល់សហគមន៍ប្រជាពលរដ្ឋ បណ្តាស្ថាប័ននិងអង្គភាពជុំវិញខេត្តផងដែរ។ ហើយយើងនឹងនៅតែបន្តធ្វើជាប់ជាប្រចាំទៀតផង។

ក្រុមកីឡាករ កីឡាការិនីគុនខ្មែរ ធ្វើទស្សនកិច្ចនៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ

ផ្សាយនៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤

បន្ទាប់ពីដំណើរទស្សនកិច្ច តាមប្រាសាទបុរាណនានា ជាពិសេសទស្សនាចម្លាក់ក្បាច់គុនបុរាណខ្មែរនៅតាមប្រាសាទ រយៈពេលមួយថ្ងៃកន្លងមកថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤នេះ ក្រុមកីឡាករ កីឡាការិនី ដែលដឹកនាំ អគ្គនាយកដ្ឋានកីឡា នៃក្រសួងអប់រំ យុវជន និងកីឡា បានធ្វើដំណើរមកទស្សនកិច្ច មកកាន់សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ។ ក្នុងដំណើរទស្សនកិច្ចខាងលើដើម្បីឈ្វេងយល់ពីតួនាទីរបស់សារមន្ទីរ និងទស្សនាវត្ថុសិល្បៈជាច្រើន ដែលមានរក្សាទុកនៅក្នុងសារមន្ទីរ អមដោយការពន្យល់បកស្រាយពីមន្ត្រីជំនាញក្នុងសារមន្ទីរផ្ទាល់។

សូមជម្រាបថា កិច្ចសហការរវាងអាជ្ញាធរជាតិអប្សរាជាមួយអគ្គនាយកដ្ឋានកីឡា នៃក្រសួងអប់រំ យុវជន និងកីឡា និងសមាគមក្លឹបទេសចរណ៍ខេត្តសៀមរាប និងភាគីពាក់ព័ន្ធមួយចំនួនទៀត បានដឹកនាំក្រុមកីឡាករ កីឡាការិនី ជួរមុខកម្ពុជា ធ្វើដំណើរទស្សនកិច្ចគុនខ្មែរនៅតំបន់អង្គរ រយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤ ក្នុងគោលសិក្សាឈ្វេងយល់ អំពីសារៈតានៃក្បាច់គុនដូនតាខ្មែរ ដែលមានឆ្លាក់នៅលើជញ្ជាំងប្រាសាទ និងផ្សព្វផ្សាយអំពីក្បាច់គុនខ្មែរ ដែលជាអត្តសញ្ញាណរបស់ដូនតាយើងទៅកាន់ពិភពលោក៕

កញ្ញា ពក ផល្លា កីឡាការិនីគុនល្បុក្កតោ និងកីឡាករ លន បញ្ញា បានបង្ហាញអារម្មណ៍រំភើបបន្ទាប់បានចូលទស្សនា សារមន្ទីរព្រះនរោត្តសីហនុ-អង្គរ ដោយបានស្ងើចសរសើរស្នាដៃរបស់ដូនតាខ្មែរដែលបានបន្សល់ទុកនូវបុរាណវត្ថុដ៏មានតម្លៃយ៉ាងច្រើនអនេកសម្រាប់កូនចៅខ្មែរជំនាន់ក្រោយ។ ពេលបញ្ចប់ដំណើរទស្សនកិច្ច ក្រុមកីឡាករ កីឡាការិនី ប្ដេជ្ញាបន្តផ្សព្វផ្សាយអំពីវប្បធម៌ ក្បាច់គុនបុរាណខ្មែរ វត្ថុសិល្បៈដែលមាននៅតំបន់រមណីយដ្ឋានអង្គរ ទៅកាន់ភ្ញៀវទេសចរ ឬយុវជនដទៃទៀតឱ្យចូលមកទស្សនា និងឈ្វេងយល់។

រូបភាពប្រចាំសប្តាហ៍៖ សម្រស់ប្រាសាទបាគងក្រោយពេលភ្លៀង

ផ្សាយនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៤

ចម្លាក់ក្រឡោតទាបនៅប្រាសាទបាយ័ន បង្ហាញគ្រប់សកម្មភាពនៅសម័យអង្គរ ដ៏រុងរឿង

ផ្សាយនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៤

ប្រាសាទបាយ័ន កសាងនៅក្នុងរាជព្រះបាទជ័យវរ្ម័នទី៧ ទម្រង់ជាប្រាសាទភ្នំមានប្រាង្គចំនួន៥៤ដែលប្រាង្គនីមួយៗ មានរូបចម្លាក់ព្រហ្មមុខ៤ ខុសប្លែកពីប្រាសាទផ្សេងៗ ទាក់ទាញភ្ញៀវទេសចរមកទស្សនាមិនរំលង។

ក្រៅពីសំណង់ស្ថាបត្យកម្មដ៏ពិសេសប្លែក នៃប្រាសាទបាយ័ន ភ្ញៀវទេសចរជាតិ និងអន្តរជាតិ បានទស្សនាស្វែងយល់កាន់តែច្បាស់ពីការធ្វើសឹកសង្គ្រាម របៀបរស់នៅប្រជាជន សេវាសាធារណៈ ការកសាងប្រាសាទ ល្បែងកម្សាន្ត ព្រះរាជកិច្ចព្រះមហាក្សត្រ និងការគោរពប្រតិបត្តិជំនឿសាសនានៅតាមរយៈចម្លាក់ក្រឡោតទាបនៅតាមជញ្ជាំងនៃថែវប្រាសាទក្នុងរាជ្ជកាលព្រះបាទជ័យវរ្ម័នទី៧៕

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែកញ្ញា

រូបភាពប្រចាំសប្តាហ៍៖ ទិដ្ឋភាពប្រាសាទលលៃ សំណង់ឥដ្ឋ ដែលមានអាយុកាលជាង១ពាន់ឆ្នាំ

ផ្សាយនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៤

ថ្ងៃទី១ កញ្ញា ឆ្នាំ២០២៤ នៅវេលាម៉ោង៤:៣០នាទីល្ងាច មានករណីដើមឈើក្រឡាញ់ និងពពេល ចំនួន២ដើម ត្រូវខ្យល់បក់ដួលចំកណ្តាលផ្លូវ នៅចំណុចស្ពានបុរាណប្រាសាទនាគព័ន្ធ ភ្លាមៗនោះ ក្រុមការងារនាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ និងភ្នាក់ងារសណ្តាប់ធ្នាប់ នៃអាជ្ញាធរជាតិអប្សរា ធ្វើការកាត់ ដកចេញរួចរាល់ហើយ

ការធ្វើដំណើរឆ្លងកាត់តាមគន្លងផ្លូវនេះអាចធ្វើចរាចរណ៍ឡើងវិញ ចាប់ពីពេលនេះតទៅ

ផ្សាយនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៤

ដោយសារភ្លៀងធ្លាក់ខ្លាំង បង្កឱ្យមានទឹកច្រើន នៅតាមប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ

ដើម្បីសុវត្ថិភាពផ្ទាល់ខ្លួន សូមភ្ញៀវទេសចរ ដើរទស្សនាដោយមានការប្រុងប្រយ័ត្ន ចំពោះការរអិល ឬគ្រោះថ្នាក់ផ្សេងៗជាយថាហេតុ

ផ្សាយនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៤



សកម្មភាពក្រុមការងារសម្អាតបរិស្ថានរបស់អាជ្ញាធរជាតិអប្សរា កាត់សម្អាតស្មៅ និងរុក្ខជាតិតូចៗនៅខាងកើតខ្លោងទ្វារតាកាវ នៅព្រឹកថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២៤ចាប់ពីពេលនេះតទៅ

ផ្សាយនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៤

ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២៤
ក្រុមការងារឆ្លាក់ងារសណ្តាប់ធ្នាប់
សហការជាមួយក្រុមការងារ HCC-Angkor
រួមគ្នាសម្អាតដើមឈើដែលដួលរលំលើផ្លូវ
នៅចំណុចកំពែងខាងត្បូង ឆៀងខាងកើត
នៃប្រាសាទតាព្រហ្ម
និងអាចធ្វើចរាចរណ៍បានឡើងវិញ

ផ្សាយនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៤

ព្រឹកថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២៤ ក្រុមការងារនាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ បានកាត់សម្អាតដើមឈើធំៗ ដែលបានបាក់រលំនៅទីតាំងរានហាល ខាងកើតប្រាសាទបន្ទាយក្ដី ជៀសវាងការរំខាននៃការដើរចូលទស្សនារបស់ភ្ញៀវទេសចរ

ផ្សាយនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរារៀបចំសិក្ខាសាលាអន្តរជាតិស្តីពី ការជួសជុលនិងអភិរក្សប្រាសាទបុរាណ នៅតាមបណ្តោយផ្លូវបុរាណខាងកើត(ថ្នល់បេង) ក្រោមការឧបត្ថមថវិកាពិសេសរបស់មេគង្គ-ឡានឆាង

ផ្សាយនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា បានរៀបចំសិក្ខាសាលាស្តីពីៈ ការជួសជុល និងអភិរក្សប្រាសាទបុរាណ នៅតាមបណ្តោយផ្លូវបុរាណខាងកើត (ថ្នល់បេង) ក្រោមកិច្ចសហប្រតិបត្តិការជាមួយមេគង្គ-ឡានឆាង(Mekong-Lanchang) រយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី២ រហូតដល់ថ្ងៃទី៤ ខែកញ្ញាឆ្នាំ២០២៤ ស្ថិតក្រោមអធិតីភាព **ឯកឧត្តម ឡុង កុសល** អគ្គនាយករងតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា និងលោក LU Qizhi ប្រធានការិយាល័យកុងស៊ុលខេត្តសៀមរាប នៃស្ថានទូតសាធារណរដ្ឋប្រជាមានិតចិន អ្នកជំនាញអន្តរជាតិមកពី៤ប្រទេសចូលរួម ដូចជា ចិន វៀតណាម ឡាវ ថៃ និងអ្នកជំនាញថ្នាក់ជាតិ មាន អាជ្ញាធរជាតិអប្សរា អាជ្ញាធរជាតិព្រះវិហារ អាជ្ញាធរសំបូរព្រៃគុក មន្រ្តីមន្ទីរវប្បធម៌ខេត្តសៀមរាប ព្រមទាំងមន្រ្តីនាយកដ្ឋានគាំពារនិងអភិរក្សសំណង់ប្រាសាទចូលរួមផងដែរ។

សិក្ខាសាលានេះ រៀបចំឡើងក្នុងគោលបំណងផ្លាស់ប្តូរបទពិសោធន៍មួយចំនួនពីបណ្តាប្រទេសនៃអន្តរ តំបន់មេគង្គ ស្តីពីការអភិរក្ស និងលើកតម្លៃនៃវត្ថុបុរាណចំប៉ាប្រទេស (វៀតណាម) ប្រាសាទវត្តភូ និងការអភិរក្ស (ឡាវ) ការអភិរក្ស និងការស្តារឡើងវិញនៃប្រាសាទភិម៉ាយ (ថៃ) ការអភិរក្ស និងជួសជុលប្រាសាទក្នុងឧទ្យានអង្គរ (កម្ពុជា) ព្រមទាំងផ្តល់ចំណេះដឹង និងបច្ចេកទេសជាក់ស្តែងទាក់ទងនឹងការអភិរក្ស និងភាពស្របច្បាប់នៃប្រាសាទ ថែមទាំងចែករំលែកនូវយុទ្ធសាស្ត្រ និងការអនុវត្តល្អៗ សម្រាប់ការអភិរក្ស ការធ្វើផែនការ និងការអភិវឌ្ឍន៍សម្រាប់វិស័យទេសចរណ៍ ប្រកបដោយចីរភាពនៃតំបន់បេតិកភណ្ឌវប្បធម៌៕

សេចក្តីជូនដំណឹង ស្តីពីហានិភ័យផ្សេងៗដែលអាចកើតឡើងដោយសារហេតុ នារដូវវស្សានៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៖ ៦២៩/២៤ អ.ប.សជក

សេចក្តីជូនដំណឹង
ស្តីពី
ហានិភ័យផ្សេងៗដែលអាចកើតឡើងដោយសារហេតុ នារដូវវស្សានៅរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជូនដំណឹងដល់សាធារណជន ភ្ញៀវទេសចរជាតិ និងអន្តរជាតិទាំងអស់មេត្តាជ្រាបថា តាមរយៈសេចក្តីជូនដំណឹងរបស់ក្រសួងធនធានទឹក និងឧតុនិយម ស្តីពីស្ថានភាពធាតុអាកាសនៅព្រះរាជាណាចក្រកម្ពុជា កម្ពុជាកំពុងទទួលរងនូវឥទ្ធិពលខ្យល់មួយចំនួន ដែលបង្កឱ្យមានភ្លៀងធ្លាក់ផ្គរ ផ្គរ រន្ទះ លាយឡំជាមួយខ្យល់កន្ត្រាក់ ដែលជាហេតុបណ្តាលឱ្យដីជ្រាយ ងាយរលំ ឬបាក់មែកឈើនានាដោយសារហេតុ នៅតាមទីតាំងមួយចំនួននៃរមណីយដ្ឋានអង្គរ។

ក្នុងន័យនេះ អាជ្ញាធរជាតិអប្សរា សូមអំពាវនាវដល់សាធារណជន ភ្ញៀវទេសចរជាតិ-អន្តរជាតិ អ្នកបើកបរយានគ្រប់ប្រភេទ និងអ្នកដឹកភ្ញៀវទេសចរទាំងអស់ សូមមេត្តាបង្កើនការប្រុងប្រយ័ត្នឱ្យបានខ្ពស់នៅក្នុងអំឡុងពេលធ្វើដំណើរ ឬទស្សនាប្រាសាទនានា នៅក្នុងតំបន់រមណីយដ្ឋានអង្គរ ជាពិសេសសូមមេត្តាកុំចតយានគ្រប់ប្រភេទ ឬឈប់ជ្រកក្រោមដើមឈើ ដើម្បីបង្ការនូវហានិភ័យនានា ដែលអាចបណ្តាលឱ្យរងរបួស ឬខូចខាតទ្រព្យសម្បត្តិ ឬអាចឈានទៅដល់ប៉ះពាល់អាយុជីវិតផងដែរ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន ភ្ញៀវទេសចរជាតិ និងអន្តរជាតិទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ ចន្ទ ១៤ រោច ខែ ស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
សៀមរាប ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០២៤
អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576
APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

លិខិតរំលែកមរណទុក្ខរបស់ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ឆ្មាំ និងពលករទាំងអស់ នៃអាជ្ញាធរជាតិអប្សរា គោរពជូនលោកជំទាវឧកញ៉ាធម្មាមង្គលមុនី ថាយ ថា គង់សំអុល ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់ សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឪ្ការ គង់ សំអុល ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ដែលបានទទួលមរណភាព កាលពីថ្ងៃចន្ទ ១៤រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៤ វេលាម៉ោង ០៨:៣៥នាទីព្រឹក ក្នុងជន្មាយុ ៩៤ឆ្នាំ ដោយជរាពាធ

ផ្សាយនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ:.....✓......

លិខិតរំលែកមរណទុក្ខ

សូមគោរពជូន
លោកជំទាវឧកញ៉ា ធម្មាមង្គលមុនី ថាយ ថា គង់ សំអុល
ព្រមទាំងក្រុមគ្រួសារ

លោកជំទាវឧកញ៉ា ជាទីគោរពរាប់អានដ៏ក្រាលក្រៃ!

តាងនាមថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ឆ្មាំ និងពលករទាំងអស់នៃអាជ្ញាធរជាតិអប្សរា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ យើងខ្ញុំមានសេចក្តីរន្ធត់ក្តុកក្តួលជាទីបំផុត បន្ទាប់ពីបានទទួលដំណឹងដ៏ក្រៀមក្រំ ចំពោះមរណភាពរបស់ សម្តេចចៅហ្វាវាំងវរវៀងជ័យ អធិបតីស្រីឪ្ការ គង់ សំអុល សមាជិករដ្ឋសភា ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ និងជាអនុប្រធានកាកបាទក្រហមកម្ពុជា ដែលបានទទួលមរណភាព នៅថ្ងៃចន្ទ ១៤រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៤ វេលាម៉ោង០៨:៣៥ នាទីព្រឹក ក្នុងជន្មាយុ ៩៤ឆ្នាំ ដោយជរាពាធ។

ក្នុងឱកាសដ៏សែនសោកសៅបំផុតនេះ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសមានទុក្ខ អាឡោះអាល័យ និងក្តីសង្វេគជាពន្លឹកជាមួយ លោកជំទាវឧកញ៉ា ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់ សម្តេចចៅហ្វាវាំងវរវៀងជ័យ អធិបតីស្រីឪ្ការ ដែលជាការបាត់បង់ស្វាមី ប្រកបដោយសង្គហធម៌ដ៏ឧត្តុង្គឧត្តមចំពោះភរិយា និងជាការបាត់បង់ឪពុក ជីតា ជីតាទួត ជាទីគោរពស្រឡាញ់ប្រកបដោយព្រហ្មវិហារធម៌ ក្នុងការចិញ្ចឹមបីបាច់ថែរក្សា អប់រំផ្តល់ដំបូន្មានដល់កូនចៅ រហូតបានក្លាយជាបញ្ញវន្ត និងជាធនធានមនុស្សដ៏មានតម្លៃសម្រាប់សង្គមជាតិ។ ទន្ទឹមនឹងនេះ មរណភាពរបស់ សម្តេចចៅហ្វាវាំង ជាការបាត់បង់ឥស្សរជនជាន់ខ្ពស់ដ៏ឆ្នើមមួយរូបដែលជានិច្ចកាលតែងតែលះបង់អស់នូវកម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី ក្នុងបុព្វហេតុបម្រើជាតិ សាសនា ព្រះមហាក្សត្រ។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នាសូមចូលរួមរំលែកមរណទុក្ខដ៏ក្រៀមក្រំបំផុតនេះ ជាមួយ លោកជំទាវឧកញ៉ា ព្រមទាំងក្រុមគ្រួសារ និងសូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធរបស់ សម្តេចចៅហ្វាវាំងវរវៀងជ័យ អធិបតីស្រីឪ្ការ គង់ សំអុល សូមបានទៅកាន់ទីឋានសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម លោកជំទាវឧកញ៉ា មេត្តាទទួលនូវមនោសញ្ចេតនារំលែកទុក្ខដោយក្តីក្រៀមក្រំបំផុត ពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ ចន្ទ ១៤រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
សៀមរាប ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០២៤
អគ្គនាយក

ហង់ ពៅ

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្គោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

សប្តាហ៍ទី៤នៃខែសីហា ឆ្នាំ២០២៤ ក្រុមការងារសហគមន៍ បន្តចុះពិនិត្យសំណើពលរដ្ឋនៅក្នុងរមណីយដ្ឋានអង្គរ បានចំនួន ៧៨ករណី និងសម្រេចអនុញ្ញាត បានចំនួន ៦៩ករណី

ផ្សាយនៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២៤

ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងរមណីយដ្ឋានអង្គរត្រូវបានទទួលនូវការយកចិត្តទុកដាក់អំពីសំណាក់អាជ្ញាធរជាតិអប្សរា ដោយមានការអនុគ្រោះក្នុងការជួសជុលតូចតាចនូវលំនៅដ្ឋានក៏ដូចជាសំណង់ឧបសម្ព័ន្ធមាន របង ដំបូល ជញ្ជាំង សសរពុកផុយ បង្គន់អនាម័យ រោងគោ ទ្រុងមាន់ និងទ្រុងជ្រូកជាដើម ហើយរាល់ការអនុញ្ញាតជួសជុលមានសុពលភាពត្រឹមពីរខែ នៅលើទីតាំងកំពុងរស់នៅផ្ទាល់តែម្តងតាមរយៈការចុះពិនិត្យ និងសម្រេចជាប្រចាំដោយក្រុមការងារសហគមន៍នាយកដ្ឋានគ្រប់គ្រងដីធ្លីបេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា។ ជាក់ស្តែងក្នុងសប្តាហ៍ទី៤នៃខែសីហា ចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី៣០ ខែសីហាឆ្នាំ២០២៤ ក្រុមការងារសហគមន៍បានចុះ ពិនិត្យសំណើបានចំនួន ៧៨ករណី និងសម្រេចអនុញ្ញាតបានចំនួន ៦៩ករណី ទៅតាមបណ្តាលស្រុក/ក្រុងទាំង៧ ដូចខាងក្រោម៖

- ស្រុកពួកអនុញ្ញាតបាន ៧ករណី
- ក្រុងសៀមរាបអនុញ្ញាតបាន ៣៨ករណី
- ស្រុកអង្គរធំអនុញ្ញាតបាន ៨ករណី
- ស្រុកបន្ទាយស្រីអនុញ្ញាតបាន ១៤ករណី
- ស្រុកប្រាសាទបាគងអនុញ្ញាតបាន ២ករណី

សូមជម្រាបថា រាល់ការដាក់ពាក្យស្នើសុំច្បាប់ និងការអនុញ្ញាត គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ។ ជាមួយគ្នានេះ ក្រុមការងារសង្កេតឃើញថា ក៏មានអ្នកដែលទទួលបានការអនុញ្ញាតហើយ ប៉ុន្តែពុំបានអនុវត្តត្រឹមត្រូវស្របនឹងការអនុញ្ញាតនោះឡើយ។

ដូច្នេះអាជ្ញាធរជាតិអប្សរា សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតឱ្យជួសជុលលំនៅដ្ឋានត្រូវអនុវត្តឲ្យស្របតាមចំណុចបច្ចេកទេសដែលមានការទទួលដឹងលឺ ពីអាជ្ញាធរមូលដ្ឋាន និងទទួលស្គាល់ដោយអាជ្ញាធរជាតិអប្សរា៕

អ្នកជំនាញអាជ្ញាធរជាតិអប្សរា កំពុងជួសជុលប្រាសាទអូរផ្អុង នៅលើភ្នំគូលែន

ផ្សាយនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៤

ក្រុមអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរា កំពុងជួសជុលប្រាសាទអូរផ្អុង នៅលើភ្នំគូលែន ដែលកំពុងរងការខូចខាតរចនាសម្ពន្ធមួយចំនួនឱ្យបានរឹងមាំឡើងវិញ។

ប្រាសាទអូរផ្អុង ដែលកសាងឡើងពីឥដ្ឋ បច្ចុប្បន្ន មានស្នាមប្រេះហែកកាន់តែធំធ្វើឱ្យដុំឥដ្ឋជាច្រើនប្រឈមនឹងការជ្រុះធ្លាក់ ហើយជញ្ជាំងឥដ្ឋផ្នែកខ្លះក៏កំពុងជ្រុះធ្លាក់ដែលឈានទៅរកបាត់ទម្រង់ដើមនៃប្រាសាទ។ មន្ត្រីទទួលបន្ទុកការដ្ឋានជួសជុល លោក ពុទ្ធ សុទ្ធ ឱ្យដឹងថា ក្រុមការងារកំពុងរៀបចំជួសជុលប្រាសាទអូរផ្អុងនេះ ជាច្រើនផ្នែក ដូចជាពង្រឹងខឿនផ្នែកខាងក្រោម ខ្លោងទ្វារខាងមុខ ពង្រឹងជញ្ជាំងឥដ្ឋលើស៊ុមទ្វារ ជើងជញ្ជាំងដែលពុកផុយទាំងបួនជ្រុង ដំបូលរបស់រូតទី៣ ជួសជុលស្នាមប្រេះ លុបថ្នក់ទឹកព្រមទាំងទល់ទ្រប្រាង្គ និងសម្អាតដោយដកកូនរុក្ខជាតិដែលដុះលើជញ្ជាំងប្រាសាទផង។

លោកពុទ្ធ សុទ្ធ បន្តទៀតថា ប្រាសាទនេះ រងការខូចខាតខ្លាំងដោយកត្តាទឹកភ្លៀង និងរុក្ខជាតិ ដែលដុះចាក់ឬសធ្វើឱ្យគ្រឹះស្រុតបណ្ដាលឱ្យមានស្នាមប្រេះតូចធំជាច្រើនកន្លែង។ បញ្ហាសំណើមក៏ធ្វើឱ្យខឿនរបស់ប្រាសាទពុកផុយ។
កាលពីឆ្នាំ២០១០ អាជ្ញាធរជាតិអប្សរា ធ្លាប់បានធ្វើការជួសជុលប្រាសាទអូរផ្អុងម្តងមកហើយ ដោយការជួសជុលកាលណោះគឺពង្រឹងផ្នែកខាងក្រៅនៃជញ្ជាំងទាំង៤ជ្រុង និងជួសជុលរូតទី១និងទី២។
ប្រាសាទអូរផ្អុង គឺជាក្រុមប្រាសាទមួយ ក្នុងចំណោមប្រាសាទផ្សេងទៀតនៅលើភ្នំគូលែន ដូចជា ប្រាសាទដំរីក្រាប ប្រាសាទរោងចិនអ្នកតា និងប្រាសាទខ្ទីងស្លាប់។ល។ ប្រាសាទនេះ បានកសាងឡើង នៅលើទីខ្ពស់ ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី២ អំឡុងសតវត្សរ៍ទី៨នៃគ្រិស្តសករាជ៕

សិក្ខាកាមសរុប៣០នាក់ បានបញ្ចប់ការសិក្សាក្នុងសិក្ខាសាលាអន្តរជាតិស្តីពីការការជួសជុល និងអភិរក្សប្រាសាទបុរាណនៅតាមបណ្តោយផ្លូវបុរាណខាងកើត (ថ្នល់បេង)

ផ្សាយនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២៤

នារសៀលថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៤នេះ អាជ្ញាធរជាតិអប្សរាបានរៀបចំកម្មវិធីបិទ សិក្ខាសាលាអន្តរជាតិស្តីពីការជួសជុល និងអភិរក្សប្រាសាទបុរាណនៅតាមបណ្តោយផ្លូវបុរាណខាងកើត (ថ្នល់បេង) ក្រោមការឧបត្ថមថវិកាពិសេសរបស់គម្រោងមេគង្គ-ឡានឆាង។

ឯកឧត្តម ឡុង កុសល អគ្គនាយករងអាជ្ញាធរជាតិអប្សរា បានសម្តែងការអបអរសាទរចំពោះសិក្ខាកាមទាំង៣០នាក់ដែលបានចូលរួមក្នុងសិក្ខាសាលាដ៏មានសារសំខាន់នេះ រហូតបានបញ្ចប់ដោយជោគជ័យ។ ឯកឧត្តមក៏មានសុទិដ្ឋិនិយមថា អ្នកជំនាញទាំងអស់នឹងយកចំណេះដឹងពីការសិក្សានេះ ដើម្បីបន្តអភិរក្ស នៅតំបន់បេតិកភណ្ឌតាមបណ្តាប្រទេសរបស់ខ្លួនឱ្យបានកាន់តែប្រសើរ និងសង្ឃឹមថា នឹងមានសិក្ខាសាលាដូចនេះជាបន្តបន្ទាប់ទៀតនាពេលអនាគត។

ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ បានរាយការណ៍ពីលទ្ធផលនៃសិក្ខាសាលា រយៈពេល៣ថ្ងៃនេះ ដោយក្នុងនោះមានទាំងការសិក្សាជាទ្រឹស្តី សកម្មភាពចុះតាមការដ្ឋាន និងស្វែងយល់ពីតំបន់ប្រវត្តិសាស្ត្រមួយចំនួន ដូចជា តំបន់ប្រាសាទបេងមាលា កន្លែងយកថ្ម ការដ្ឋានជួសជុលនៅប្រាសាទអង្គរវត្ត បាយ័ន និងប្រាសាទភិមានអាកាសជាដើម។ល។

លោក ផាណុវ៉ាត់ ជាសិក្ខាកាមមកពីស្ថាប័ន Head of Phimai Historical Park នៃប្រទេសថៃ បានបង្ហាញអារម្មណ៍រីករាយដែលបានចូលរួមសិក្ខាសាលារយៈពេល៣ថ្ងៃមកនេះ។ លោក ផាណុវ៉ាត់ ថាបានស្គាល់ និងឃើញប្រាសាទខ្មែរច្រើននៅតំបន់រមណីយដ្ឋានអង្គរ ហើយលោកបានស្វែងយល់ពីការងារអភិរក្ស និងគ្រប់គ្រងតំបន់នេះកាន់តែច្រើនបន្ថែម។ មន្ត្រីអភិរក្សរូបនេះ យល់ថា ការងារអភិរក្សនៅតំបន់ប្រាសាទខ្មែរ គឺមានភាពស្រដៀងគ្នាទៅនឹងតំបន់ភិម៉ាយដែរ គឺព្យាយាមប្រើប្រាស់ថ្មចាស់ៗឱ្យអស់លទ្ធភាព។

សូមបញ្ជាក់ថា សិក្ខាសាលានេះ រៀបចំឡើងរយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី២ ដល់ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៤ ក្នុងបំណងផ្លាស់ប្តូរបទពិសោធន៍មួយចំនួនពីបណ្តាប្រទេសនៃអន្តរតំបន់មេគង្គ ស្តីពីការភិរក្ស និងលើកតម្លៃនៃវត្ថុបុរាណ ចំប៉ាប្រទេស (វៀតណាម) ប្រាសាទវត្តភូ និងការអភិរក្ស (ឡាវ) ការអភិរក្ស និងការស្តារឡើងវិញនៃប្រាសាទភិម៉ាយ (ថៃ) ការអភិរក្ស និងជួសជុលប្រាសាទក្នុងឧទ្យានអង្គរ (កម្ពុជា) ព្រមទាំងផ្តល់ចំណេះដឹង និងបច្ចេកទេសជាក់ស្តែងទាក់ទងនឹងការអភិរក្ស និងភាពស្របច្បាប់នៃប្រាសាទថៃមទាំងចែករំលែកនូវយុទ្ធសាស្ត្រ និងការអនុវត្តល្អៗសម្រាប់ការអភិរក្ស ការធ្វើផែនការ និងការអភិវឌ្ឍន៍សម្រាប់វិស័យទេសចរណ៍ ប្រកបដោយចីរភាពនៃតំបន់បេតិកភណ្ឌវប្បធម៌៕

អ្នកជំនាញ បន្តជួសជុលជញ្ជាំងរូតទី២ប្រាសាទភ្នំបាខែង ទិសខាងត្បូងឆៀងខាងលិច

ផ្សាយនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា ក្រោមកិច្ចសហប្រតិបត្តិការជាមួយអង្គការមូលនិធិប្រាសាទពិភពលោក (World Monument Fund) របស់សហរដ្ឋអាមេរិក បន្តការងារជួសជុល ពង្រឹងជញ្ជាំងរូតទី២ ប្រាសាទភ្នំបាខែង ទិសខាងត្បូងឆៀងខាងលិច ប្រវែង៣៦ម៉ែត្រជាបន្តទៀត។

លោក ជីវ ភារម្យ ស្ថាបត្យករនៅការដ្ឋានជួសជុលប្រាសាទភ្នំបាខែង ឱ្យដឹងថា ជញ្ជាំងរូតទី២ប្រាសាទភ្នំបាខែងរងការខូចខាតស្ទើរតែ៩០ភាគរយ។ ពិសេស នៅត្រង់ចំណុចកាច់ជ្រុង ធ្វើឱ្យប្រាសាទរណបបាត់បង់ថ្មស្ទើរតែទាំងស្រុង ហើយកម្រាល និងជញ្ជាំងបានខូចខាតបាត់បង់ថ្មមួយផ្នែកធំ។ ការខូចខាតបណ្ដាលមកពីអាយុកាល និងធម្មជាតិ បណ្ដាលឱ្យឫសឈើដុះចាក់តាមកន្លៀតថ្មភ្នំ និងថ្មជញ្ជាំង ទឹកភ្លៀងហូរច្រោះ ថ្មភ្នំពុកផុយ ព្រមទាំងថ្មជញ្ជាំងចល័តខុសពីទីតាំងដើម។ ការងារជួសជុលផ្នែករូតទី២នេះ គ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០២៤ខាងមុខ។

លោក ជីវ ភារម្យ បញ្ជាក់ទៀតថា ការងារជួសជុលរចនាសម្ព័ន្ធប្រាសាទភ្នំបាខែង ជ្រុងខាងត្បូងឆៀងខាងលិច គឺចាប់ផ្ដើមតាំងពីខែសីហា ឆ្នាំ២០១៩ ដែលជួសជុលសម្រេចនូវប្រាសាទរណបចំនួន៤ និង ជួសជុលជណ្ដើរទាំង៥ថ្នាក់សម្រេចបាន៩០ភាគរយ។ ជាមួយគ្នានោះដែរ ក៏បានជួសជុលកម្រាលនៅតាមរូតទី៣ និងទី៤ សម្រេចបាន៣០ភាគរយ។ ដោយឡែក ក៏បានជួសជុលជញ្ជាំងរូតទី១ រូតទី៣ និងរូតទី៤ សម្រេចបាន៨០ភាគរយ៕

អាជ្ញាធរជាតិអប្សរាអនុញ្ញាតឱ្យក្រុមហ៊ុនអិកស៍ ឃែភីថល អ៊ិនវេសម៉ិន ចូលរួមបង្ហាញគម្រោងដើម្បីផ្សព្វផ្សាយវិស័យទេសចរណ៍កម្ពុជា

ផ្សាយនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៤នេះ អាជ្ញាធរជាតិអប្សរា ដែលដឹកនាំដោយ **ឯកឧត្តម ឡុង កុសល** អគ្គនាយករង អាជ្ញាធរជាតិអប្សរា បានអនុញ្ញាតឱ្យលោក ជា ខន តំណាងក្រុមហ៊ុន អិកស៍ ឃែភីថល អ៊ិនវេសម៉ិន និងជាអនុប្រធានសមាគមជំរុញកិច្ចសហប្រតិបត្តិការកម្ពុជា-ចិន ដើម្បីបង្ហាញពីគម្រោងជួយជំរុញផ្សព្វផ្សាយវិស័យទេសចរណ៍ខេត្តសៀមរាប ទៅកាន់ទីផ្សារប្រទេសចិន។

លោក ជា ខន តំណាងក្រុមហ៊ុនអិកស៍ ឃែភីថល អ៊ីនវេសម៉ិន បានលើកឡើងថា ក្រុមហ៊ុនស្នើសុំកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរជាតិអប្សរា ដើម្បីសុំគោលការណ៍ថតរូបភាព និងវីដេអូខ្លីៗនៅតាមតំបន់ប្រាសាទ ដើម្បីយកទៅផ្សព្វផ្សាយនៅក្នុងទីផ្សារទេសចរណ៍ចិនឱ្យបានទូលំទូលាយ។ គោលបំណងសំខាន់នៃការងារនេះ គឺដើម្បីផ្សព្វផ្សាយគោលដៅទេសចរណ៍ខេត្តសៀមរាប ទៅដល់ទេសចរចិន ដើម្បីជំរុញឱ្យពួកគេមកកម្សាន្តប្រទេសកម្ពុជា ពិសេសខេត្តសៀមរាប ដែលសម្បូរដោយប្រាង្គប្រាសាទបុរាណជាច្រើន។

បើតាមតំណាងក្រុមហ៊ុន ក្រោយពីថតរួចក្រុមហ៊ុនមានដៃគូសហការជាមួយក្រុមហ៊ុនធំៗនៅប្រទេសចិន ដើម្បីផ្សព្វផ្សាយឱ្យឆាប់រហ័ស និងទូលំទូលាយ ធ្វើយ៉ាងណាស្រូបទាញទេសចរចិនដែលជាទីផ្សារធំ មកកម្សាន្តប្រទេសកម្ពុជា។

ឆ្លើយតបទៅនឹងការងារនេះ **ឯកឧត្តម ឡុង កុសល** បានរីករាយចំពោះគម្រោងខាងលើនេះ គឺស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក៏ដូចជាអាជ្ញាធរជាតិអប្សរា ក្នុងបំណងដើម្បីបង្កើនកំណើនទេសចរមកកាន់ព្រះរាជាណាចក្រកម្ពុជា ពិសេសខេត្តសៀមរាបឱ្យបានកាន់តែច្រើន៕

កម្មវិធីអប់រំបេតិកភណ្ឌ របស់អាជ្ញាធរជាតិអប្សរា នៅសាលាបឋមសិក្សាក្របីរៀលៈ ការបញ្ជ្រាបតម្លៃមរតកជូនតា ដល់ក្មេងៗជំនាន់ក្រោយ

ផ្សាយនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៤នេះ អាជ្ញាធរជាតិអប្សរា តាមរយៈនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ បន្តអនុវត្តកម្មវិធីអប់រំបេតិកភណ្ឌនៅសាលាបឋមសិក្សាក្របីរៀល ក្រុងសៀមរាប។ កម្មវិធីបង្រៀនថ្ងៃនេះ មានលក្ខណៈពិសេសបន្តិច គឺក្រុមគ្រូបង្គោលបានរៀបចំពិធីធ្វើបទបង្ហាញស្តីពីបេតិកភណ្ឌហត្ថកម្មប្រពៃណីរបស់សហគមន៍ក្របីរៀល ដែលជាការផលិតរបស់របរប្រើប្រាស់ពីធម្មជាតិ មានផ្តៅ និងរពាក់ រំចេក និងវត្ថុធាតុដើមធម្មជាតិមួយចំនួនទៀត ដល់សិស្សានុសិស្សថ្នាក់ទី៥ និងទី៦ ចំនួន២០០នាក់បានស្វែងយល់អំពីមរតកជូនតារបស់ខ្លួន។

លោក អ៊ឹម សុខរិទ្ធី គ្រូបង្គោល និងជាប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ នៃអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ក្នុងឱកាសនោះថា រយៈពេលជាច្រើនឆ្នាំមកហើយ ដែលអាជ្ញាធរជាតិអប្សរា សហការជាមួយអង្គការដៃគូអនុវត្តគម្រោងមួយឈ្មោះថា កម្មវិធីអប់រំបេតិកភណ្ឌ ដោយមានមេរៀនជាច្រើនពាក់ព័ន្ធជាមួយនិងវប្បធម៌ សាសនា បេតិកភណ្ឌរូបិយ និងអរូបិយ និងការចុះទស្សនកិច្ចសិក្សានៅតាមប្រាសាទឬសារមន្ទីរជាដើម។ លោកថា ជាផ្នែកមួយនៃបេតិកភណ្ឌអរូបិយ ពលរដ្ឋជាច្រើនគ្រួសារក្នុងសង្កាត់ក្របីរៀល កំពុងនៅបន្តកេរដំណែល ចំណេះជំនាញ គឺការផលិតរបស់របរប្រើប្រាស់ដោយដៃ ចេញពីធម្មជាតិមានផ្តៅ រពាក់ និងស្លឹករំចេកជាដើម សម្រាប់ប្រើប្រាស់ រហូតមានកេរ្តិ៍ឈ្មោះល្បាញ។ ការចែករំលែកបទពិសោធន៍អំពីដំណើរការផលិតរបស់ប្រើប្រាស់ពីផ្តៅ និងរពាក់នេះ និងផ្សារភ្ជាប់គ្នារវាងមេរៀននៅក្នុងថ្នាក់ និងអ្វីដែលបានឃើញជាក់ស្តែង ដើម្បីឱ្យក្មេងៗដែលជាសមាជិកក្នុងសហគមន៍បានឃើញនិងត្រូវបន្តវេនមរតកទាំងនោះទៅថ្ងៃខាងមុខ។

សូមជម្រាបថា កម្មវិធីអប់រំបេតិកភណ្ឌ ពិតមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់អ្នកដែលរស់នៅក្នុងតំបន់បេតិកភណ្ឌ ជាពិសេសសម្រាប់យុវជនជំនាន់ក្រោយ បានយល់ដឹងអំពីតម្លៃបេតិកភណ្ឌ និងផ្តល់ឱកាសដល់យុវជន បានយល់ដឹងនូវតម្លៃមរតកវប្បធម៌ បេតិកភណ្ឌ បណ្តុះគំនិតជាមួយនឹងបេតិកភណ្ឌ ឱ្យពួកគាត់ចេះស្រឡាញ់ និងចូលរួមថែរក្សាការពារ យល់ដឹងពីភារកិច្ច នៃការការពារ អភិរក្ស និងការងារគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា និងធ្វើជាគម្រូដល់សហគមន៍របស់ខ្លួន៕

មន្ត្រី-បុគ្គលិកសណ្តាប់ធ្នាប់ និងទេសចរណ៍៨០រូប ចូលរួមវគ្គសិក្ខាសាលាស្តីពី ការពង្រឹងសមត្ថភាពផ្នែកបដិសណ្ឋារកិច្ច

ផ្សាយនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៤

នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ បានរៀបចំសិក្ខាសាលាស្តីពី ការពង្រឹងសមត្ថភាពបដិសណ្ឋារកិច្ចភ្ញៀវទេសចររបស់ ភ្នាក់ងារទេសចរ ក្រោយសម័យកូវីដ-១៩។ វគ្គសិក្សានេះអ្នកចូលរួមសរុប៨០រូប ដែលជាមន្ត្រី-បុគ្គលិកជាភ្នាក់ងារសណ្តាប់ធ្នាប់ និងភ្នាក់ងារទេសចរ ដែលប្រចាំការនៅតាមប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ។

លោក សេង សុធារ៉ា ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ បានលើកឡើងថា សិក្ខាសាលានេះមានសារសំខាន់ណាស់ ដើម្បីឱ្យមន្ត្រី-បុគ្គលិកនៅតាមគោលដៅទាំងអស់ ពង្រឹងចំណេះដឹងទាក់ទងនឹងផ្នែកបដិសណ្ឋារកិច្ចភ្ញៀវទេសចរ។ ជាធម្មតា ភ្នាក់ងារទេសចរ និងសណ្តាប់ធ្នាប់ ជាអ្នកដែលប្រាស្រ័យផ្ទាល់ជាមួយភ្ញៀវទេសចរ ដូច្នេះការមានចំណេះដឹងគ្រប់គ្រាន់ លើផ្នែកបដិសណ្ឋារកិច្ច ការទទួលស្វាគមន៍ រាក់ទាក់ និងណែនាំភ្ញៀវ កំឡុងពេលពួកគេចូលទស្សនា នៅតាមប្រាសាទ។

ជឿតថា សិក្ខាសាលាមានរយៈពេលខ្លីក៏ពិតមែន ប៉ុន្តែលោក សេង សុធារ៉ា មានសុទិដ្ឋិនិយមថា សិក្ខាកាមទាំងអស់ នឹងតោងចាប់បាននូវចំណេះដឹងថ្មីៗដែលបង្រៀនដោយវាគ្មិន ក៏ដូចជាចែករំលែកចំណេះដឹងកន្លងមក និងសួរនាំនូវចំណុចនានាដែលមានចម្ងល់ ដើម្បីឱ្យទទួលបាន ចំណេះដឹងគ្រប់ជ្រុងជ្រោយ។

គួរបញ្ជាក់ថា សិក្ខាសាលានេះមានរយៈពេល២ថ្ងៃ គឺថ្ងៃទី៥-៦ ខែកញ្ញា ដែលធ្វើឡើងនៅនាយកដ្ឋានសណ្តាប់ធ្នាប់៕

សិស្សានុសិស្សថ្នាក់ទី១០ នៃវិទ្យាល័យហ៊ុនសែនប្រាសាទបាគង ធ្វើទស្សនកិច្ចសិក្សានៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ

ផ្សាយនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៤

បន្ទាប់ពីបានសិក្សានៅក្នុងថ្នាក់រៀន ស្តីពីការអប់រំបេតិកភណ្ឌអស់រយៈពេលជាច្រើនខែមក សិស្សានុសិស្សនៃវិទ្យាល័យហ៊ុន សែន ប្រាសាទបាគង ខេត្តសៀមរាប នៅព្រឹកថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៤នេះ បានធ្វើទស្សនកិច្ចសិក្សានៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ។

អាជ្ញាធរជាតិអប្សរា បានរៀបចំឱ្យមានដំណើរទស្សនកិច្ចរបស់សិស្សានុសិស្សនេះ ក្នុងគោលបំណង ធ្វើការតម្រង់ទិសដល់យុវជន ក្រោយពេលបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ ដើម្បីកិច្ចការងារស្រាវជ្រាវអំពីប្រវត្តិសាស្ត្រមុនឈានទៅសិក្សានៅឧត្តមសិក្សា ជាពិសេសពួកគេភាគច្រើនរស់នៅក្នុងតំបន់បេតិកភណ្ឌ ត្រូវតែសិក្សាស្វែងយល់ឱ្យបានច្បាស់អំពីតម្លៃវប្បធម៌ និងបេតិកភណ្ឌជាតិ ដើម្បីជាអ្នកបន្តវេន និងថែរក្សាសម្បត្តិវប្បធម៌ទាំងនោះនាពេលអនាគត់។

សូមជម្រាបថា ជារៀងរាល់ឆ្នាំអាជ្ញាធរជាតិអប្សរា សហការជាមួយអង្គការមរតកវប្បធម៌ និងអាជ្ញាធរក្នុងតំបន់មួយចំនួននៃរមណីយដ្ឋានអង្គរ បានបើកវគ្គបណ្តុះបណ្តាលស្តីពី៖ កម្មវិធីអប់រំបេតិកភណ្ឌ។ កម្មវិធីនេះមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់អ្នកដែលរស់នៅក្នុងតំបន់បេតិកភណ្ឌ ជាពិសេសសម្រាប់យុវជនជំនាន់ក្រោយ បានយល់ដឹងអំពីតម្លៃបេតិកភណ្ឌ និងផ្តល់ឱកាសដល់យុវជន បានយល់ដឹងនូវតម្លៃមរតកវប្បធម៌ បេតិកភណ្ឌ បណ្តុះគំនិតជាមួយនឹងបេតិកភណ្ឌ ឱ្យពួកគាត់ចេះស្រឡាញ់ និងចូលរួមថែរក្សាការពារ ជាពិសេសយល់ដឹងអំពីតួនាទីភារកិច្ច នៃការការពារ អភិរក្ស និងការងារគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា និងអាចធ្វើជាគម្រូដល់សហគមន៍របស់ខ្លួនថែមទៀតផង៕

នេះជាដំណើរទស្សនកិច្ចលើកទី២ហើយ បន្ទាប់ពីដំណើរទស្សនកិច្ចលើកទី១ សិស្សានុសិស្សបានទៅទស្សនកិច្ចការធ្វើកំណាយស្រាវជ្រាវនៅតំបន់ភ្នំបូក។ ជាបន្តបន្ទាប់ អាជ្ញាធរជាតិអប្សរា និងបន្តរៀបចំដំណើរទស្សនកិច្ចទៅកាន់ប្រាសាទបុរាណជាច្រើនទៀតក្នុងតំបន់រមណីយដ្ឋានអង្គរ។

កូនឈើចម្រុះចំនួន៦២៩០ដើមបន្ថែមទៀត ត្រូវបានអាជ្ញាធរជាតិអប្សរាចែកចាយដល់សាធារណជន

ផ្សាយនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៤

កូនឈើសរុបចំនួន ៦២៩០ ដើមបន្ថែមទៀត ត្រូវបានអាជ្ញាធរជាតិអប្សរា បន្តចែកចាយដល់សាធារណជនពីថ្ងៃទី២៦ ខែសីហា ដល់ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៤។ ដើមឈើទាំងនោះរួមមាន៖

- ប្រគេនកូនឈើចម្រុះជូនព្រះអង្គ ស៊ិន សែត ចំនួន ២៥០ដើម ដើម្បីយកទៅដាំក្នុងបរិវេណទីធ្លាវត្តព្រៃធុតង្គព្រះនិព្វាន ស្ថិតនៅភូមិត្រពាំងត្រុំ ឃុំពពេល ស្រុកសូទ្រនិគម ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន ដើមយាង ឬឈើទាល១០០ដើម គគីរ១០ដើម កកោះ១០ដើម ពពេល១០ដើម ផ្ចឿក១០ដើម ត្រាច១០ដើម អង្កាញ់១០ដើម ត្រយឹង១០ដើម ធ្នង់២០ដើម គ្រញូង២០ដើម បេង២០ដើម និងច្រេស២០ដើម។

- ផ្ដល់កូនឈើចម្រុះជូនលោក ពិក អេង មេឃុំក្លាំងហាយ ចំនួន២ ៨០០ដើម ដើម្បីយកទៅដាំស្តារព្រៃឈើឡើងវិញ ក្នុងបរិវេណព្រៃសហគមន៍ និងដាំតាមដងផ្លូវជុំវិញត្រពាំងសហគមន៍ និងតាមផ្លូវក្នុងភូមិសាស្ត្រឃុំក្លាំងហាយ ស្រុកស្រីស្នំ ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន បេង៥០០ដើម ធ្នង់៥០០ដើម ច្រេស៥០០ដើម កកោះ២០០ដើម គគីរ៣០០ដើម ផ្ចឿក៣០០ដើម និងដើមយាង៥០០ដើម។

- ផ្ដល់កូនឈើចម្រុះជូនលោក អឿម វដ្ឋា និងលោក ជា ប៉ាវី ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន៥០០ដើម ដើម្បីយកទៅដាំលើដីផ្ទាល់ខ្លួន ស្ថិតនៅស្រុកបន្ទាយស្រី ស្រុកវ៉ារិន និងស្រុកសូទ្រនិគម ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន គ្រញូង៣០ដើម បេង៨០ដើម ធ្នង់១៨០ដើម គគីរ១០០ដើម និងរំដួល១១០ដើម។

- ផ្ដល់កូនឈើចម្រុះជូនលោក ថា ច័ន្ទថន និងអ្នកស្រី ជា វុធហេង ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន៤០ដើម ដើម្បីយកទៅដាំលើដីផ្ទាល់ខ្លួន ស្ថិតនៅសង្កាត់ក្របីរៀល និងសង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន គ្រញូង១៤ដើម បេង៩ដើម ធ្នង់៩ដើម កកោះ៤ដើម និងរំដួល៤ដើម។

- ផ្ដល់កូនឈើចម្រុះជូនអ្នកស្រី ពុយ សារ៉ៃ និងលោក ឈឹម លីវ៉ៃ ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន៣៣០ដើម ដើម្បីយកទៅដាំនៅលើដីផ្ទាល់ខ្លួន ស្ថិតនៅសង្កាត់ទឹកវិល និងសង្កាត់សាលកំរើក ក្រុងសៀមរាប ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន ធ្នង់៩០ដើម គគីរ៩៥ដើម ស្តៅ៥០ដើម ពុល២០ដើម ក្រាកតូច១០ដើម និងរំដួល៦៥ដើម។

- ផ្តល់កូនឈើចម្រុះជូនលោក ផាង រ៉ូកា និងលោក ម៉េង ប៉ូគាង ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន ៤៦០ ដើម ដើម្បីយកទៅដាំនៅលើដីផ្ទាល់ខ្លួន ស្ថិតនៅភូមិក្លង់គោកគ្រើល ឃុំលាងដៃ ស្រុកអង្គរធំ និងភូមិអន្លង់ពីរ ឃុំអន្លង់ពីរ ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន គ្រញូង៥០ដើម បេង៨០ដើម គគីរ៨០ដើម ស្តៅ២០ដើម ពុល៣០ដើម ក្រៅក១០ដើម ចាមរី៥០ដើម និងរំដួល១៤០ដើម។

- ផ្តល់កូនឈើចម្រុះ ចំនួន១,៣១០ដើម ដើម្បីយកទៅដាំបន្ថែមនៅបរិវេណខាងជើងមុខនាគប្រាសាទអង្គរវត្ត សួនរុក្ខជាតិអង្គរ និងខាងជើងស្ពានរ៉ាក់រ៉ាកនៃរមណីយដ្ឋានអង្គរ។កូនឈើទាំងនោះរួមមានធ្នង់១៥០ដើមប្រេស១០០ដើម រំដួល៥០០ដើម ពុល១៥០ដើម ស្រឡៅ៣០ដើម ឥន្ទនេល៥០ដើម ចារ៥០ដើម អូញម៉ូញ៣០ដើម កណ្ដក់១០០ដើម ស្តៅ១០០ដើម និងក្រៅក៥០ដើម។

- ផ្តល់កូនឈើចម្រុះជូនតំណាងឧត្តមសេនីយ៍ត្រី និត ណារ៉ុង ប្រធានក្រុមការងារប្រវត្តិសាស្រ្តយោធានៃយោធភូមិភាគទី៤ ចំនួន៦០០ដើម ដើម្បីយកទៅដាំនៅបរិវេណសារមន្ទីរប្រវត្តិសាស្រ្តយោធាយោធភូមិភាគទី៤ និងដាំនៅតំបន់មរតកប្រវត្តិសាស្រ្ត តេជោភ្នំស្រួច ខេត្តឧត្តរមានជ័យ។ កូនឈើទាំងនោះរួមមានគគីរ២០០ដើមកកោះ២០០ដើម និងបេង២០០ដើម។

រូបភាពប្រចាំសប្តាហ៍៖ ប្រាសាទតាណៃ ស្ថិតក្នុងចំណោមប្រាសាទជាច្រើន នៅតាមបណ្តោយផ្លូវវង់តូច នៃរមណីយដ្ឋានអង្គរ មានសភាពស្ងប់ស្ងាត់ ហាក់កំបាំងពីភ្ញៀវទេសចរទាំងឡាយ ដើមឈើតូចធំ ធ្វើឱ្យប្រាសាទ ដែលកសាងនៅចុងសតវត្សទី១២នេះ កាន់តែមានភាពទាក់ទាញក្រៃលែង

ផ្សាយនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៤

រូបភាពប្រចាំសប្តាហ៍៖
ប្រាសាទមេបុណ្យខាងកើត មានទម្រង់ និងលក្ខណៈស្រដៀងទៅនឹងប្រាសាទប្រែរូប ដែលមានប្រាង្គសំខាន់ចំនួន៥ សាងអំពីឥដ្ឋ ស្ថិតនៅលើខឿនថ្មបាយក្រៀម និងថ្មភក់

ក្រៅពីបានទាក់ទាញទេសចរ អ្នកសិក្សាស្រាវជ្រាវ ក៏ជាទីសក្ការៈ ដែលអ្នកស្រុកនៅជុំវិញប្រាសាទមានជំនឿជាក់ថា ពូកែស័ក្តិសិទ្ធិ ក្នុងការរៀបចំពិធីសុំទឹកភ្លៀងជារៀងរាល់ឆ្នាំទៀតផង

ផ្សាយនៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៤

ក្រុមការងាររបស់នាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ បានកាត់ក្រីមែកឈើមួយចំនួននៅតាមបណ្តោយផ្លូវខាងលិចប្រាសាទក្រវ៉ាន់ ដើម្បីរក្សាបាននូវ សោភ័ណភាព និងបង្ការហានិភ័យដោយថាហេតុផ្សេងៗ

ផ្សាយនៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៤

ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ជួបសំណេះសំណាលជាមួយគណៈប្រតិភូ នាយកដ្ឋានកិច្ចការកម្មសិទ្ធិបោះពុម្ពផ្សាយ ភាសាបរទេស នៃសាធារណរដ្ឋប្រជាមានិតចិន

ផ្សាយនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៤នេះ **ឯកឧត្តម ឡុង កុសល** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានជួបសំណេះសំណាលជាមួយ ឯកឧត្តម Du Zhanyuan ប្រធាននាយកដ្ឋានកិច្ចការកម្មសិទ្ធិបោះពុម្ពផ្សាយ ភាសាបរទេស នៃសាធារណរដ្ឋប្រជាមានិតចិន។

ជំនួបសំណេះសំណាលនេះ ក្នុងគោលបំណង ពង្រឹងទំនាក់ទំនងនៃកិច្ចសហប្រតិបត្តិការ លើការផ្សព្វផ្សាយតំបន់អង្គរ ដែលជាសម្បត្តិបេតិកភណ្ឌកាន់ពិភពលោក ព្រមទាំងការទាក់ទាញចំណាប់អារម្មណ៍ របស់ប្រជាជនចិនឱ្យឈានទៅរកការពង្រីកទីផ្សារទេសចរណ៍ កាន់តែទូលំទូលាយថែមទៀត៕

អ្នកជំនាញ បន្តជួសជុល រចនាសម្ពន្ធមុខព្រហ្ម របស់ខ្លោងទ្វារខាងកើត ប្រាសាទតាព្រហ្ម

ផ្សាយនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៤



អាជ្ញាធរជាតិអប្សរា តាមរយៈកិច្ចសហការជាមួយស្ថាប័នស្រាវជ្រាវបុរាណវិទ្យាឥណ្ឌា (ASI) បន្តជួសជុលកំពូលមុខព្រហ្មរបស់ខ្លោងទ្វារខាងកើតនៃប្រាសាទតាព្រហ្មជាបន្តទៀត បន្ទាប់ពីក្រុមអ្នកជំនាញការអាដហុកនៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ និងសំបូរព្រៃគុក (ICC-Angkor/ Sambor Prei Kuk) បានអនុញ្ញាតឱ្យប្រើថ្មថ្មីមកជំនួសថ្មចាស់ដែលខូចខាត និងបាត់បង់ ដើម្បីអាចឱ្យខ្លោងទ្វារនេះមានរូបរាងពេញលេញឡើងវិញ។

ប្រធានគ្រប់គ្រងការដ្ឋានជួសជុលនៅប្រាសាទតាព្រហ្ម លោក Chitranjan Kumar ឱ្យដឹងថា ការងារជួសជុលខ្លោងទ្វារខាងកើតរបស់ប្រាសាទតាព្រហ្ម គឺសម្រេចបានតួខ្លោងទ្វារ រួមទាំងស្លាបសងខាង និងរចនាសម្ពន្ធដំបូល។ បច្ចុប្បន្នក្រុមការងារជួសជុលបន្តចាប់ពីរចនាសម្ពន្ធចង្ការនៃផ្ទៃមុខព្រហ្មឡើងទៅលើបន្ថែមទៀត តាមថ្មចាស់ដែលនៅសេសសល់ ដើម្បីឱ្យខ្លោងទ្វារនេះមានរូបរាងដូចដើមឡើងវិញ។ ក្រុមការងារមានការត្រេកអរដែលអ្នកជំនាញអាយស៊ីស៊ី-អង្គរ និងសំបូរព្រៃគុក បានអនុញ្ញាត ហើយខ្លោងទ្វារទាំងមូលនឹងបង្ហាញរូបរាងពេញលេញតាមលំនាំដើមក្នុងពេលឆាប់ៗខាងមុខនេះ។

សូមបញ្ជាក់ថា គម្រោងជួសជុលខ្លោងទ្វារខាងកើតនៃប្រាសាទតាព្រហ្មនេះ បានចាប់ផ្ដើមជួសជុលកាលពីដើមឆ្នាំ២០២២ ហើយគ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០២៤ខាងមុខ។ នៅមុនពេលជួសជុល ខ្លោងទ្វារខាងកើតនៃប្រាសាទតាព្រហ្ម មានសភាពទ្រុឌទ្រោមខ្លាំង គឺប្រាង្គកណ្ដាលផ្នែកខាងលើ និងថ្មដំបូលរលុះទាំងស្រុង គឺនៅសល់ផ្នែកខ្លះនៃស្លាបសងខាងប៉ុណ្ណោះ តែគ្មានលំនឹង ហែក ក្រៀកចេញពីគ្នាក្នុងស្ថានភាពហានិភ័យខ្ពស់៕

រចនាសម្ពន្ធខ្លោងទ្វារប្រាសាទតាព្រហ្មកិល ដែលជាមន្ទីរពេទ្យបុរាណត្រូវបានរៀបចំរួចរាល់

ផ្សាយនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរាបានបញ្ចប់ការរៀបចំរចនាសម្ពន្ធមួយចំនួននៅប្រាសាទតាព្រហ្មកិល ដែលរងការខូចខាតដោយអន្លើៗ មានថ្មខ្លះរាយប៉ាយ និងថ្មជាច្រើនទៀតបានបាត់ ឱ្យមានរបៀបរៀបរយឡើងវិញ។

លោក ម៉ៅ សុខនី ប្រធានការដ្ឋានជួសជុលប្រាសាទតាព្រហ្មកិល ឱ្យដឹងថា ក្រោយបញ្ចប់ការជួសជុលតួប្រាសាទតាព្រហ្មកិល ក្រុមការងារកំពុងបន្តរៀបចំបរិវេណខាងមុខប្រាសាទនោះ មាន ខ្លោងទ្វារ និងបណ្ណាល័យនៅជ្រុងនិរតី។

ការរៀបចំរចនាសម្ពន្ធរបស់មន្ទីរពេទ្យបុរាណនេះឡើងវិញ ចាំបាច់ត្រូវពង្រឹងខឿនខ្លោងទ្វារច្រកចូលខាងកើត យកថ្មចល័តខុសទីតាំងមកដាក់កន្លែងដើម រៀបផ្គុំហោជាងឡើងវិញ រៀបចំថ្មមួយចំនួនឱ្យមានសណ្តាប់ធ្នាប់ ហើយទេសចរអាចទស្សនានូវក្បាច់ចម្លាក់ផ្សេងៗ ដូចជា ហោជាង និងផ្តែរបាន ព្រមទាំងរៀបចំខឿនបណ្ណាល័យនៅជ្រុងអាគ្នេយ៍ផង៕

ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា និងភ្នាក់ងារបេតិកភណ្ឌកូរ៉េ ជួបពិភាក្សាការងារជួសជុល អភិរក្សក្នុងតំបន់អង្គរ

ផ្សាយនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤

រសៀលថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា រួមទាំងអគ្គនាយករង ជួបពិភាក្សាការងារជាមួយឯកឧត្តម Na JungHee អគ្គនាយកនៃទីភ្នាក់ងារបេតិកភណ្ឌកូរ៉េ របស់ស្ថាប័នភ្នាក់ងារបេតិកភណ្ឌកូរ៉េ (Korea Heritage Agency) ក្នុងគោលបំណងធ្វើកិច្ចសហប្រតិបត្តិការនាថ្ងៃអនាគតលើកិច្ចការជួសជុល អភិរក្សនៅក្នុងក្រុងអង្គរជំនៃរមណីយដ្ឋានអង្គរ ជាពិសេសសកម្មភាពផ្សេងៗដើម្បីលើកកម្ពស់វិស័យទេសចរណ៍។

សប្តាហ៍ទី១នៃខែកញ្ញា ឆ្នាំ២០២៤ ក្រុមការងារសហគមន៍ បន្តចុះពិនិត្យសំណើពលរដ្ឋនៅក្នុងរមណីយដ្ឋានអង្គរ បានចំនួន ៤៣ករណី និងសម្រេចអនុញ្ញាតបានចំនួន៣៥ករណី

ផ្សាយនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤

ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងរមណីយដ្ឋានអង្គរ ត្រូវបានទទួលនូវការយកចិត្តទុកដាក់អំពីសំណាក់អាជ្ញាធរជាតិអប្សរា ដោយមានការអនុគ្រោះក្នុងការជួសជុលតូចតាចនូវលំនៅដ្ឋានក៏ដូចជាសំណង់ឧបសម្ព័ន្ធមាន របង ដំបូល ជញ្ជាំង សសរពុកផុយ បង្គន់អនាម័យ រោងគោ ទ្រុងមាន់ និងទ្រុងជ្រូកជាដើម ហើយរាល់ការអនុញ្ញាតជួសជុលមានសុពលភាពត្រឹមពីរខែ នៅលើទីតាំងកំពុងរស់នៅផ្ទាល់តែម្តងតាមរយៈការចុះពិនិត្យ និងសម្រេចជាប្រចាំដោយក្រុមការងារសហគមន៍ នាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍នៃអាជ្ញាធរជាតិអប្សរា។ជាក់ស្តែងក្នុងសប្តាហ៍ទី១នៃខែកញ្ញា ក្រុមការងារសហគមន៍បានចុះ ពិនិត្យសំណើបានចំនួន៤៣ករណី និងសម្រេចអនុញ្ញាតបានចំនួន៣៥ករណី ទៅតាមបណ្តាលស្រុក/ក្រុងទាំង៦ ដូចខាងក្រោម៖

- ស្រុកបន្ទាយស្រីអនុញ្ញាតបាន ចំនួន១០ករណី

១.លោក នឿម រ៉េត អាសយដ្ឋាននៅ ភូមិព្រះដាក់ ឃុំព្រះដាក់ (តសំយាបផ្ទះ)

២.អ្នកស្រី ប៉ត ពិក្សី អាសយដ្ឋាននៅ ភូមិថ្នល់ទទឹង ឃុំព្រះដាក់ (ធ្វើទ្រុងមាន់ និងចាក់ដី)

៣.អ្នកស្រី ឈឹង សេត អាសយដ្ឋាននៅ ភូមិអូរទទឹង ឃុំព្រះដាក់ (កតដ្ឋធ្វើបន្ទប់ក្រោមផ្ទះ)

៤.លោក ស៊ុក ធី អាសយដ្ឋាននៅ ភូមិថ្នល់បណ្តោយ ឃុំព្រះដាក់ (ជួសជុលដំបូលសំយាបតូបលក់ដូរ)

៥.លោក ទុយ ស្រីហន អាសយដ្ឋាននៅ ភូមិថ្នល់បណ្តោយ ឃុំព្រះដាក់ (ធ្វើបន្ទប់ទឹកនិងបង្គន់)

៦.អ្នកស្រី ភិន កែវ អាសយដ្ឋាននៅ ភូមិអូរទទឹង ឃុំព្រះដាក់ (តសំយាប និងធ្វើអាងចំរុះទឹក)

៧.អ្នកស្រី ប៉ុល មិត អាសយដ្ឋាននៅ ភូមិអូរទទឹង ឃុំព្រះដាក់ (រំកិលជង្រុកស្រូវ)

៨.អ្នកស្រី ស៊ិច លួន អាសយដ្ឋាននៅ ភូមិអូរទទឹង ឃុំព្រះដាក់ (ជួសជុលដំបូលសំយាប ធ្វើនិងជួសជុលរបង)

៩.លោក អេង នឿន អាសយដ្ឋាននៅ ភូមិសាលាក្រវ៉ាន់ ឃុំរំចេក (ជួសជុលដំបូលផ្ទះ ធ្វើសំយាបគ្របជណ្តើរ និងជួសជុលជញ្ជាំង)

១០.អ្នកស្រី មេ ម៉ាន់ អាសយដ្ឋាននៅ ភូមិសាលាក្រវ៉ាន់ ឃុំរំចេក (ធ្វើរោងគោ និងចាក់ដី)

- ស្រុកប្រាសាទបាគងអនុញ្ញាតបាន ចំនួន២ករណី

១.លោក ផល វាច អាសយដ្ឋាននៅ ភូមិត្រាច ឃុំបល្ល័ង្គ(លើករំកិលរោងជួសជុលម៉ូតូ)

២.អ្នកស្រី ណូយ រ៉ាម អាសយដ្ឋាននៅ ភូមិបង្កោង ឃុំអំពិល (ជួសជុលដំបូលផ្ទះ)

- ស្រុកពួកអនុញ្ញាតបាន ចំនួន០២ករណី

១.អ្នកស្រី វ៉ាន់ គាន់ អាសយដ្ឋាននៅ ភូមិគោកត្រាច ឃុំខ្នាត (ប្តូរដំបូល និងជញ្ជាំងផ្ទះ តសំយាបមុខផ្ទះ)

២.អ្នកស្រី ថន សួរ អាសយដ្ឋាននៅ ភូមិដូនអុន ឃុំដូនកែវ (ធ្វើបន្ទប់ក្រោមផ្ទះ និងតសំយាបធ្វើផ្ទះបាយ)

- ស្រុកអង្គរធំអនុញ្ញាតបាន ចំនួន០៣ករណី
១.អ្នកស្រី អ៊ុក ឡាំ អាសយដ្ឋាននៅ ភូមិសំរោង ឃុំលាងដៃ (ជួសជុលទ្រុងជ្រូករោងបបរបាយជ្រូក និងចាក់ដី)
២.លោក គុណ គឹម អាសយដ្ឋាននៅ ភូមិលាងដៃ ឃុំលាងដៃ (តសំយាបធ្វើផ្ទះបាយ និងបង្គន់)
៣.លោក ឌឿន ចាន់ អាសយដ្ឋាននៅ ភូមិសំរោង ឃុំលាងដៃ (តសំយាបផ្ទះ)

សូមជម្រាបថា រាល់ការដាក់ពាក្យស្នើសុំច្បាប់ និងការអនុញ្ញាត គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ។ ជាមួយគ្នានេះ ក្រុមការងារសង្កេតឃើញថា ក៏មានអ្នកដែលទទួលបានការអនុញ្ញាតហើយ ប៉ុន្តែពុំបានអនុវត្តត្រឹមត្រូវ ស្របនឹងការអនុញ្ញាតនោះឡើយ។ ដូច្នេះអាជ្ញាធរជាតិអប្សរា សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតឱ្យជួសជុលលំនៅដ្ឋានត្រូវអនុវត្តឲ្យស្របតាមចំណុចបច្ចេកទេសដែលមានការទទួលដឹងលឺ ពីអាជ្ញាធរមូលដ្ឋាន និងទទួលស្គាល់ដោយអាជ្ញាធរជាតិអប្សរា៕

- ក្រុងសៀមរាបអនុញ្ញាតបាន ចំនួន១៩ករណី
១.លោក អ៊ូ សាជា អាសយដ្ឋាននៅ ភូមិវាល សង្កាត់គោកចក (ពង្រីកបន្ទប់ តសំយាបថ្មីធ្វើផ្ទះបាយ និងជួសជុលសំយាបចាស់)
២.លោក សៅ សៀម អាសយដ្ឋាននៅ ភូមិនគរក្រៅ សង្កាត់គោកចក (ធ្វើរោងដាក់ស្រូវ)
៣.អ្នកស្រី សូរ សុឃេង អាសយដ្ឋាននៅ ភូមិនគរក្រៅ សង្កាត់គោកចក (ប្តូរដំបូលផ្ទះ និងសសរពុក១ដើម)
៤.អ្នកស្រី សៅ សុផល អាសយដ្ឋាននៅ ភូមិនគរក្រៅ សង្កាត់គោកចក (តសំយាបធ្វើផ្ទះបាយ)
៥.លោក កង វិបុល អាសយដ្ឋាននៅ ភូមិវាល សង្កាត់គោកចក (អនុគ្រោះរក្សាទុកទ្រើងផ្កា)
៦.អ្នកស្រី ប៊ុន កន អាសយដ្ឋាននៅ ភូមិខ្វៀន សង្កាត់គោកចក (តសំយាបធ្វើផ្ទះបាយ និងចាក់ដី)
៧.លោក ដោក ដា អាសយដ្ឋាននៅ ភូមិគោកតាចាន់ សង្កាត់គោកចក (ជួសជុលសំយាប)
៨.លោក ថោង ស៊ីណាត អាសយដ្ឋាននៅ ភូមិនគរក្រៅ សង្កាត់គោកចក (ប្តូរដំបូលផ្ទះ)
៩.លោក ឆែម សុជាត់ អាសយដ្ឋាននៅ ភូមិនគរក្រៅ សង្កាត់គោកចក (អនុគ្រោះរក្សាទុកសំយាប)
១០.លោក ណាន សុជា អាសយដ្ឋាននៅ ភូមិរហាល សង្កាត់នគរធំ (ជួសជុលតូបលក់ដូរ)
១២.អ្នកស្រី ណាន ស៊ីណា អាសយដ្ឋាននៅ ភូមិរហាល សង្កាត់នគរធំ (ជួសជុលតូបលក់ដូរ)
១៣.លោក នៅ ណាន អាសយដ្ឋាននៅ ភូមិរហាល សង្កាត់នគរធំ (ជួសជុលតូបលក់ដូរ)
១៤.អ្នកស្រី ធន ស អាសយដ្ឋាននៅ ភូមិរហាល សង្កាត់នគរធំ (ជួសជុលតូបលក់ដូរ)
១៥.អ្នកស្រី មាន ស៊ីណាត អាសយដ្ឋាននៅ ភូមិក្រវ៉ាន់ សង្កាត់នគរធំ (ធ្វើផ្ទះបាយ)
១៦.លោក គុណ រិទ្ធី អាសយដ្ឋាននៅ ភូមិក្រវ៉ាន់ សង្កាត់នគរធំ (ក្សាទុករោងលំហែ និងជួសជុលសំយាប)
១៧.អ្នកស្រី ឈុប ហ៊ាន់ អាសយដ្ឋាននៅ ភូមិស្រះស្រង់ខាងត្បូង សង្កាត់នគរធំ (ជួសជុលសំយាបគ្របជណ្តើរដែលរលំ)
១៨.សេង សារ៉េន អាសយដ្ឋាននៅ ភូមិគោកដូង សង្កាត់ទឹកវិល (អនុគ្រោះរក្សាទុករោងគោ)
១៩.លោក តាប់ តន អាសយដ្ឋាននៅ ភូមិជ័យ សង្កាត់ទឹកវិល (ធ្វើតូបលក់ដូរ)

អាជ្ញាធរជាតិអប្សរា គ្រោងនឹងបញ្ចប់ការជួសជុលប្រាសាទបាទជុំ នៅចុងឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៤

ការងារជួសជុលប្រាសាទបាទជុំ ដែលបានចាប់ផ្ដើមនៅដើមខែមិថុនា ឆ្នាំ២០២៤ មកដល់ពេលនេះ សម្រេចបានប្រមាណ៧០ភាគរយ គ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០២៤ ខាងមុខនេះ។



កញ្ញា ជយ ពេជ្រជីវ៉ា វិស្វករនៃអាជ្ញាធរជាតិអប្សរា ឱ្យដឹងថា ការងារជួសជុលពង្រឹងប្រាសាទបាទជុំ នៅដំណាក់កាលទី៥នេះ បានសម្រេចចាប់ពីរួតទី១ ដល់រួតទី៣ ក្នុងចំណោមទាំង៤រួត និងកំពុងបន្តជួសជុលរួតទី៤។ អ្នកជំនាញរូបនេះបញ្ជាក់ថា រួតទី៣ និងទី៤ រងការខូចខាតធ្ងន់ធ្ងរ គឺរចនាសម្ពន្ធជញ្ជាំងបានរលុះធ្លុះពីមួយចំហៀងទៅមួយចំហៀងនៅតាមជ្រុងនីមួយៗមិនមានស្ថិរភាព។ ក្រុមការងារសម្អាតកំណកដី ស្លែ ឫសរុក្ខជាតិ និងឥដ្ឋពុកផុយចេញ ហើយប្រើប្រាស់ឥដ្ឋចាស់ដែលនៅមានគុណភាពឡើងវិញ រួមទាំងឥដ្ឋថ្មីនៅទីតាំងចាំបាច់។ ប្រើស្នូលដែកទាមនៅទីតាំងហែកខ្លាំង។ បិទកំបោរបាយអការពារជម្រាបទឹកជាដើម ដើម្បីពង្រឹងរចនាសម្ពន្ធប្រាសាទឥដ្ឋ ដែលមានអាយុកាលជាង១ពាន់ឆ្នាំនេះនៅតែរឹងមាំគង់វង្សយូរអង្វែងបន្តទៀត។

បន្ទាប់ពីបញ្ចប់ការងារជួសជុលរួតទាំង៤រួតផ្នែកខាងលើតួប៉មកណ្ដាលប្រាសាទបាទជុំ អាជ្ញាធរជាតិអប្សរា នឹងបន្តជួសជុលជណ្ដើរបន្ថែមទៀត ជាការលើកតម្លៃប្រាសាទបុរាណនេះ រក្សាបាននូវសោភ័ណភាព ដើម្បីសម្រួលដល់ការឡើង-ចុះ របស់ទេសចរផង៕

និស្សិត និងសហគមន៍ ពីវិទ្យាស្ថានជាតិកសិកម្ម ព្រែកលៀប ចុះសិក្សាស្វែងយល់ពីការងារព្រៃឈើ នៅតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៤ និស្សិត និងសហគមន៍ នៃគម្រោង «យុវជនចូលរួមក្នុងការស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ ជីវៈចម្រុះ» នៃវិទ្យាស្ថានជាតិកសិកម្ម ព្រែកលៀប បានធ្វើដំណើរទស្សនកិច្ចសិក្សាស្វែងយល់ពីការងារគ្រប់គ្រងព្រៃឈើ និងជីវៈចម្រុះ នៅក្នុងតំបន់រមណីយដ្ឋានអង្គរ។

ក្នុងដំណើរទស្សនកិច្ចនេះ ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា តាមរយៈនាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ បានធ្វើបទបង្ហាញត្រួសៗពីការងារគ្រប់គ្រងព្រៃឈើ និងការអភិរក្សជីវៈចម្រុះមួយចំនួន នៅតំបន់រមណីយដ្ឋានអង្គរ។ល។ បន្ទាប់ពីនោះ សាស្ត្រាចារ្យ និស្សិត និងសហគមន៍ សរុបជិត២០រូប បានធ្វើដំណើរទៅមើលទីតាំងមួយចំនួនដូចជា ស្ថានីយបណ្តុះកូនឈើប្រាសាទតាកែវ ការដំឡើងរន្ទាសម្រាប់កាត់ក្រីមែកឈើធំៗខាងលិចប្រាសាទបាភួន។

សូមបញ្ជាក់ថា ទស្សនកិច្ចខាងលើនេះធ្វើឡើងក្នុងបំណងផ្តល់ចំណេះដឹងដល់និស្សិត និងសហគមន៍អំពីព្រៃឈើ និងជីវៈចម្រុះនានានៅក្នុងតំបន់រមណីយដ្ឋានអង្គរ ក៏ដូចជាទទួលបានបទពិសោធន៍ល្អៗលើការងារព្រៃឈើ និងបរិស្ថាន ពីអាជ្ញាធរជាតិអប្សរា៕

អាជ្ញាធរជាតិអប្សរា បិទវគ្គបណ្តុះបណ្តាល ស្តីពីការអប់រំបេតិកភណ្ឌ ដល់សិស្សានុសិស្ស នៃសាលាបឋមសិក្សាវត្តលលៃ សម្រាប់ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៤

កម្មវិធីអប់រំបេតិកភណ្ឌដល់កុមារ ដែលរួមសហការរវាងអាជ្ញាធរជាតិអប្សរា និងអង្គការមរតកវប្បធម៌ខ្មែរ នៅសាលាបឋមសិក្សាវត្តលលៃ បានឈានដល់ទីបញ្ចប់សម្រាប់ឆ្នាំ២០២៤។ កម្មវិធីអប់រំបេតិកភណ្ឌនេះ មានរយៈពេល៩ខែដោយចាប់ផ្តើមពី ខែមករា ដល់ខែកញ្ញា ឆ្នាំ២០២៤ ដោយមានសិស្សានុសិស្សចំនួន៦៩នាក់ មកពីថ្នាក់ទី៥ចំនួន១ថ្នាក់ និងថ្នាក់ទី៦ចំនួន១ថ្នាក់ រួមទាំងលោកនាយក និងលោកគ្រូអ្នក-គ្រូទទួលបន្ទុក ថ្នាក់សរុបចំនួន៣នាក់។

កម្មវិធីអប់រំបេតិកភណ្ឌ ផ្តល់ឱកាសឱ្យកុមារដែលកើត និងរស់នៅក្នុងតំបន់រមណីយដ្ឋានវប្បធម៌-ប្រវត្តិសាស្ត្រ បានយល់ដឹង នូវកេរមរតកវប្បធម៌របស់ខ្លួន ព្រមទាំងបណ្តុះគំនិតកុមារឱ្យជ្រួតជ្រាបពីតម្លៃមរតកវប្បធម៌ទាំងនេះ ឱ្យចេះស្រឡាញ់ ចេះថែរក្សាការពារ ជាពិសេស កុមារទាំងនេះអាចធ្វើជាគំរូចំពោះសហគមន៍របស់ខ្លួនលើវិស័យថែរក្សាការពារ និងគ្រប់គ្រងកេរមរតកវប្បធម៌ក្នុងសហគមន៍របស់ខ្លួននាពេលអនាគត។

អញ្ជើញចូលរួមក្នុងឱកាសបិទកម្មវិធីនេះ មានលោក អ៊ុន មណីនីតា នាយកប្រតិបត្តិអង្គការមរតកវប្បធម៌ខ្មែរ និងតំណាងលោក អ៊ឹម សុខរិទ្ធី ប្រធាននាយកដ្ឋានស្រាវជ្រាវបណ្តុះបណ្តាល និងផ្សព្វផ្សាយនៃអាជ្ញាធរជាតិអប្សរា លោកនាយកសាលា លោកគ្រូ អ្នកគ្រូ និងតំណាងអាជ្ញាធរមូលដ្ឋានជាច្រើនរូប៕

រសៀលថ្ងៃទី១២កញ្ញា ឆ្នាំ២០២៤ ម៉ោង២:០០នាទី ឆ្មាក់ងារទេសចរប្រចាំការគោលដៅចំនុចច្រកចូលសាលរបាំ នៃប្រាសាទតាព្រហ្ម ប្រទះឃើញកាបូបស្ពាយចំហៀងពណ៌សូកូឡា លុះក្រោយមក ម្ចាស់កាបូបបានមករកវិញ ដោយពិនិត្យឃើញថា ជារបស់គាត់ពិតប្រាកដមែន ក្រុមឆ្មាក់ងារទេសចរ បានធ្វើការប្រគល់ជូនម្ចាស់វិញនៅវេលាថ្ងៃដដែល

ផ្សាយនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរាសូមគោរពអបអរសាទរ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសដ៏នក្ខត្តឫក្ស នៃការទទួលសញ្ញាបត្របណ្ឌិតកិត្តិយស «ភាពជាអ្នកដឹកនាំ និងការកសាងសន្តិភាព» ពីសាកលវិទ្យាល័យ ដុងហ្គុកវាយស៍ (Dongguk Wise University) នៃសាធារណរដ្ឋកូរ៉េ នាថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា ជួសជុលចម្លាក់តោថ្ម នៅប្រាសាទភ្នំក្រោម

ផ្សាយនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា ជួសជុលចម្លាក់តោថ្មចំនួនមួយមានកម្ពស់១.៣៧ម៉ែត្រ ទទឹង៤៦សង់ទីម៉ែត្រ បែកបាក់បួនបំណែក និងបាត់បង់ជើងទាំង៤ ដែលចម្លាក់តោនេះមានទីតាំងនៅខាងស្តាំនៃជណ្តើរខាងលិចតួប៉មកណ្តាលប្រាសាទភ្នំក្រោម ដោយត្រូវប្រើពេលប្រមាណ៦ខែ។

អ្នកជំនាញអភិរក្សថ្ម លោក ទ្រី ប៊ុនលី បានឱ្យដឹងថា ចម្លាក់តោនេះត្រូវបានរងការខូចខាតអស់ពេលជាយូរមកហើយដោយកត្តាផ្សេងៗ។ បំណែកតោនៅសេសសល់បួនបំណែក មានក្បាលដងខ្លួន និងភ្លៅមុខខាងស្តាំ រួមទាំងជើងទម្រផង។ ក្រុមការងារបានយកបំណែកចម្លាក់តោមកសម្អាតស្ងួត សម្អាតសើម និងសម្អាតបែបគីមី រួចហើយពង្រឹងថ្ម និងផ្គុំតភ្ជាប់ឡើងវិញនោះ។ ចំណែកជើងទាំង៤ ដែលបាត់បង់ត្រូវបន្ថែមថ្មថ្មី ដើម្បីឱ្យចម្លាក់តោមានជំហររឹងមាំឡើងវិញ។

ចំណែកលោក អៀន ធី និងលោក យក់ ក្រូច អ្នកអភិរក្សថ្មបានឱ្យដឹងថា ការងារជួសជុលចម្លាក់តោនេះ បានសហការគ្នាជាក្រុម តាំងពីចាប់ផ្តើមរហូតពេលដាប់ឆ្លាក់ថ្មថ្មីតភ្ជាប់ដងខ្លួនតោឡើងវិញ។ ឆ្លងកាត់ការសិក្សា និងមុនឈានដល់ការដាប់ថ្មថ្មីជំនួសជើងទាំងបួនដែលបាត់បង់ឱ្យត្រូវតាមទម្រង់ដើម អ្នកជំនាញបានធ្វើពុម្ពដីឥដ្ឋឱ្យចេញជារូបរាងតាមទម្រង់ និងកម្ពស់ដើម បន្ទាប់មកដាប់ឆ្លាក់ថ្មថ្មីជាទម្រង់ជើងតភ្ជាប់ឡើងវិញ។ ចម្លាក់តោនេះ នឹងត្រូវតម្កល់នៅទីតាំងដើម ក្រោយពេលបញ្ចប់ការជួសជុល៕

រូបភាពប្រចាំសប្តាហ៍៖ ប្រាសាទបាពួន គឺជាប្រាសាទភ្នំ ដែលជាទេវស្ថានរបស់ព្រះឥសូរ

ផ្សាយនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៤

មកដល់ទៀតហើយ ព្រឹត្តិការណ៍ដ៏អស្ចារ្យនៅប្រាសាទអង្គរវត្តក្នុងខែកញ្ញានេះ

ផ្សាយនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៤

ប្រជាពលរដ្ឋចំនួន៧៣៨គ្រួសារ ក្នុងសង្កាត់ក្របីរៀល បានទទួលចង្ក្រានបង្កើនថាមពល កាត់បន្ថយការបំពុលបរិស្ថាន

ផ្សាយនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៤ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា និងជាប្រធានក្រុមការងារចុះជួយមូលដ្ឋានសង្កាត់ក្របីរៀល រួមជាមួយលោកសាខុន ប៉ូរិន ប្រធានបណ្តាញសង្គមស៊ីវិលកម្ពុជា (CCN) និងលោក ឈួន យ៉ែប ចៅសង្កាត់ក្របីរៀល បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីចែកចង្ក្រានបង្កើនថាមពល ដែលជាអំណោយរបស់ក្រុមហ៊ុន Guangzhou Iceberg Environmental Consulting Services Co Ltd (ជាងស៊ូ អៃប៊ឺក អិនវ៉ាយរ៉ុនមិនថលខុនសូលធីស៊ីវីស) ជូនប្រជាពលរដ្ឋចំនួន៧៣៨គ្រួសារ នៅក្នុងភូមិចំនួន៧ នៃសង្កាត់ក្របីរៀល ក្រុងសៀមរាប ខេត្តសៀមរាប។

ការចែកជូនចង្ក្រានបង្កើនថាមពលខាងលើនេះ គឺមិនត្រឹមតែបង្ហាញពីការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំចំពោះប្រជាពលរដ្ឋក្នុងមូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់ជីវភាពប្រជាជន ព្រមទាំងកាត់បន្ថយការបំពុលបរិស្ថានក្នុងសហគមន៍ផងដែរ៕

រូបភាពប្រចាំសប្តាហ៍៖ ប្រាសាទភិមានអាកាស

ផ្សាយនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៤

ភ្ញៀវទេសចរតែងតែលង់នឹងសម្រស់ដ៏ស្រស់ត្រកាល ព្រមទាំងផ្តិតយករូបភាពស្អាតៗរបស់ប្រាសាទភិមានអាកាស ដែលមានវ័យចំណាស់ក្នុងចំណោមប្រាង្គប្រាសាទបុរាណនានា។ ប្រាសាទដែលកសាងឡើងពីថ្មភក់នៅលើជើងគ្រឹះថ្មបាយក្រៀមមានបីជាន់ស្រដៀងនឹងប្រាសាទពីរ៉ាមីត និងមានរូបចម្លាក់ល្អឥតខ្ចោះ ហើយមានរូបខ្លះស្រដៀងនឹងរូបចម្លាក់នៅតាមជញ្ជាំងទីព្រះលានស្តេចគម្លង់។

ផ្នែកទី២នៃជណ្តើរឡើងអមសងខាងដោយបដិមាផុសរូបសិង្ហ និងរូបដំរីនៅមុំជើងគ្រឹះទាំង៣ជាន់៕

នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៤ ក្រុមការងារភ្នាក់ងារទេសចរ សហការជាមួយក្រុមការងារ សណ្ដាប់ធ្នាប់ នៃអាជ្ញាធរជាតិអប្សរា ប្រចាំការគោលដៅប្រាសាទអង្គរវត្ត បានជួយសម្រួលដល់ភ្ញៀវទេសចរ ដែលមានអាការៈមិនស្រួលខ្លួន កំឡុងពេលដើរទស្សនា នៅច្រកខាងក្រោយ ជ្រុងកូរសមុទ្រទឹកដោះ ខាងត្បូងនៃប្រាសាទអង្គរវត្ត

បន្ទាប់ពីគាត់បានធូរស្បើយ ក្រុមការងារបានសម្រួលឱ្យរ៉ឺម៉កកង់បី ចូលមកយកគាត់ទៅសម្រាក

ផ្សាយនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៤

ភ្នាក់ងារទេសចរនៃអាជ្ញាធរជាតិអប្សរា ប្រគល់ជូនរបស់របរដែលភ្ញៀវទេសចរភ្លេច ឬជ្រុះ ចំនួន២ករណី

ផ្សាយនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៤

ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៤ ក្រុមភ្នាក់ងារទេសចរ បានទទួលកាបូបស្ពាយចំហៀងពីភ្ញៀវទេសចរខ្មែរម្នាក់ ដែលរើសបាន និងយកមកប្រគល់ឱ្យក្រុមភ្នាក់ងារនៅចំនុចខាងលើរួតបាកាន។ ក្រោយពីទទួលបានកាបូបស្ពាយនេះ ក្រុមភ្នាក់ងារទេសចរបានសហការជាមួយនគរបាលបេតិកភណ្ឌប្រគល់ជូនម្ចាស់ដើមជាទេសចរជនជាតិចិន ក្រោយពីពិនិត្យឃើញថាពិតជាម្ចាស់ពិតប្រាកដមែន។

ករណីដូចគ្នានេះដែរ នៅប្រាសាទបាយ័ន ក្រុមការងារភ្នាក់ងារទេសចរ បានប្រគល់ទូរស័ព្ទដែលភ្ញៀវទេសចរភ្លេច ឬជ្រុះ ក្រោយពីពិនិត្យឃើញថា ពិតជាម្ចាស់ពិតប្រាកដមែន៕

អបអរសាទរ ប្រាសាទអង្គរវត្ត របស់ប្រទេសកម្ពុជា បានជាប់ចំណាត់ថ្នាក់លេខ១ ជាសម្បត្តិបេតិកភណ្ឌពិភពលោក របស់អង្គការយូណេស្កូ នៅតំបន់អាស៊ី ដែលថតរូបស្អាតបំផុត

ផ្សាយនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៤

សម្រស់ប្រាសាទបុរាណខ្មែរនាពេលរាត្រីអមជាមួយការបំភ្លឺភ្លើងចម្រុះពណ៌

ផ្សាយនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា សហការជាមួយវិស័យឯកជន បន្តដាំកូនឈើក្នុងបរិវេណរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៤

ក្នុងយុទ្ធនាការដាំដើមឈើ ដើម្បីអភិរក្សរមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោក កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៤ ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ធនាគារកាណាឌីយ៉ា សាខាសៀមរាប អង្គរអាកខេត ចំនួន៣០នាក់ បានសហការជាមួយអាជ្ញាធរជាតិអប្សរា ចូលរួមដាំកូនឈើចម្រុះចំនួន៣៤២ដើម តាមដងស្ទឹងសៀមរាប ស្ថិតនៅខាងជើងស្ពានបច្ចេកទេស (ស្ពានប៉ាក់ប៉ាក)។ ការងារនេះ ក្នុងបំណងដើម្បីបន្សល់ទុកជាស្នាដៃការងារដល់សង្គម បរិស្ថាន និងទុកជាអនុស្សាវរីយ៍នៃការចងចាំក្នុងរមណីយដ្ឋានអង្គរផង៕

អាជ្ញាធរជាតិអប្សរាផ្តល់កូនឈើ៦០០ដើម ជូនរដ្ឋបាលស្រុកបន្ទាយស្រី យកទៅដាំតាមដងផ្លូវ

ផ្សាយនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា បានផ្តល់កូនឈើសរុបចំនួន ៦០០ដើម ជូនរដ្ឋបាលស្រុកបន្ទាយស្រី និងត្រូវបានយកទៅដាំតាមបណ្តោយផ្លូវជាតិលេខ ៦៧ ស្ថិតនៅភូមិប្រិយ៍ ឃុំខ្នារសណ្តាយ នាព្រឹកថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៤។

កូនឈើទាំង៦០០ដើម រួមមាន ដើមយាង ឬដើមឈើទាល ៣០០ដើម ដើមបេង ១០០ដើម ដើមធ្នង់ ១០០ដើម និងដើមផ្ចឿក ១០០ដើម៕

កូនឈើចម្រុះចំនួន៩,៥០៧ដើម ត្រូវបានអាជ្ញាធរជាតិអប្សរាចែកចាយពីថ្ងៃទី០៩ ដល់ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤

- ប្រគេនកូនឈើចម្រុះជូនព្រះភិក្ខុ ថាវរប្បញ្ញោ នូ ថេត ព្រះចៅអធិការវត្តពោធិរតនៈសាមគ្គី ចំនួន២,៧០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណវត្ត និងទីធ្លាសាលារៀន ស្ថិតនៅភូមិកោះស្នួល ឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ កូនឈើទាំងនោះរួមមាន គ្រញូង៥០០ដើម បេង៥០០ដើម ធ្នង់៥០០ដើម គគីរ៥០០ដើម ដើមយាង ឬឈើទាល៥០០ដើម និងរំដួល២០០ដើម។
- ផ្តល់កូនឈើចម្រុះជូនលោក តែម គឹមសេង មេឃុំសង្វើយ ចំនួន១,២០០ដើម ដើម្បីយកទៅដាំនៅតាមសាលារៀន ក្នុងឃុំសង្វើយ ស្រុកជីក្រែង ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន បេង២០០ដើម ធ្នង់២០០ដើម គ្រញូង២០០ដើម ផ្ចឹក២០០ដើម គគីរ១០០ដើម និងឈើទាល៣០០ដើម។

- ផ្តល់កូនឈើចម្រុះជូនលោក កងសំរិទ្ធ កិត្យា តំណាងគណៈគ្រប់គ្រងវិទ្យាល័យព្រៃឈរ និងរដ្ឋបាលឃុំ ចំនួន២០០ដើម ដើម្បីយកទៅដាំនៅបរិវេណសាលារៀន និងសាលាឃុំ ស្ថិតនៅភូមិព្រៃឈរ ឃុំព្រៃឈរ ស្រុកព្រៃឈរ ខេត្តកំពង់ចាម។ កូនឈើទាំងនោះរួមមាន ធ្នង់៥០ដើម គ្រញូង៥០ដើម បេង៥០ដើម និងច្រេស៥០ដើម។
- ផ្តល់កូនឈើចម្រុះជូនលោក ធៀប ធឿន អនុប្រធានអង្គការអាប៉ូប៉ូប្រចាំកម្ពុជា ចំនួន១០០ដើម ដើម្បីយកទៅដាំនៅបរិវេណដីរបស់អង្គការ ស្ថិតនៅភូមិពពេលលិច ឃុំពពេល ស្រុកសូទ្រនិគម ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន ធ្នង់៥០ដើម និងបេង៥០ដើម។

- ផ្តល់កូនឈើចម្រុះជូនលោក រ៉ាត់ តុលា ប្រធានរដ្ឋបាលទូទៅក្រុមហ៊ុន ស៊ីនទ្រី (ខេមបូឌា) សាខាខេត្តសៀមរាប ចំនួន១,០០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណទីលានចាក់សំរាម ស្ថិតនៅភូមិអន្លង់ពីរ ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន បេង៣០០ដើម ធ្នង់៣០០ដើម គ្រញូង៣០០ដើម និង ច្រេស១០០ដើម។

- ផ្តល់កូនឈើចម្រុះ ចំនួន១,៩១០ដើម ដើម្បីយកទៅដាំបន្ថែមនៅបរិវេណខាងជើងមុខនាគប្រាសាទអង្គរវត្ត សួនរុក្ខជាតិអង្គរ និងភូមិមណ្ឌល៣នៃរមណីយដ្ឋានអង្គរ។ កូនឈើទាំងនោះរួមមាន ធ្នង់៧៩០ដើម ច្រេស៨៥០ដើម បេង១០០ដើម វែ្លល១៦០ដើម និងឥន្ទនេល១០ដើម។

- ផ្តល់កូនឈើចម្រុះជូនតំណាង លោក គង់ ចំណាប់ នាយកធនាគារជាតិនៃកម្ពុជា សាខាខេត្តសៀមរាប ចំនួន២,០០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណវត្តប្រាសាទសំបូរ និងវត្តសន្ទុក ស្ថិតនៅស្រុកសន្ទុក ខេត្តកំពង់ធំ។ កូនឈើទាំងនោះរួមមាន គគីរ១,០០០ដើម ឈើទាល៥០០ដើម និងគ្រញូង៥០០ដើម។

- ផ្តល់កូនឈើចម្រុះជូនតំណាងធនាគារកាណាឌីយ៉ា សាខាសៀមរាប អង្គរអាកខេត ចំនួន៣៩៧ដើម យកទៅដាំតាមដងស្ទឹងសៀមរាប ស្ថិតនៅខាងជើងស្ពានរ៉ាក់រ៉ាក នៃរមណីយដ្ឋានអង្គរ។ កូនឈើទាំងនោះរួមមាន ធ្នង់៧០ដើម ច្រេស៧០ដើម កកោះ៥០ដើម គគីរ២០ដើម អង្កាញ់៣០ដើម វែ្លល៤០ដើម ក្រោក៤៧ដើម ត្របែកព្រៃ៣០ដើម រាំងភ្នំ២០ដើម អូញម៉ូញ១០ដើម និងឥន្ទនេល១០ដើម។

អាជ្ញាធរជាតិអប្សរា
កំណាយរកឃើញបំណែកក្បាលនាគ
ដែលជាផ្នែកមួយរបស់បដិមាព្រះពុទ្ធប្រក់នាគ
នៅក្នុងសាលរបាំនៃប្រាសាទតាព្រហ្ម

ផ្សាយនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤

ក្រុមអ្នកបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា សហការជាមួយស្ថាប័នស្រាវជ្រាវបុរាណវិទ្យាឥណ្ឌា(ASI) កំពុងធ្វើកំណាយនៅក្នុងបរិវេណប្រាសាទតាព្រហ្ម រកឃើញបំណែកក្បាលនាគដែលជាផ្នែកមួយរបស់បដិមាព្រះពុទ្ធបដិមាប្រក់នាគតម្កល់នៅក្នុងសាលរបាំ រួមទាំងបំណែកផ្សេងៗរបស់បដិមាតូចធំមួយចំនួនផង។

បុរាណវិទូ លោកស្រី នេត ស៊ីមន ឱ្យដឹងថា កាលពីខែកក្កដា ឆ្នាំ២០២៤ ក្នុងពេលដែលក្រុមការងារបានរៀបចំសម្រង់ប្លង់បំណែកថ្មដែលនៅរាយប៉ាយជុំវិញរោងទងទី៣នៃប្រាសាទតាព្រហ្មបានប្រទះឃើញបំណែកខ្លួននាគមួយផ្នែកនៃចម្លាក់បដិមាព្រះពុទ្ធប្រក់នាគ មួយផ្នែកកប់នៅក្នុងដី។ ក្រោយពីកំណាយឃើញថា ថ្មនៃបំណែកក្បាលនាគនេះ គឺជាបំណែកចម្លាក់នាគ ដែលជាដងខ្លួននាគរបស់ព្រះពុទ្ធប្រក់នាគ ដែលបានយកទៅដាក់តម្កល់ក្នុងសាលរបាំ។

ប៉ុន្តែ បំណែកក្បាលនាគមានត្រឹមក្បាលតែ២ប៉ុណ្ណោះ គឺក្បាលផ្នែកកណ្តាល និងខាងស្តាំ ក្នុងចំណោមនាគក្បាល៧។ អ្វីដែលធ្វើឱ្យអ្នកជំនាញសន្និដ្ឋានថា ជាបំណែកមួយរបស់ព្រះពុទ្ធប្រក់នាគ គឺមុខថ្មមានទំហំត្រូវគ្នា សាច់ថ្មតែមួយ រួមទាំងក្បូរក្បាច់ក្នុងទម្រង់ដូចគ្នា។ តាមស្ថានភាពនៃបំណែកក្បាលនាគកប់នៅក្នុងដីនេះ គឺមានការរៀបចំទុកយ៉ាងត្រឹមត្រូវ ដែលអ្នកជំនាញគិតថា បំណែករូបនេះត្រូវបានគេកប់ទុកនៅទីតាំងនេះ ដោយការគោរព ដែលប្រហែលជានៅក្រោយរាជព្រះបាទជ័យវរ្ម័នទី៧ ពេលដែលផ្លាស់ប្តូរសាសនាពីពុទ្ធសាសនាមហាយានទៅព្រហ្មសាសនាវិញ។ ក្រុមការងារសង្ឃឹមថា នឹងអាចរកឃើញផ្នែកផ្សេងៗរបស់ពុទ្ធបដិមាប្រក់នាគដ៏ធំមួយនេះបន្ថែមទៀតនាពេលអនាគត ដើម្បីយកមកផ្គុំឡើងវិញ ឱ្យបដិមានេះពេញរូបរាង ទុកឱ្យពុទ្ធសាសនិកគោរពបូជាតាមជំនឿ។

បុរាណវិទូ ឱ្យដឹងទៀតថា ក្រៅពីបំណែកក្បាលនាគដ៏សំខាន់នេះ ក៏រកឃើញបំណែកផ្សេងៗរបស់ពុទ្ធបដិមា និងចម្លាក់ផ្សេងៗមួយចំនួនទៀត មានដូចជា ប្រអប់ដៃ ប្រអប់ជើង ដងខ្លួន ជើងទម្រ ព្រះសិរ ជាដើម៕

ព្រឹកថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤ ភ្នាក់ងារទេសចរ និងភ្នាក់ងារសណ្តាប់ធ្នាប់ នៃអាជ្ញាធរជាតិអប្សរា បានជួយសង្គ្រោះបឋមភ្ញៀវទេសចរ ដែលមានអាការៈមិនស្រួលខ្លួន កំឡុងពេលទស្សនានៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤

អ្នកជំនាញកំពុងជួសជុលខ្លោងទ្វារខាងត្បូង នៃប្រាសាទតាព្រហ្មឡើងវិញ

ផ្សាយនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៤

ខ្លោងទ្វារទិសខាងត្បូងប្រាសាទតាព្រហ្ម ដែលរលំដួលទាំងស្រុងអស់ជាច្រើនឆ្នាំមកហើយ ចាប់ផ្តើមបង្ហាញរូបរាងដើមជាបណ្តើរៗហើយ បន្ទាប់ពីអាជ្ញាធរជាតិអប្សរារួមសហការជាមួយស្ថាប័នស្រាវជ្រាវបុរាណវិទ្យាឥណ្ឌា (ASI) ជួសជុលអស់ពេលជាច្រើនខែមក។ ការងារនេះ ចាប់ផ្តើមតាំងពីពាក់កណ្តាលឆ្នាំ២០២៤ ដោយពង្រឹងគ្រឹះ និងតួខ្លោងទ្វារឡើងវិញ បន្ទាប់ពីអ្នកជំនាញបានចំណាយពេល១ឆ្នាំក្នុងការសិក្សា រុះរើថ្មតាមបច្ចេកទេសអាណាស្ទីលូស៊ី។

លោក Chitranjan Kumar ប្រធានគ្រប់គ្រងការដ្ឋានជួសជុលនៅប្រាសាទតាព្រហ្ម ឱ្យដឹងថា តាំងពីដើមឆ្នាំ២០២៣ ក្រុមការងារបានសិក្សា រុះរើគំនរថ្មដែលជ្រុះធ្លាក់សន្ធប់មកលើតួខ្លោងទ្វារទាំងមូល និងស្វែងរកថ្មដែលចល័តខុសពីទីតាំងដើមមកផ្គុំសាកល្បងឱ្យត្រូវតាមទីតាំងដើម ព្រមទាំងជួសជុលថ្មបាក់បែក ឬខូចខាតមួយចំនួន កំណាយបុរាណវិទ្យា ពិសោធន៍ដីគ្រឹះជាដើម។ អ្នកគ្រប់គ្រងការដ្ឋានបន្ថែមថា មកដល់ពាក់កណ្តាលឆ្នាំ២០២៤ ក្រុមការងារបានរៀបចំជួសជុលពង្រឹងគ្រឹះខ្លោងទ្វារនិងខឿន ជញ្ជាំងមួយចំនួនតាមលំនាំឡើងវិញជាបន្តបន្ទាប់។ កិច្ចការនេះអាចរលូនទៅបានឆាប់រហ័សដោយសារតែថ្មដើមរបស់ខ្លោងទ្វារ អាចរកឃើញប្រមាណជា៩៥ភាគរយយកមកដាក់នៅទីតាំងដើមឡើងវិញ។

លោក Chitranjan Kumar បញ្ជាក់ទៀតថា ការងារជួសជុលខ្លោងទ្វារខាងត្បូងនៃប្រាសាទតាព្រហ្មនេះ ត្រូវបានអភិរក្សទាំងដើមឈើផង ស្របតាមអនុសាសន៍របស់ក្រុមអ្នកជំនាញការអាដហុកនៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួល កិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ និងសំបូរព្រៃគុក (ICC-Angkor/ Sambor Prei Kuk)៕

ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិ ទស្សនាប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤

ទិដ្ឋភាពភ្ញៀវទេសចរ ទស្សនារមណីយដ្ឋានអង្គរ ពេលភ្លៀងធ្លាក់ ទោះបីជាមានភ្លៀង ក៏មិនមែនជាឧបសគ្គក្នុងការដើរទស្សនា នោះឡើយ ព្រោះសម្រស់ប្រាសាទ ស្រស់ស្អាតម្យ៉ាង ដែលកម្រនឹងបានឃើញ ផ្ទាល់ភ្នែកបែបនេះ

ផ្សាយនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤

សិស្សានុសិស្សចំនួន២០០នាក់ នៃសាលាបឋមសិក្សាក្របីរៀល បានមកទស្សនកិច្ចសិក្សា នៅប្រាសាទបន្ទាយសំរែ

ផ្សាយនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤

បន្ទាប់ពីបានសិក្សាអំពីទ្រឹស្តីនៅក្នុងថ្នាក់រៀនអស់រយៈពេលជាច្រើនខែមក នៅថ្ងៃទី១៩ និង២០ ខែកញ្ញា ឆ្នាំ២០២៤នេះ សិស្សានុសិស្សចំនួន២០០នាក់ ក្នុងនោះមានសិស្សថ្នាក់ទី៥ ចំនួន២ថ្នាក់ និងសិស្សថ្នាក់ទី៦ ចំនួន២ថ្នាក់ នៃសាលាបឋមសិក្សាក្របីរៀល ស្ថិតក្នុងសង្កាត់ក្របីរៀល ក្រុងសៀមរាប បានមកទស្សនកិច្ចសិក្សាអំពីកិច្ចការងារអភិរក្សប្រាសាទបន្ទាយសំរែ។

គោលបំណងដឹកនាំសិស្សានុសិស្សមកទស្សនកិច្ចសិក្សានៅប្រាសាទបន្ទាយសំរែ ក៏ដូចជា នៅតំបន់រមណីយដ្ឋានអង្គរនេះ គឺដើម្បីឱ្យកុមារដែលរស់នៅក្បែររមណីយដ្ឋានអង្គរ បានសិក្សាស្វែងយល់ពីអរិយធម៌ ការរៀបចំរមណីយដ្ឋានអង្គរ ជាពិសេស បង្ហាញនូវភាពជាក់ស្តែង នៃកិច្ចការពារ ថែរក្សា អភិរក្ស ការងារគ្រប់គ្រង និងការអភិវឌ្ឍដោយចីរភាពជាយូរអង្វែងសម្រាប់តំបន់អង្គរ។

សូមជម្រាបផងដែរថា ដើម្បីបណ្តុះគំនិតយុវជនជំនាន់ក្រោយ ឱ្យបានយល់ដឹងអំពី ការថែរក្សាបេតិកភណ្ឌ ចាប់តាំងពីឆ្នាំ២០០៧មក ក៏មានវគ្គបណ្តុះបណ្តាលមួយដល់សិស្សានុសិស្សរស់នៅតំបន់បេតិកភណ្ឌមានក្នុងខេត្តឧត្តរមានជ័យ បន្ទាយមានជ័យ សៀមរាប ព្រះវិហារ និងខេត្តកំពង់ធំ៕

រូបភាពប្រចាំសប្តាហ៍៖
ប្រាសាទតាកែវ
ថ្វីត្បិតគ្មានក្បាច់រចនា
ដូចប្រាសាទនានានៅតំបន់អង្គរ

ប៉ុន្តែសំណង់ស្ថាបត្យកម្ម
របស់ប្រាសាទនេះមានភាពស្រស់ស្អាត
និងទាក់ទាញ ដែលជាគោលដៅ
ដ៏ពេញនិយមរបស់ទេសចរ

ផ្សាយនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៤

រូបភាពប្រចាំសប្ដាហ៍៖ សម្រស់ប្រាសាទជ្រុង (អាគ្នេយ៍) នៅលើកំពែងក្រុងអង្គរធំ អមដោយធម្មជាតិស្រស់បំព្រង

ផ្សាយនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៤

ទិដ្ឋភាពភ្ញៀវទេសចរយ៉ាងច្រើនកុះកររង់ចាំទស្សនាព្រះអាទិត្យរះ លើកំពូលប្រាសាទអង្គរវត្តនាថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៤

ដោយមូលហេតុអាកាសធាតុ ព្រះអាទិត្យពុំបានចែងចាំងនូវពន្លឺដ៏អស្ចារ្យ នៅលើកំពូលប្រាសាទអង្គរវត្តឡើយ

ផ្សាយនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៤

ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៤ ក្រុមភ្នាក់ងារទេសចរ បានទទួលកូនកាបូបពណ៌ទឹកប៊ិចលាយរូបកូនដំរី ពីមគ្គុទ្ទេសក៍ទេសចរណ៍ម្នាក់ ដែលរើសបាន និងយកមកប្រគល់ឱ្យក្រុមភ្នាក់ងារ នៅចំនុចផ្លូវដីច្រកចូល ពីខ្លោងទ្វារខាងកើតនៃប្រាសាទតាព្រហ្ម

ក្រោយពីទទួលបានកូនកាបូបនេះ ក្រុមភ្នាក់ងារទេសចរបានសហការជាមួយ នគរបាលបេតិកភណ្ឌ ប្រគល់កូនកាបូបនោះជូនម្ចាស់ដើមវិញ ដែលជាទេសចរ ជនជាតិខ្មែរ ក្រោយពីពិនិត្យឃើញថាពិតជាម្ចាស់ពិតប្រាកដមែន

ផ្សាយនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៤

ទេសចរយ៉ាងច្រើនកុះករ ស្អាត់មកពីទីជិតឆ្ងាយ ដើម្បីរង់ចាំទស្សនាថ្ងៃរះ ចំកំពូលកណ្តាលប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៤

រយៈពេល៣ថ្ងៃចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៤នេះ ភ្ញៀវទេសចរជាតិ និងអន្តរជាតិយ៉ាងច្រើនកុះករ បានស្អាត់មកពីទីជិតឆ្ងាយ រួតរះក្រោកតាំងពីព្រលឹមស្រាងៗ ដើម្បីរង់ចាំទស្សនាទិដ្ឋភាពដ៏អស្ចារ្យ គឺថ្ងៃរះចំកំពូលកណ្តាលប្រាសាទអង្គរ និងឆ្លៀតចូលទស្សនាសម្រស់ប្រាសាទអង្គរវត្ត នាពេលព្រឹកផងៗ

ព្រះតេជគុណ សុង ពិសិដ្ឋ គង់នៅវត្តដំណាក់ ក្រុងសៀមរាប បានថេរដីកាថា នេះទើបតែជាលើកទីពីរប៉ុណ្ណោះដែលព្រះអង្គបាននិមន្តមកទស្សនាថ្ងៃរះចំកំពូលកណ្តាលប្រាសាទអង្គរវត្ត បើទោះបីប៉ុន្មានថ្ងៃនេះអាកាសធាតុមិនអំណោយផលល្អ តែនេះជាព្រឹត្តិការណ៍ដ៏អស្ចារ្យ អាចទាក់ទាញទេសចរជាតិ និងអន្តរជាតិ រាប់ម៉ឺននាក់ ឱ្យចូលមកទស្សនាប្រាសាទអង្គរវត្ត និងប្រាសាទដទៃក្នុងតំបន់រមណីយដ្ឋានអង្គរ។

ចំណែកលោកយាយ ម៉ម វាត់ អាយុ៧៧ឆ្នាំ ភ្ញៀវទេសចររស់នៅក្នុងខេត្តពោធិសាត់ បានឱ្យដឹងថា នេះជាលើកទី៥ហើយ ដែលលោកយាយបានមកទស្សនាព្រឹត្តិការណ៍ថ្ងៃរះចំកំពូលកណ្តាលនៃប្រាសាទអង្គរវត្ត ព្រមទាំងបាននាំបងប្អូនញាតិមិត្តមកទស្សនាថែមទៀត។លោកយាយថា បើទោះបីឃើញថា អាកាសធាតុមិនអំណោយផលល្អ តែលោកយាយនៅតែចង់មកទស្សនាប្រាសាទអង្គរវត្ត ព្រោះតែកោតសសើរស្នាដៃបុព្វបុរសខ្មែរ ដែលលោកបានកសាងអង្គរវត្ត និងប្រាសាទបុរាណជាច្រើនលើទឹកដីនៃខេត្តសៀមរាប។

សូមជម្រាបថា រយៈពេល៣ថ្ងៃចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៤នេះ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ សរុបជិត ៤ម៉ឺននាក់ បានចូលមកទស្សនាថ្ងៃរះនៅប្រាសាទអង្គរវត្ត៕

អ្នកជំនាញអាជ្ញាធរជាតិអប្សរា
រៀបចំការងារត្រៀមជួសជុលខ្លោងទ្វារទី២ខាងកើតប្រាសាទបន្ទាយប្រី

ផ្សាយនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៤

ខ្លោងទ្វារទី២នៃប្រាសាទបន្ទាយប្រី ដែលមានសភាពទ្រុឌទ្រោមខ្លាំង ហើយថ្មមួយចំនួនបានធ្លាក់នៅរាយប៉ាយ និងមួយចំនួនទៀតកប់ក្នុងដី ត្រូវបានក្រុមការងារនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា ស្វះស្វែងផ្គុំឡើងវិញ។

លោក ជា សារិទ្ធិ បុរាណវិទូ អ្នកគ្រប់គ្រងការដ្ឋានបានឱ្យដឹងថា ខ្លោងទ្វារទី២នេះ មានស្ថានភាពទ្រុឌទ្រោមខ្លាំង ដោយផ្នែកខ្លះនៃរចនាសម្ពន្ធខ្លោងទ្វារបានរលុះធ្លាក់ចេញទីតាំងដើម ដោយសារតែកង្វះការថែទាំ អាយុកាលនៃសំណង់គ្រឹះចុះខ្សោយ និងគុណភាពថ្មមួយចំនួនពុកផុយជាដើម។ អ្នកជំនាញរូបនេះបន្តថា ក្នុងឆ្នាំ២០២៤ ក្រុមការងារបានស្រាវជ្រាវឯកសារ ធ្វើសម្រង់ប្លង់ កំណាយរកថ្ម រៀបផ្គុំថ្មសាកល្បង ជួសជុលគ្រឹះ នឹងបន្តជួសជុលតួខ្លោងទ្វារក្នុងឆ្នាំ២០២៥ខាងមុខ។ លោក សារិទ្ធិ បញ្ជាក់ថា ការងាររកថ្មដែលចាប់ផ្តើមតាំងពីពាក់កណ្តាលខែសីហាមក រកឃើញថ្មប្រមាណពី៧០ ទៅ៨០ភាគរយ ដែលជាផ្នែកនៃរចនាសម្ពន្ធហោជាង និងដំបូលនៅទិសខាងកើត ទិសខាងជើង និងទិសខាងលិច រួមទាំងជញ្ជាំងជ្រុងពាយ័ព្យផង ។

លោក ស្មើយ សុផល អ្នកជំនាញស្វែងរកថ្ម ឱ្យដឹងថា ទោះបីខ្លោងទ្វារប្រាសាទបន្ទាយប្រី មានសភាពតូចនិងថ្មមានចំនួនតិចក្តី ក៏មិនមានភាពងាយស្រួលប៉ុន្មានឡើយ។ ការស្វែងរកទីតាំងដើមនៃថ្មនីមួយៗ ត្រូវដឹងពីដំណរថ្មពីមួយដុំទៅមួយដុំទៀត ដែលទាមទារការព្យាយាម និងភាពអត់ធ្មត់។ ម្យ៉ាងទៀត ថ្មមួយចំនួនបានបាត់បង់ និងខូចខាតធ្វើឱ្យពិបាកសម្គាល់។ ទោះបីយ៉ាងណា ក្រុមការងារបានខិតខំឱ្យស្វែងរកថ្មដើម្បីយកមកបំពេញនូវរចនាសម្ពន្ធខ្លោងទ្វារឱ្យរឹងមាំឡើងវិញ៕

អាជ្ញាធរជាតិអប្សរាសហការជាមួយក្រុមហ៊ុនមេនូឡាយហ្វ៍បន្តដាំកូនឈើក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៤ ក្រុមការងារអាជ្ញាធរជាតិអប្សរា សហការជាមួយក្រុមហ៊ុនមេនូឡាយហ្វ៍ បន្តដាំកូនឈើបន្ថែមទៀត នៅឧទ្យានសហគមន៍អង្គរមេនូឡាយហ្វ៍ នៅខាងជើងប្រាសាទប្រី ដែលស្ថិតនៅភូមិក្លូង់ ឃុំលាងដៃ ស្រុកអង្គរធំ។ ដើមឈើដែលបានដាំគឺប្រភេទឈើធ្នង់ សរុបចំនួន៣០ដើម៕

អាជ្ញាធរជាតិអប្សរា បន្តជួសជុលច្រាំងកសិន្ធុប្រាសាទអង្គរវត្ត ផ្នែកខាងជើងស្ពានហាលប្រវែង២០ម៉ែត្រ

ផ្សាយនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា ជួសជុលច្រាំងកសិន្ធុប្រាសាទអង្គរ ផ្នែកខាងជើងស្ពានហាលប្រវែងចំនួន២០ម៉ែត្រជាបន្តទៀត ក្នុងដំណាក់កាលទី៨ នៅឆ្នាំ២០២៤។ ការងារនេះ គ្រោងនឹងបញ្ចប់នៅដើមឆ្នាំ២០២៥ខាងមុខនេះ។

អ្នកស្រី នង បូរ៉ាវី មន្ត្រីបច្ចេកទេសគ្រប់គ្រងការដ្ឋានជួសជុល ច្រាំងកសិន្ធុប្រាសាទអង្គរវត្ត ឱ្យដឹងថា ស្ថានភាពច្រាំងកសិន្ធុប្រវែង២០ម៉ែត្រ ដែលត្រូវបន្តជួសជុលនេះ កាំជណ្ដើរថ្មភក់មួយចំនួនស្រុតធ្លាក់ចូលក្នុងកសិន្ធុ និងកប់ក្នុងភក់ នាំឱ្យខូចខាតប្រមាណ៦០ភាគរយ។

អ្នកជំនាញរូបនេះ បញ្ជាក់ថា ដំបូងគឺត្រូវធ្វើទំនប់ហើយបូមទឹកចេញ ធ្វើសម្រង់ប្លង់ សម្អាតកំណកដី ហើយលើកកាំជណ្ដើរថ្មភក់ មកលាងសម្អាត ចុះបញ្ជីថ្ម គូសប្លង់លម្អិតស្ថានភាពដុំថ្មនីមួយៗមុននឹងជួសជុលពង្រឹងថ្មដែលខូចខាត។ ជួសជុលពង្រឹងគ្រឹះ ហើយរៀបកាំជណ្ដើរថ្មបាយក្រៀមថ្មីចំនួន៧កាំ ជំនួសថ្មបាយក្រៀមចាស់ដែលខូចខាត។ បន្ទាប់មក រៀបកាំជណ្ដើរថ្មភក់ចំនួន៤កាំតាមលំនាំដើមឡើងវិញ។

អ្នកស្រី នង បូរ៉ាវី បន្ថែមថា ការដ្ឋានជួសជុលដែលស្ថិតនៅជាប់នឹងទឹកនេះ មានបញ្ហាប្រឈមមួយចំនួនត្រូវការពេលវេលា ការយកចិត្តទុកដាក់ អត់ធ្មត់ ការស្រឡាញ់ និងចង់ថែរក្សាមរតកដូនតា ដើម្បីឱ្យរឹងមាំគង់វង្សយូរអង្វែងបន្តទៀត។ មកដល់បច្ចុប្បន្ននេះ គិតទាំងនៅដំណាក់កាលទី៨នេះផង ការងារជួសជុលច្រាំងកសិន្ធុប្រាសាទអង្គរវត្ត ផ្នែកខាងជើងស្ពានហាលសរុបបានប្រវែងចំនួន១៦៣ម៉ែត្រហើយ៕



អាជ្ញាធរជាតិអប្សរា កំពុងជួសជុលកំពែងក្រុងអង្គរធំ ប្រវែង២៥ម៉ែត្រ ដែលខូចខាតឱ្យរឹងមាំឡើងវិញ

ផ្សាយនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៤

ក្រុមអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរា ចំណាយពេល៨ខែ ដើម្បីជួសជុលកំពែងធ្វើពីថ្មបាយក្រៀមរបស់ក្រុងអង្គរធំ ដែលស្ថិតនៅប៉ែកខាងជើង ខ្លោងទ្វារដីឆ្នាំង ប្រវែង២៥ម៉ែត្រ ធ្វើឱ្យរឹងមាំឡើងវិញ។

កំពែងរបស់ក្រុងអង្គរធំប្រវែង២៥ម៉ែត្រនេះ បានខូចខាតបណ្តាលមកពីអាយុកាលរបស់ថ្ម ព្រមទាំងកត្តាធម្មជាតិមួយចំនួនទៀតដូចជា ទឹកភ្លៀងហូរច្រោះ រុក្ខជាតិដុះចាក់ឫសធ្វើឱ្យថ្មរញែកចេញពីគ្នា ព្រមទាំងកង្វះការថែទាំធ្វើឱ្យថ្មជញ្ជាំងកំពែងពុកផុយហើយដួលរលំ។
លោក ម៉ៅ សុខនី មន្ត្រីបច្ចេកទេសរបស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា ឱ្យដឹងថា ការជួសជុលកំពែងក្រុងអង្គរធំពេលនេះ គឺត្រូវពង្រឹងគ្រឹះជើងក្រោមរបស់កំពែងចំនួន៣ស្រទាប់ ឱ្យបានរឹងមាំជាមុន រួចហើយរៀបជញ្ជាំងដែលខូចខាតទាំងអស់ឡើងវិញ។
នេះ គឺជាការជួសជុលកំពែងរបស់ក្រុងអង្គរធំដំណាក់កាលទី៦។ ជាច្រើនឆ្នាំមកនេះ ក្រុមអ្នកជំនាញធ្លាប់បានជួសជុលកំពែងរបស់ក្រុងអង្គរធំដែលសាងសង់ពីថ្មបាយក្រៀមចំនួន៥កន្លែងរួចមកហើយ។

ក្រុមអ្នកជំនាញផ្នែកជួសជុល ឱ្យដឹងទៀតថា នៅមុនពេលឈានដល់ការជួសជុលកំពែងក្រុងអង្គរធំប្រវែង២៥ម៉ែត្រនេះ គឺក្រុមអ្នកស្រាវជ្រាវបានធ្វើកំណាយ ដើម្បីសិក្សាពីរចនាសម្ពន្ធទាំងមូលរបស់កំពែង ដើម្បីឱ្យប្រាកដថា តើការដួលរលំរបស់កំពែងនេះបណ្តាលមកពីកត្តាអ្វី? តើនៅទីនេះធ្លាប់មានការជួសជុលពីមុនដែរឬទេ? បន្ទាប់មកទើបក្រុមការងារធ្វើការសម្អាត សិក្សាពីជើងគ្រឹះក្រោម ដើម្បីពង្រឹងគ្រឹះឡើងវិញ។

គម្រោងជួសជុលនេះ ក៏មានការត្រួតពិនិត្យបច្ចេកទេសពីគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់អង្គរសម្រាប់អង្គរហៅកាត់ថា អាយស៊ីស៊ីអង្គរ និងសំបូរព្រៃគុកផងដែរ៕

អាជ្ញាធរជាតិអប្សរា និងក្រុមហ៊ុន អ៊ីមមើស៊ីវ អង្គរ ចុះអនុស្សរណៈ នៃការយោគយល់គ្នា ស្តីពីការបង្កើត «សារមន្ទីរអ៊ីមមើស៊ីវ អង្គរ»

ផ្សាយនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៤

នាព្រឹកថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៤ អាជ្ញាធរជាតិអប្សរា និងក្រុមហ៊ុន អ៊ីមមើស៊ីវ អង្គរ បានចុះអនុស្សរណៈ នៃការយោគយល់គ្នា ដើម្បីបង្កើតសារមន្ទីរអ៊ីមមើស៊ីវ អង្គរ ដើម្បីបង្កើតបទពិសោធន៍ថ្មី ឬជាកញ្ចប់ទេសចរណ៍ថ្មី នៅក្នុងខេត្តសៀមរាប។

ឯកឧត្តមបណ្ឌិត ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ថា ភាពជាដៃគូនៃកិច្ចសហប្រតិបត្តិការនេះ ស្របតាមបេសកកម្មរបស់អាជ្ញាធរជាតិអប្សរា ក្នុងការថែរក្សា និងផ្សព្វផ្សាយរមណីយដ្ឋានអង្គរ។ គម្រោងកិច្ចសហប្រតិបត្តិការនេះដែរ នឹងជំរុញឱ្យភ្ញៀវទេសចរទទួលបានបទពិសោធន៍ថ្មីៗកាន់តែប្រសើរ និងរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងអភិរក្សបែបឌីជីថល ធ្វើឱ្យអង្គរជារូបតំណាងផ្នែកវប្បធម៌ពិភពលោកដ៏រឹងមាំ។ គម្រោងខាងលើនេះ អាជ្ញាធរជាតិអប្សរានឹងផ្តល់ ការណែនាំផ្នែកវិទ្យាសាស្ត្រ ដើម្បីធានាបាននូវភាពត្រឹមត្រូវនៃប្រវត្តិសាស្ត្រ និងបញ្ហារសើបផ្នែកវប្បធម៌ទន្ទឹមនឹងនោះ ក្រុមហ៊ុនអ៊ីមមើស៊ីវ អង្គរ នឹងអភិវឌ្ឍន៍ និងគ្រប់គ្រងសារមន្ទីរ។

លោក កែ ប៊ិន សូរស្មី នាយកប្រតិបត្តិក្រុមហ៊ុនអ៊ីមមើស៊ីវអង្គរ បានសង្កត់ធ្ងន់ថា កិច្ចសហប្រតិបត្តិការនេះ មានសារសំខាន់ណាស់សម្រាប់ចែករំលែកប្រវត្តិសាស្ត្រអង្គរតាមរយៈបច្ចេកវិទ្យាថ្មីៗ។ សារមន្ទីរអ៊ីមមើស៊ីវ អង្គរ នឹងផ្តល់ជូននូវការធ្វើដំណើរឆ្លងកាត់ពេលវេលា ធ្វើឱ្យអ្នកទស្សនាយល់ដឹងកាន់តែស៊ីជម្រៅអំពីបេតិកភណ្ឌវប្បធម៌របស់កម្ពុជាស្របពេលជាមួយគ្នានោះ ក៏ធានាបាននូវការអភិរក្សកេរដំណែលនៃបេតិកភណ្ឌវប្បធម៌។

សូមបញ្ជាក់ថា គម្រោងខាងលើនេះ មិនមែនផ្តល់តែបទពិសោធន៍បែបសារមន្ទីរប៉ុណ្ណោះទេ ប៉ុន្តែជាផ្នែកមួយនៃគំនិតផ្តួចផ្តើមនេះ គឺការស្កេនប្រាសាទទ្រង់ទ្រាយធំនឹងត្រូវបានធ្វើឡើង ដែលជាព្រឹត្តិការណ៍ដ៏សំខាន់មួយក្នុងការបង្កើតបណ្ណាល័យឌីជីថលអំពីប្រាសាទអង្គរ។ កិច្ចខិតខំប្រឹងប្រែងអភិរក្សបែបឌីជីថលនេះ ធានាបាននូវកេរដំណែលរបស់ប្រាសាទ សម្រាប់មនុស្សជំនាន់ក្រោយ៕





អបអរសាទរ ទិវាទេសចរណ៍ពិភពលោក

(World Tourism Day)

ក្រោមប្រធានបទ ៖ ទេសចរណ៍ និងសន្តិភាព

២៧ កញ្ញា ១៩៨០ ~ ២៧ កញ្ញា ២០២៤

ផ្សាយនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤

រូបភាពប្រចាំសប្តាហ៍៖
ប្រាសាទសួរព្រ័ត ឬខ្លះហៅថាប្រាសាទនាង១២ សាងសង់នៅចុងសតវត្សរ៍ទី១២

ផ្សាយនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៤

កូនឈើចម្រុះចំនួន៧,២០៦ដើម ត្រូវបានអាជ្ញាធរជាតិអប្សរា ចែកចាយពីថ្ងៃទី១៦ ដល់ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៤

- ប្រគេនកូនឈើចម្រុះជូនតំណាងព្រះអង្គ តាត មហាទី ព្រះគ្រូចៅអធិការវត្តឥន្ទបត្តបុរី ហៅវត្តអង្គរខាងជើង ចំនួន៦០០ដើម ដើម្បីយកទៅដាំនៅបរិវេណទួលបុរាណ ស្ថិតក្នុងភូមិតាឃើង ឃុំគំរូ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ កូនឈើទាំងនោះរួមមាន ធ្នង់៣០០ដើម និងដើមយាង ឬ ឈើទាល ៣០០ដើម។

- ប្រគេនកូនឈើចម្រុះជូនព្រះកិត្តិធម្មបាល ជុំ សុជី ព្រះគ្រូចៅអធិការវត្តទីពោ ចំនួន៨០០ដើម ដើម្បីយកទៅដាំនៅបរិវេណទីធ្លាវត្ត ស្ថិតក្នុងភូមិទីពោ ឃុំទីពោ ស្រុកសន្ទុក ខេត្តកំពង់ធំ។ កូនឈើទាំងនោះរួមមាន ធ្នង់១០០ដើម គ្រញូង៥០ដើម បេង៥០ដើម ឥន្ទនេល៥០ដើម ពុល៥០ដើម រំដួល៥០ដើម ក្រោកធំ៥០ដើម ក្រោកតូច៥០ដើម ផ្ដៀក១០០ដើម ពពេល១០០ដើម ត្រាច៥០ដើម និងកកោះ១០០ដើម។

- ផ្ដល់កូនឈើចម្រុះជូនតំណាងសភាយុវពាណិជ្ជករអន្តរជាតិ សាខាខេត្តសៀមរាប (JCI Siem Reap) ចំនួន១៦០ដើម ដើម្បីយកទៅដាំនៅភូមិមេជ្រៃ ឃុំពួក ស្រុកពួក ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន រាំងទឹក១០០ដើម ក្រោក២០ដើម រំដួល២០ដើម និងគគីរ២០ដើម។

- ផ្ដល់កូនឈើចម្រុះជូនលោក ម៉ៅ រតនា លោក ឆោម មករា និងលោក ស៊ង់ ម៉ាប់ ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន៩៧៩ដើម ដើម្បីយកទៅដាំលើដីផ្ទាល់ខ្លួន ស្ថិតនៅជើងភ្នំគូលែន នៅសង្កាត់ស្រង៉ែ និងសង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន បេង១២៥ដើម ធ្នង់១៨៥ដើម ប្រេស១៧០ដើម រំដួល៣០ដើម ឈើទាល១៥០ដើម កកោះ៥០ដើម ផ្ដៀក៥០ដើម និងគគីរ២១៩ដើម។

- ផ្តល់កូនឈើចម្រុះជូនលោក ហូ វ៉ាន់ណូ និងលោក ម៉ម គឹមយ៉ាន ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ ចំនួន២៥០ដើម ដើម្បីយកទៅដាំលើដីផ្ទាល់ខ្លួន ស្ថិតនៅភូមិជ្រោយនាងនួន ឃុំជ្រោយនាងនួន ស្រុកស្រីស្នំ ខេត្តសៀមរាប និងនៅបរិវេណអង្គភាពវរសេនាតូចថ្មើរជើងលេខ៥១៤ ក្នុងភូមិថ្មដែកកេះ ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ កូនឈើទាំងនោះរួមមាន បេង៣០ដើម គ្រញូង៣០ដើម ច្រេស៣០ដើម រំដួល៨០ដើម និងពុ្កល៨០ដើម។

- ផ្តល់កូនឈើចម្រុះ ចំនួន៣,៤១៧ដើម ដើម្បីយកទៅដាំបន្ថែមនៅបរិវេណផ្លូវដើរក្នុងព្រៃនៃសួនរុក្ខជាតិអង្គរ ខាងជើងស្ពានរ៉ាករ៉ាក ភូមិមណ្ឌល៣ នៅអតីតផ្សារយាងធំ និងបរិវេណឧទ្យានសហគមន៍អង្គរ មេនូឡាយហ្វ៍នៃរមណីយដ្ឋានអង្គរ។កូនឈើទាំងនោះរួមមាន ធ្នង់៩០០ដើម ច្រេស៤៣០ដើម បេង៣២០ដើម ឈើទាល៤០០ដើម គគីរ៤០០ដើម ត្រសេក៤០០ដើម រំដួល១០០ដើម ពុ្កល៥០ដើម អូញម៉ូញ៦៧ដើម ត្របែកព្រៃ១៥០ដើម និងឥន្ទ្រនេល២០០ដើម។

- ផ្តល់កូនឈើចម្រុះជូនតំណាងលោក ផុន ណារិន សាកលវិទ្យាធិការនៃសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រអេស៊ីលីដា ចំនួន១,០០០ដើម ដើម្បីយកទៅដាំលំអបន្ថែមក្នុងបរិវេណវិទ្យាស្ថាន ស្ថិតក្នុងភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ កូនឈើទាំងនោះរួមមាន គ្រញូង២០០ដើម ធ្នង់២០០ដើម បេង២០០ដើម គគីរ២០០ដើម រំដួល១០០ដើម និងផ្កាពុ្កល១០០ដើម។

រូបភាពប្រចាំសប្ដាហ៍៖
ប្រាសាទប្រែរូប
អមដោយវាលស្មៅខៀវស្រងាត់
ផ្សាយនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា បន្តសហការជាមួយក្រុមហ៊ុន អ៊ីអន (AEON) ដើម្បីដាំកូនឈើ នៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤ **ឯកឧត្តម បណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានជួបពិភាក្សាជាមួយលោកស្រីបណ្ឌិត យូរីកុ យ៉ាម៉ាម៉ូតូ (Dr. Yuriko Yamamoto) តំណាងក្រុមហ៊ុនអ៊ីអន (AEON) ដើម្បីពិនិត្យលទ្ធភាពបន្តកិច្ចសហការក្នុងការដាំកូនឈើបន្ថែម ក្នុងតំបន់រមណីយដ្ឋានអង្គរ នាពេលអនាគត។

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែតុលា

ភ្នាក់ងារទេសចរ រួមជាមួយនគរបាលទេសចរណ៍ ប្រចាំការនៅក្រុងអង្គរធំ និងបារាយណ៍ទឹកថ្លា ប្រគល់សម្ភារជូនភ្ញៀវដែលបានភ្លេច

ផ្សាយនៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២៤

នៅថ្ងៃទី០១ ខែតុលាឆ្នាំ២០២៤ នៅវេលាម៉ោង០៩ព្រឹក ក្រុមការងារប្រចាំការនៅគោលដៅក្រុងអង្គរធំ និងបារាយណ៍ទឹកថ្លា បានចូលរួមជាមួយកម្លាំងនគរបាលបេតិកភណ្ឌប៉ុស្តិ៍ការពារទី១០ និងកម្លាំងនគរបាលទេសចរណ៍ ធ្វើការប្រគល់កាតVisa ជូនទៅភ្ញៀវជនជាតិកូរ៉េ ដែលបានភ្លេចនៅត្រង់ចំណុចរួតទីមួយ មុខខាងកើតនៃប្រាសាទបាយ័ន៕

ទិដ្ឋភាពភ្ញៀវទេសចរដើរទស្សនា រមណីយដ្ឋានអង្គរ នាថ្ងៃទី២ ខែតុលា ដែលត្រូវនឹងបិណ្ឌទី១៥ នៃពិធីបុណ្យភ្ជុំបិណ្ឌ

ផ្សាយនៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៤

ការធ្វើដំណើរទស្សនារមណីយដ្ឋានអង្គរ របស់បងប្អូនប្រជាពលរដ្ឋខ្មែរ និងបរទេស ប្រកបដោយក្តីរីករាយ និងសណ្តាប់ធ្នាប់សាធារណៈដ៏ល្អប្រសើរ

ផ្សាយនៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៤

រូបភាពប្រចាំសប្តាហ៍៖ ប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៤

ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៤ ក្រុមការងារនាយកដ្ឋានសណ្ដាប់ធ្នាប់ នៃអាជ្ញាធរជាតិអប្សរា រៀបចំសម្អាតតាមដងផ្លូវនៅក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៤

រូបភាពប្រចាំសប្តាហ៍៖ ប្រាសាទធម្មនន្ទ

ផ្សាយនៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា និងទីភ្នាក់ងារបេតិកភណ្ឌកូរ៉េ រៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ប្រើប្រាស់បេតិកភណ្ឌវប្បធម៌

ផ្សាយនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៤ អាជ្ញាធរជាតិអប្សរា សហការជាមួយទីភ្នាក់ងារបេតិកភណ្ឌកូរ៉េ បានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពប្រើប្រាស់បេតិកភណ្ឌវប្បធម៌ ដោយផ្តោតលើការងារអភិរក្ស ការអភិវឌ្ឍន៍ផលិតផលទេសចរណ៍ និងការប្រើប្រាស់នូវបេតិកភណ្ឌវប្បធម៌។

ថ្លែងនាពិធីបើកវគ្គបណ្តុះបណ្តាលខាងលើដែលរៀបចំនៅនាយកដ្ឋានសណ្តាប់ធ្នាប់ នាព្រឹកថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៤ **ឯកឧត្តម ឡុង កុសល** អគ្គនាយករងអាជ្ញាធរជាតិអប្សរា បានបង្ហាញអារម្មណ៍សប្បាយក្តីរីករាយ និងអរគុណដល់ទីភ្នាក់ងារបេតិកភណ្ឌកូរ៉េ ដែលបានសហការរៀបចំវគ្គបណ្តុះបណ្តាលខាងលើ ដែលជាផ្នែកមួយសំខាន់ក្នុងការអភិរក្សប្រាសាទ ក៏ដូចជាជួយអភិវឌ្ឍន៍វិស័យទេសចរណ៍ក្នុងរមណីយដ្ឋានអង្គរ។ ឯកឧត្តមអគ្គនាយករង បានបន្ថែមថាវគ្គបណ្តុះបណ្តាលនេះ ជាផ្នែកមួយនៃគម្រោងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា និងទីភ្នាក់ងារបេតិកភណ្ឌកូរ៉េ លើការជួសជុលរួតបាកានប្រាសាទអង្គរវត្តផងដែរ។

តាមការបញ្ជាក់ពី**ឯកឧត្តម ឡុង កុសល** ក្រៅពីមន្ត្រីរាជការនៃស្ថាប័នរដ្ឋ ក្នុងនោះវគ្គបណ្ដុះបណ្ដាលនេះ ក៏មានវិស័យឯកជនចូលរួមផងដែរ ដូចជាអ្នកផលិតវត្ថុអនុស្សាវរីយ៍ សមាគមទេសចរណ៍ និងមគ្គុទ្ទេសក៍ទេសចរណ៍ជាដើម។ លោករំពឹងថា តាមរយៈវគ្គបណ្ដុះបណ្ដាលខាងលើនេះ សិក្ខាកាមនឹងទទួលបានចំណេះដឹង និងបទពិសោធន៍ពីអ្នកជំនាញបេតិកភណ្ឌកូរ៉េ ដើម្បីយកទៅអនុវត្តន៍នៅកន្លែងធ្វើការរបស់ខ្លួន ពិសេសអភិវឌ្ឍន៍លើផ្នែកអភិវឌ្ឍន៍ទេសចរណ៍ និងការកែច្នៃវត្ថុអនុស្សាវរីយ៍ដែលផ្ដោតលើបេតិកភណ្ឌ ធ្វើឱ្យសេដ្ឋកិច្ចនៅមូលដ្ឋាន កាន់តែរីកចម្រើនទៅមុខ។

លោក គីម ហ្យ៉ន់សង់ (KIM Hyunsung) តំណាងនៃទីភ្នាក់ងារបេតិកភណ្ឌកូរ៉េ មានក្ដីរីករាយជាពន់ពេក ដែលបានសហការរៀបចំវគ្គបណ្ដុះបណ្ដាលនេះឡើង។ ក្រៅពីវិស័យអភិរក្ស លោក គីម ពន្យល់ថា វគ្គបណ្ដុះបណ្ដាលនេះ ក៏ផ្ដោតលើការអភិវឌ្ឍន៍ផលិតផលទេសចរណ៍នៅមូលដ្ឋាន និងការប្រើប្រាស់នូវបេតិកភណ្ឌវប្បធម៌របស់កម្ពុជា ធ្វើយ៉ាងណា កែច្នៃវត្ថុ ឬសម្ភារនានាឱ្យមានគុណតម្លៃបែបវប្បធម៌ និងទាក់ទាញភ្ញៀវទេសចរ។ ក្នុងនាមទីភ្នាក់ងារបេតិកភណ្ឌកូរ៉េ លោក គីម ថានឹងបន្តកិច្ចសហប្រតិបត្តិផ្សេងៗទៀតដើម្បីការអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ។

គួរបញ្ជាក់ថា វគ្គបណ្ដុះបណ្ដាលខាងលើរៀបចំឡើងរយៈពេល៤ថ្ងៃ ចាប់ពីថ្ងៃទី៧ ដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤ ដោយមានការសិក្សាទាំងទ្រឹស្ដី និងចុះកម្មសិក្សានៅតាមភូមិបុរាណមួយចំនួនក្នុងរមណីយដ្ឋានអង្គរ រួមមានភូមិល្វា ភូមិរហាល ភូមិបង្កោង និងភូមិសំរោង៕

សេចក្ដីជូនដំណឹង ស្ដីពីការបិទជាបណ្ដោះអាសន្ន ផ្លូវចេញ-ចូលខាងត្បូង នៃច្រកខាងកើត ប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខៈ ៧៥៥០/អ.ជអ៧ណ
២៤

សេចក្ដីជូនដំណឹង
ស្ដីពី
ការបិទជាបណ្ដោះអាសន្នផ្លូវចេញ-ចូលខាងត្បូងនៃច្រកចូលខាងកើតប្រាសាទអង្គរវត្ត

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ មេត្តាជ្រាបថា ដើម្បីរៀបចំប្រព័ន្ធលូរំដោះទឹកនៅច្រកចូលខាងកើតប្រាសាទអង្គរវត្ត អាជ្ញាធរជាតិអប្សរានឹងបិទជាបណ្ដោះអាសន្នផ្លូវចេញ-ចូលខាងត្បូងនៃច្រកចូលខាងកើតប្រាសាទអង្គរវត្ត ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៤។ ក្នុងអំឡុងពេលនេះ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ អាចចេញ-ចូលទស្សនាប្រាសាទអង្គរវត្ត ពីច្រកខាងកើតតាមគំនូសបង្ហាញផ្លូវ ដូចមានជូនភ្ជាប់មកជាមួយ។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ៧កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
សៀមរាប ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២៤
អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋានៈ ភូមិបង្កោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

ទីតាំងបិទផ្លូវបណ្ដោះអាសន្ន

អាជ្ញាធរជាតិអប្សរា ធ្វើបទបង្ហាញស្តីពី ការគ្រប់គ្រងព្រៃឈើ និងជីវៈចម្រុះ នៅតំបន់រមណីយដ្ឋានអង្គរ ដល់និស្សិត វិទ្យាស្ថានជាតិកសិកម្ម ព្រែកលៀប

ផ្សាយនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤

នាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធរបស់អាជ្ញាជាតិអប្សរា ធ្វើបទបង្ហាញស្តីពី ការគ្រប់គ្រងព្រៃឈើ និងជីវៈចម្រុះនៅតំបន់រមណីយដ្ឋានអង្គរ ក្នុងគោលបំណងផ្សារភ្ជាប់ទ្រឹស្តីជាមួយការអនុវត្តជាក់ស្តែង ដើម្បីអភិវឌ្ឍចំណេះដឹង ដល់និស្សិតឆ្នាំទី២ សិក្សាលើផ្នែកជំនាញព្រៃឈើ និងជំនាញបរិស្ថាន នៃវិទ្យាស្ថានជាតិកសិកម្ម ព្រែកលៀប ចំនួន១៧នាក់ នាថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤ នៅទីស្នាក់ការកណ្តាលនៃអាជ្ញាធរជាតិអប្សរា។

បទបង្ហាញនេះ និស្សិតនឹងអាចសិក្សាស្វែងយល់ ព្រមទាំងទទួលបានចំណេះដឹងបន្ថែមពីអ្នកជំនាញអាជ្ញាធរជាតិអប្សរា ជុំវិញការគ្រប់គ្រងព្រៃឈើ និងជីវចម្រុះ។ ការគ្រប់គ្រងហានិភ័យដើមឈើក្នុងបរិវេណរមណីយដ្ឋានអង្គរ។ ស្ថានីយបណ្តុះកូនឈើ យុទ្ធនាការដាំ និងចែកចាយ។ ដោះលែងសត្វព្រៃនៅក្នុងរមណីយដ្ឋានអង្គរជាដើម៕

សិក្ខាកាម៣០នាក់បញ្ចប់ការសិក្សាវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពអភិវឌ្ឍន៍បេតិកភណ្ឌវប្បធម៌

ផ្សាយនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៤

បន្ទាប់ពីសិក្សាទាំងទ្រឹស្តី និងការចុះកម្មសិក្សាផ្ទាល់នៅតាមភូមិបុរាណមួយចំនួននៅខេត្តសៀមរាបរួចហើយ សរុប៣០នាក់ បានបញ្ចប់ការសិក្សាដោយជោគជ័យ ដោយរំពឹងថានឹងយកចំណេះដឹងដែលសិក្សារួច ទៅចូលរួមអភិវឌ្ឍន៍ផលិតផលបេតិកភណ្ឌវប្បធម៌របស់ខ្លួន ឱ្យកាន់តែមានភាពទាក់ទាញបន្ថែមទៀត។

ថ្លែងនាឱកាសបិទវគ្គបណ្តុះបណ្តាលនាថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤ **ឯកឧត្តម ឡុង កុសល** អគ្គនាយករងអាជ្ញាធរជាតិអប្សរា បានកោតសរសើរដល់វាគ្មិន ក៏ដូចជាសិក្ខាកាមទាំងអស់ ដែលប្រឹងប្រែងចែករំលែក និងសិក្សារហូតទទួលបានជោគជ័យ។ បន្ថែមពីនេះ ឯកឧត្តមអគ្គនាយករង ក៏បានកោតសរសើរចំពោះការប្តេជ្ញាចិត្តរបស់សិក្ខាកាម ក្នុងការយកចំណេះដឹងដែលរៀនបាន សម្រាប់ការចូលរួមអភិវឌ្ឍន៍វិស័យទេសចរណ៍ តាមរយៈការកែច្នៃសម្ភារផ្សេងៗចេញពីបេតិកភណ្ឌវប្បធម៌ផងដែរ។

ទោះបីមានរយៈពេល៤ថ្ងៃ **ឯកឧត្តម ឡុង កុសល** បានចាត់ទុកវគ្គបណ្តុះបណ្តាលនេះ ថាជាការចាប់ផ្តើមដាំដើមឈើ ហើយមិនយូរមិនឆាប់ ដើមឈើទាំងនោះនឹងចាក់ឫសបែកមែក និងមានផ្លែផ្កាជាមិនខាន។

លោកស្រី Jin Nara តំណាងគ្រូបង្គោលទាំង៤រូប នៃស្ថាប័នទីភ្នាក់ងារបេតិកភណ្ឌកូរ៉េ បានបង្ហាញក្តីរីករាយជាខ្លាំងដែលវគ្គបណ្តុះបណ្តាលខាងលើទទួលបានជោគជ័យ។ បន្ថែមពីនេះ លោកស្រីក៏សប្បាយចិត្តផងដែរ ដែលបានសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្រនៃរមណីយដ្ឋានអង្គរ បានឃើញភូមិបុរាណ និងទំនៀមទម្លាប់ការរស់នៅរបស់អ្នកភូមិនៅតំបន់រមណីយដ្ឋានអង្គរ។

ក្នុងនាមទីភ្នាក់ងារបេតិកភណ្ឌកូរ៉េ លោកស្រី Jin Nara ជឿជាក់ថា សិក្ខាកាមទាំងអស់នឹងយកចំណេះដឹងដែលរៀនបាន ទៅបង្កើតគំនិតច្នៃប្រឌិតថ្មីៗបន្ថែម តាមរយៈការបង្កើតវត្ថុអនុស្សាវរីយ៍ប្លែកៗ តូចៗ ទាក់ទាញការទិញពីភ្ញៀវទេសចរ។ បន្ថែមពីនេះ ត្រូវរកគំនិតដើម្បីបង្កើនគុណភាព និងការតុបតែងសិប្បកម្មនៅក្នុងសហគមន៍ជុំវិញ ដើម្បីឱ្យផលិតផលពួកគេកាន់តែមានតម្លៃបន្ថែម៕

ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិ ទស្សនានៅខ្លោងទ្វារទន្លេអុំ

ផ្សាយនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៤

រូបភាពប្រចាំសប្តាហ៍៖ ប្រាសាទបន្ទាយប្រី កសាងនៅចុងសតវត្សរ៍ទី១២

ផ្សាយនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៤

រូបភាពប្រចាំសប្តាហ៍៖ ប្រាសាទមេបុណ្យខាងកើត កសាងនៅសតវត្សរ៍ទី១០

ផ្សាយនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៤

ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិ ទស្សនាប្រាសាទអង្គរវត្ត នៅព្រឹកទី១៤ ខែតុលា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៤

ក្រុមអ្នកជំនាញអាជ្ញាធរជាតិអប្សរា កំពុងប្រឹងប្រែងលើកិច្ចការជួសជុលប្រាសាទនាគព័ន្ធ ឱ្យវិលទៅរកសោភ័ណភាពដើមឡើងវិញ

ផ្សាយនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៤

ក្រុមអ្នកជំនាញរបស់នាយកដ្ឋានអភិរក្សប្រាសាទ និង បុរាណវិទ្យា កំពុងប្រែងប្រែងលើការងារជាច្រើននៃគម្រោង ជួសជុលប្រាសាទនាគព័ន្ធ ដែលកំពុងរងការខូចខាត ឱ្យមានសភាពល្អប្រសើរឡើងវិញ។

បុរាណវិទូ លោក ជា សារិទ្ធ ឱ្យដឹងថា ក្រុមអ្នកជំនាញ កំពុងអនុវត្តន៍គម្រោងជួសជុលជណ្តើរខាងលិចនៃស្រះ ខាងកើត ជណ្តើរខាងត្បូងនៃស្រះខាងជើង ព្រមទាំង កម្រាលដែលនៅជុំវិញស្រះ។

ក្នុងឆ្នាំ២០២៤នេះ ក្នុងចំណោមគម្រោងដែលអ្នកជំនាញ បានជួសជុលជណ្តើរខាងលិចនៃស្រះខាងកើត ជណ្តើរ ខាងត្បូងនៃស្រះខាងជើង ព្រមទាំងកម្រាលដែលនៅជុំវិញ ស្រះនោះ គឺទើបតែបានបញ្ចប់មួយទីតាំងទេ។

រចនាសម្ពន្ធរបស់ប្រាសាទនាគព័ន្ធជាច្រើនកន្លែង កំពុង រងការខូចខាត ដោយសារតែកត្តាអាយុកាល គុណភាព សំណង់ កត្តាទឹកហូរច្រោះ និងរុក្ខជាតិដុះចាក់ឫស។

ដោយសារតែរចនាសម្ពន្ធជាច្រើនរបស់ប្រាសាទនាគព័ន្ធរងការខូចខាតជាច្រើន ធ្វើឱ្យក្រុមអ្នកអភិរក្សធ្លាប់ធ្វើការជួសជុលជាច្រើនសម័យកាលមកហើយដែរ។
ចាប់តាំងពីឆ្នាំ២០០៧-២០០៨ អាជ្ញាធរជាតិអប្សរាធ្លាប់បានស្តារបារាយណ៍ជ័យតដាកនៅនាគព័ន្ធឡើងវិញដើម្បីបញ្ចូលទឹកឱ្យដូចកាលពិសម័យបុរាណ។
ឆ្នាំ២០១០ អាជ្ញាធរជាតិអប្សរា ធ្លាប់បានធ្វើការសិក្សាស្រាវជ្រាវ និងធ្វើកំណាយនៅស្រះកណ្តាលរបស់ប្រាសាទនាគព័ន្ធ ដើម្បីសិក្សាពីរចនាសម្ពន្ធរបស់ស្រះកណ្តាល និងរចនាសម្ពន្ធរបស់ស្រះផ្សេងៗ ដែលនៅជុំវិញ។

ឆ្នាំ២០២១ អាជ្ញាធរជាតិអប្សរា បានចាប់ផ្តើមជួសជុលដំបូលបង្ហូរទឹកខាងត្បូងនិងជណ្តើរផ្នែកខាងជើងរបស់ស្រះខាងត្បូង ព្រមទាំងកម្រាលជុំវិញ។ ជាមួយគ្នានេះ ក្រុមអ្នកជំនាញក៏បានជួសជុលជណ្តើរថ្មបាយក្រៀម នៅផ្នែកខាងជើង ដែលគេហៅថាកំពង់ទូក។
នៅចន្លោះឆ្នាំ១៩៣៨-១៩៣៩ក្នុងសម័យបារាំងក៏ធ្លាប់មានការជួសជុលដំបូលបង្ហូរទឹកទាំង៤និងស្រះតូចៗព្រមទាំងតួប៉មកណ្តាលនៃប្រាសាទនាគព័ន្ធដែរ។
នៅអំឡុងឆ្នាំ១៩៥៦-១៩៥៧បារាំងក៏បានជួសជុលស្រះកណ្តាលនិងជណ្តើរថ្មបាយក្រៀមផងដែរ៕

សូមថ្វាយមហាព្រះរាជកុសល ខួបគម្រប់ ១២ឆ្នាំ នៃការយាងសោយព្រះទិវង្គត របស់ព្រះករុណា សម្ដេចព្រះនរោត្ដម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យបូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ (១៥ តុលា ឆ្នាំ២០១២ - ១៥ តុលា ឆ្នាំ២០២៤) នាថ្ងៃអង្គារ ១៣កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៤

ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ចូលរួមគោរពព្រះវិញ្ញាណក្ខន្ធ ថ្វាយព្រះរាជកុសលព្រះបរមរតនកោដ្ឋ គម្រប់ខួបសោយទិវង្គត១២ព្រះវស្សា

ផ្សាយនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៤

កាលពីព្រឹកថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៤ **ឯកឧត្តម គឹម សុធិន** អគ្គនាយករង តំណាង**ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា អមដំណើរដោយ ប្រធាននាយកដ្ឋាន និងមន្ត្រីបុគ្គលិក នៃអាជ្ញាធរជាតិអប្សរា បានចូលរួមគោរពព្រះវិញ្ញាណក្ខន្ធថ្វាយព្រះរាជកុសល ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ គម្រប់ខួបសោយទិវង្គត ១២ព្រះវស្សា នៅបរិវេណព្រះរាជដំណាក់ខេត្តសៀមរាប។

ក្នុងឱកាសដ៏ក្រៀមក្រំនេះ តាំងនាមឱ្យថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា សូមសម្តែងព្រះរាជមរណទុក្ខយ៉ាងក្រៀមក្រំបំផុត ចំពោះការយាងចូលទិវង្គតរបស់**សម្តេចតា សម្តេចតាទួត ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ និងបូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៃប្រជានុរាស្ត្រ ទូទាំងព្រះនគរ មហាទុក្ខសោកនៃប្រជាជាតិកម្ពុជា ១៥ តុលា ២០១២ ថ្ងៃដែលប្រជាជាតិកម្ពុជាមិនអាចបំភ្លេចបាន។

អាជ្ញាធរជាតិអប្សរា ចងចាំជានិច្ចនូវរាល់ស្នាព្រះហស្ត ព្រះរាជបូជនីយកិច្ច និងគុណូបការៈដ៏ធំធេងរបស់ព្រះអង្គ ដែលបានលះបង់ព្រះកាយពល ព្រះបញ្ញាញាណ ដើម្បីបូរណភាពទឹកដីកម្ពុជា ក៏ដូចជាព្រះរាជកិច្ចដាក់បញ្ចូលតំបន់អង្គរជាបេតិកភណ្ឌពិភពលោករហូតដល់សព្វថ្ងៃនេះ៕

អាជ្ញាធរជាតិអប្សរា អញ្ជើញសាធារណជនចូលរួមស្តាប់បាឋកថា ក្រោមប្រធានបទ«សមុច្ច័យរូបចម្លងពុម្ពអំពីម្នាងសិលានៅសារមន្ទីរ Guimet មានប្រភពមកពីប្រទេសកម្ពុជា» នាថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៤ វេលាម៉ោង៨:៣០នាទីព្រឹក នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ នៃទីស្នាក់ការអាជ្ញាធរជាតិអប្សរា ស្ថិតនៅភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប

វាគ្មិនកិត្តិយសដោយលោក សាន ច័ន្ទសុខា បរិញ្ញាបត្រជាន់ខ្ពស់ពីសាកលវិទ្យាល័យ Paris 1 Panthéon-Sorbonne ឆ្នាំ២០២២-២០២៣ និងជាមន្ត្រីបច្ចេកទេស របស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៤

លិខិតអញ្ជើញ

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមគោរពអញ្ជើញ ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រី-បុគ្គលិក នៃអាជ្ញាធរជាតិអប្សរា និងសាធារណៈជនទូទៅ មេត្តាអញ្ជើញចូលរួមស្តាប់ បាឋកថា

ក្រោមប្រធានបទ ៖ "**សមុច្ច័យរូបចម្លងពុម្ពអំពីម្នាងសិលានៅសារមន្ទីរ** Guimet **មានប្រភពមកពីប្រទេសកម្ពុជា**"

វាគ្មិន ៖ លោក សាន ច័ន្ទសុខា បរិញ្ញាបត្រជាន់ខ្ពស់ពីសាកលវិទ្យាល័យ Paris 1 Panthéon-Sorbonne ឆ្នាំ2022-2023 និងជាមន្ត្រីបច្ចេកទេស របស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា

នៅថ្ងៃព្រហស្បតិ៍ ១៥កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
ត្រូវនឹង ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៤ វេលាម៉ោង ០៨:៣០នាទី ព្រឹក
នៅអគារមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ នៃអាជ្ញាធរជាតិអប្សរា

កំណត់សម្គាល់ ៖ដើម្បីសម្រួលដល់ការរៀបចំ សូមមន្ត្រី-បុគ្គលិក អាជ្ញាធរជាតិអប្សរា និងសាធារណជនទូទៅ មេត្តាជូនដំណឹងអំពីការចូលរួម តាមលេខទូរស័ព្ទ/តេឡេក្រាម៖ ០១២ ៧៣៤ ៥២០ ឲ្យបាន០១ថ្ងៃមុន

អាសយដ្ឋាន៖ ភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរជាតិអប្សរាផ្តល់កូនឈើ៩០០ដើម ដល់រដ្ឋបាលស្រុកសូទ្រនិគម យកដាំតាមភូមិ និងតាមដងផ្លូវ

ផ្សាយនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរាកាលពីពេលថ្មីៗនេះ បានផ្តល់កូនឈើសរុបចំនួន ៩០០ដើម ជូនរដ្ឋបាលស្រុកសូទ្រនិគម ដែលស្នើសុំយកទៅដាំនៅតាមភូមិ និងដាំលម្អតាមដងផ្លូវដែលទើបសាងសង់ថ្មី ស្ថិតនៅភូមិសំរោងត្បូង ឃុំសំរោង ស្រុកសូទ្រនិគម ខេត្តសៀមរាប។ ដើមឈើដែលផ្តល់ជូនពេលនោះរួមមាន ដើមធ្នង់ ៣០០ដើម ដើមបេង ៣០០ដើម និងដើមគគីរ ៣០០ដើម៕

លិខិតគោរពជូនពររបស់ថ្នាក់ដឹកនាំ មន្រ្តី និងបុគ្គលិកគ្រប់លំដាប់ថ្នាក់ នៃអាជ្ញាធរជាតិអប្សរា គោរពជូន សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្រ្តី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសដ៏មហានក្ខត្តឫក្សថ្លៃថ្លា នៃពិធីចម្រើនជន្មាយុ គម្រប់៤៧ឆ្នាំ ឈានចូល ៤៨ឆ្នាំ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៤



អាជ្ញាធរជាតិអប្សរាបើកវគ្គបណ្តុះបណ្តាលស្តីពីៈ « ជំនាញអភិរក្ស និងសិក្សាវិភាគលើកុលាលភាជន៍ »ដល់មន្ត្រី បុគ្គលិកតាមនាយកដ្ឋានជំនាញ

ផ្សាយនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៤

សិក្ខាកាមចំនួន២០រូប ជាមន្ត្រី បុគ្គលិក នៃអាជ្ញាធរជាតិអប្សរា បានបញ្ចប់ដោយជោគជ័យ លើវគ្គបណ្តុះបណ្តាលស្តីពី៖ « ជំនាញអភិរក្ស និងសិក្សាវិភាគលើកុលាលភាជន៍ » ចំនួន៣ថ្ងៃ កាលពីពេលកន្លងទៅថ្មីៗនេះ។ វគ្គបណ្តុះបណ្តាលខាងលើ រៀបចំឡើងតាមរយៈនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ នៃអាជ្ញាធរជាតិអប្សរា ជូនដល់អ្នកដែលធ្វើការផ្នែកអភិរក្ស និងសិក្សាវិភាគលើកុលាលភាជន៍ មកពីនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ និងសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ។

គោលបំណងសំខាន់នៃវគ្គបណ្តុះបណ្តាលនេះ ដើម្បីផ្ទេរចំណេះដឹង និងជំនាញពាក់ព័ន្ធ នឹងមូលដ្ឋានគ្រឹះពិនិត្យដីភាជន៍ បច្ចេកទេសផលិតភាជន៍ ដុតភាជន៍ ពិនិត្យសីតុណ្ហភាព និងប្រភពព័រសើឡែន ព្រមទាំងការងារអភិរក្សមួយចំនួនទៀត ដែលទាក់ទងនិងបច្ចេកទេសអភិរក្សភាជន៍ជាដើម៕

ឯកឧត្តមបណ្ឌិត ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា ពិភាក្សាការងារជាមួយ អនុប្រធានសារមន្ទីរ Palace នៃប្រទេសចិន

ផ្សាយនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៤

ព្រឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៤ នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយក បានទទួលជួបពិភាក្សាការងារជាមួយលោក DU Haijiang អនុប្រធានសារមន្ទីរ Palace នៃប្រទេសចិន។ គោលបំណងសំខាន់នៃជំនួបខាងលើដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការនាពេលអនាគតជាមួយសារមន្ទីរដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា បង្កើនកិច្ចសហប្រតិបត្តិការវប្បធម៌រវាងចិន និងកម្ពុជា កាន់តែប្រសើរឡើងថែមទៀត៕

អាជ្ញាធរជាតិអប្សរា និងក្រុមហ៊ុន X Capital Investment ចុះអនុស្សរណៈយោគយល់គ្នា ដើម្បីជំរុញការផ្សព្វផ្សាយរមណីយដ្ឋានអង្គរទៅកាន់ទីផ្សារប្រទេសចិន

ផ្សាយនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៤

នារសៀលថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៤ អាជ្ញាធរជាតិអប្សរា និងក្រុមហ៊ុន X Capital បានចុះអនុស្សរណៈយោគយល់គ្នា ដើម្បីជំរុញការផ្សព្វផ្សាយគោលដៅរមណីយដ្ឋានអង្គរ ទៅកាន់ទីផ្សារប្រទេសចិនឱ្យបានកាន់តែទូលំទូលាយ។ ពិធីចុះអនុស្សរណៈយោគយល់នេះធ្វើឡើង ក្រោមវត្តមាន **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា និងលោកស្រី អៀ សុភា អភិបាលក្រុមហ៊ុន X Capital Investment ដោយមានតំណាងស្ថាប័នពាក់ព័ន្ធជាច្រើនរូបទៀតចូលរួមផងដែរ។

ឯកឧត្តមបណ្ឌិត ហង់ ពៅ បានសម្ដែងនូវក្ដីសោមនស្សរីករាយ និងថាអាជ្ញាធរជាតិអប្សរា បានត្រៀមក្នុងកិច្ចសហការនានាជាមួយក្រុមហ៊ុន X Capital ដើម្បីជំរុញការផ្សព្វផ្សាយរមណីយដ្ឋានអង្គរ ទៅភ្ញៀវទេសចរចិនស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ឯកឧត្តមក៏បានលើកឡើងពីកិច្ចខិតខំប្រឹងប្រែងនាពេលកន្លងមក ដែលអាជ្ញាធរជាតិអប្សរាបានធ្វើទាំងលើការងារអភិរក្ស និងអភិវឌ្ឍន៍ ក៏ដូចជាការផ្សព្វផ្សាយរមណីយដ្ឋានអង្គរឱ្យមាននិរន្តរភាព និងគង់វង្សតទៅអ្នកជំនាន់ក្រោយ។



លោកស្រី អៀ សុភា អភិបាលក្រុមហ៊ុន X Capital បានលើកឡើងពីការប្ដេជ្ញាចិត្តរបស់ក្រុមហ៊ុននិងប្រឹងប្រែងលើការជំរុញការផ្សព្វផ្សាយនេះឱ្យបានល្អ ក្នុងនោះមានការផលិតវីដេអូឯកសារ រួមនឹងការតាំងពិព័រណ៍ផ្សេងៗ ក្នុងន័យទាក់ទាញទេសចរចិនមកកាន់តំបន់រមណីយដ្ឋានអង្គរ ក៏ដូចជាប្រទេសកម្ពុជា ឱ្យបានកាន់តែច្រើន។ បន្ថែមពីនេះ លោកស្រីអភិបាលក្រុមហ៊ុន ក៏នឹងបន្តកិច្ចសហការយ៉ាងជិតស្និទ្ធ ជាមួយអ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរា មុននឹងផលិតវីដេអូ ឬការផ្សព្វផ្សាយនានា ដើម្បីឱ្យការផលិតស្របតាមគោលនយោបាយផ្សព្វផ្សាយពីតំបន់បេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ៕

រសៀលថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៤ ក្រុមឆ្មាំការពារទេសចរបានប្រទះឃើញទូរស័ព្ទដៃមួយគ្រឿង ដែលភ្ញៀវបានភ្លេច ឬជ្រុះនៅចំណុចរួត១នៃប្រាសាទអង្គរវត្ត និងបានប្រគល់ជូនម្ចាស់ដើម ដែលជាភ្ញៀវទេសចរជនជាតិអេស្ប៉ាញ ក្រោយពីពិនិត្យឃើញថា ពិតជាទូរស័ព្ទដៃរបស់គាត់ពិតប្រាកដមែន

ផ្សាយនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា បន្តការជួសជុលជណ្ដើរប្រាសាទបាទជុំ

ផ្សាយនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៤

បន្ទាប់ពីបញ្ចប់ការជួសជុលពង្រឹងប្រាង្គកណ្ដាលតួកណ្ដាលរបស់ប្រាសាទបាទជុំ ក្រុមអ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរាបន្តការងារជួសជុលជណ្ដើរ នៅទិសខាងកើត ដែលមានស្ថានភាពខូចខាតដោយហែកចេញពីគ្នា និងផ្នែកខ្លះនៃសំណង់របស់រចនាសម្ពន្ធជណ្ដើរមិនមានស្ថិរភាពជាដើម។

វិស្វករ និងអ្នកគ្រប់គ្រងការដ្ឋានជួសជុលប្រាសាទបាទជុំ កញ្ញា ដយ ពេជ្រដឺរ៉ា ឱ្យដឹងថា ការខូចខាតរចនាសម្ពន្ធជណ្ដើរនេះគឺបណ្ដាលមកពីអាយុសម្ភារសំណង់ថ្មបាយក្រៀមពុកផុយ កង្វះការថែទាំយូរអង្វែងបណ្ដាលឱ្យដើមឈើដុះចាក់ឫសញែកថ្ម។ ទីតាំងផ្នែកជណ្ដើរនេះ ធ្លាប់បានជួសជុលនៅសម័យបារាំង។ ប៉ុន្តែ ដោយសារអាយុកាល និងវិវត្តជាច្រើនឆ្នាំកន្លងមក បានធ្វើឱ្យរចនាសម្ពន្ធជណ្ដើរនេះបានរងការខូចខាតជាថ្មី។

អ្នកជំនាញដដែលបញ្ជាក់ថា ការជួសជុល គឺក្រុមការងារបានវិភាគទៅលើចំណុចខូចខាតមួយចំនួនដែលជាផ្នែកត្រូវរុះរើ និងជួសជុលឡើងវិញ។ បន្ទាប់មកចុះបញ្ជីថ្ម និងរុះរើថ្មដែលហែកចេញពីគ្នា សម្អាតកំណកដី ឬសឈើព្រមទាំងពង្រឹងថ្មដែលបែកបាក់ឬខូចខាត ហើយទើបរៀបផ្គុំទៅតាមទីតាំងដើមនៃរចនាសម្ពន្ធកាំជណ្ដើរឡើងវិញ។ កិច្ចការនេះ គ្រោងនឹងបញ្ចប់នៅដំណាច់ខែតុលា ឆ្នាំ២០២៤ ខាងមុខ។

ក្រោយពីបញ្ចប់ការជួសជុល ទីតាំងនេះនឹងមានសុវត្ថិភាពទាំងរចនាសម្ពន្ធសំណង់ជណ្ដើរ ស្ថិតនៅគង់វង្សយូរអង្វែងបន្តទៀត និងសម្រួលដល់ភ្ញៀវទេសចរដើរឡើង-ចុះ ដើម្បីទស្សនានៅប្រាសាទបាទជុំនេះផង៕

រសៀលថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៤ ក្រុមការងារភ្នាក់ងារទេសចរ គោលដៅប្រាសាទអង្គរវត្ត បានប្រទះឃើញទូរស័ព្ទដៃមួយគ្រឿង ដែលភ្ញៀវទេសចរភ្លេចឬជ្រុះ នៅចំណុចខាងជើងស្ពានបណ្តោតទឹក ទិសខាងលិច នៃច្រាំងកសិន្ធុ ប្រាសាទអង្គរវត្ត និងបានសហការ ជាមួយនគរបាលទេសចរណ៍ ប្រគល់ជូនម្ចាស់ដើមដែលជាភ្ញៀវទេសចរ ជនជាតិអាមេរិក ក្រោយពីពិនិត្យឃើញថា ពិតជាទូរស័ព្ទដៃរបស់គាត់ពិតប្រាកដមែន

ផ្សាយនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៤

សកម្មភាពក្រុមការងារពិនិត្យ និងតាមដានការសាងសង់ក្រោយទទួលបានការអនុញ្ញាត ជួសជុលផ្ទះប្រជាពលរដ្ឋក្នុងរមណីដ្ឋានអង្គរ ក្នុងសប្តាហ៍ទី៣ នៃខែតុលា

ផ្សាយនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៤

ប្រជាពលរដ្ឋដែលរស់នៅក្នុងរមណីយដ្ឋានអង្គរពីយូរមកហើយ ត្រូវបានទទួលការអនុញ្ញាតសាងសង់សំណង់នានាស្របតាមគោលការណ៍ច្បាប់ និងការងារជួសជុលតូចតាច (ដោយក្រុមការងារសហគមន៍)។ រាល់សំណង់នានាដែលនៅមានសុពលភាព ត្រូវបាននាយកដ្ឋានគ្រប់ គ្រងដីធ្លីបេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា បានចុះទៅពិនិត្យ និងផ្តល់នូវលក្ខណៈបច្ចេកទេស ដោយពុំគិតប្រាក់កម្រៃជាប្រចាំ រហូតសំណង់ទាំង នោះសង់រួចរាល់មួយរយភាគរយ។

ជាក់ស្តែងក្នុងសប្តាហ៍ទី៣ នៃខែតុលា ឆ្នាំ២០២៤ នេះ មន្ត្រី-បុគ្គលិកជំនាញ បានចុះពិនិត្យ និងផ្តល់លក្ខណៈបច្ចេកទេសនូវសំណង់ដែលបានការអនុញ្ញាត កន្លងមកចំនួន ៣៥ករណី និងការជួសជុលតូចតាចដោយក្រុមការងារសហគមន៍ ចំនួន ៦៩ករណី ដែលស្ថិតក្នុងភូមិសាស្ត្រ ដូចខាងក្រោម៖

១. ក្រុងសៀមរាបចំនួន ២៥ករណី
២. ស្រុកបន្ទាយស្រីចំនួន ៣០ករណី
៣. ស្រុកពួកចំនួន ២៣ករណី
៤. ស្រុកអង្គរធំចំនួន ២៤ករណី
៥. ក្រុងរុនតាឯកតេជោសែន ០២ករណី

សូមបញ្ជាក់ជូនផងដែរថា សំណង់ដែលទទួលបានការអនុញ្ញាតចំនួន ១០៤ករណី នេះមាន ៨៤ករណី កំពុងតែជួសជុលត្រឹមត្រូវតាមការអនុញ្ញាត និងមាន ២០ករណី មិនទាន់ជួសជុល។

ក្នុងចំណោមសំណង់ទាំង ៨៤ករណី ដែលកំពុងតែជួសជុលត្រឹមត្រូវ មានសំណង់ដែលបាន ជួសជុលរួចរាល់ជាស្ថាបពរចំនួន១៧ករណី និងសំណង់ដែលសង់ពុំទាន់រួចរាល់ តែហួសសុពលភាពមានចំនួន ០៦ករណី។ ក្រុមការងារបច្ចេកទេស និងបន្តតាមដានការសាងសង់ និងជួសជុលរហូតដល់ការ អនុញ្ញាតផុតសុពលភាព និងការសាងសង់រួចរាល់មួយរយភាគរយ៕

សាស្ត្រាចារ្យ និងនិស្សិត មកពីវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ធ្វើទស្សនកិច្ចសិក្សា នៅតំបន់រមណីយដ្ឋានអង្គរ ដើម្បីស្វែងយល់អំពីសាវតា និងកិច្ចការអភិរក្សមួយចំនួន

ផ្សាយនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៤

សាស្ត្រាចារ្យ និងនិស្សិត ចំនួន១២៦នាក់ មកពីវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា បានធ្វើទស្សនកិច្ចសិក្សានៅតំបន់រមណីយដ្ឋានអង្គរ និងសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ក្នុងគោលបំណងស្វែងយល់អំពីសាវតា បទពិសោធន៍ នៃការប្រើប្រាស់បច្ចេកវិទ្យា សម្រាប់ការងារអភិរក្សប្រាសាទ និងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ក្នុងតំបន់រមណីយដ្ឋានអង្គរ ព្រមទាំងទទួលយកចំណេះដឹងបន្ថែម ពីអ្នកជំនាញអាជ្ញាធរជាតិអប្សរា។ ដំណើរទស្សនកិច្ចខាងលើ ប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៤។ ជាមួយគ្នានេះ អាជ្ញាធរជាតិអប្សរា ក៏បានជួយសម្របសម្រួលដល់ដំណើរទស្សនកិច្ចរបស់សាស្ត្រាចារ្យ និងនិស្សិតវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ព្រមជាមួយការធ្វើបទបង្ហាញលើប្រធានបទ មួយចំនួន ដើម្បីជាចំណេះដឹងបន្ថែមផងដែរ៕

ចម្លាក់បដិមាទ្វារបាល រកឃើញនៅខ្លោងទ្វារខាងជើង ព្រះបរមរាជវាំង នៃក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៤

ចម្លាក់បដិមាទ្វារបាល ចំនួន១២ ធ្វើពីថ្មភក់ ត្រូវបានក្រុមបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា សហការជាមួយក្រុមការងាររដ្ឋាភិបាលចិន-កម្ពុជា ដើម្បីថែរក្សារមណីយដ្ឋានអង្គរ(CCSA) ប្រទះឃើញពេលធ្វើកំណាយស្រាវជ្រាវនៅខ្លោងទ្វារខាងជើង ជ្រុងខាងលិចនៃព្រះបរមរាជវាំង នៃក្រុងអង្គរធំ កាលពីថ្មីៗនេះ។

បុរាណវិទ្យា លោក សន ចាន់ថន បានឱ្យដឹងថា ចម្លាក់ទ្វារបាលធ្វើពីថ្មភក់ចំនួន១២ ត្រូវបានក្រុមអ្នកបុរាណវិទ្យា ធ្វើកំណាយស្រាវជ្រាវនៅខ្លោងទ្វារខាងជើងព្រះបរមរាជវាំងនៃក្រុងអង្គរធំ ដើម្បីសិក្សាស្រាវជ្រាវរចនាសម្ពន្ធនៃខ្លោងទ្វារ និងស្វែងរកថ្មដែលជ្រុះធ្លាក់ដើម្បីជួសជុលខ្លោងទ្វារនេះឡើងវិញ។

បុរាណវិទ្យារូបនេះ ឱ្យដឹងទៀតថាចម្លាក់បដិមាទ្វារបាលទី១២ដែលទើបរកឃើញនេះស្ថិតនៅក្នុងដីជម្រៅ១៤០សង់ទីម៉ែត្រ គឺស្រទាប់ដីគ្រឹះសម័យកាលកសាង គឺអាចថា ចម្លាក់នេះ បានធ្លាក់អស់រយៈពេលជាយូរមកហើយ។ ចម្លាក់បដិមាទ្វារបាលទាំង១២ ដែលមួយចំនួនធ្លាក់នៅរាយប៉ាយលើដីក្បែរខ្លោងទ្វារ គឺមានទំហំ និងទម្រង់ខុសៗគ្នាទៅតាមជាន់នីមួយៗ។ លោក ចាន់ថន បញ្ជាក់ថា ចម្លាក់ទ្វារបាលនៅជាន់ទី១ មានកម្ពស់១១០សង់ទីម៉ែត្រ និងជាន់ទី២ មានកម្ពស់១០០សង់ទីម៉ែត្រ មួយចំនួននៅមានរូបរាងនៅលល្អពេញលេញ ខ្លះទៀត ខូចខាតដោយអន្លើ ដោយសារធ្លាក់ពីកម្ពស់ខ្ពស់។ ចំណែករូបចម្លាក់ទ្វារបាលនីមួយៗមានលម្អគ្រឿងអលង្ការ សក់ ផ្ទៃមុខខុសៗគ្នា។

ក្រោយពីបានរកឃើញចម្លាក់ទ្វារបាលទាំងអស់នេះ ក្រុមការងារបានកំណត់ទីតាំងដើម ចុះបញ្ជី ថតរូប រៀបចំឯកសារមុនឈានដល់ការលើកមកសម្អាត និងជួសជុល ដើម្បីយកទៅដាក់នៅទីតាំងដើម។ ក្រុមអ្នកជំនាញសន្និដ្ឋានថា ចម្លាក់បដិមាទ្វារបាល ដែលប្រទះឃើញ គឺស្ថិតក្នុងរចនាប័ទ្មឃ្លាំង ដែលស្របពេលជាមួយគ្នានៃការកសាងព្រះបរមរាជវាំង ស្ថិតនៅសតវត្សរ៍ទី១១៕

សារថ្វាយព្រះពររបស់ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំទាំងអស់ នៃអាជ្ញាធរជាតិអប្សរា ក្រាបបង្គំទូលថ្វាយព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសព្រះរាជពិធីគម្រប់ខួបលើកទី២០ព្រះវស្សា នៃការយាងគ្រងព្រះបរមសិរីរាជសម្បត្តិ (២៩ តុលា ២០០៤ - ២៩ តុលា ២០២៤)

ផ្សាយនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សារលិខិតថ្វាយព្រះពរ

អាជ្ញាធរជាតិអប្សរា សហការចូលរួមជាមួយ សមាគមសិល្បករខ្មែរ ក្នុងការរៀបចំកម្មវិធី ស្នាមញញឹមនៃកម្ពុជា លើកទី២

ផ្សាយនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា សហការចូលរួមជាមួយសមាគមសិល្បករខ្មែរ ក្នុងការរៀបចំកម្មវិធី ស្នាមញញឹមនៃកម្ពុជា លើកទី២ ដើម្បីផ្សព្វផ្សាយវប្បធម៌ដល់ទេសចរណ៍ និងទាក់ទាញភ្ញៀវទេសចរអន្តរជាតិមកទស្សនារមណីយដ្ឋានអង្គរ និងរមណីយដ្ឋានសំខាន់ៗទូទាំងប្រទេស។ ពិធីនេះនឹងរៀបចំនៅខាងមុខប្រាសាទអង្គរវត្ត រយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី២៩-៣០ ខែតុលា ឆ្នាំ២០២៤ ដែលត្រូវនឹងថ្ងៃខួបលើកទី២០ នៃព្រះរាជពិធីគ្រងព្រះបរមរាជសម្បត្តិរបស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

សម្រាប់កម្មវិធីនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៤ នឹងមានការរៀបចំនូវសកម្មភាពមួយចំនួនដូចជា ពិធីបើកព្រឹត្តិការណ៍ ការតាំងពិព័រណ៍ម្ហូបអាហារ និងវត្ថុអនុស្សាវរីយ៍ស្នាដៃសិល្បៈខ្មែរ កម្មវិធីកម្សាន្តជាមួយចម្រៀង ប្រពៃណីខ្មែរ ពិធីដង្ហែក្បួនព្រះមហាក្សត្រខ្មែរ នាសម័យអាណាចក្រអង្គរ (នៅក្នុងបរិវេណប្រាសាទអង្គរវត្ត)។

ចំណែកថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៤ នឹងរៀបចំតាំងបង្ហាញពីពិព័រណ៍ម្ហូបអាហារខ្មែរ ការកម្សាន្តជាមួយនិងសិល្បៈចម្រៀងចម្រុះ ការប្រកួតទីងមោង។

ចំពោះភ្ញៀវជាតិ ដែលស្លៀកសំលៀកបំពាក់ប្រពៃណីខ្មែរ និងភ្ញៀវទេសចរបរទេស ដែលចូលរួមនឹងទទួលបានការពិសាអាហារ និងភេសជ្ជៈ ដោយឥតគិតថ្លៃ៕

លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា ចូលរួមក្នុងពិធីបើកព្រឹត្តិការណ៍ស្នាមញញឹមនៃកម្ពុជា លើកទី២

ផ្សាយនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៤

នាព្រឹកថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៤នេះ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាតំណាងដ៏ខ្ពង់ខ្ពស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចូលរួមជាអធិបតីភាព ក្នុងពិធីបើកព្រឹត្តិការណ៍ស្នាមញញឹម នៃកម្ពុជា លើកទី២ ដែលប្រព្រឹត្តិទៅនៅបរិវេណខាងមុខប្រាសាទអង្គរវត្ត។ កម្មវិធីនេះ ក៏មានការចូលរួមពីថ្នាក់ដឹកនាំខេត្ត អាជ្ញាធរជាតិអប្សរា សមាគមសិល្បករខ្មែរ មន្ត្រី និងសិល្បករ សិល្បការិនី និងប្រជាពលរដ្ឋជាច្រើនរយនាក់។

មានប្រសាសន៍នាពិធីនៅពេលនោះ **លោកជំទាវ ភឿង សកុណា** បានវាយតម្លៃខ្ពស់ចំពោះការរៀបចំព្រឹត្តិការណ៍ស្នាមញញឹមនៃកម្ពុជា លើកទី២នេះ ហើយដោយមានការសហការសម្របសម្រួលពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ស្ថាប័នពាក់ព័ន្ធជាច្រើនទៀត ធ្វើឱ្យព្រឹត្តិការណ៍ខាងលើកាន់រស់រវើក និងទាក់ទាញ។ ក្រៅពីនេះ លោកជំទាវរដ្ឋមន្ត្រី ក៏បានកោតសរសើរ និងថ្លែងអំណរគុណដល់ស្ថាប័នជាដៃគូចូលរួម និងឧបត្ថម្ភ ដែលតែងតែគាំទ្រវាល់ព្រឹត្តិការណ៍ទាក់ទងនឹងវប្បធម៌ និងសិល្បៈខ្មែរ ដើម្បីរួមចំណែកលើកតម្កើង និងផ្សព្វផ្សាយ វប្បធម៌ ប្រពៃណី ដែលជាមរតកប្រពៃណីជាតិនេះទៅកាន់សាធារណជន និងភ្ញៀវទេសចរឱ្យបានកាន់តែទូលំទូលាយបន្ថែម។

ចំពោះការតាំងបង្ហាញមុខម្ហូបអាហារខ្មែរវិញ លោកជំទាវរដ្ឋមន្ត្រីយល់ថា ម្ហូបអាហារមានតម្លៃណាស់ ដែលបង្ហាញពីវប្បធម៌ប្រពៃណី និងទំនៀមទម្លាប់នៃការរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ ដែលមានប្រវត្តិដ៏យូរលង់មកហើយ។

សូមបញ្ជាក់ថា ព្រឹត្តិការណ៍ស្នាមញញឹមនៃកម្ពុជា លើកទី២ នេះមានការតាំងបង្ហាញនូវម្ហូបអាហារ ស្តង់ពិព័រណ៍ ការសម្តែងសិល្បៈចម្រុះបែប។ល។ នៅរសៀលថ្ងៃទី២៩ ខែតុលានេះ ក៏មានកម្មវិធីក្បួនដង្ហែព្រះមហាក្សត្រនៅសម័យអង្គរ ដែលរៀបចំនៅបរិវេណខាងក្នុងប្រាសាទអង្គរវត្ត៕

អាជ្ញាធរជាតិអប្សរា មមាញឹកដឹកជញ្ជូនថ្មភក់ថ្មី ដើម្បីជួសជុលបណ្ណាល័យខាងត្បូង នៅរួតទី២ប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤

ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា មមាញឹកដឹកជញ្ជូនថ្មភក់ថ្មីចំនួនប្រមាណជាង៦០ដុំ ដើម្បីយកទៅជួសជុលបណ្ណាល័យខាងត្បូង នៅរួតទី២នៃប្រាសាទអង្គរវត្ត។ ថ្មភក់១ដុំៗ មានទម្ងន់ចាប់ពីជាង៩០គីឡូក្រាមរហូតទៅដល់ជាង២តោននេះ និងមានប្រវែងជាង៣ម៉ែត្រផងគឺប្រើឧបករណ៍កៅឡាក់លើកដាក់លើរន្ទាឡេរី ហើយអូសឆ្លងកាត់ថៃវទី១និងទី២ នៅទិសខាងកើតនៃប្រាសាទអង្គរវត្ត។ បន្ទាប់មកលើកដាក់រទេះអូសចម្ងាយជាង១០០ម៉ែត្រថែមទៀត ទើបដល់ការដ្ឋានជួសជុលស្ថិតនៅខាងលិចរួតបាកាន្ត។

លោក យាម មុនី ស្ថាបត្យករ និងគ្រប់គ្រងការដ្ឋានជួសជុលបណ្ណាល័យខាងត្បូង រួតទី២ប្រាសាទអង្គរវត្តឱ្យដឹងថា ការងារជួសជុលរចនាសម្ពន្ធបណ្ណាល័យ និងស្ពានហាលបណ្ណាល័យ ត្រូវការថ្មភក់ថ្មីចំនួន៦៥ដុំ ដើម្បីបំពេញបន្ថែមនៅតាមទីតាំងចាំបាច់មួយចំនួនដែលថ្មចាស់បានបាត់ និងខូចខាត ស្របតាមអនុសាសន៍របស់គណៈកម្មាធិការអោយស៊ីស៊ី-អង្គរ។ អ្នកជំនាញរូបនេះ បញ្ជាក់ថា ទីតាំងដែលត្រូវជំនួសថ្មថ្មីទាំងនោះ មានសសរស្ពានហាលនៃបណ្ណាល័យ ថ្មក្រាលស្ពានហាលថ្មជើងទម្របង្កាន់ដៃនាគ ថ្មបង្កាន់ដៃនាគ ថ្មក្រាលបណ្ណាល័យ ថ្មសម្រាប់តភ្ជាប់និងសសរ ថ្មសសរពេជ្រ ថ្មទម្រសសរពេជ្រជាដើម។

ដើម្បីអាចដឹកជញ្ជូនថ្មដែលមានទម្ងន់ធ្ងន់ទាំងនោះ ទៅដល់ទីតាំងការដ្ឋានជួសជុលបាន គឺក្រុមការងារបានខិតខំយកចិត្តទុកដាក់ ត្រូវចំណាយពេលប្រមាណជាង២ខែ រៀបចំធ្វើរន្ទារឡូរីនៅរួតទី១ និងទី២ ប្រវែងជាង៦០ម៉ែត្រ ព្រមទាំងដំឡើងកៅឡាក់សម្រាប់លើកថ្មផង ព្រោះការលើកដាក់ថ្មពីរួតទី១ ឡើងមករួតទី២ មានកម្ពស់ប្រមាណ១២ម៉ែត្រ។ ចំណែកថ្មទាំង៦៥ដុំ ត្រូវយកមកជួសជុល បានដឹកជញ្ជូនតាមរថយន្តមកដាក់នៅច្រកចូលខាងកើតរួតទី១ដើម្បីឱ្យក្រុមការងារលើកម្តងមួយដុំៗ តាមបច្ចេកទេស ដែលបានរៀបចំ។

សូមបញ្ជាក់ថា ការងារដឹកជញ្ជូនថ្មសម្រាប់ជួសជុលបណ្ណាល័យខាងត្បូង នៅរួតទី២នៃប្រាសាទអង្គរវត្តចាប់ផ្តើមតាំងពីដើមខែតុលា គ្រោងនឹងបញ្ចប់នៅចុងខែតុលានេះ៕

សប្ដាហ៍ទី៣ នៃខែតុលា ឆ្នាំ២០២៤ ក្រុមការងារសហគមន៍ បន្តចុះពិនិត្យសំណើពលរដ្ឋនៅក្នុងរមណីយដ្ឋានអង្គរ បានចំនួន៤២ករណី និងសម្រេចអនុញ្ញាត បានចំនួន ៣៤ករណី

ផ្សាយនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤

ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងរមណីយដ្ឋានអង្គរត្រូវបានទទួលនូវការយកចិត្តទុកដាក់អំពីសំណាក់អាជ្ញាធរជាតិអប្សរា ដោយមានការអនុគ្រោះក្នុងការជួសជុលតូចតាចនូវលំនៅដ្ឋានក៏ដូចជាសំណង់ឧប្បសម្ព័ន្ធមាន របង ដំបូល ជញ្ជាំង សសរពុកផុយ បង្គន់អនាម័យ រោងគោ ទ្រុងមាន់ និងទ្រុងជ្រូកជាដើម ហើយរាល់ការអនុញ្ញាតជួសជុលមានសុពលភាពត្រឹមពីរខែ នៅលើទីតាំងកំពុងរស់នៅផ្ទាល់ តែម្ដងតាមរយៈការចុះពិនិត្យ និងសម្រេចជាប្រចាំដោយក្រុមការងារសហគមន៍នាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា។ជាក់ស្ដែងក្នុងសប្ដាហ៍ទី៣នៃខែតុលា ក្រុមការងារសហគមន៍បានចុះ ពិនិត្យសំណើបានចំនួន៤២ករណី និងសម្រេចអនុញ្ញាតបានចំនួន ៣៤ករណី ទៅតាមបណ្ដាលស្រុក/ក្រុងទាំង៧ ដូចខាងក្រោម៖

- ស្រុកបន្ទាយស្រីអនុញ្ញាតបាន ១០ករណី
- ក្រុងសៀមរាបអនុញ្ញាតបាន ១១ករណី
- ស្រុកអង្គរធំអនុញ្ញាតបាន ១០ករណី
- ស្រុកពួកអនុញ្ញាតបាន ៣ករណី

សូមជម្រាបថា រាល់ការដាក់ពាក្យស្នើសុំច្បាប់ និងការអនុញ្ញាត គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ។ ជាមួយគ្នានេះ ក្រុមការងារសង្កេតឃើញថា ក៏មានអ្នកដែលទទួលបានការអនុញ្ញាតហើយ ប៉ុន្តែពុំបានអនុវត្តត្រឹមត្រូវស្របនឹងការអនុញ្ញាតនោះឡើយ។

ដូច្នេះអាជ្ញាធរជាតិអប្សរា សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតឱ្យជួសជុលលំនៅដ្ឋានត្រូវអនុវត្តឲ្យស្របតាមចំណុចបច្ចេកទេសដែលមានការទទួលដឹងលឺ ពីអាជ្ញាធរមូលដ្ឋាន និងទទួលស្គាល់ដោយអាជ្ញាធរជាតិអប្សរា៕

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែវិច្ឆិកា

នៅព្រឹកថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៤ ក្រុមភ្នាក់ងារទេសចរប្រចាំប្រាសាទអង្គរវត្ត បានប្រទះឃើញ និងប្រគល់ទូរសព្ទដៃមួយគ្រឿងដល់ភ្ញៀវទេសចរជនជាតិអូស្ត្រាលីវិញ បន្ទាប់ពីគាត់ភ្លេចនៅក្បែរជណ្តើរឡើងបាកាន្តប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា ជួបសំណេះសំណាលជាមួយសិក្ខាកាម អប់រំមរតកវប្បធម៌អាស៊ាន

ផ្សាយនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៤

នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានជួបសំណេះសំណាលជាមួយសិក្ខាកាមចូលរួមក្នុងសន្និសីទអន្តរជាតិ ស្តីពីការអប់រំមរតកវប្បធម៌អាស៊ាន ដឹកនាំដោយលោកបណ្ឌិត ទ្បៀ គឹមលាង។ ក្នុងជំនួបពិភាក្សានេះ សិក្ខាកាមទាំងអស់បានស្វែងយល់អំពីតួនាទី និងភារកិច្ចរបស់អាជ្ញាធរជាតិអប្សរា ក្នុងការអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ ដែលចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ នៅឆ្នាំ១៩៩២៕

សេចក្តីជូនដំណឹង ស្តីពីការបិទជាបណ្តោះអាសន្ន ច្រកកណ្តាលខាងកើតឆ្លងកាត់ពីរូតទី១ ទៅកាន់រូតទី២ នៃប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៤



រូបភាពប្រចាំសប្ដាហ៍៖
ទិដ្ឋភាពប្រាសាទព្រះខ័នពីលើអាកាស

ផ្សាយនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៤

ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ជួបពិភាក្សាការងារជាមួយ មជ្ឈមណ្ឌលអន្តរជាតិ សម្រាប់ការគ្រប់គ្រងបរិស្ថាន (ICEM)

ផ្សាយនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៤

កាលពីរសៀលថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៤ **ឯកឧត្តម យិត ចាន់ដារដ្ឋ** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានជួបពិភាក្សាការងារជាមួយលោកបណ្ឌិត Jeremy Carew-Reid អគ្គនាយកនៃមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការគ្រប់គ្រងបរិស្ថាន (ICEM)។



ក្នុងជំនួបពិភាក្សានោះ បានផ្តោតសំខាន់លើលទ្ធភាពនៃកិច្ចសហការគ្នា លើការងារគ្រប់គ្រងទឹក ការប្រែប្រួលអាកាសធាតុ ការស្តារឡើងវិញនូវគម្របព្រៃឈើ ជីវចម្រុះ និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់រមណីយដ្ឋានអង្គរ៕

ពិព័រណ៍

ផ្សាយនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៤

សេចក្តីជូនដំណឹង !!!

គណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោក គណៈកម្មការជាតិយូណេស្កូកម្ពុជា សហការជាមួយសាកលវិទ្យាល័យវ៉ាសេដា នៃប្រទេសជប៉ុន និងនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ នឹងមានការរៀបចំពិព័រណ៍ក្រោមប្រធានបទ«ប្រពៃណីផលិតកុលាលភាជន៍នៅក្នុងប្រទេសកម្ពុជា» ចាប់ពីថ្ងៃទី១១ - ២០ ខែវិច្ឆិកា ឆ្នាំ២០២៤ វេលាម៉ោង ៩:០០នាទីព្រឹក ដល់ម៉ោង៤:៣០នាទីរសៀល នៅសារមន្ទីរខ្លែងខ្មែរ ក្នុងបរិវេណនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ស្ថិតនៅលើបណ្តោយវិថីវិជ្ជសភាថ្មី (ខាងត្បូងរង្វង់មូលសម្តេចព្រះសង្ឃរាជ ជួន ណាត) ក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចម្ការមន រាជធានីភ្នំពេញ។

សូមចូលរួមដោយសេរី!

រូបភាពប្រចាំសប្ដាហ៍៖ សម្រស់ប្រាសាទក្រវ៉ាន់ សំណង់ឥដ្ឋតូចច្រលឹង ដែលមិនគួរមើលរំលង

ផ្សាយនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២៤

ពិធីប្រគល់កិច្ចព្រមព្រៀង និងសម្ពោធគម្រោង«ឧទ្យានអង្គរ-ស៊ីអាយអិមប៊ី» និងពិធីដាំកូនឈើរួមគ្នា រវាងអាជ្ញាធរជាតិអប្សរា និងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី (CIMB)

ផ្សាយនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៤

នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៤ មានប្រារព្ធពិធីប្រគល់កិច្ចព្រមព្រៀង និងសម្ពោធគម្រោង«ឧទ្យានអង្គរ-ស៊ីអាយអិមប៊ី»រវាងអាជ្ញាធរជាតិអប្សរា និងធនាគា ស៊ីអាយអិមប៊ី ភីអិលស៊ី (CIMB) ព្រមទាំងពិធីដើមឈើ រួមគ្នាចំនួនប្រមាណ២,០០០ដើម ជានិមិត្តរូប បង្ហាញឱ្យឃើញពីស្មារតីចូលរួមគាំពារ និងថែរក្សា អភិរក្សបរិស្ថាន នៅបរិវេណខាងកើតប្រាសាទបន្ទាយប្រី នៃរមណីយដ្ឋានអង្គរ។

ពិធីនេះប្រព្រឹត្តិទៅក្រោមអធិបតីភាព ឯកឧត្តម Ambassador Shaharuddin On ឯកអគ្គរាជទូតម៉ាឡេស៊ីប្រចាំកម្ពុជា **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា លោកប៊ុន ឃីន ប្រធាននាយកប្រតិបត្តិធនាគា ស៊ីអាយអិមប៊ី ភីអិលស៊ី ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិកអាជ្ញាធរជាតិអប្សរា និងបុគ្គលិកធនាគាស៊ីអាយអិមប៊ី ចំនួន៥០០នាក់។

ឯកឧត្តមបណ្ឌិត ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ ស្វាគមន៍ចំពោះវិស័យឯកជននានា ដែលមានបំណងចង់ចូលរួមជាមួយអាជ្ញាធរជាតិអប្សរា ក្នុងសកម្មភាពដាំដើមឈើឡើងវិញ ដើម្បីបរិស្ថាន និងការពារប្រាសាទបុរាណ។ ឯកឧត្តមអគ្គនាយក បានបញ្ជាក់អំពីសារសំខាន់មួយចំនួននៃដើមឈើចំពោះបរិស្ថាន សុខភាពមនុស្សនិងសត្វ ក្រៅពីនោះដើមឈើដែលមានវត្តមាននៅរមណីយដ្ឋានអង្គរ ក៏បានដើរតួនាទីសំខាន់ក្នុងការការពារទៅដល់ប្រាសាទបុរាណ ឱ្យចៀសផុតពីហានិភ័យនានា។ ហេតុដូច្នេះ ចាប់តាំងពី២០០៤មក អាជ្ញាធរជាតិអប្សរា បានយកចិត្តទុកដាក់ និងរៀបចំផែនការដាំដុះដើមឈើវិញជាបន្តបន្ទាប់ រហូតទទួលបានជោគជ័យដូចសព្វថ្ងៃនេះ។

លោក ប៊ុន យីន ប្រធាននាយកប្រតិបត្តិធនាគាស៊ីអាយអិមប៊ី ភីអិលស៊ី បានលើកឡើងថា ធនាគាស៊ីអាយអិមប៊ី ពិតជាមានសេចក្តីសោមនស្សរីករាយ ដែលបានចូលរួម ជាអាជ្ញាធរជាតិអប្សរា ក្នុងសកម្មភាពការពារ អភិរក្ស និងថែរក្សាបរិស្ថាន។
លោកថា គិតចាប់ពីឆ្នាំ២០២០មក នេះជាលើកទី៣ហើយ ដែលធនាគាស៊ីអាយអិមប៊ី បានសហការជាមួយអាជ្ញាធរជាតិអប្សរា ដាំកូនឈើឡើងវិញក្នុងរមណីយដ្ឋានអង្គរ ព្រមទាំងបង្កើតឱ្យមានគម្រោង «ឧទ្យានអង្គរ-ស៊ីអាយអិមប៊ី» ដែលបានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្ត និងកិច្ចខិតខំប្រឹងប្រែង លើការដាំ និងថែរក្សាដើមឈើ រយៈពេលយូរអង្វែង៕

សេចក្តីជូនដំណឹង !!!

សូមចូលរួមគូរគំនូរប្រចាំថ្ងៃ " អេនីគី "គណៈកម្មការជាតិយូណេស្កូកម្ពុជានឹងមានរៀបចំប្រឡងគំនូរកុមារក្រោមប្រធានបទ«នេះគឺជាជីវិតរបស់ខ្ញុំ»។ កម្មវិធីនេះរៀបចំឡើងដើម្បីផ្តល់ឱកាសដល់កុមារកម្ពុជាបានចែករំលែកអំពីជីវិភាពប្រចាំថ្ងៃទៅដល់កុមារទូទាំងពិភពលោកតាមរយៈគំនូរ និងភ្ជាប់ដោយសំណេរខ្លីៗ។ចាប់ទទួលស្នាដៃចូលរួមពីថ្ងៃទី១ ខែវិច្ឆិកា ដល់ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៤ នៅអាគារគណៈកម្មការជាតិយូណេស្កូកម្ពុជា (ខាងត្បូងវង់វិមានឯករាជ្យ)។

សូមអរគុណ

មហោស្រពមីតស៊ូប៊ីស៊ី គំនូរកុមារអាស៊ី អេនីគី

ផ្សាយនៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២៤

អគ្គនាយកអាជ្ញាធរជាតិអប្សរា ជួបពិភាក្សាការងារជាមួយ ឯកអគ្គរាជទូតម៉ាឡេស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា

ផ្សាយនៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២៤

នារសៀលថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៤ **ឯកឧត្តម បណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា ព្រមទាំងសហការី បានទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម Shaharuddin Onn ឯកអគ្គរាជទូតម៉ាឡេស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា។ ក្នុងជំនួបនោះ ភាគីទាំងពីរបានរំឭកពីការងារខ្លះ ដែលស្ថាប័ននៃប្រទេសម៉ាឡេស៊ី បានជួយលើការងារគ្រប់គ្រងរមណីយដ្ឋានអង្គរ នាពេលកន្លងមក។ បន្ថែមពីនេះ ក៏មានការជជែកលើគម្រោងកិច្ចសហការនាពេលអនាគត រវាងប្រទេសម៉ាឡេស៊ី និងអាជ្ញាធរជាតិអប្សរា លើការងារអភិរក្ស និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរផងដែរ៕

អ្នកជំនាញអាជ្ញាធរជាតិអប្សរា កំពុងជួសជុលប្រាសាទទ្រមូង ឱ្យរឹងមាំឡើងវិញ

ផ្សាយនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២៤

ក្រុមអ្នកជំនាញរបស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា កំពុងអនុវត្តគម្រោងជួសជុលប្រាសាទទ្រមូង ដែលស្ថិតនៅខាងលិច នៃខ្លោងទ្វារតាកាវ ក្រុងអង្គរធំ ឱ្យរឹងមាំឡើងវិញ។

ប្រាសាទទ្រមូង គឺជាមន្ទីរពេទ្យបុរាណមួយ ក្នុងចំណោមមន្ទីរពេទ្យបុរាណចំនួន៤ របស់អតីតក្រុងអង្គរធំ ដែលបច្ចុប្បន្នកំពុងរងការខូចខាតខ្លាំង។

បុរាណវិទូ និងជាប្រធានការងារការដ្ឋាន លោក ជា សារិទ្ធ ឱ្យដឹងថា ប្រាសាទទ្រមូង រងការខូចខាតខ្លាំងនៅត្រង់តួប៉មកណ្តាល ដោយមានការដួលរលំស្ទើរទាំងស្រុង គឺនៅសល់ទ្រង់ទ្រាយដើមប្រហែល២០-៣០ភាគរយប៉ុណ្ណោះ។ ចំណែកថ្មចាប់ពីជញ្ជាំងរហូតទៅដល់ផ្នែកដំបូលវិញ បានរលំ និងធ្លាក់ចុះមកលើដីទាំងស្រុង ដោយនៅសេសសល់តែស៊ុមទ្វារផ្នែកខាងមុខ ខឿនផ្នែកខាងត្បូង និងផ្នែកខាងកើត។ ចំណែករចនាសម្ពន្ធផ្នែកខាងលិច និងខាងជើងក៏បាត់ថ្មអស់ប្រហែល៥០ភាគរយដែរ។

ដោយសារតែប្រាសាទទ្រមូង រងការខូចខាតធ្ងន់ធ្ងរ ទើបបច្ចុប្បន្នក្រុមការងារ នៃអាជ្ញាធរជាតិអប្សរា ចាប់ផ្ដើមអនុវត្តគម្រោងជួសជុល ថែទាំឡើងវិញទៅតាមដំណាក់កាល។ ដំណាក់កាលទី១ គឺក្រុមការងារ ចាប់ផ្ដើមធ្វើសម្រង់ប្លង់បច្ចុប្បន្នរបស់ប្រាសាទ ធ្វើការវិភាគវិនិច្ឆ័យលក្ខណៈរបស់សំណង់ និងការខូចខាត ដើម្បីឈានដល់ការជួសជុល។

ចំណែកដំណាក់កាលទី២ គឺធ្វើការចុះបញ្ជីថ្មដែលកំពុងរាយប៉ាយ ដើម្បីកំណត់មុខងារ និងទីតាំងរបស់ថ្ម។ លោក ជា សារិទ្ធ បញ្ជាក់ថា តាមការចុះបញ្ជីកន្លងមក អាចឱ្យដឹងថា ថ្មដែលនៅរាយប៉ាយលើដី នាផ្នែកខាងលិចនៃប្រាសាទ គឺមានចំនួនរហូតទៅដល់៥០០ដុំ ផ្នែកខាងជើងមានចំនួន ៦០០ដុំ។ ថ្មទាំងនោះ បានកំណត់អត្តសញ្ញាណរួចហើយ មានដូចជា ថ្មដំបូល ថ្មជញ្ជាំង ថ្មខឿន ផ្តែរ សសរពេជ្រ និងទ្វារបញ្ឆោតរបស់ប្រាសាទជាដើម។ល។

បច្ចុប្បន្ន ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា កំពុងដំណើរការជួសជុលប្រាសាទទ្រមូងនេះ ដោយចាប់ផ្ដើមពីដំណាក់កាលនៃការពង្រឹងខឿន គ្រឹះរបស់តួប៉មកណ្ដាល៕

សប្តាហ៍ទី៤ នៃខែតុលា ឆ្នាំ២០២៤ ក្រុមការងារសហគមន៍ បន្តចុះពិនិត្យសំណើពលរដ្ឋនៅក្នុងរមណីយដ្ឋានអង្គរ បានចំនួន៦៧ករណី និងសម្រេចអនុញ្ញាតបានចំនួន ៥៧ករណី

ផ្សាយនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២៤

ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងរមណីយដ្ឋានអង្គរ ត្រូវបានទទួលនូវការយកចិត្តទុកដាក់អំពីសំណាក់អាជ្ញាធរជាតិអប្សរា ដោយមានការអនុគ្រោះក្នុងការជួសជុលតូចតាចនូវលំនៅដ្ឋានក៏ដូចជាសំណង់ឧបសម្ព័ន្ធមាន របងដំបូល ជញ្ជាំង សសរពុកផុយ បង្គន់អនាម័យ រោងគោ ទ្រុងមាន់ និងទ្រុងជ្រូកជាដើម ហើយរាល់ការអនុញ្ញាតជួសជុលមានសុពលភាពត្រឹមពីរខែ នៅលើទីតាំងកំពុងរស់នៅផ្ទាល់តែម្តងតាមរយៈការចុះពិនិត្យ និងសម្រេចជាប្រចាំដោយក្រុមការងារសហគមន៍នាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា។ជាក់ស្តែងក្នុងសប្តាហ៍ទី៤នៃខែតុលា ក្រុមការងារសហគមន៍បានចុះ ពិនិត្យសំណើបានចំនួន ៦៧ករណី និងសម្រេចអនុញ្ញាតបានចំនួន ៥៧ករណី ទៅតាមបណ្តាលស្រុក/ក្រុងទាំង៧ ដូចខាងក្រោម៖

- ស្រុកពួកអនុញ្ញាតបាន ៦ករណី
- ក្រុងសៀមរាបអនុញ្ញាតបាន ៣៤ករណី
- ស្រុកបន្ទាយស្រីអនុញ្ញាតបាន ១០ករណី
- ស្រុកអង្គរធំអនុញ្ញាតបាន ៧ករណី

សូមជម្រាបថា រាល់ការដាក់ពាក្យស្នើសុំច្បាប់ និងការអនុញ្ញាត គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ។ ជាមួយគ្នានេះ ក្រុមការងារសង្កេតឃើញថា ក៏មានអ្នកដែលទទួលបានការអនុញ្ញាតហើយ ប៉ុន្តែពុំបានអនុវត្តត្រឹមត្រូវ ស្របនឹងការអនុញ្ញាតនោះឡើយ។

ដូច្នេះអាជ្ញាធរជាតិអប្សរា សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតឱ្យជួសជុលលំនៅដ្ឋានត្រូវអនុវត្តឲ្យស្របតាមចំណុចបច្ចេកទេសដែលមានការទទួលដឹងលឺ ពីអាជ្ញាធរមូលដ្ឋាន និងទទួលស្គាល់ដោយអាជ្ញាធរជាតិអប្សរា៕

សេចក្តីជូនដំណឹង
ស្តីពីការបិទជាបណ្តោះអាសន្ននូវទីតាំងសក្ការៈបូជារោងឧបោសថាគារព្រះអង្គចេក

ផ្សាយនៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
A P S A R A

លេខ ៤៦២/សប.សជក
២៤

សេចក្តីជូនដំណឹង
ស្តីពី
ការបិទជាបណ្តោះអាសន្ននូវទីតាំងសក្ការៈបូជា
រោងឧបោសថព្រះអង្គចេក

អាជ្ញាធរជាតិអប្សរា សូមជម្រាបជូនដំណឹងដល់ភ្ញៀវទេសចរជាតិ-អន្តរជាតិ ពុទ្ធបរិស័ទ និងសាធារណជនទាំងអស់មេត្តាជ្រាបថា អាជ្ញាធរជាតិអប្សរា សូមបិទជាបណ្តោះអាសន្ននូវទីតាំងសក្ការៈបូជារោងឧបោសថព្រះអង្គចេក ដើម្បីធ្វើការជួសជុលចាប់ពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៤ រហូតដល់ការងារចប់រួចរាល់។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ភ្ញៀវទេសចរជាតិ-អន្តរជាតិ ពុទ្ធបរិស័ទ និងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ ពុធ ៦កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
សៀមរាប ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០២៤
អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្គោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

គម្រោងថែទាំ និងជួសជុល កំពែងក្រុងអង្គរធំ ក្នុងប្រវែង២៥ម៉ែត្រ នឹងបញ្ចប់នាចុងឆ្នាំ២០២៤ខាងមុខ

ផ្សាយនៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២៤

តាមរយៈការខិតខំប្រឹងប្រែងរបស់ក្រុមអ្នកជំនាញ នៃអាជ្ញាធរជាតិអប្សរា បានចំណាយពេលជិត៦ខែមកហើយ ដើម្បីជួសជុល ថែទាំ និងពង្រឹងកំពែងធ្វើអំពីថ្មបាយក្រៀម របស់ក្រុងអង្គរធំ ស្ថិតនៅប៉ែកខាងជើង ខ្លោងទ្វារដីឆ្នាំងឱ្យរឹងមាំឡើងវិញ។ មកដល់ពេលនេះ គម្រោងថែទាំ និងជួសជុល កំពែងក្រុងអង្គរធំ ក្នុងប្រវែង២៥ម៉ែត្រ សម្រេចលទ្ធផលបានជាង៧០ភាគរយហើយ ដោយគម្រោងនឹងបញ្ចប់នាខែធ្នូ ឆ្នាំ២០២៤ខាងមុខ។

លោក ម៉ៅ សុខនី មន្ត្រីបច្ចេកទេសនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា គម្រោងថែទាំ ជួសជុល និងពង្រឹងកំពែងក្រុងអង្គរធំនៅប៉ែកខាងជើង ខ្លោងទ្វារដីឆ្នាំង ក្នុងប្រវែង២៥ម៉ែត្រ ឈានចូលដំណាក់កាលទី៦ហើយ ដោយបានចាប់ផ្តើមពីខែមិថុនា ឆ្នាំ២០២៤ មកដល់ពេលនេះអនុវត្តបានប្រមាណជាង៧០ភាគរយ ដោយគ្រោងនិងបញ្ចប់គម្រោងនាខែធ្នូ ឆ្នាំ២០២៤ខាងមុខ។ លោកបញ្ជាក់ថា ដោយសារកត្តាអាយុកាលរបស់ថ្ម ព្រមទាំងកត្តាធម្មជាតិមួយចំនួនទៀត ដូចជា ទឹកភ្លៀងហូរច្រោះ រុក្ខជាតិដុះចាក់ឫសធ្វើឱ្យថ្មញែកចេញពីគ្នា ព្រមទាំងកង្វះការថែទាំ ធ្វើឱ្យថ្មជញ្ជាំងកំពែងពុកផុយ ហើយដួលរលំ។ ដូច្នេះដំណើរការជួសជុល អ្នកជំនាញអាចយកថ្មចាស់ខ្លះមកជួសជុលរៀបផ្គុំវិញនៅផ្នែកខឿន បានប្រមាណ៣០ភាគរយ ចំណែកដីដែលហូរច្រោះ ត្រូវចំណាយយកដីមកចាក់បំពេញបន្ថែម។ ចំណែកបច្ចេកទេសជួសជុល អ្នកជំនាញអះអាងថា អនុវត្តទៅតាមបច្ចេកទេសពីបុរាណមក ដោយគ្រាន់តែបន្ថែមជញ្ជាំងទប់ពីខាងក្រោយ បន្ថែមកម្លាំងឱ្យរឹងមាំ ទប់ស្កាត់កម្លាំងរុញរបស់ដីដែលហូរបុកមក។

ជាច្រើនឆ្នាំមកនេះ ក្រុមអ្នកជំនាញធ្លាប់បានជួសជុលកំពែងរបស់ក្រុងអង្គរធំ ដែលសាងសង់ពីថ្មបាយក្រៀមចំនួន៥កន្លែងរួចមកហើយ។ ការជួសជុលថែទាំ ពង្រឹងកំពែងក្រុងអង្គរធំ ក្រៅពីផ្តល់ឱ្យពលរដ្ឋរស់នៅជុំវិញនោះមានការងារ ក៏ជួយឱ្យកំពែងមានសោភ័ណឡើងវិញ ចៀសផុតពីការដួលរលំ និងអាចរក្សាទីក្រុងបុរាណមួយនេះ ឱ្យមានរូបរាងដើម ស្រស់ស្អាតបន្តដល់កូនចៅជំនាន់ក្រោយ និងអាចទាក់ទាញទេសចរឱ្យមកកម្សាន្តបានទៀតផង៕

អាជ្ញាធរជាតិអប្សរា
បញ្ចប់ការជួសជុលខ្លោងទ្វារខាងកើតនៃប្រាសាទប្រែរូប ផ្នែកខាងជើង

ផ្សាយនៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២៤

ក្រុមការងារអាជ្ញាធរជាតិអប្សរា បន្តជួសជុលខ្លោងទ្វារជើង ផ្នែកខាងកើត របស់ប្រាសាទប្រែរូប ដំណាក់កាលទី២ សម្រេចបានប្រមាណ៩០ភាគរយ។ ការងារជួសជុលនេះ ដំណើរការតាំងពីពាក់កណ្តាលខែឧសភា ឆ្នាំ២០២៤ នឹងបញ្ចប់នៅខែវិច្ឆកា ឆ្នាំ២០២៤ នេះ។

លោក សូរ ប៉ោត បុរាណវិទូ និងគ្រប់គ្រងការដ្ឋានជួសជុលប្រាសាទប្រែរូប ឱ្យដឹងថា ស្ថានភាពនៃខ្លោងទ្វារខាងជើងផ្នែកខាងកើតរបស់ប្រាសាទប្រែរូប បានខូចខាត និងមានហានិភ័យដល់សំណង់ ព្រមទាំងភ្ញៀវទេសចរមិនអាចដើរឆ្លងកាត់។ ដើម្បីសង្គ្រោះខ្លោងទ្វារនេះឱ្យរឹងមាំឡើងវិញ ក្រុមការងារជួសជុលពង្រឹងផ្នែកខាងក្នុងនៃស្លាបខាងជើងផ្នែកខាងក្រៅផ្នែកខាងលិច និងផ្នែកខាងកើត ព្រមទាំងជួសជុលពង្រឹងរចនាសម្ពន្ធឥដ្ឋដែលខូចខាតធ្ងន់ធ្ងរ គ្មានស្ថិរភាពនៅផ្នែកខាងលើនៃតួខ្លោងទ្វារ។ បិទបំពេញស្នាមប្រេះហែកការពារជម្រាបទឹក និងបន្ថែមរចនាសម្ពន្ធមួយចំនួនសម្រាប់ភាពរឹងមាំយូអង្វែងដល់រចនាសម្ពន្ធខ្លោងទ្វារទាំងមូល។

លោក សូរ ប៉ោត បញ្ជាក់ថា ការងារជួសជុលខ្លោងទ្វារខាងកើតប្រាសាទប្រែរូប ផ្នែកខាងជើង រួចរាល់ គឺរចនាសម្ពន្ធនៃសំណង់ខ្លោងទ្វារទាំងមូល នឹងមានភាពរឹងមាំឡើងវិញ មានសុវត្ថិភាពទាំងខ្លោងទ្វារ ហើយភ្ញៀវទេសចរក៏អាចដើរចេញចូលទស្សនាតាមខ្លោងទ្វារទិសខាងកើតដ៏សំខាន់នេះដោយសុវត្ថិភាព។

អ្នកជំនាញរូបនេះរម្លឹកថា ការខូចខាតនៃរចនាសម្ពន្ធប្រាសាទប្រែរូប បណ្តាលមកពីការកង្វះការថែទាំយូរអង្វែង មានដើមឈើ និងស្មៅដុះចាក់ឫស កំណកដី និងបណ្តាលពីអាយុកាលនៃសម្ភារសំណង់ អាកាសធាតុ ពិសេសទឹកភ្លៀងហូរជ្រាបចូលក្នុងប្រាសាទ ដែលធ្វើឱ្យរចនាសម្ពន្ធចុះខ្សោយ ថ្មប្រាសាទងាយនឹងពុកផុយ។ កន្លងមកនៅប្រាសាទប្រែរូបក៏ធ្លាប់មានការជួសជុលនៅសម័យបារាំង និងក្រោយមកទៀត មានប្រទេសអ៊ីតាលីផង៕

ទឹកភ្លៀងជាង៦០លានម៉ែត្រគ្រីគុណ ត្រូវបានប្រមូលទុកនៅ តំបន់រមណីយដ្ឋានអង្គរនារដូវវស្សានេះ

ផ្សាយនៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២៤

ទោះបីស្ថានភាពទឹកភ្លៀងឆ្នាំនេះមានការអូសបន្លាយ និងមិនទៀងទាត់យ៉ាងណាក៏ដោយ ប៉ុន្តែអាជ្ញាធរជាតិអប្សរា បានរៀបចំប្រមែប្រមូលទឹកពេញអាងស្តុកទឹកទាំងអស់ដែលមានក្នុង តំបន់រមណីយដ្ឋានអង្គរ។ តាមមន្ត្រីអាជ្ញាធរជាតិអប្សរា ទឹកភ្លៀងជាង៦០លានម៉ែត្រគ្រីគុណ ឬម៉ែត្រគីប ត្រូវបានប្រមូលទុកនារដូវវស្សាឆ្នាំនេះ។

ប្រធាននាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ នៃអាជ្ញាធរជាតិអប្សរា លោក គឿន សុឃីម បានឱ្យដឹងថា គិតមកដល់ខែវិច្ឆិកា ការប្រមូលទឹកចូលអាងស្តុកទឹកសំខាន់ៗនៅតំបន់រមណីយដ្ឋានអង្គរ គឺសម្រេចបាន១០០ភាគរយ ក្នុងនោះរាប់ទាំងបារាយណ៍តូចធំ កសិន្ធុទឹក អូរ និងប្រឡាយជាដើម។ ទឹកដែលប្រមូលបានទាំងនេះមានបរិមាណជាង៦០លានម៉ែត្រគ្រីគុណ ដែលត្រៀមសម្រាប់ការប្រើប្រាស់នារដូវប្រាំងខាងមុខ ក្នុងនោះរាប់ទាំងការងារអភិរក្សប្រាសាទ បរិស្ថាន និងវិស័យកសិកម្មសម្រាប់ប្រជាពលរដ្ឋនៅតំបន់ជុំវិញប្រមាណ៧ពាន់ហិកតា។ អ្នកជំនាញបញ្ជាក់ថា បរិមាណនេះ គឺមានចំនួនប្រហាក់ប្រហែលនឹងឆ្នាំទៅមិញដែរ ដោយមិនបារម្ភពីកង្វះខាតទឹកនៅតំបន់ឡើយ។

បើតាមការបញ្ជាក់ពីលោក គឿន សុឃីម ការងារគ្រប់គ្រងទឹកនៅតំបន់រមណីយដ្ឋានអង្គរ កាន់តែល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ ក្រោយអាជ្ញាធរជាតិអប្សរាបានរៀបចំ និងស្តារប្រព័ន្ធទឹកបុរាណក្នុងតំបន់រមណីយដ្ឋានអង្គរឡើងវិញចាប់ពីឆ្នាំ២០១២មក។ ជាងនេះទៅទៀត ក្រោមការគិតគូរដ៏វែងឆ្ងាយ និងភាពឈ្លាសវៃពីថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ដោយយល់ពីសារសំខាន់ នៃការងារគ្រប់គ្រងទឹក ដែលធ្វើឱ្យប្រព័ន្ធគ្រប់គ្រងទឹកក្នុងតំបន់កាន់តែមានភាពជឿនលឿន និងមានប្រសិទ្ធភាពខ្ពស់។ តួយ៉ាង នាឆ្នាំ២០២៤នេះ សំណង់ទ្វារទឹកមួយចំនួនត្រូវបានស្តារ និងជួសជុលឡើងវិញជាបន្តបន្ទាប់ ក្នុងបំណងដើម្បីធានាថា ការងារគ្រប់គ្រងទឹកនឹងមានវិសាលភាពកាន់តែទូលំទូលាយ និងពេញលេញ ដើម្បីបំពេញតម្រូវការក្នុងតំបន់រមណីយដ្ឋានអង្គរ។

ចំពោះការប្រើប្រាស់ទឹកវិញ លោក គឿន សុឃីម បញ្ជាក់ថា ទឹកមានសារសំខាន់នៅតំបន់ប្រាសាទ ដោយសារបុព្វបុរសសម័យមុនបានរៀបចំ និងកសាងប្រាសាទដោយមានគ្រឹះដីខ្សាច់ ដូច្នេះទើបកសាងកសិន្ធុជុំវិញដើម្បីបញ្ចូលទឹកឱ្យគ្រឹះរឹងមាំល្អ។ ប្រសិនគ្មានទឹក ប្រាសាទនឹងរងការដួលរលំ និងបាក់បែកខ្លាំង។ ក្រៅពីនេះ ទឹកក៏ជាបង្កើនសម្រស់ និងសោភ័ណភាពនៅតំបន់ប្រាសាទផង។ ទឹកក៏ជួយឱ្យដើមឈើលូតលាស់បានល្អ ទាក់ទាញទេសចរ និងជួយកាត់បន្ថយការកើនឡើងនៃរលកកម្តៅខ្លាំងនារដូវប្រាំង៕

រូបភាពប្រចាំសប្តាហ៍៖ ប្រាសាទ ទ សំណាក់ថ្មបាយក្រៀម កសាងនៅចុងស.វទី១២

ផ្សាយនៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២៤

សម្រស់ប្រាសាទវាលធ្លី នៅកណ្តាលបារាយណ៍ខាងកើត ប្រាសាទបេងមាលា មានទីតាំង នៅភូមិបេងមាលា ឃុំបេងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២៤

ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ចូលរួមគោរពវិញ្ញាណក្ខន្ធវីរយុទ្ធជន និងរំលឹកខួបលើកទី៧១ ទិវាបុណ្យឯករាជ្យជាតិ

ផ្សាយនៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី៩ វិច្ឆិកា នេះ ថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរា បានចូលរួមក្នុងពិធីគោរពវិញ្ញាណក្ខន្ធវីរយុទ្ធជន និងរំលឹកខួបអនុស្សាវរីយ៍លើកទី៧១ ទិវាបុណ្យឯករាជ្យជាតិ និងថ្ងៃបង្កើតកងយោធពលខេមរភូមិន្ទ ៩ វិច្ឆិកា ១៩៥៣- ៩ វិច្ឆិកា ២០២៤ ដែលពិធីនេះធ្វើឡើងនៅវិមានរំលឹកគុណ អតីតវីរយុទ្ធជន ខេត្តសៀមរាប។

ពិធីនេះមានការចូលរួមពីមន្ត្រីរាជការ កងកម្លាំងគ្រប់លំដាប់ថ្នាក់ ក៏ដូចជាសិស្សានុសិស្ស ដើម្បីដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធយុទ្ធជន យុទ្ធនារី និងវីរបុរសអ្នកស្នេហាជាតិ ដែលបានពលីជីវិតដ៏ថ្លៃថ្លាសម្រាប់បុព្វហេតុមាតុភូមិ និងប្រជាជន។

ជាមួយគ្នានេះដែរ ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា គឺជាការរំលឹកដល់ពលរដ្ឋកម្ពុជា ជាពិសេសយុវជនយុវនារីជំនាន់ក្រោយឱ្យបានយល់ដឹងអំពីព្រះរាជបេសកកម្មដើម្បីជាតិមាតុភូមិ និងប្រជារាស្ត្រខ្មែររបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះបិតាឯករាជ្យជាតិ ព្រះបរមរតនកោដ្ឋ ដែលព្រះអង្គបានលះបង់ព្រះកាយពល និងព្រះបញ្ញាញាណយ៉ាងក្លៀវក្លាបំផុត តស៊ូរំដោះជាតិទាមទារឯករាជ្យពីនឹមអាណានិគមនិយមបារាំង ដោយជោគជ័យទាំងស្រុង នៅថ្ងៃទី ៩ វិច្ឆិកា ឆ្នាំ ១៩៥៣៕

រូបភាពប្រចាំសប្តាហ៍៖ ទិដ្ឋភាពខ្លោងទ្វារខាងត្បូង នៃប្រាសាទបន្ទាយក្តី ដែលស្រស់ស្អាតមិនចាញ់ខ្លោងទ្វារពផ្សេងទៀត

ផ្សាយនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរាពន្លឿនការងារជួសជុលពង្រឹងតួប៉ម A នៃប្រាសាទគោកពោធិ៍

ផ្សាយនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៤

អស់រយៈពេលជាង៥ខែមកហើយ ដែលក្រុមអ្នកជំនាញបាននឹងកំពុងពង្រឹងតួប៉ម A នៃប្រាសាទគោកពោធិ៍ ដោយបានចាប់ផ្ដើមតាំងពីខែមិថុនា ឆ្នាំ២០២៤មក រហូតមកដល់បច្ចុប្បន្នសម្រេចលទ្ធផលជិតរួចរាល់ហើយ។

លោក ហួរ សុធន បុរាណវិទូ នាយកដ្ឋានអភិរក្សប្រាសាទនៃអាជ្ញាធរជាតិអប្សរា និងជាអ្នកទទួលខុសត្រូវនៅការដ្ឋានជួសជុលប្រាសាទគោកពោធិ៍ បានឱ្យដឹងថា បន្ទាប់ពីអ្នកជំនាញបានជួសជុលពង្រឹងជញ្ជាំង ផ្នែកខាងត្បូង និងខាងលិច សម្រេចបាន៩៥ភាគរយហើយ បានធ្វើឱ្យរចនាសម្ពន្ធនៃតួប៉មA ដែលធ្លាប់តែព្រួយបារម្ភពីហានិភ័យនៃការដួលរលំ បានប្រែមកជារឹងមាំឡើងវិញ។ ក្នុងនោះ ចំពោះផ្នែកខឿនខាងក្រោម ក៏បានបន្ថែមឥដ្ឋខ្លះៗ ដើម្បីពង្រឹងឡើងវិញទៅតាមផ្នែកនីមួយៗ។ ចំណែកការងារដែលនៅសេសសល់ គឺរៀបចំផ្គុំផ្នែកដំបូលឡើងវិញ និងសម្អាតរុក្ខជាតិ ដែលដុះចាក់ឫសជ្រៅៗនៅតាមដំបូល ខណៈក្រុមការងារកំពុងពន្លឿនកិច្ចទាំងនេះ ដោយរំពឹងថានិងបញ្ចប់នាចុងខែវិច្ឆិកាខាងមុខនេះ។

អ្នកជំនាញរូបនេះបានបញ្ជាក់ថា ក្រុមប្រាសាទគោកពោធិ៍មានតួប៉មចំនួន៤ ត្រូវបានកំណត់ជាតួប៉មA B C និងD តែមិនស្ថិតនៅក្នុងខ្សែបន្ទាត់តែមួយឡើយ ព្រោះសាងសង់ក្នុងសម័យកាលខុសគ្នា និងក្នុងរាជ្យនៃព្រះមហាក្សត្រផ្សេងៗគ្នា។ ដោយសារកត្តាអាយុកាល ធម្មជាតិ និងកង្វះការថែទាំយូរអង្វែង ជាពិសេសដើមឈើដុះចាក់ឫសយ៉ាងជ្រៅ ធ្វើឱ្យរចនាសម្ពន្ធប្រាសាទរងការបំផ្លាញ ហើយតួប្រាង្គចំនួន២ តួប្រាង្គC និងD បានរលំដួលទាំងស្រុង នៅតែប្រាង្គ A សេសសល់ជញ្ជាំងជុំវិញ និងB នៅសល់តែខឿន និងជញ្ជាំងផ្នែកខាងត្បូង។

លោក ហួរ សុធន បន្ថែមថា ការជួសជុលពង្រឹងឡើងវិញ នូវរចនាសម្ពន្ធនៃប្រាសាទគោកពោធិ៍ មិនត្រឹមតែរក្សាឱ្យបាននូវតម្លៃនៃបេតិកភណ្ឌវប្បធម៌ប៉ុណ្ណោះទេ ថែមទាំងជាទីកន្លែងសក្ការៈបូជា សម្រាប់ពលរដ្ឋរស់នៅជុំវិញនោះ និងជាទីកន្លែងដែលទេសចរជាតិនិងអន្តរជាតិ តែចូលមកទស្សនាមិនចេះដាច់ ដោយសារជាទីកន្លែងឆ្លងកាត់ទៅកាន់ប្រាសាទដទៃទៀត។

សូមជម្រាបថា ប្រាសាទគោកពោធិ៍ ជាក្រុមប្រាសាទមួយ មានទីតាំងស្ថិតនៅខាងជើងបារាយណ៍ទឹកថ្លា ប្រមាណជា២គីឡូម៉ែត្រ ស្ថិតក្នុងភូមិគោកពោធិ៍ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប។ ក្រុមប្រាសាទនេះកសាងឡើងនៅចុងសតវត្សរ៍ទី៨ និងទី៩៕

អាជ្ញាធរជាតិអប្សរា បើកសិក្ខាសាលាស្តីពី ការអនុវត្តន៍ផែនការ បរិស្ថានដើម្បីតំបន់អង្គរ ប្រចាំឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤

នាព្រឹកថ្ងៃ ១២ ខែវិច្ឆិកា ឆ្នាំ២០២៤នេះ នៅសាលសន្និសីទអង្គរ ស្នាក់ការកណ្ដាលអាជ្ញាធរជាតិអប្សរា មានបើកសិក្ខាសាលាស្តីពី ការអនុវត្តន៍ផែនការ បរិស្ថានដើម្បីតំបន់អង្គរ ប្រចាំឆ្នាំ២០២៤ ក្រោមអធិបតីភាព **ឯកឧត្តម សុខ លក្ខិណា** តំណាង**ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា និងជាប្រធានប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ ព្រមទាំងសិក្ខាកាមមកពីតាមបណ្ដានាយកដ្ឋានចំណុះទាំង៨របស់អាជ្ញាធរជាតិអប្សរា។

អង្គសិក្ខាសាលា ដែលរៀបចំឡើងដោយអង្គភាពគ្រប់គ្រងបរិស្ថាន-អង្គរ នៃអាជ្ញាធរជាតិអប្សរានេះ ក្នុងគោលបំណងដើម្បីៈ ផ្សព្វផ្សាយ និងណែនាំពីការប្រើប្រាស់សៀវភៅប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ បញ្ជ្រាបការយល់ដឹងពីសកម្មភាពគ្រប់គ្រងបរិស្ថានរបស់នាយកដ្ឋាននីមួយៗ ព្រមទាំងលទ្ធភាពក្នុងការចូលរួមការពារបរិស្ថានក្នុងតំបន់អង្គរ។ ដោយផ្ដោតទៅលើប្រធានបទសំខាន់ៗមួយចំនួនដូចជា អង្គរនិងបរិស្ថាន តួនាទីនិងភារកិច្ចនៃភ្នាក់ងារសណ្ដាប់ធ្នាប់ប្រាសាទដែលកំពុងអនុវត្ត កិច្ចការសាងសង់និងជួសជុលសំណង់ក្នុងរមណីយដ្ឋានអង្គរជាដើម។

ឯកឧត្តម សុខ លក្ខិណា បានលើកឡើងថា ក្នុងមួយឆ្នាំអាជ្ញាធរជាតិអប្សរា បានរៀបចំសិក្ខាសាលាស្តីពី ការអនុវត្តន៍ផែនការបរិស្ថានដើម្បីតំបន់អង្គរនេះចំនួន៤លើក ដោយក្នុងមួយលើកតម្រូវឱ្យមានសិក្ខាមចំនួន១០០នាក់ មកពីនាយកដ្ឋានទាំង៨ចំណុះឱ្យអាជ្ញាធរជាតិអប្សរាចូលរួម។
ឯកឧត្តមក៏បានបង្ហាញអំពីប្រព័ន្ធគ្រប់គ្រងបរិស្ថានបែបស្តង់ដាអន្តរជាតិISO14001 ដែលអាជ្ញាធរជាតិអប្សរា យកមកអនុវត្តតាំងពីឆ្នាំ2003មកនេះ គឺមានសារៈសំខាន់ណាស់ សម្រាប់កិច្ចការអភិរក្សនិងលើកតម្លៃរមណីយដ្ឋាន-អង្គរ។ មិនចំពោះតែផ្ទៃក្នុងអាជ្ញាធរជាតិអប្សរាប៉ុណ្ណោះទេ យើងក៏នៅបានផ្សព្វផ្សាយដល់សហគមន៍ប្រជាពលរដ្ឋ បណ្ដាស្ថាប័ន និងអង្គភាពជុំវិញខេត្តផងដែរ។ ហើយយើងនឹងនៅតែបន្តធ្វើជាប់ជាប្រចាំទៀតផង៕



ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំ នៃរដ្ឋាភិបាលក្រុងថាតុង

ផ្សាយនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤

នារសៀលថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤ **ឯកឧត្តម យិត ចាន់ដារដ្ឋ** អគ្គនាយកស្តីទី អាជ្ញាធរជាតិអប្សរា បានទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ លោក Meng DeChang អគ្គលេខាធិការនៃរដ្ឋាភិបាលប្រជាជនក្រុង ថាតុង (Datong) ដើម្បីពិភាក្សាលើលទ្ធភាពកិច្ចសហប្រតិបត្តិការលើការងារអភិរក្សនាពេលអនាគត។

ឯកឧត្តម យិត ចាន់ដារដ្ឋ បានបង្ហាញការស្វាគមន៍ និងថ្លែងអំណរគុណដល់ រដ្ឋាភិបាលក្រុងថាតុង ដែលបង្ហាញការចង់ចូលរួមក្នុងកិច្ចសហប្រតិបត្តិការដើម្បីអភិរក្សតំបន់រមណីយដ្ឋានអង្គរ ពិសេសការចែករំលែកនូវបទពិសោធន៍គ្នាទៅវិញទៅមក រវាងរមណីយដ្ឋានបេតិកភណ្ឌ YUNGANG និងរមណីយដ្ឋានអង្គរ តាមរយៈការគ្រោងចុះអនុស្សរណៈនៃការយោគយល់គ្នារវាងអាជ្ញាធរជាតិអប្សរា និងវិទ្យាស្ថានស្រាវជ្រាវ YUNGANG ស្តីពីការអភិរក្ស និងស្រាវជ្រាវបេតិកភណ្ឌវប្បធម៌ និងបុរាណវិទ្យា ព្រមទាំងឌីជីថលវត្ថុសិល្បៈពីថ្ម នាពេលដ៏ខ្លីខាងមុខនេះ។

ជាមួយគ្នានេះ ឯកឧត្តមអគ្គនាយកស្តីទី មានសុទិដ្ឋិនិយមថា ស្ថាប័នទាំងពីរនឹងធ្វើការជាមួយគ្នាប្រកបដោយប្រសិទ្ធភាព ក្នុងន័យរួមគ្នាអភិរក្ស និងអភិវឌ្ឍន៍តំបន់បេតិកភណ្ឌទាំងពីរឱ្យស្របតាមគោលការណ៍ និងបទដ្ឋានអន្តរជាតិ។

ទាក់ទងនឹងការងារអភិរក្សនេះដែរ **ឯកឧត្តម យិត ចាន់ដារដ្ឋ** ក៏បានរំឭកពីកិច្ចសហប្រតិបត្តិការជាមួយ ស្ថាប័នជាច្រើនរបស់ចិនកន្លងមក ដែលស្ថាប័នទាំងនោះបាននិងកំពុងជួយលើការងារអភិរក្សនៅតាមប្រាសាទ នៃរមណីយដ្ឋានអង្គរ ដូចជាប្រាសាទតាកែវ ប្រាសាទចៅសាយទេវតា និងប្រាសាទភិមានអាកាសជាដើម។ល។ ឯកឧត្តមសង្ឃឹមថា រដ្ឋាភិបាលក្រុងថាតុង នឹងពន្លឿនកិច្ចសហប្រតិបត្តិការឱ្យបានរហ័ស ក្នុងន័យបង្កើនទំនាក់ទំនងរវាងស្ថាប័នទាំងពីរឱ្យកាន់តែប្រសើរលើវិស័យបេតិកភណ្ឌ៕

វឌ្ឍនភាពការជួសជុលស្ពានហាលខាងកើត នៃប្រាសាទបេងមាលា

ផ្សាយនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៤

ដំណើរការជួសជុលស្ពានហាលខាងកើត នៃប្រាសាទបេងមាលា ដែលក្រុមអ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរា រយៈពេលជាង៣ខែមកនេះ បានធ្វើឱ្យផ្នែកជាច្រើនប្រែក្លាយទៅជាល្អប្រសើរឡើងវិញជាជំហានៗ។ ដោយបានជួសជុលកម្រាលស្ពានហាល បង្កាន់ដៃនាគ តួខ្លួននាគ ជើងទម្រនាគ ផ្ទឹម និងសសរសេងខាងស្ពាននៅផ្នែកខាងជើង បានប្រមាណជាង៤០ភាគរយហើយ។

ស្ពានហាលខាងកើតប្រាសាទបេងមាលា ដែលរងការខូចខាត បានចាប់ផ្តើមដំណើរការជួសជុល តាំងតែពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៤ ក្រោមមូលនិធិពិសេស របស់មេគង្គ-ឡានឆាង។

អ្នកស្រី បឿត សុប៉ាក បុគ្គលិកបច្ចេកទេសនៃអាជ្ញាធរជាតិអប្សរា ឱ្យដឹងថា ជំហានដំបូងក្រុមការងារបានចាប់ផ្តើមជួសជុលនៅផ្នែកខាងជើងនៃស្ពានហាល ដោយចាប់ផ្តើមពីក្បាលនាគនៅទិសខាងកើត។ ក្រុមការងារបានជួសជុលពង្រឹងគ្រឹះដែលស្រុត ដោយជំនួសថ្មបាយក្រៀមថ្មីដែលពុកផុយ។ រៀបផ្គុំកម្រាលថ្មភក់នៃស្ពានហាល ដំឡើងធ្នឹមបង្កាន់ដៃនាគ ជើងទម្រនាគ សសរសេងខាងស្ពានហាល និងតភ្ជាប់បំណែកក្បាលនាគដែលបែកជាបីបំណែកនៅតាមទីតាំងដើមបានមួយចំហៀង គឺនៅសល់តែផ្នែកខាងត្បូងមួយចំហៀងទៀតប៉ុណ្ណោះ។

អ្នកស្រី បឿត សុប៉ាក បញ្ជាក់ថា ការងារជួសជុលស្ពានហាលនៅផ្នែកខាងជើងនៃស្ពានហាល សម្រេចបានប្រមាណជាង៤០ភាគរយ ហើយបច្ចុប្បន្ន ក្រុមការងាររបស់អាជ្ញាធរជាតិអប្សរា កំពុងជួសជុលដោយយកចិត្តទុកដាក់ ដើម្បីឱ្យការងារប្រព្រឹត្តិទៅដោយរលូន និងត្រូវតាមលំនាំដើមបុរាណឡើងវិញ។ មិនតែប៉ុណ្ណោះ ក្រុមការងារក៏មានសេចក្តីត្រេកអរចំពោះការងារជួសជុលនេះដែរ ដោយហេតុថា ក្រុមការងារបានរកឃើញថ្មនៃរចនាសម្ពន្ធរបស់ស្ពានហាលនេះស្ទើរតែពេញលេញទាំងមូលឡើងវិញ។ រីឯ ថ្មភក់មួយចំនួនដែលបាក់បែក ខូចខាត ក្រុមការងារបានជួសជុលពង្រឹង និងអាចយកទៅរៀបផ្គុំទៅទីតាំងដើម។

បន្ទាប់ពីបញ្ចប់ការជួសជុលនៅផ្នែកខាងជើងរួច ក្រុមការងារនឹងចាប់ផ្តើមផ្នែកខាងត្បូងជាបន្តទៀត៕

សប្តាហ៍ទី១ នៃខែវិច្ឆិកា ឆ្នាំ២០២៤ ក្រុមការងារសហគមន៍ បន្តចុះពិនិត្យសំណើពលរដ្ឋនៅក្នុងរមណីយដ្ឋានអង្គរ បានចំនួន៦៦ករណី និងសម្រេចអនុញ្ញាត បានចំនួន ៥៨ករណី

ផ្សាយនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៤

ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងរមណីយដ្ឋានអង្គរត្រូវបានទទួលនូវការយកចិត្តទុកដាក់អំពីសំណាក់អាជ្ញាធរជាតិអប្សរា ដោយមានការអនុគ្រោះក្នុងការជួសជុលតូចតាចនូវលំនៅដ្ឋានក៏ដូចជាសំណង់ឧបសម្ព័ន្ធមាន របងដំបូល ជញ្ជាំង សសរពុកផុយ បង្គន់អនាម័យ រោងគោ ទ្រុងមាន់ និងទ្រុងជ្រូកជាដើម ហើយរាល់ការអនុញ្ញាតជួសជុលមានសុពលភាពត្រឹមពីរខែ នៅលើទីតាំងកំពុងរស់នៅផ្ទាល់តែម្តងតាមរយៈការចុះពិនិត្យ និងសម្រេចជាប្រចាំដោយក្រុមការងារសហគមន៍នាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា។ ជាក់ស្តែងក្នុងសប្តាហ៍ទី១នៃខែវិច្ឆិកា ក្រុមការងារសហគមន៍បានចុះ ពិនិត្យសំណើបានចំនួន៦៦ករណី និងសម្រេចអនុញ្ញាតបានចំនួន ៥៨ករណី ទៅតាមបណ្តាលស្រុក/ក្រុងទាំង៦ ដូចខាងក្រោម៖

- ស្រុកបន្ទាយស្រីអនុញ្ញាតបាន ១៥ករណី
- ស្រុកពួកអនុញ្ញាតបាន ៣ករណី
- ក្រុងសៀមរាបអនុញ្ញាតបាន ២៦ករណី
- ស្រុកអង្គរធំអនុញ្ញាតបាន ១៣ករណី
- ស្រុកប្រសាទបាគងអនុញ្ញាតបាន ១ករណី

សូមជម្រាបថា រាល់ការដាក់ពាក្យស្នើសុំច្បាប់ និងការអនុញ្ញាត គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ។ ជាមួយគ្នានេះ ក្រុមការងារសង្កេតឃើញថា ក៏មានអ្នកដែលទទួលបានការអនុញ្ញាតហើយ ប៉ុន្តែពុំបានអនុវត្តត្រឹមត្រូវស្របនឹងការអនុញ្ញាតនោះឡើយ។

ដូច្នេះអាជ្ញាធរជាតិអប្សរា សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតឱ្យជួសជុលលំនៅដ្ឋានត្រូវអនុវត្តឲ្យស្របតាមចំណុចបច្ចេកទេសដែលមានការទទួលដឹងលឺ ពីអាជ្ញាធរមូលដ្ឋាន និងទទួលស្គាល់ដោយអាជ្ញាធរជាតិអប្សរា៕

ទេសចរចម្រុះជាតិសាសន៍យ៉ាងច្រើនកុះករ បានសម្រុកមកទស្សនាអង្គរវត្ត ក្នុងថ្ងៃទីមួយនៃពិធីបុណ្យអុំទូក

ផ្សាយនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៤នេះ ភ្ញៀវទេសចរជាតិ និងអន្តរជាតិយ៉ាងច្រើនកុះករ បានសម្រុកមកទស្សនាប្រាសាទអង្គរវត្ត ដែលជាថ្ងៃទីមួយក្នុងឱកាសនៃពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក។

រមណីយដ្ឋានអង្គរសូមស្វាគមន៍ទេសចរជាតិ និងអន្តរជាតិពីគ្រប់ទិសទី អញ្ជើញមកកម្សាន្តក្នុងឱកាសនៃពិធីបុណ្យអុំទូក។ សូមការធ្វើដំណើរកម្សាន្តប្រកដោយសុខសុវត្ថិភាពនិងភាពសប្បាយរីករាយ៕

ភ្នាក់ងារទេសចរ និងភ្នាក់ងារសណ្តាប់ធ្នាប់ បានជួយសម្រួលចរាចរណ៍ជូនភ្ញៀវទេសចរ ដែលមកទស្សនារមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៤

នាថ្ងៃទី២ នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងអកអំបុក សំពះព្រះខែ ក្រុមភ្នាក់ងារទេសចរ និងភ្នាក់ងារសណ្តាប់ធ្នាប់របស់អាជ្ញាធរជាតិអប្សរា ដែលប្រចាំការនៅទីតាំងប្រាសាទនានា បានជួយសម្រួលដល់ការធ្វើដំណើរ និងការចតយានយន្តរបស់ភ្ញៀវទេសចរ ដែលមកទស្សនារមណីយដ្ឋានអង្គរ ដើម្បីរក្សាបាននូវសណ្តាប់ធ្នាប់ល្អ និងសុវត្ថិភាពចំពោះភ្ញៀវទេសចរ។

រូបភាពប្រចាំសប្តាហ៍៖ បន្ទាយក្តី សំណល់ប្រាសាទល្អឯក មិនចាញ់ប្រាសាទធំៗដទៃ

ផ្សាយនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៤

ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិ ទស្សនាក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៤នេះ ភ្ញៀវទេសចរជាតិ និងអន្តរជាតិយ៉ាងច្រើនកុះករ បានចូលមកទស្សនារមណីយដ្ឋានអង្គរ ដែលជាថ្ងៃទី៣ក្នុងឱកាសនៃពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក។

អាជ្ញាធរជាតិអប្សរា សូមអំពាវនាវដល់ភ្ញៀវទេសចរចូលរួមថែរក្សាបរិស្ថាន គោរពក្រមប្រតិបត្តិអង្គរ បើកបរដោយប្រុងប្រយ័ត្នយោគយល់អធ្យាស្រ័យ និងចូលចតនៅទីចំណតបានត្រឹមត្រូវ។ ការធ្វើដំណើរកម្សាន្តសុខសុវត្ថិភាព និងដំណើរកម្សាន្តប្រកបដោយស្នាមញញឹមភាពសប្បាយរីករាយគ្រប់ៗគ្នា៕

អាជ្ញាធរជាតិអប្សរា យកចិត្តទុកដាក់រក្សាសណ្តាប់ធ្នាប់ និងសុវត្ថិភាពដល់ភ្ញៀវទេសចរ នៅក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៤

ដើម្បីរក្សាបាននូវសណ្តាប់ល្អ និងសុខសុវត្ថិភាពដល់ភ្ញៀវទេសចរនៅក្នុងរមណីយដ្ឋានអង្គរ ក្រុមការងារភ្នាក់ងារទេសចរ និងក្រុមការងារភ្នាក់ងារសណ្តាប់ធ្នាប់នៃអាជ្ញាធរជាតិអប្សរា បានយកចិត្តទុកដាក់បំពេញការងារតាមតួនាទីនៅតាមគោលដៅរបស់ខ្លួនយ៉ាងខ្ជាប់ខ្ជួន។ ជាពិសេស ក្នុងឱកាសនៃពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក រយៈពេលបីថ្ងៃកន្លងមក៕

អាជ្ញាធរជាតិអប្សរា រៀបចំសិក្ខាសាលាស្តីពី «ការពង្រឹងសមត្ថភាព និងតួនាទីភារកិច្ចអ្នកគ្រប់គ្រងប្រាសាទ» ដល់សិក្ខាកាមចំនួន៨០នាក់

ផ្សាយនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា រៀបចំសិក្ខាសាលាស្តីពី«ការពង្រឹងសមត្ថភាព និងតួនាទីភារកិច្ចអ្នកគ្រប់គ្រងប្រាសាទ»ដល់សិក្ខាកាមចំនួន៨០នាក់ ដែលមកពីនាយកដ្ឋានសណ្តាប់ធ្នាប់ នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា និងនាយកដ្ឋានទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ ដែលបម្រើការងារតាមប្រាសាទនានា ក្នុងរមណីយដ្ឋានអង្គរ។ សិក្ខាសាលានេះបានប្រព្រឹត្តទៀងក្រោមអធិបតីភាព **ឯកឧត្តម ឡុង កុសល** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅនាយកដ្ឋានសណ្តាប់ធ្នាប់។

វគ្គសិក្ខាសាលាមានគោលបំណង ចែករំលែកចំណេះដឹង ដើម្បីបង្កើនសមត្ថភាពក្នុងការគ្រប់គ្រងការងារប្រចាំថ្ងៃ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ធានាឱ្យបាននូវកិច្ចការពារការងារអភិរក្ស ការលើកតម្លៃសម្បត្តិវប្បធម៌ធម្មជាតិ និងបង្កើនកិច្ចសហការរវាងនាយកដ្ឋាននីមួយដោយបង្កើតផែនការគ្រប់គ្រងរួមនៅតាមប្រាសាទនីមួយៗក្នុងរមណីយដ្ឋានអង្គរ។

ឯកឧត្តម ឡុង កុសល មានប្រសាសន៍ក្នុងឱកាសនោះថា សិក្ខាសាលាថ្ងៃនេះពិតជាមានសារសំខាន់ក្នុងការចូលរួមចំណែកដុសខាត់ចំណេះដឹង និងបង្កើនសមត្ថភាពបំពេញការងាររបស់សិក្ខាកាម តាមរយៈការធ្វើបទបង្ហាញពីថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកជំនាញដែលជាវាគ្មិនមកពីនាយកដ្ឋាននានា ដែលពួកគាត់សុទ្ធតែមានបទពិសោធន៍យូរឆ្នាំលើការងាររបស់ពួកគាត់រៀងៗខ្លួន។ ឯកឧត្តមក៏បានសំណូមពរឲ្យរៀបចំផែនការគ្រប់គ្រងរួមដោយផ្អែកលើផែនទីហានីភ័យរួមមួយ ហើយធ្វើសកម្មភាពដើម្បីលុបបំបាត់ភាពហានីភ័យទាំងនោះ។

ឯកឧត្តមសង្ឃឹមថា សិក្ខាកាមទាំងអស់នឹងទទួលបាននូវចំណេះដឹងថ្មីៗបន្ថែមទៀតសម្រាប់យកទៅអនុវត្តការងារប្រចាំថ្ងៃរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពខ្ពស់នៅពេលបញ្ចប់វគ្គសិក្សានេះ៕

សេចក្តីជូនដំណឹង ស្តីពីការកាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើមានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៖ ៤២០/២៤ អ.ស.ស៧
២៤

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើ
មានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់មន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន ក៏ដូចជាដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវ នៅតាមបរិវេណប្រាសាទក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា អាជ្ញាធរជាតិអប្សរានឹងកាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើ នៅតាមទីតាំងនានាដូចខាងក្រោម៖

- កាត់ដកហូត និងកាត់ក្រីមែកឈើចំនួន០៥ដើម (កាត់ដកហូតដើមត្នោតងាប់ស្រពោនស្លឹក១ដើម ដើមស្រឡៅងាប់១ដើម កាត់ក្រីដើមក្រឡាញ់១ដើម ដើមស្លែងគង់១ដើម និងដើមសិរមាន់១ដើម) ស្ថិតនៅបរិវេណប្រាសាទនាគព័ន្ធ។
- កាត់ដកហូតដើមឈើទាលចំនួន០១ដើម ស្ថិតនៅបរិវេណចំណតរថយន្តភ្នំបាខែង។

ក្រុមការងារនៃអាជ្ញាធរជាតិអប្សរានឹងចាប់ផ្តើមអនុវត្តការងារខាងលើ ចាប់ពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ តទៅរហូតដល់ចប់ភារកិច្ច។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមមន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ ចន្ទ ៣ រោច ខែ កត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
សៀមរាប ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០២៤
អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្កោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

អាជ្ញាធរជាតិអប្សរា សហការជាមួយសាកលវិទ្យាល័យHARDING ដាំកូនឈើក្នុងបរិវេណរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤

ឆ្លៀតឱកាសក្នុងដំណើរទស្សនកិច្ចមកកាន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងសិក្សាស្វែងយល់អំពីវប្បធម៌របស់ប្រទេសក្នុងតំបន់អាស៊ីអគ្នេយ៍ នាចុងសប្តាហ៍កន្លងទៅ សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យHARDING របស់សហរដ្ឋអាមេរិក ចំនួន៤៥នាក់ បានសហការជាមួយអាជ្ញាធរជាតិអប្សរា ចូលរួមដាំកូនឈើចម្រុះចំនួន៣០០ដើម តាមដងស្ទឹងសៀមរាប ស្ថិតនៅខាងជើងស្ពានបច្ចេកទេស នៃឧទ្យានអង្គរ។ ការងារនេះ ដើម្បីចូលរួមក្នុងយុទ្ធនាការដាំដើមឈើ ដើម្បីអភិរក្សរមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោក សម្រាប់បន្សល់ទុកជាស្នាដៃការងារសង្គម និងកិច្ចការពារបរិស្ថាន ប្រយុទ្ធប្រឆាំងការប្រែប្រួលអាកាសធាតុ និងទុកជាអនុស្សាវរីយ៍នៃការចងចាំក្នុងរមណីយដ្ឋានអង្គរផង៕

អាជ្ញាធរជាតិអប្សរា បញ្ចប់ការងារជួសជុលចម្លាក់ក្បាលមករ

ផ្សាយនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៤

ប្រព័ន្ធបង្ហូរទឹកបុរាណ ជាចម្លាក់សត្វមករ ដែលអាជ្ញាធរជាតិអប្សរា បានចាប់ផ្តើមជួសជុលដំណាក់កាលទី១ នាពាក់កណ្តាលខែឧសភា ឆ្នាំ២០២៤ បានបញ្ចប់ដោយជោគជ័យនៅខែវិច្ឆិកា ឆ្នាំ២០២៤នេះ។

អ្នកស្រីបឿត សុប៉ាកវិស្វករនៃអាជ្ញាធរជាតិអប្សរា ឱ្យដឹងថា ការងារជួសជុលប្រព័ន្ធបង្ហូរទឹកចម្លាក់សត្វមករ ក្នុងដំណាក់កាលទី១ ក្នុងប្រវែង១៨ម៉ែត្រ។ ដើម្បីជួសជុលប្រព័ន្ធបង្ហូរទឹកនៃចម្លាក់សត្វមករនេះឡើងវិញ ក្រុមការងារបានសម្រង់ប្លង់ថ្មរាយប៉ាយ កំណាយស្រាវជ្រាវ ចុះបញ្ជីថ្ម ជួសជុលពង្រឹងថ្មដែលខូចខាត និងរៀបចំដងខ្លួនសត្វមករតាមលំនាំដើមឡើងវិញ។ លើសពីនេះ ក្រុមការងារបានសិក្សាគ្រឹះធ្វើយ៉ាងណាឱ្យចម្លាក់សត្វមករនេះរឹងមាំយូរអង្វែង ដោយការពារនូវការហូរច្រោះនៃទឹក ដែលជាបញ្ហាចម្បងនៃការបំផ្លាញរចនាសម្ពន្ធនៃចម្លាក់សត្វមករកទាំងមូល។

អ្នកជំនាញរូបនេះ រម្លឹកថា មុនជួសជុលស្ថានភាពនៃចម្លាក់សត្វមករ ថ្មនៃដងខ្លួនបានចល័តចេញពីទីតាំងដើម នៅរាយប៉ាយជាមួយថ្មធម្មជាតិ លែងមានតួនាទីជាប្រព័ន្ធបង្ហូរបន្តទៀត ដោយសារកត្តាអាយុកាល ពុំមានការថែទាំជាពិសេសការហូរច្រោះនៃទឹកបំផ្លាញគ្រឹះ និងរំកិលថ្មធម្មជាតិដែលទ្រដងខ្លួនមករជាដើម។ ប៉ុន្តែបច្ចុប្បន្ននេះ អាជ្ញាធរជាតិអប្សរា បានបញ្ចប់ការជួសជុលលើកតម្លៃចម្លាក់សត្វមករទោល ដែលមានទំហំធំ និងកម្របានរួចរាល់ឡើងវិញ ដោយភ្ញៀវទេសចរអាចមកទស្សនាស្វែងយល់។ ក្រៅពីទំនប់ទឹកមុជ និងចម្លាក់សត្វមករទីនេះក៏មានការដ្ឋានយកថ្មទៅកសាងប្រាសាទនៅសម័យបុរាណផង។ ស្របពេលជាមួយការជួសជុលចម្លាក់សត្វមករនេះ អាជ្ញាធរជាតិអប្សរា បានរៀបចំកែសម្រួលផ្លូវចូលមកទីតាំងនេះ អាចធ្វើដំណើរបានដោយងាយស្រួលដែរ។

សូមបញ្ជាក់ថា ចម្លាក់សត្វមករ មានទីតាំងនៅទំនប់ទឹកមុជជាទំនប់ទឹកបុរាណ ស្ថិតនៅក្នុងភូមិទឹកលិច ឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប នាជ្រុងនិរតីចម្ងាយប្រមាណ៣គីឡូម៉ែត្រពីប្រាសាទបេងមាលា៕

អាជ្ញាធរជាតិអប្សរា បានបញ្ចប់ការជួសជុលព្រះវិហារ វត្តដំណាក់ រួចរាល់ជាស្ថាពរ

ផ្សាយនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៤

វត្តដំណាក់ មានទីតាំងស្ថិតនៅតាមបណ្តោយដងស្ទឹងសៀមរាប ត្រើយម្ខាងផ្សារចាស់ ក្នុងភូមិវត្តដំណាក់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប។ ក្រោមកិច្ចខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ពីសំណាក់ ថ្នាក់ដឹកនាំ មន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរា ព្រះវិហារដែលបានជួសជុលមួយរយៈកន្លងមក បច្ចុប្បន្នគឺបានរួចរាល់ ១០០ភាគរយហើយ។

អាជ្ញាធរជាតិអប្សរា សង្ឃឹមយ៉ាងមុតមាំថា ក្រោយការជួសជុល សំណង់ព្រះវិហារនេះអាចបំពេញតួនាទីរបស់ខ្លួនបន្តទៅទៀត សម្រាប់ពុទ្ធសាសនិកចូលបំពេញបុណ្យ ក៏ដូចជាព្រះសង្ឃបំពេញកិច្ចវត្ត និងផ្តល់ប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវ និងការសិក្សារៀនសូត្រ ជាពិសេស រក្សាបាននូវមរតកពីបុរាណ ព្រមទាំងអាចទាក់ទាញចំណាប់អារម្មណ៍របស់ទេសចរមកទស្សនាស្វែងយល់បន្ថែម ក្រៅពីសំណង់ប្រាសាទបុរាណរបស់យើងផងដែរ៕

អាជ្ញាធរជាតិអប្សរា រៀបចំកម្មវិធីផ្លាស់ប្ដូរ និងចែករំលែកបទពិសោធន៍ស្ដីពី "សារមន្ទីរ និង និរន្តរភាព"

ផ្សាយនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤

នៅរសៀលថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៤ នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ នៃអាជ្ញាធរជាតិអប្សរា បានរៀបចំកម្មវិធីផ្លាស់ប្ដូរ និងចែករំលែកបទពិសោធន៍ស្ដីពី សារមន្ទីរ និងនិរន្តរភាព ដែលកម្មវិធីនេះរៀបចំឡើងរយៈពេល៤ថ្ងៃ គឺថ្ងៃទី១៩ ដល់ថ្ងៃទី២២ ខែវិច្ឆិកា នៅសារមន្ទីរវាយណភណ្ឌ និងប្រពៃណីអាស៊ី។

មន្ត្រី និងបុគ្គលិកនៃសារមន្ទីរទាំងបីរបស់អាជ្ញាធរជាតិអប្សរា និងស្ថាប័នពាក់ព័ន្ធសរុបចំនួន៣០រូប បានចូលរួមក្នុងកម្មវិធីផ្លាស់ប្ដូរ និងចែករំលែកបទពិសោធន៍ស្ដីពី សារមន្ទីរ និងនិរន្តរភាព។ ខាងអាជ្ញាធរជាតិអប្សរាដែលបានចូលរួម រួមមាន នាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ ព្រមទាំងមានការអញ្ជើញឱ្យចូលរួមផងដែរពីសារមន្ទីរជាតិអង្គរ សារមន្ទីរជាតិភ្នំពេញ សារមន្ទីរព្រះស្រីឦសានវរ្ម័ន សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងសារមន្ទីរខេត្តព្រះវិហារ ដែលអ្នកចូលរួមមានដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ។

លោក យូ ចន្ថា មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ និងជាអ្នកសម្របសម្រួលរៀបចំកម្មវិធីខាងលើបានឱ្យដឹងថា ការងារនេះធ្វើឡើងក្នុងបំណងដើម្បីបញ្ជ្រាប និងបង្ហាញពីការគ្រប់គ្រង និងអភិវឌ្ឍន៍សារមន្ទីរ ដែលមានរួមបញ្ចូលទស្សនៈទាន «និរន្តរភាព»។ វាគ្មិនជំនាញដែលចូលរួមធ្វើបទបង្ហាញមកពីប្រទេសបារាំង ចិន ឥណ្ឌា សាំងហ្គាពួរ ប្រេស៊ីល បេណាំង យ៉ូហ្គេនដា កូឡុំប៊ី កូរ៉េខាងត្បូង និងប៉ារ៉ាហ្គាយ។ អ្នកជំនាញទាំងនេះនឹងធ្វើបទបង្ហាញតាមអនឡាញពីការរៀបចំ និងគ្រប់គ្រងសារមន្ទីរប្រភេទផ្សេងៗគ្នា ដើម្បីឱ្យអ្នកចូលរួមអាចយល់ និងយល់ពីការគ្រប់គ្រង ព្រមទាំងវិធីសាស្ត្រនៃការរៀបចំពិព័រណ៍អចិន្ត្រៃយ៍ និងមិនអចិន្ត្រៃយ៍ សកម្មភាពវប្បធម៌ កម្មវិធីអប់រំជាដើម របស់សារមន្ទីរ ដែលបានគិតគូរដល់គោលការណ៍គ្រឹះទាំង១៧ នៃនិរន្តរភាព។

សូមបញ្ជាក់ថា កម្មវិធីខាងលើរៀបចំដោយអាជ្ញាធរជាតិអប្សរា ដោយមានការគាំទ្រពីក្រុមប្រឹក្សាអន្តរជាតិនៃសារមន្ទីរកម្ពុជា (ICOM Cambodia) និងទីស្នាក់ការកណ្ដាលនៃក្រុមប្រឹក្សាអន្តរជាតិនៃសារមន្ទីរនៅទីក្រុងបារីស (ICOM Headquarter in Paris)៕

សប្តាហ៍ទី២នៃវិច្ឆិកា ឆ្នាំ២០២៤ ក្រុមការងារសហគមន៍ បន្តចុះពិនិត្យសំណើពលរដ្ឋនៅក្នុងរមណីយដ្ឋានអង្គរ បានចំនួន២២ករណី និងសម្រេចអនុញ្ញាតបានចំនួន ២០ករណី

ផ្សាយនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤

ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងរមណីយដ្ឋានអង្គរត្រូវបានទទួលនូវការយកចិត្តទុកដាក់អំពីសំណាក់អាជ្ញាធរជាតិអប្សរា ដោយមានការអនុគ្រោះក្នុងការជួសជុលតូចតាចនូវលំនៅដ្ឋានក៏ដូចជាសំណង់ឧបរសម្ព័ន្ធមាន របង ដំបូល ជញ្ជាំង សសរពុកផុយ បង្គន់អនាម័យ រោងគោ ទ្រុងមាន់ និងទ្រុងជ្រូកជាដើម ហើយរាល់ការអនុញ្ញាតជួសជុលមានសុពលភាពត្រឹមពីរខែ នៅលើទីតាំងកំពុងរស់នៅផ្ទាល់តែម្តងតាមរយៈការចុះពិនិត្យ និងសម្រេចជាប្រចាំដោយក្រុមការងារសហគមន៍នាយកដ្ឋានគ្រប់គ្រងដីធ្លីបេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា។ ជាក់ស្តែងក្នុងសប្តាហ៍ទី២នៃខែវិច្ឆិកា ក្រុមការងារសហគមន៍បានចុះ ពិនិត្យសំណើបានចំនួន២២ករណី និងសម្រេចអនុញ្ញាតបានចំនួន ២០ករណី ទៅតាមបណ្តាលស្រុក/ក្រុងទាំង៦ ដូចខាងក្រោម៖

- ស្រុកបន្ទាយស្រីអនុញ្ញាតបាន ៨ករណី
- ស្រុកប្រាសាទបាគងអនុញ្ញាតបាន ២ករណី
- ស្រុកពួកអនុញ្ញាតបាន ១ករណី
- ក្រុងសៀមរាបអនុញ្ញាតបាន ៩ករណី

សូមជម្រាបថា រាល់ការដាក់ពាក្យស្នើសុំច្បាប់ និងការអនុញ្ញាត គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ។ ជាមួយគ្នានេះ ក្រុមការងារសង្កេតឃើញថា ក៏មានអ្នកដែលទទួលបានការអនុញ្ញាតហើយ ប៉ុន្តែពុំបានអនុវត្តត្រឹមត្រូវ ស្របនឹងការអនុញ្ញាតនោះឡើយ។

ដូច្នេះអាជ្ញាធរជាតិអប្សរា សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតឱ្យជួសជុលលំនៅដ្ឋានត្រូវអនុវត្តឲ្យស្របតាមចំណុចបច្ចេកទេសដែលមានការទទួលដឹងលឺ ពីអាជ្ញាធរមូលដ្ឋាន និងទទួលស្គាល់ដោយអាជ្ញាធរជាតិអប្សរា៕

អាជ្ញាធរជាតិអប្សរា សហការជាមួយអង្គការ មូលនិធិប្រាសាទពិភពលោករៀបចំសិក្ខាសាលាស្ដីពី ការវាយតម្លៃហានិភ័យដោយការប្រែប្រួលអាកាសធាតុនៅតំបន់អង្គរ

ផ្សាយនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ អាជ្ញាធរជាតិអប្សរា សហការជាមួយអង្គការមូលនិធិប្រាសាទពិភពលោក (World Monument Fund) ក្រោមគម្រោង Preserving Legacies បានរៀបចំសិក្ខាសាលាស្តីពីការវាយតម្លៃហានិភ័យដោយការប្រែប្រួលអាកាសធាតុនៅតំបន់អង្គរ ដែលរៀបចំឡើងនៅស្នាក់ការនាយកដ្ឋានសណ្ដាប់ធ្នាប់ នៃអាជ្ញាធរជាតិអប្សរា។

មានប្រសាសន៍ចូលរួមបើកកម្មវិធីសិក្ខាសាលានេះ **ឯកឧត្តម គឹម សុធិន** អគ្គនាយករងអាជ្ញាធរជាតិអប្សរា ថ្លែងអំណរគុណដល់គម្រោង Preserving Legacies ដែលមានស្ថាប័ន ICOMOS, Climate Heritage Network អង្គការ WMF និង National Geographic Society បានរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីចំនួន៣រូប របស់អាជ្ញាធរជាតិអប្សរា និង១រូបទៀតមកពីមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រះវិហារ តាមអនឡាញ និងដោយផ្ទាល់នៅប្រទេសហ្សកដានី និងប្រទេសហ្វីលីពីន ដោយផ្តោតការយកចិត្តទុកដាក់លើការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់លើតំបន់បេតិកភណ្ឌ។ ឯកឧត្តមបន្តថា បច្ចុប្បន្នអាជ្ញាធរជាតិអប្សរា មានការយកចិត្តទុកដាក់ខ្ពស់ និងរៀបចំក្រុមការងារវាយតម្លៃហានិភ័យនៃការប្រែប្រួលអាកាសធាតុសម្រាប់រមណីយដ្ឋានអង្គរ។ បន្ថែមពីនេះ ឯកឧត្តមអគ្គនាយករង បានណែនាំឱ្យសិក្ខាកាមទាំងអស់ដែលជាថ្នាក់ដឹកនាំ អ្នកអាស្រ័យផល និងសហគមន៍រស់នៅក្នុងតំបន់អង្គរ យកចិត្តទុកដាក់រៀនសូត្រ និងស្វែងយល់ពីចំណុចសំខាន់ៗពីវាគ្មិន ដើម្បីយកចំណេះដឹងមកប្រើប្រាស់ក្នុងបុព្វហេតុអភិរក្សរមណីយដ្ឋានអង្គរឱ្យមាននិរន្តរភាព កាត់បន្ថយភាពងាយរងគ្រោះ និងផលប៉ះពាល់ដល់គុណតម្លៃលេចធ្លោជាសកលផ្នែកប្រវត្តិសាស្ត្រ វប្បធម៌ សេដ្ឋកិច្ច និងបរិស្ថាន ដែលកើតឡើងដោយការប្រែប្រួលអាកាសធាតុជាសកលនេះ។

លោកស្រី Victoria Hermann នាយកគម្រោង Preserving Legacies បានថ្លែងអំណរគុណដល់អាជ្ញាធរជាតិអប្សរា ក្នុងភាពជាដៃគូដើម្បីអនុវត្តន៍គម្រោងបណ្តុះបណ្តាលខាងលើ។ លោកស្រីបន្តថា ការថែរក្សាមរតកបេតិកភណ្ឌឱ្យមាននិរន្តរភាព គឺមានសារសំខាន់ណាស់ សម្រាប់មនុស្សជាតិបច្ចុប្បន្ន និងទៅអនាគត ហើយការសិក្សាពីការគ្រប់គ្រងអាកាសធាតុ នឹងជួយឱ្យយើងមានភាពឈ្លាសវៃដើម្បីការពារ និងអភិរក្សមរតកវប្បធម៌នានាឱ្យបានគង់វង្សសម្រាប់មនុស្សជំនាន់ក្រោយទៀត។

សូមបញ្ជាក់ថា សិក្ខាសាលាខាងលើរៀបចំឡើងរយៈពេល ២ថ្ងៃ គឺថ្ងៃទី២០-២១ ខែវិច្ឆិកា ឆ្នាំ២០២៤ ក្នុងនោះមានការសិក្សាទាំងទ្រឹស្តី និងចុះកម្មសិក្សាផ្ទាល់នៅតាមប្រាសាទ និងការដ្ឋាននានាក្នុងរមណីយដ្ឋានអង្គរផងដែរ៕

អាជ្ញាធរជាតិអប្សរាកំពុងជួសជុលជណ្តើរមុខនៅផ្នែកខាងលិចឆៀងខាងជើង និងជួយសង្គ្រោះក្បាច់ចម្លាក់នៅប្រាសាទភ្នំក្រោម ដែលកំពុងរងការខូចខាតធ្ងន់ធ្ងរ

ផ្សាយនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៤

ក្រុមអ្នកអភិរក្សថ្មរបស់អាជ្ញាធរជាតិអប្សរា កំពុងបន្តការជួសជុលជណ្តើរមុខនៅផ្នែកខាងលិច ឆៀងខាងជើង ដែលស្ថិតក្នុងស្ថានភាពហែកចេញពីគ្នា ព្រមទាំងផ្នែកខ្លះនៃរចនាសម្ពន្ធជណ្តើរជាច្រើនផ្នែកទៀត ឱ្យប្រសើរឡើងវិញ។ ជាមួយគ្នានេះ ក្រុមអ្នកជំនាញ ក៏កំពុងជួយសង្គ្រោះក្បាច់ចម្លាក់នៅតាមតួប៉មកណ្តាលផ្នែកខាងលិច និងតួប៉មខាងជើងនៃជ្រុងខាងលិច ឆៀងខាងត្បូង ដែលមានចម្លាក់នៅសល់តិចតួចបំផុត ហើយកំពុងមានសភាពពុកផុយខ្លាំងកុំឱ្យបាត់បង់ផងដែរ។

ការជួសជុលនេះ បន្ទាប់ពីក្រុមអ្នកអភិរក្សថ្ម បានបញ្ចប់ជួសជុលជណ្តើរតួប៉មកណ្តាល ផ្នែកខាងលិច និងចម្លាក់តោនៃប្រាសាទភ្នំក្រោមរួចមក។

អ្នកអភិរក្សថ្ម លោក ឡុង ណារី ឱ្យដឹងថា ការជួសជុលជណ្តើរមុខនៅផ្នែកខាងលិច ឆៀងខាងជើងរបស់ប្រាសាទភ្នំក្រោមនេះ គឺចែកជា២ដំណាក់កាល។ ដំណាក់កាលទី១ គឺជួសជុលពង្រឹងគ្រឹះជណ្តើរមុខផ្នែកខាងលិច ឆៀងខាងជើង និងកម្រាលថ្មភក់។ ដំណាក់កាលទី២ គឺជួសជុលសង្គ្រោះក្បាច់ចម្លាក់នៅតួប៉មកណ្តាលមុខផ្នែកខាងលិច និងតួប៉មខាងជើងជ្រុងខាងលិចឆៀងខាងត្បូង ដែលចម្លាក់ទាំងនោះ នៅសេសសល់តិចតួចបំផុត ហើយថ្មកំពុងមានស្ថានភាពពុកផុយខ្លាំង។

អ្នកអភិរក្សថ្មដដែលឱ្យដឹងទៀតថា ការខូចខាតរចនាសម្ព័ន្ធជណ្តើរមុខនៅផ្នែកខាងលិច ឆៀងខាងជើងរបស់ប្រាសាទភ្នំក្រោម បណ្តាលមកពីអាយុកាលនៃសម្ភារសំណង់ថ្មបាយក្រៀមមានសភាពពុកផុយគ្មានលំនឹង។ បច្ចេកទេសនៃការជួសជុលជណ្តើរ គឺត្រូវរុះរើថ្មកាំជណ្តើរ និងគ្រឹះទម្រ មកសម្អាតកំណកដី ហើយផ្នែកកម្រាលក្រោម គឺត្រូវប្រើកម្ទេចថ្មមកបង្ហាប់ដី។ រីឯដុំថ្មកាំជណ្តើរដែលបាក់បែក ត្រូវតភ្ជាប់ឬក៏ជំនួសដោយថ្មថ្មី រួចហើយចាប់រៀបផ្គុំទៅតាមទីតាំងដើមនៃរចនាសម្ព័ន្ធឡើងវិញ ព្រមទាំងប្រើបាយអបិទភ្ជិតមុខតំណដើម្បីឱ្យទឹកហូរចេញនិងជ្រាបចូលគ្រឹះប្រាសាទដាដើម។

គម្រោងជួសជុលជណ្តើរមុខនៅផ្នែកខាងលិច ឆៀងខាងជើង និងសង្គ្រោះក្បាច់ចម្លាក់នៅប្រាសាទភ្នំក្រោមនេះ ចាប់ផ្តើមតាំងពីខែកញ្ញា ឆ្នាំ២០២៤ គម្រោងនេះអាចនឹងបញ្ចប់នាដំណាច់ឆ្នាំ២០២៤ខាងមុខ៕

អាជ្ញាធរជាតិអប្សរា ប្រកាសរកម្ចាស់ទូរសព្ទ ដែលជ្រុះឬភ្លេចនៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា ប្រកាសស្វែងរកម្ចាស់ទូរសព្ទប្រភេទ Samsung Galaxy Note ១០ ពណ៌ខ្មៅចំនួនមួយគ្រឿង ដែលបានជ្រុះ ឬភ្លេចនៅប្រាសាទអង្គរវត្ត។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមម្ចាស់របស់ខាងលើ អាចទាក់ទងមកយកតាមរយៈក្រុមការងារភ្នាក់ងារទេសចរ នៃអាជ្ញាធរជាតិអប្សរា និងនគរបាលទេសចរណ៍ ប្រចាំគោលដៅប្រាសាទអង្គរវត្ត៕

រូបភាពប្រចាំសប្តាហ៍៖
បក្សីចាំក្រុង ជាប្រាសាទតូចប្រទាឡីឯមួយ ដែលមានឃឿន៣ថ្នាក់ សាងឡើងរវាងដើមស.វទី១០ ក្រោយពេលដែលប្រាសាទលើភ្នំបាខែងសាងរួចហើយ

ផ្សាយនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា គ្រោងនឹងបញ្ចប់ការជួសជុលប្រាង្គG15 នៃប្រាសាទភ្នំបាខែង នៅចុងឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៤

ការងារជួសជុលប្រាង្គG15 នៃប្រាសាទភ្នំបាខែង ដោយក្រុមអ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរា មកពីនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា បានចាប់ផ្តើមនៅខែឧសភាហើយគ្រោងនឹងបញ្ចប់នៅខែធ្នូ ឆ្នាំ២០២៤ ខាងមុខនេះ។

អ្នកស្រីឈុនរតនាបុរាណវិទូនៃអាជ្ញាធរជាតិអប្សរាឱ្យដឹងថា ការងារជួសជុលប្រាង្គG15 រយៈពេល៦ខែ កន្លងនេះ បានសម្រេចបាននូវការងារដូចជា ជួសជុលជញ្ជាំងផ្នែកខាងក្នុង ជួសជុលខ្លោងទ្វារទិសខាងកើត ជួសជុលពង្រឹងខឿនខាងត្បូង និងកំពុងបន្តពន្លឿនការងារជួសជុលជញ្ជាំងផ្នែកខាងត្បូង ខាងជើងមកដល់បច្ចុប្បន្ន សម្រេចការងារសរុបបានប្រមាណ៩៥ភាគរយហើយ។

អ្នកស្រី រតនា ឱ្យដឹងទៀតថា ប្រាង្គនេះមានហានិភ័យខ្លាំង១ក្នុងចំណោមប្រាង្គដែលសាងអំពីថ្មបាយក្រៀម និងឥដ្ឋ ដែលទាមទារឱ្យជួសជុលជាបន្ទាន់ ដើម្បីការពារកុំឱ្យជញ្ជាំងឥដ្ឋដែលនៅសល់ដួលរលំ។

អ្នកជំនាញរូបនេះ បញ្ជាក់ថា មុនជួសជុល ប្រាង្គG15 មានស្ថានភាពខូចខាតដោយសារអាយុកាល កង្វះការថែទាំ រុក្ខជាតិដុះជ្រែកឥដ្ឋប្រាសាទ និងកត្តាទឹកភ្លៀងជ្រាបចូលរចនាសម្ពន្ធប្រាសាទ ធ្វើឱ្យប្រាសាទរងការពុកផុយនៅផ្នែកកំពូលខាងលើ និងនៅតាមជ្រុងនីមួយៗជាបន្តបន្ទាប់។ ដូច្នេះហើយ ក្រុមការងាររបស់អាជ្ញាធរជាតិអប្សរា បានជួសជុលទប់ស្កាត់ការខូចខាតជាបន្តទៀត ដើម្បីការពារជម្រាបទឹក ការពាររុក្ខជាតិដុះ ដើម្បីឱ្យប្រាង្គនេះ មានភាពរឹងមាំយូរអង្វែងបន្តទៀត៕

សេចក្ដីជូនដំណឹង
ស្ដីពីការដាក់ឱ្យប្រើប្រាស់ជណ្ដើរឈើថ្មីនៅជ្រុងអាគ្នេយ៍នៃរូតបាកានប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ ៤៣១/អប.ស៧ណ
២៤

សេចក្ដីជូនដំណឹង
ស្ដីពី
ការដាក់ឱ្យប្រើប្រាស់ជណ្ដើរឈើថ្មីនៅជ្រុងអាគ្នេយ៍នៃរូតបាកានប្រាសាទអង្គរវត្ត

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិ និងសាធារណៈជនទាំងអស់ឱ្យបានជ្រាបថា ដើម្បីអភិរក្ស និងជួសជុលរូតបាកានជ្រុងឦសាននៃប្រាសាទអង្គរវត្ត អាជ្ញាធរជាតិអប្សរានឹងដាក់ឱ្យប្រើប្រាស់ជណ្ដើរឈើថ្មីនៅជ្រុងអាគ្នេយ៍នៃរូតបាកានប្រាសាទអង្គរវត្ត ជំនួសជណ្ដើរឈើនៅជ្រុងឦសានបច្ចុប្បន្ន ចាប់ពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៤ នេះតទៅ។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិ និងសាធារណៈជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ១០រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
សៀមរាប ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤
អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្កោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

អាជ្ញាធរជាតិអប្សរា បញ្ចប់ការជួសជុលរានហាល នៅទិសខាងកើតប៉ែកខាងជើង នៃប្រាសាទបន្ទាយសំរ៉ែ នៅចុងឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៤

ការងារជួសជុលរចនាសម្ពន្ធរបស់រានហាលនៅទិសខាងកើតប៉ែកខាងជើងនៃប្រាសាទបន្ទាយសំរ៉ែ ផ្នែកខាងលិចដណ្តើរ ដែលចាប់ផ្តើមតាំងតែពីកំឡុងខែមករា រហូតមកដល់ពេលនេះ បានសម្រេចបានប្រមាណ៩០ភាគរយ គ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០២៤ខាងមុខនេះ។

លោក ឡុង ណារី អ្នកជំនាញអភិរក្សថ្មនៃនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា ឱ្យដឹងថា ការងារជួសជុលរចនាសម្ពន្ធរានហាលនៅទិសខាងកើតប៉ែកខាងជើងនៃប្រាសាទបន្ទាយសំរ៉ែ ផ្នែកខាងលិចដណ្តើរ បានចំណាយពេលជិត១ឆ្នាំ ដោយត្រូវសិក្សាបន្ថែម និងស្វែងរកបំណែកថ្មនៃបង្កាន់ដៃនាគដើម្បីយកមកជួសជុលឡើងវិញ ដោយសារតែរចនាសម្ពន្ធនៃរានហាលមានសភាពទ្រុឌទ្រោមខ្លាំង ដូចជា សសររបស់រានហាលពុកផុយ ចម្លាក់បង្កាន់ដៃនាគ និងជើងទម្រនាគបានដួលរលំបាក់បែកនៅលើរានហាល និងមួយផ្នែកទៀតជ្រុះធ្លាក់កប់ក្នុងដី ហើយថ្មមួយចំនួនបានចល័តចេញពីទីតាំងដើម និងធ្លាប់ត្រូវបានជួសជុលម្តងហើយនៅសម័យបារាំង។

លោក ឡុង ណារី បន្ថែមថា ដោយសារតែរចនាសម្ពន្ធរានហាលនេះ មានភាពទ្រុឌទ្រោមខ្លាំង គឺក្រុមការងារត្រូវចំណាយពេលស្វែងរកថ្ម និងប្រមូលបំណែកថ្មទាំងនោះមកផ្គុំរកទីតាំងដើមឡើងវិញ។ ចំណែកថ្មដែលខូចខាតមួយចំនួនក៏ត្រូវជួសជុលពង្រឹង ដោយផ្នែកខ្លះត្រូវប៉ះភ្ជាប់ជាមួយថ្មថ្មី និងផ្នែកខ្លះទៀតដែលបាត់បង់ ឬខូចខាតខ្លាំងត្រូវបន្ថែមថ្មថ្មី ដើម្បីភាពរឹងមាំរបស់រចនាសម្ពន្ធរានហាលនៃប្រាសាទនេះ។

សូមបញ្ជាក់ថា ការជួសជុលរានហាលនៅទិសខាងកើតប៉ែកខាងជើងនៃប្រាសាទបន្ទាយសំរ៉ែ ផ្នែកខាងលិចជណ្តើរក្រោមកិច្ចសហប្រតិបត្តិការរវាងស្ថាប័នអាជ្ញាធរជាតិអប្សរា និងស្ថាប័នអាល្លឺម៉ង់ GIZ ក្នុងគោលបំណងបណ្តុះបណ្តាលជំនាញផ្នែកអភិរក្សថ្ម ក្នុងជំនាន់ទី២ ដល់មន្ត្រី-បុគ្គលិករបស់អាជ្ញាធរជាតិអប្សរាចំនួន២០នាក់ សម្រាប់សិក្សារៀនសូត្រ និងអនុវត្តផ្ទាល់ក្នុងការដ្ឋាន ដោយមានការបណ្តុះបណ្តាលផ្ទេរចំណេះដឹងពីអ្នកជំនាញជាន់មុនដល់អ្នកបន្តវេនជំនាន់ក្រោយក្នុងកិច្ចការជួសជុល អភិរក្សប្រាសាទក្នុងតំបន់អង្គរ បានកាន់តែប្រសើរឡើង៕

ឯកឧត្តម អគ្គនាយកអាជ្ញាធរជាតិអប្សរា អញ្ជើញចូលរួមជាវាគ្មិនក្នុង International Festival Diversity of Cultural Expression, The World in Florence, Community Heritage លើកទី៤

ផ្សាយនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៤

ឯកឧត្តមបណ្ឌិត ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា ចូលរួមជាវាគ្មិនកិត្តិយសក្នុងកម្មវិធី International Festival Diversity of Cultural Expression, The World in Florence, Community & Heritage លើកទី៤ ដោយបានលើកយកនូវបទពិសោធន៍ នៃកិច្ចការអភិរក្ស និងអភិវឌ្ឍប្រកបដោយចីរភាពក្នុងរមណីយដ្ឋានអង្គរដើម្បីចែករំលែកដល់កម្មវិធីទាំងមូល។

ក្នុងឱកាសនេះដែរ ឯកឧត្តមបណ្ឌិត ក៏បានជួបពិភាក្សាជាមួយប្រធានកិត្តិយស និងប្រធានរបស់ Fondazione Romualdo Del Bianco ដែលជាស្ថាប័នអ្នករៀបចំកម្មវិធីខាងលើ ដើម្បីបង្កើននូវកិច្ចសហប្រតិបត្តិការនាថ្ងៃអនាគត៕

ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៤ ភ្នាក់ងារទេសចររបស់អាជ្ញាធរជាតិអប្សរា សហការជាមួយភ្នាក់ងារសណ្តាប់ធ្នាប់ នគរបាលទេសចរណ៍ នគរបាលបេតិកភណ្ឌ ប្រចាំតំបន់អង្គរ ប្រគល់ការបូបស្ពាយចំនួនមួយ ជូនភ្ញៀវទេសចរជនជាតិអ៊ីតាលី ដែលជាម្ចាស់វិញ ក្រោយពីគាត់បានភ្លេចនៅទិសខាងត្បូងរួតទីមួយ នៃប្រាសាទបាយ័ន កំឡុងពេលដើរទស្សនា

ផ្សាយនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៤



សេចក្តីជូនដំណឹង ស្តីពីការបិទចរាចរការចូលទស្សនា នៅទីតាំងប្រាសាទមួយចំនួន ក្នុងទិវារត់ប្រណាំងពាក់កណ្តាលម៉ារ៉ាតុង អន្តរជាតិអង្គរលើកទី២៩ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៤

សិស្សថ្នាក់បឋមសិក្សាក្នុងរមណីយដ្ឋានអង្គរចំនួន៣សាលា ទទួលបានការអប់រំឱ្យចេះកាត់បន្ថយនិងទុកដាក់សំរាមឱ្យបានត្រឹមត្រូវ

ផ្សាយនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៤

សិស្សបឋមសិក្សាចំនួន ៣សាលាទទួលបានការអប់រំបរិស្ថាន ដែលកម្មវិធីនេះរៀបចំឡើងដោយស្ថាប័នជានាគុណភាពជប៉ុន Japan Quality Organization ហៅកាត់ថា (JQA) អាជ្ញាធរជាតិអប្សរា សាកលវិទ្យាល័យ សូហ្វីយ៉ា និង មន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប។ សិស្សដែលត្រូវបានបង្រៀនមានថ្នាក់ទី ៤ដល់ទី៦ នៅតាមសាលាចំនួន៣ ក្នុងរមណីយដ្ឋានអង្គរ មានសាលាបឋមសិក្សាគោកគ្រើល សាលាបឋមដូនឪ និងសាលាបឋមសិក្សាត្រពាំងស្វាយ។

សូមបញ្ជាក់ថា គម្រោងអបរំបរិស្ថានបានចូលមកក្នុងតំបន់អង្គរ ក្រោយស្ថាប័នជានាគុណភាពជប៉ុន បានធ្វើការបញ្ចូលប្រព័ន្ធគ្រប់គ្រងបរិស្ថាន ISO14001 នៅក្នុងអាជ្ញាធរជាតិអប្សរា ហើយដើម្បីធ្វើសកម្មភាពផ្ទាល់ ស្ថាប័នជានាគុណភាពនេះ ក៏បានដំណើរការគម្រោងរបស់ខ្លួន ដើម្បីជាចំណេះដឹងចំពោះក្មេងៗឱ្យមានទម្លាប់ល្អទាក់ទងនឹងបរិស្ថានចាប់ពីតូចៗនេះតទៅ៕

អាជ្ញាធរជាតិអប្សរាដាក់ដំណើរការជណ្តើរឡើងចុះរួតបាកាននៅជ្រុងអាគ្នេយ៍

ផ្សាយនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៤នេះ អាជ្ញាធរជាតិអប្សរា បានរៀបចំពិធីប្រោសព្រំដើម្បីរៀបចំ ដាក់ឱ្យដំណើរការ ជណ្តើរជ្រុងអាគ្នេយ៍រួតបាកានប្រាសាទអង្គរវត្ត ដើម្បីសម្រួល ដល់ការឡើងចុះរបស់ភ្ញៀវទេសចរ។

លោក ទេស សុធីរ អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ ទេសចរណ៍និងវប្បធម៌នៃអាជ្ញាធរជាតិអប្សរាបានឱ្យដឹងថា ការងាររៀបចំជណ្តើរថ្មីនេះ ធ្វើឡើងដើម្បីសម្រួលដល់ ការងារឡើងចុះរបស់ភ្ញៀវទេសចរ នៅរួតបាកាន ខណៈដែល ជណ្តើរបច្ចុប្បន្ននៅជ្រុងឦសាននឹងរើចេញ ដើម្បីសម្រួល ដល់ការងារជួសជុលខឿនប្រាសាទ នៃរួតបាកាន។ ជណ្តើរ ថ្មីនេះមានប្រវែង១៥ម៉ែត្រ និងទទឹង២.២៥ម៉ែត្រ ដែល សាងសង់រយៈពេល៣ខែ។

បើតាមការបញ្ជាក់ពីលោក ទេស សុធីរ ការសាងសង់គឺមានភាពរឹងមាំ ដោយប្រើប្រាស់ដែក ជាគម្រោងផ្នែកខាងក្រោម និង កាំជណ្តើរធ្វើពីឈើ។ ក្នុងនោះជណ្តើរនេះបានសម្រិតសម្រាំង និងប្រើប្រាស់ពណ៌ឱ្យស៊ីនឹងសាច់ថ្មប្រាសាទផងដែរ។ លោក ទេស សុធីរ សំណូមពរឱ្យភ្ញៀវទេសចរ ឡើងចុះនៅរួតបាកានដោយមានការប្រុងប្រយ័ត្នខ្ពស់ ដើម្បីជានាសុវត្ថិភាព។

គួរបញ្ជាក់ថា ជណ្តើរចាស់ដែលនៅជ្រុងឦសាននឹងត្រូវរើចេញ ស្របពេលដែលអាជ្ញាធរជាតិអប្សរា សហការជាមួយ ទីភ្នាក់ងារកូរ៉េដើម្បីបេតិកភណ្ឌ កំពុងរៀបចំគម្រោងជួសជុលខឿនបាកាន៕

អគ្គនាយកអាជ្ញាធរជាតិអប្សរា ទទួលស្វាគមន៍គណៈប្រតិភូ និងភ្ញៀវកិត្តិយសអន្តរជាតិ ចូលរួមកិច្ចប្រជុំកំពូលសៀមរាប-អង្គរ មកទស្សនាប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៤

ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា អមដំណើរដោយឯកឧត្តមអគ្គនាយករង នៅរសៀលថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៤នេះ បានអញ្ជើញទទួលបដិសណ្ឋាកិច្ចចំពោះវត្តមាន **ឯកឧត្តមបណ្ឌិត លី ធុជ** ទេសរដ្ឋមន្ត្រី អនុប្រធានទី១ អាជ្ញាធរមីននិងជាប្រធានអនុសញ្ញាអូតាវ៉ាឆ្នាំ២០២៤ ព្រមទាំងគណៈប្រតិភូតំណាងឱ្យ១០៥ប្រទេស និងអង្គការអន្តរជាតិសំខាន់ៗជាង៥០ស្ថាប័នទៀត ចូលរួមកិច្ចប្រជុំកំពូលសៀមរាប-អង្គរ អញ្ជើញទស្សនាប្រាសាទអង្គរវត្តនៃរមណីយដ្ឋានអង្គរ៕

អ្នកជំនាញអភិរក្សវត្ថុបុរាណអំពីថ្មភក់នៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ

ផ្សាយនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៤

សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ដែលស្ថិតនៅក្នុងភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប ជាសារមន្ទីរបែបព្រះពុទ្ធសាសនា តាំងបង្ហាញ និងរក្សាទុកនូវវត្ថុសិល្បៈដែលបានមកពីកំណាយស្រាវជ្រាវនានានៅក្នុងតំបន់អង្គរ។

បច្ចុប្បន្នទីនោះ មិនត្រឹមតែជាកន្លែងរក្សាទុកវត្ថុសិល្បៈបុរាណជាច្រើនប្រភេទ និងដាក់តាំងបង្ហាញឱ្យភ្ញៀវជាតិអន្តរជាតិបានទស្សនាប៉ុណ្ណោះទេ គឺថែមទាំងមានអ្នកជំនាញអភិរក្សវត្ថុបុរាណនានាឱ្យមានភាពរឹងមាំយូរអង្វែងបន្តទៀត។

លោក កង ច័ន្ទតារា ជាប្រធានក្រុមការងារអភិក្សវត្ថុបុរាណផ្នែកថ្មភក់ នៅក្នុងសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ឱ្យដឹងថា បច្ចុប្បន្ន នៅក្នុងសារមន្ទីរ ព្រះនរោត្តមសីហនុ-អង្គរ គឺមានអ្នកជំនាញផ្នែកអភិរក្សថ្មភក់ ចំនួន៣នាក់ តែងធ្វើការសម្អាតវត្ថុសិល្បៈបុរាណដែលអាជ្ញាធរជាតិអប្សរាបានរកឃើញ និងយកមករក្សាទុកនៅទីនោះ។

លោក កង ច័ន្ទតារា បញ្ជាក់ទៀតថា ជាច្រើនឆ្នាំមកនេះ ក្រុមរបស់លោកអភិរក្សវត្ថុបុរាណ រួមមានធ្វើពីថ្មភក់ លោហៈ និងកុលាលភាជន៍ជាដើម។ ក្នុងការងារអភិរក្សវត្ថុបុរាណទាំងនោះ មុនដំបូងត្រូវធ្វើការសម្អាតស្ងួត សម្អាតកំណកដី សម្អាតស្លែ និងសម្អាតផ្ទៃវត្ថុសិល្បៈទាំងមូលដោយប្រុងប្រយ័ត្ន ចៀសវាងការខូចខាត និងរក្សាបាននូវរូបរាងដើមរបស់វត្ថុសិល្បៈ។ វត្ថុបុរាណទាំងនោះ បន្ទាប់ពីទទួលបានការអភិក្សហើយ ត្រូវយកទៅរក្សាទុក ឬក៏វត្ថុខ្លះត្រូវដាក់តាំងបង្ហាញអចិន្ត្រៃយ៍ និងមិនអចិន្ត្រៃយ៍សម្រាប់ឱ្យភ្ញៀវជាតិ និងអន្តរជាតិបានទស្សនា។

ចាប់តាំងពីកំឡុងខែតុលា ឆ្នាំ២០២៤ រហូតមកដល់បច្ចុប្បន្ន ក្រុមអ្នកជំនាញនៃសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ កំពុងធ្វើការសម្អាតវត្ថុបុរាណមួយចំនួនទៀត ដែលក្រុមអ្នកស្រាវជ្រាវទើបតែបានរកឃើញដូចជា ព្រះកេសរបស់ទេវរូប ចំនួន២ ដែលយកមកពីខ្លោងទ្វារជ័យនៃក្រុងអង្គរធំ បំណែកចម្លាក់ទ្វារបាល ដែលយកមកពីប្រាសាទបន្ទាយប្រី ចំនួន៧បំណែក និងសិលាចារឹក១ផ្ទាំង ដែលមានលេខសម្គាល់ K170 យកមកពីការិយាល័យវប្បធម៌ស្រុកជីក្រែង។ល។

ក្រុមការងារអភិរក្សថ្មភក់ បានឱ្យដឹងថា ថ្វីត្បិតតែវត្ថុបុរាណនៅក្នុងសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ បច្ចុប្បន្នមានការអភិរក្ស ដើម្បីឱ្យវត្ថុទាំងនោះមានភាពរឹងមាំ និងសោភ័ណភាពឡើងវិញក្តី ក៏ប៉ុន្តែ ចំពោះវត្ថុសិល្បៈខ្លះដែលបាក់បែក គឺមិនទាន់មានការជួសជុលឱ្យល្អឡើងវិញទេ។ ក្រុមអ្នកអភិរក្សវត្ថុបុរាណនៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ក៏ស្នើសុំឱ្យអ្នកជំនាញផ្នែកជួសជុល ជួយជួសជុលវត្ថុសិល្បៈបុរាណជាច្រើននោះ ឱ្យបានល្អឡើងវិញផងដែរ៕

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែធ្នូ

អាជ្ញាធរជាតិអប្សរា សហការជាមួយក្រុមហ៊ុនមេនូឡាយហ្វ៍ ដាំកូនឈើចំនួន៣ពាន់ដើម នៅក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៤

ឯកឧត្តមបណ្ឌិត ហង់ ពៅ អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា និងថ្នាក់ដឹកនាំជាច្រើនរូបទៀត បានសហការជាមួយក្រុមហ៊ុនមេនូឡាយហ្វ៍ធ្វើពិធីដាំកូនឈើចម្រុះចំនួន៣០០០ដើម នៅក្នុងឧទ្យានសហគមន៍អង្គរ-មេនូឡាយហ្វ៍ កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៤។

ឯកឧត្តមបណ្ឌិត ហង់ ពៅ អគ្គនាយកនៃអាជ្ញាធរជាតិអប្សរាបានថ្លែងក្នុងពេលបើកកម្មវិធីនៃការដាំកូនឈើនោះថា ដើមឈើពិតជាមានសារសំខាន់ខ្លាំងណាស់សម្រាប់ជួយដល់ប្រាសាទបុរាណ។ ការណ៍មិនមានដើមឈើនៅជុំវិញប្រាសាទបុរាណ គឺនៅពេលដែលមានខ្យល់បក់ខ្លាំង វានឹងបំផ្លាញទៅដល់ប្រាសាទបុរាណជាច្រើន។ ក៏ប៉ុន្តែប្រសិនបើមានដើមឈើនៅជុំវិញប្រាសាទបុរាណ គឺអាចជួយទប់ស្កាត់កម្លាំងខ្យល់ខ្លាំង ហើយការពារប្រាសាទបុរាណនានាបាន។ បន្ថែមលើនេះ ដើមឈើក៏មានតួនាទីជួយកាត់បន្ថយជាតិពុលនៅក្នុងបរិស្ថាន និងជួយការពារព្រះអាទិត្យមិនឱ្យជះកម្ដៅខ្លាំងមកលើថ្មប្រាសាទបុរាណ ដែលនាំឱ្យខូចខាតផងដែរ។

ឯកឧត្តមអគ្គនាយកមានប្រសាសន៍ទៀតថា ការចូលរួមរបស់ក្រុមហ៊ុនមេនូឡាយហ្វ៍ ដែលមានមនុស្សចម្រុះជាតិសាសន៍នៅពេលនេះ គឺមានសារសំខាន់យ៉ាងខ្លាំងក្នុងការចូលរួមជួយថែរក្សាអង្គរ។ ការដាំដើមឈើជុំវិញរមណីយដ្ឋានប្រាសាទបុរាណ គឺជាការបង្កើតខ្សែក្រវ៉ាត់បៃតងនៅជុំវិញប្រាសាទបុរាណ និងក៏ជាការជួយសង្គ្រោះដល់សម្បត្តិបេតិកភណ្ឌរបស់យើងគ្រប់គ្នា។ សម្បត្តិបេតិកភណ្ឌនេះ មិនមែនជារបស់កម្ពុជាប៉ុណ្ណោះទេ វាក៏ជាសម្បត្តិបេតិកភណ្ឌរបស់មនុស្សគ្រប់គ្នានៅក្នុងពិភពលោកផងដែរ។

ចាប់តាំងពីអំឡុងឆ្នាំ២០០៤មក អាជ្ញាធរជាតិអប្សរា បានដាំដើមឈើជាច្រើនកន្លែង នៅក្នុងតំបន់រមណីយដ្ឋានអង្គរចំនួនជាង២លានដើមមកហើយ៕

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត អញ្ជើញជាអធិបតីក្នុងទិវារត់ប្រណាំងអន្តរជាតិពាក់កណ្តាលម៉ារ៉ាតុងអង្គរ លើកទី២៩

ផ្សាយនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៤

ព្រឹកថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៤នេះ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត បានអញ្ជើញជាអធិបតីក្នុងទិវារត់ប្រណាំងអន្តរជាតិ ពាក់កណ្តាលម៉ារ៉ាតុងអង្គរ លើកទី២៩ នៅខេត្តសៀមរាប ព្រមជាមួយវត្តមានឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិចំនួនជិត១ម៉ឺន៤ពាន់នាក់បានចូលរួមផងដែរ៕

ក្រុមអ្នកជំនាញការអាដហុក នៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ និងសំបូរព្រៃគុក ចុះពិនិត្យតាមដានវឌ្ឍនភាពការងារអភិរក្ស និងអភិវឌ្ឍន៍ នៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៤

ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៤នេះ ក្រុមអ្នកជំនាញការអាដហុក បានអញ្ជើញចុះពិនិត្យតាមដានវឌ្ឍនភាពការងារអភិរក្ស និងកិច្ចការអភិវឌ្ឍន៍នៅរមណីយដ្ឋានអង្គរ អមដំណើរដោយ **ឯកឧត្តម គឹម សុធិន** អគ្គនាយករងអាជ្ញាធរជាតិអប្សរា និងមន្ត្រីជំនាញខ្មែរ។ ការចុះពិនិត្យនេះ ធ្វើឡើងដើម្បីពិភាក្សាស្វែងយល់អំពីដំណើរការជួសជុលបន្ទាន់ដល់រចនាសម្ពន្ធដែលកំពុងប្រឈមនឹងគ្រោះថ្នាក់។ ទន្ទឹមនឹងនេះដែរក្រុមអ្នកជំនាញការអាដហុក ក៏បានផ្តល់អនុសាសន៍ដល់ក្រុមការងារជំនាញខ្មែរអំពីកិច្ចការផ្សេងៗដែលកំពុងធ្វើ នឹងត្រៀមធ្វើនៅពេលអនាគត៕

អាជ្ញាធរជាតិអប្សរា បញ្ចប់ការជួសជុល ប្រាង្គលេខ៧ នៃប្រាសាទបាគង ដោយជោគជ័យ

ផ្សាយនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២៤

ប្រាសាទប្រាង្គលេខ៧ ស្ថិតនៅខាងជើងប្រាង្គកណ្តាលនៃប្រាសាទបាគង ក្នុងកំពែងទី១ មានកម្ពស់១៤.៥០ម៉ែត្រ ទទឹង ៧.៤០ម៉ែត្រ ដែលអ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរា បានចាប់ផ្តើមជួសជុលនៅក្នុងដំណាក់កាលទី២ តាំងពីខែឧសភា ឆ្នាំ២០២៤ រហូតមកដល់ចុងខែវិច្ឆិកា ឆ្នាំ២០២៤នេះ បានបញ្ចប់ដោយជោគជ័យហើយ។

លោកសារាយគឹមហួលប្រធានអភិរក្សតំបន់រលួសឱ្យដឹងថា នៅដំណាក់កាលទី២នេះ អាជ្ញាធរជាតិអប្សរា បានជួសជុលប្រាង្គឥដ្ឋលេខ៧នេះនៅផ្នែកខាងត្បូង ខាងជើង និងខាងលិច ដែលរងការខូចខាតខ្លាំងចាប់ពីគ្រឹះជណ្តើររហូតដល់កំពូល និងប្រើក្រវ៉ាត់ដែកការពារបន្ថែមនៅផ្នែកកំពូលផង ដែលបានធ្វើឱ្យប្រាង្គលេខ៧ មានភាពរឹងមាំឡើងវិញ។

អ្នកជំនាញរូបនេះ បន្តថាមុនជួសជុលប្រាង្គទី៧នេះ មានសភាពខូចខាតខ្លាំង គឺចាប់ពីរួតទី១ដល់រួតទី៥ នៅតាមជ្រុងនីមួយៗបានពុកផុយ ឥដ្ឋមួយចំនួនបានរលុះធ្លាក់។ តួប្រាសាទប្រេះចាប់ពីគ្រឹះដល់កំពូលប្រាសាទ និងជណ្តើរទាំង៣ជ្រុងបានរលុះឥដ្ឋ ហើយថ្មភក់កាំជណ្តើរធ្លាក់រប៉ាត់រប៉ាយមិនមានសណ្តាប់ធ្នាប់ជាដើម។ ការខូចខាត គឺបណ្តាលមកពីកត្តាអាយុកាលជាង១ពាន់ឆ្នាំនៃសំណង់ កត្តាធម្មជាតិ ដែលអាកាសធាតុក្តៅសើម អំណោយផលដល់ស្លែ និងរុក្ខជាតិដុះ ដែលបង្ករហានិភ័យដល់ប្រាសាទឥដ្ឋធ្ងន់ធ្ងរ។

លោក គឹមហួល បញ្ជាក់ដោយទឹកមុខរំភើបថា ក្រោយពីបញ្ចប់ការងារជួសជុល ប្រាង្គលេខ៧ មានភាពរឹងមាំឡើងវិញហើយ ចៀសផុតពីហានិភ័យ ដោយអាជ្ញាធរជាតិអប្សរា បានសង្គ្រោះបន្ទាន់ បានទាន់ពេលវេលា រក្សានូវសុវត្ថិភាពដល់ប្រាសាទ និងភ្ញៀវទេសចរដែលមកទស្សនា៕

ក្រុមអ្នកជំនាញការអាដហុក នៃគណៈកម្មាធិការអន្តរជាតិ សម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់រមណីយដ្ឋាន ប្រវត្តិសាស្ត្រអង្គរ និងសំបូរព្រៃគុក ចុះពិនិត្យតាមដានវឌ្ឍនភាព ការងារអភិរក្ស និងអភិវឌ្ឍន៍ នៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២៤

នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២៤នេះ ក្រុមអ្នកជំនាញការអាដហុក បានអញ្ជើញចុះពិនិត្យតាមដានវឌ្ឍនភាពការងារអភិរក្ស និងកិច្ចការអភិវឌ្ឍន៍នៅរមណីយដ្ឋានអង្គរ អមដំណើរដោយ **ឯកឧត្តម បណ្ឌិតហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា និងមន្ត្រីជំនាញ បានបន្តចុះពិនិត្យការងារតាមការដ្ឋានមួយចំនួនក្នុងតំបន់រមណីយដ្ឋានអង្គរ មានដូចជា៖ ប្រាសាទព្រះគោ និងប្រាសាទប្រែរូប។ ការចុះពិនិត្យនេះធ្វើឡើងដើម្បីពិភាក្សាស្វែងយល់អំពីដំណើរការជួសជុលបន្ទាន់ដល់រចនាសម្ពន្ធដែលកំពុងប្រឈមនឹងគ្រោះថ្នាក់។ ទន្ទឹមនឹងនេះដែរ ក្រុមអ្នកជំនាញការអាដហុក ក៏បានផ្តល់អនុសាសន៍ដល់ក្រុមការងារជំនាញខ្មែរអំពីកិច្ចការផ្សេងៗដែលកំពុងធ្វើ នឹងត្រៀមធ្វើនៅពេលអនាគត៕

រូបភាពផ្លូវថ្មើរជើងថ្មីនៅខាងត្បូងនៃផ្លូវចូលខាងកើតប្រាសាទអង្គរវត្ត



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៤៦០/រស.ទជសា/២៤

សេចក្តីជូនដំណឹង
ស្តីពី
ការដាក់ឱ្យប្រើប្រាស់ផ្លូវថ្មើរជើងថ្មី នៅខាងត្បូងនៃផ្លូវចូលខាងកើតប្រាសាទអង្គរវត្ត

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិ និងសាធារណៈជនទាំងអស់ឱ្យបានជ្រាបថា ដើម្បីធានាសុវត្ថិភាព និងផាសុខភាពជូនដល់ភ្ញៀវទេសចរជាតិ-អន្តរជាតិ ដែលអញ្ជើញមកទស្សនាប្រាសាទអង្គរវត្ត អាជ្ញាធរជាតិអប្សរានឹងដាក់ឱ្យប្រើប្រាស់ផ្លូវថ្មើរជើងថ្មី នៅខាងត្បូងនៃផ្លូវចូលខាងកើតប្រាសាទអង្គរវត្ត ចាប់ពីកន្លែងត្រួតពិនិត្យសំបុត្រប្រាសាទអង្គរវត្ត ដល់ខ្លោងទ្វារខាងកើត ចាប់ពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤ តទៅ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិ និងសាធារណៈជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ២កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
សៀមរាប ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៤
អាជ្ញាធរជាតិអប្សរា

APSARA National Authority
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576
Address: Bang Kong Village, Ampil Commune, Prasat Bakong District, Siem Reap Province

សេចក្តីជូនដំណឹង ស្តីពីការដាក់ឱ្យប្រើប្រាស់ផ្លូវថ្មើរជើងថ្មី នៅខាងត្បូងនៃផ្លូវចូលខាងកើតប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា នឹងបញ្ចប់ការងារជួសជុល ប្រាសាទឥដ្ឋ ជ្រុងឦសាន នៃប្រាសាទភ្នំក្រោម ចុងឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៤

រយៈពេលជាង៥ខែមកហើយ ដែលក្រុមអ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរា ជួសជុលប្រាសាទឥដ្ឋនៅជ្រុងឦសាននៃប្រាសាទភ្នំក្រោម ដែលគ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០២៤នេះ។

លោក រស់ វិសុទ្ធ អ្នកគ្រប់គ្រងការដ្ឋានជួសជុលប្រាសាទភ្នំក្រោម បានលើកឡើងថា ដំណើរការងារដំបូង ក្រុមការងារបានធ្វើសម្រង់ប្លង់ រៀបចំឯកសារជួសជុលពង្រឹងគ្រឹះជុំវិញ ជួសជុលពង្រឹងទីតាំងដែលឥដ្ឋពុកផុយរលុះ មានសសរផ្តោប ជញ្ជាំងជើងខឿន ក្បាលជញ្ជាំង។ ជាពិសេសជ្រុងពាយ័ព្យដែលមានស្ថានភាពរលុះឥដ្ឋធ្ងន់ធ្ងរ ត្រូវបានជួសជុលពង្រឹងបានរឹងមាំឡើងវិញ។ បច្ចុប្បន្នក្រុមការងារបានបន្តជួសជុលនៅផ្នែកកំពូលដំពូលខាងលើនៃតួប្រាសាទ ដែលសម្រេចបាន៩០ភាគរយ គ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០២៤នេះ។

អ្នកជំនាញរូបនេះ បញ្ជាក់ថា ប្រាសាទឥដ្ឋនៅជ្រុងឦសាននៃប្រាសាទភ្នំក្រោមនេះ បើមើលពីខាងក្រៅ ឃើញថាមានការខូចខាតតិចតួច។ ប៉ុន្តែបើការសិក្សាស៊ីជម្រៅ ប្រាសាទនេះ មានការខូចខាតធ្ងន់ធ្ងរប្រឈមនឹងការរលំនៅជ្រុងពាយ័ព្យ និងផ្នែកដំបូល។ ការជួសជុល បានសង្គ្រោះប្រាសាទនេះឱ្យរួចផុតពីហានិភ័យទប់ស្កាត់ការខូចខាតបានទាន់ពេលវេលា ហើយបច្ចុប្បន្នប្រាង្គមានភាពរឹងមាំឡើងវិញ និងរក្សាបានទម្រង់ដើមស្ទើរតែទាំងស្រុង ដោយក្រុមការងារបានខិតខំធ្វើយ៉ាងណាបំពេញការងារបានទាន់ពេលវេលា មានភាពរឹងមាំ និងត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស បន្តអាយុកាលយូរអង្វែងដល់កូនខ្មែរជំនាន់ក្រោយ៕

ក្រុមអ្នកជំនាញការអាដហុក បន្តចុះពិនិត្យការងារនៅតាមការដ្ឋាន ក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៤

នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៤ ក្រុមអ្នកជំនាញការអាដហុក នៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ និង សំបូរព្រៃគុក បានបន្តចុះពិនិត្យតាមដានវឌ្ឍនភាពការងារ អភិរក្ស និងអភិវឌ្ឍន៍ នៅរមណីយដ្ឋានអង្គរ ដោយក្នុង នោះនៅពេលព្រឹក បានចុះពិនិត្យស្ពានហាលខាងលិច ប្រាសាទអង្គរវត្ត រោងទងខាងត្បូងប្រាសាទអង្គរវត្ត បណ្ណាល័យខាងត្បូងនៃរួតទី២ប្រាសាទអង្គរវត្ត បាកាន អង្គរវត្ត និងខ្លោងទ្វារខាងកើតប្រាសាទអង្គរវត្ត។ ចំណែក នៅពេលរសៀលវិញ ក្រុមអ្នកជំនាញការបានចុះទៅ ពិនិត្យការដ្ឋានជួសជុលប្រាសាទភិមានអាកាស និងក្រុម ប្រាសាទព្រះពិធូរ នៃក្រុងអង្គរធំ៕

ក្រុមអ្នកជំនាញការអាដហុក បន្តចុះពិនិត្យការងារនៅតាមការដ្ឋាន ក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២៤

នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤ ក្រុមអ្នកជំនាញការអាដហុក នៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ និងសំបូរព្រៃគុក បានបន្តចុះពិនិត្យតាមដានវឌ្ឍនភាពការងារអភិរក្ស និងអភិវឌ្ឍន៍ នៅរមណីយដ្ឋានអង្គរ ដោយក្នុងនោះ នៅពេលព្រឹកបានចុះពិនិត្យការដ្ឋានប្រាសាទបន្ទាយក្តី និងប្រាសាទតាព្រហ្ម។ ចំណែកនៅពេលរសៀល ក្រុមអ្នកជំនាញការបានចុះទៅពិនិត្យការដ្ឋានជួសជុលប្រាសាទបាតជុំ និងប្រាសាទបន្ទាយសំរ៉ែ៕

សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ រៀបចំពិព័រណ៌មិនអចិន្ត្រៃយ៍ តាំងបង្ហាញវត្ថុសិល្បៈ ដែលបានមកពីការធ្វើកំណាយបុរាណវិទ្យានៅស្ថានីយភូមិល្វា ព្រៃក្មេង និងភ្នំគូលែន

ផ្សាយនៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២៤

ចាប់តាំងពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៤មក សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ បានរៀបចំពិព័រណ៌មិនអចិន្ត្រៃយ៍មួយ ដើម្បីតាំងបង្ហាញវត្ថុសិល្បៈដែលបានមកពីការធ្វើកំណាយបុរាណវិទ្យា នៅស្ថានីយភូមិល្វា ព្រៃក្មេង និងភ្នំគូលែន ដោយ ពិព័រណ៌ខាងលើ មានរយៈពេល៣ខែ គ្រោងនិងបញ្ចប់នៅចុងខែមករា ឆ្នាំ២០២៥ខាងមុខ ។

វត្ថុសិល្បៈដែលបានដាក់តាំងបង្ហាញនៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ទាំងអស់មានចំនួន៥៧វត្ថុ។ ដោយយកមកពី ភូមិល្វា និងព្រៃក្មេង ជាស្ថានីយសម័យបុរេប្រវត្តិសាស្ត្រ ដែលវត្ថុទាំងអស់ គឺយកចេញពីផ្នូរសព គ្រឿងអលង្ការ មានចិញ្ចៀន ក្រវិល និងកងដៃអំពីសំរិទ្ធ។ ហើយក្នុងនោះក៏មានកណ្តឹង ចង្រ្កង់ និងកាក់ធ្វើអំពីសំរិទ្ធ ខ្វារអំបោះ និងគ្រាប់លុញធ្វើពីឥដ្ឋដុតផងដែរ។ រីឯវត្ថុសិល្បៈមកពីភ្នំគូលែនវិញ ជាបុរាណដ្ឋានសម័យប្រវត្តិសាស្ត្រ ដែលវត្ថុទាំងនោះ កំណាយយកចេញពីកន្លែងខុសៗគ្នា មានប្រាសាទ ,បន្ទាយ និងពើងថ្មជាដើម។ វត្ថុដែលរកឃើញមានច្រើនយ៉ាងក្នុងនោះមាន សន្លឹកមាស ,ត្បូង ,ត្រាធ្វើអំពីថ្ម អង្កាំ ,បន្ទះសំរិទ្ធ និងផ្លែកាំបិទជាដើម។

សូមបញ្ជាក់ថា វត្ថុសិល្បៈដែលបានមកពីការធ្វើកំណាយបុរាណវិទ្យានៅភូមិល្វា និងព្រៃក្មេង ជាកិច្ចសហប្រតិបត្តិការស្រាវជ្រាវរវាងសាកលវិទ្យាល័យស៊ីដនី តាមរយៈគម្រោងពីវាលស្រែ ក្លាយមកជាទីក្រុង ជាមួយអាជ្ញាធរជាតិអប្សរា រវាងឆ្នាំ២០១១ ដល់ ឆ្នាំ២០១៤។ រីឯនៅភ្នំគូលែន ជាកិច្ចសហប្រតិបត្តិការរវាងអង្គការមូលនិធិបុរាណវិទ្យា និងការអភិវឌ្ឍន៍ ហៅកាត់ថា ADFជាមួយអាជ្ញាធរជាតិអប្សរា ក្នុងកំឡុងឆ្នាំ២០០៨ ដល់ឆ្នាំ២០១២។ គោលបំណងនៃការតាំងពិព័រណ៍នេះគឺដើម្បីបង្ហាញជូនសាធារណៈជនទូទៅ ដែលចង់ស្វែងយល់អំពីវត្ថុសិល្បៈនិងរបស់ប្រើប្រាស់ផ្សេងៗពីបុរាណ។ ជាពិសេសគឺចង់ឲ្យសាធារណៈជនដឹងថា ក្រោយពេលធ្វើកំណាយរួច តើវត្ថុដែលគេរកឃើញទាំងនោះ គេយកទៅទីណា?

ដូច្នេះហើយការតាំងបង្ហាញនៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ អាចផ្តល់ភាពងាយស្រួល ដល់សាធារណៈជន ដែលចង់យល់ដឹងអំពីប្រវត្តិសាស្ត្រតាមរយៈវត្ថុសិល្បៈផ្សេងៗ ដែលបុព្វបុរសយើងធ្លាប់ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃផង និងក្នុងកិច្ចគោរពបូជាផង។ ក្នុងន័យនេះ សូមអញ្ជើញសាធារណជន ចូលរួមទស្សនា និងឈ្វេងយល់ពីវត្ថុសិល្បៈ ដែលបានដាក់តាំងបង្ហាញក្នុងសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ដែលមានទីតាំងក្នុងភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប និងបើកឱ្យភ្ញៀវទេសចរជាតិ និងអន្តរជាតិ ចូលទស្សនាចាប់ពីថ្ងៃអង្គារ ដល់ថ្ងៃអាទិត្យ វេលាម៉ោង៨:៣០នាទីព្រឹក ដល់ម៉ោង៤:៣០ល្ងាច៕

សប្តាហ៍ទី៤នៃវិច្ឆិកា ឆ្នាំ២០២៤ ក្រុមការងារសហគមន៍ បន្តចុះពិនិត្យ សំណើពលរដ្ឋនៅក្នុងរមណីយដ្ឋានអង្គរ បានចំនួន៤០ករណី និងសម្រេចអនុញ្ញាត បានចំនួន ៣១ករណី

ផ្សាយនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២៤

ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងរមណីយដ្ឋានអង្គរ ត្រូវបានទទួលនូវការយកចិត្តទុកដាក់អំពីសំណាក់អាជ្ញាធរជាតិអប្សរា ដោយមានការអនុគ្រោះក្នុងការជួសជុលតូចតាចនូវលំនៅដ្ឋានក៏ដូចជាសំណង់ឧបសម្ព័ន្ធមាន របង ដំបូល ជញ្ជាំង សសរពុកផុយ បង្គន់អនាម័យ រោងគោ ទ្រុងមាន់ និងទ្រុងជ្រូកជាដើម ហើយរាល់ការអនុញ្ញាតជួសជុលមានសុពលភាពត្រឹមពីរខែ នៅលើទីតាំងកំពុងរស់នៅផ្ទាល់តែម្តងតាមរយៈការចុះពិនិត្យ និងសម្រេចជាប្រចាំដោយក្រុមការងារសហគមន៍នាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា។ជាក់ស្តែងក្នុងសប្តាហ៍ទី៤នៃខែវិច្ឆិកា ក្រុមការងារសហគមន៍បានចុះ ពិនិត្យសំណើបានចំនួន៤០ករណី និងសម្រេចអនុញ្ញាតបានចំនួន ៣០ករណី ទៅតាមបណ្តាលស្រុក/ក្រុងទាំង៧ ដូចខាងក្រោម៖

- ស្រុកបន្ទាយស្រីអនុញ្ញាតបាន ៥ករណី
- ស្រុកពួកអនុញ្ញាតបាន ៣ករណី
- ក្រុងសៀមរាបអនុញ្ញាតបាន ២២ករណី
- ស្រុកប្រាសាទបាគងអនុញ្ញាតបាន ១ករណី

សូមជម្រាបថា រាល់ការដាក់ពាក្យស្នើសុំច្បាប់ និងការអនុញ្ញាត គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ។ ជាមួយគ្នានេះ ក្រុមការងារសង្កេតឃើញថា ក៏មានអ្នកដែលទទួលបានការអនុញ្ញាតហើយ ប៉ុន្តែពុំបានអនុវត្តត្រឹមត្រូវ ស្របនឹងការអនុញ្ញាតនោះឡើយ។

ដូច្នេះអាជ្ញាធរជាតិអប្សរា សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតឱ្យជួសជុលលំនៅដ្ឋានត្រូវអនុវត្តឲ្យស្របតាមចំណុចបច្ចេកទេសដែលមានការទទួលដឹងលឺ ពីអាជ្ញាធរមូលដ្ឋាន និងទទួលស្គាល់ដោយអាជ្ញាធរជាតិអប្សរា៕

សេចក្តីជូនដំណឹង ស្តីពីការប្រារព្ធពិធីសាសនា ការសម្តែងល្ខោន និងសិល្បៈទស្សនីយភាពនានា ដើម្បីអបអរសាទរ ពិធី "បុណ្យរំលឹកគុណអង្គរ" លើកទី៤ ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខៈ ៤៦៤/២៤ អប.សជណ

សេចក្តីជូនដំណឹង
ស្តីពី
ការប្រារព្ធពិធីសាសនា ការសម្តែងល្ខោន និងសិល្បៈទស្សនីយភាពនានា ដើម្បីអបអរសាទរ ពិធី "បុណ្យរំលឹកគុណអង្គរ" លើកទី៤ ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា សូមជម្រាបជូនសាធារណជនទាំងអស់ មេត្តាជ្រាបថា ដើម្បីចូលរួមអបអរសាទរខួប៣២ឆ្នាំ នៃការចុះបញ្ជីរមណីយដ្ឋានអង្គរ ទៅក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោក នាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២ អាជ្ញាធរជាតិអប្សរាសហការជាមួយក្រសួង/ស្ថាប័នពាក់ព័ន្ធ នឹងរៀបចំប្រារព្ធពិធីសាសនា ការសម្តែងល្ខោន និងសិល្បៈទស្សនីយភាពនានា ដែលនឹងបើកជូនមហាជនចូលរួម និងទស្សនា ដោយសេរី ទៅតាមពេលវេលា និងទីតាំងមួយចំនួនក្នុងរមណីយដ្ឋានអង្គរ ដូចខាងក្រោម៖

១- ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៤

- ម៉ោង០៧:០០នាទី៖ ពិធីបើក "បុណ្យរំលឹកគុណអង្គរ" និងការរាប់បាត្រព្រះសង្ឃ ចំនួន១៣២អង្គ នៅបរិវេណមុខប្រាសាទអង្គរវត្ត
- ម៉ោង១៤:៣០នាទី៖ ពិធីដង្ហែព្រះពុទ្ធរូប៥អង្គ ពីបរិវេណមុខប្រាសាទអង្គរវត្ត ឆ្ពោះទៅប្រាសាទបាយ័ន និងតម្កល់ព្រះពុទ្ធរូបនៅខេមរាសថាតាព្រះអង្គចេក នៃក្រុងអង្គរធំ រយៈពេល២យប់ ៣ថ្ងៃ
  - ➢ ជួបជុំព្រះសង្ឃ និងពុទ្ធបរិស័ទ នៅវេលាម៉ោង១៤:០០នាទី នៅមុខប្រាសាទអង្គរវត្ត សម្រាប់ការចូលរួមពិធីដង្ហែ
  - ➢ ជួបជុំពុទ្ធបរិស័ទ នៅវេលាម៉ោង១៤:០០នាទី នៅបរិវេណជុំវិញប្រាសាទបាយ័ន ដើម្បីទទួលពុទ្ធដំណើរ និងបាចផ្កាភ្ញីសម្រាប់ការបូជា
- ម៉ោង១៦:០០នាទី៖ ពិធីពុទ្ធាភិសេក និងបូជាគ្រឿងសក្ការៈ នៅខេមរាសថាតាព្រះអង្គចេក នៃក្រុងអង្គរធំ
- ម៉ោង១៨:០០នាទី៖ ព្រឹត្តិការណ៍ "រាត្រីចងចាំលើកទី៥" នៅព្រះលានជល់ដំរី នៃក្រុងអង្គរធំ

២- ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៤

- ម៉ោង១៦:០០នាទី៖ ពិធីសមាធិ និងផ្សាយមេត្តាចិត្ត ឧទ្ទិសកុសល នៅបរិវេណខាងមុខប្រាសាទភ្នំបាខែង
- ម៉ោង១៨:០០ នាទី៖
  - ➢ ការសម្តែងសិល្បៈល្ខោនយីកេមហាជន នៅព្រះលានជល់ដំរី នៃក្រុងអង្គរធំ
  - ➢ ការសម្តែងសិល្បៈល្ខោនស្បែកធំ ដោយក្រុមសិល្បៈវត្តរាជបុណ៌ នៅបរិវេណផ្នែកខាងត្បូងនៃបារាយណ៍ប្រាសាទអង្គរវត្ត

៣- ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤

- ម៉ោង១៦:០០ នាទី៖ ពិធីស្រង់ព្រះសុគន្ធវារីព្រះពុទ្ធរូប៥អង្គ នៅខេមរាសថាតាព្រះអង្គចេក នៃក្រុងអង្គរធំ
- ម៉ោង១៨:០០ នាទី៖ ការសម្តែងសិល្បៈល្ខោនខោល នៅព្រះលានជល់ដំរី នៃក្រុងអង្គរធំ

ដោយឡែក អាជ្ញាធរជាតិអប្សរាក៏នឹងមានរៀបចំពិព័រណ៍សមិទ្ធផលការងារជូនសាធារណជនទស្សនា និងស្វែងយល់ ចាប់ពីថ្ងៃទី១៤-២១ ខែធ្នូ ឆ្នាំ២០២៤ នៅបរិវេណខាងមុខប្រាសាទអង្គរវត្តផងដែរ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន និងចូលរួមឱ្យបានច្រើនកុះករ។

ថ្ងៃ ពុធ ៤ កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
សៀមរាប ថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០២៤
អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
ភូមិបង្កោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប
អាជ្ញាធរដើម្បីការពារតំបន់រមណីយដ្ឋាន និងរៀបចំដែនដីតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576
APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

ក្រុមអ្នកជំនាញការអាដហុក បន្តចុះពិនិត្យគម្រោងការងារ នៅប្រាសាទភ្នំបាខែង និងប្រាសាទតានៃ

ផ្សាយនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២៤

នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៤ ក្រុមអ្នកជំនាញការអាដហុក នៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ និងសំបូរព្រៃគុក បានចុះពិនិត្យគម្រោងការងារនៅប្រាសាទភ្នំបាខែង និងប្រាសាទតានៃ។ នេះជាថ្ងៃទី៥ហើយ ដែលក្រុមអ្នកជំនាញការចុះពិនិត្យការងារនៅតាមការដ្ឋាននានា មុននឹងកិច្ចប្រជុំធំនៃគណៈកម្មាធិការអន្តរជាតិមួយនេះ រៀបចំធ្វើចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៤ ដែលជាកិច្ចប្រជុំបច្ចេកទេសលើកទី៣៩ និងកិច្ចប្រជុំពេញអង្គលើកទី៣១៕

សម្រស់ចម្លាក់ទេពអប្សរ នៅរូតទី៣នៃប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៤

ក្រុមអ្នកជំនាញការអាជហុក អញ្ជើញចុះពិនិត្យការងារ នៅតាមការដ្ឋាននៅតំបន់រុនតាឯក និងក្រុងសៀមរាប

ផ្សាយនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៤

ក្រុមអ្នកជំនាញការអាជហុក នៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ និងសំបូរព្រៃគុក បានបន្តសកម្មភាពចុះពិនិត្យតាមដានវឌ្ឍនភាពការងារអភិរក្ស និងអភិវឌ្ឍន៍ នៅរមណីយដ្ឋានអង្គរ។ ជាក់ស្តែងនៅព្រឹកថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៤ ក្រុមអ្នកជំនាញដែលដឹកនាំដោយ**ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា រួមទាំងមន្ត្រីជំនាញ បានអញ្ជើញពិនិត្យកិច្ចការងារអភិវឌ្ឍន៍នៅតំបន់រុនតាឯកតេជោសែន។ ចំណែកនៅពេលរសៀល ក្រុមអ្នកជំនាញបន្តអញ្ជើញចុះពិនិត្យការដ្ឋានមួយចំនួនតាមដងស្ទឹងសៀមរាប។

សូមជម្រាបថា នៅមុនកិច្ចប្រជុំរបស់គណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ និងសំបូរព្រៃគុកឈានចូលមកដល់ ក្រុមអ្នកជំនាញការអាជហុក តែងបានអញ្ជើញចុះពិនិត្យនៅតាមការដ្ឋាននានាក្នុងរមណីយដ្ឋានអង្គរ។ ខណៈកិច្ចប្រជុំ នឹងរៀបចំឡើងចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៤ខាងមុខ ដែលជាកិច្ចប្រជុំបច្ចេកទេសលើកទី៣៩ និងកិច្ចប្រជុំពេញអង្គលើកទី៣១៕

ក្រុមអ្នកជំនាញការអាដហុក ចុះពិនិត្យគម្រោងការងារនៅប្រាសាទមេបុណ្យខាងលិច និងប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៤

នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៤ ក្រុមអ្នកជំនាញការអាដហុក នៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ និងសំបូរព្រៃគុក បានចុះពិនិត្យគម្រោងការងារនៅប្រាសាទមេបុណ្យខាងលិច និងប្រាសាទបាយ័ន។

នេះជាថ្ងៃបញ្ចប់ហើយ ដែលក្រុមអ្នកជំនាញការចុះពិនិត្យការងារនៅតាមការដ្ឋាននានា មុននឹងកិច្ចប្រជុំធំនៃគណៈកម្មាធិការអន្តរជាតិមួយនេះរៀបចំធ្វើចាប់ពីថ្ងៃទី១១ដល់ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៤ ដែលជាកិច្ចប្រជុំបច្ចេកទេសលើកទី៣៩ និងកិច្ចប្រជុំពេញអង្គលើកទី៣១។

ក្នុងរយៈពេលមួយសប្តាហ៍កន្លងទៅ ក្រុមអ្នកជំនាញការអាដហុក បានចុះពិនិត្យការដ្ឋានមួយចំនួនដូចជា ទៅស្ពានហាលខាងលិចប្រាសាទអង្គរវត្ត រោងទងខាងត្បូងប្រាសាទអង្គរវត្ត បណ្ណាល័យខាងត្បូងនៃរួតទី២ប្រាសាទអង្គរវត្ត បាកានអង្គរវត្ត ខ្លោងទ្វារខាងកើតប្រាសាទអង្គរវត្តប្រាសាទភិមានអាកាស ក្រុមប្រាសាទព្រះពិធូរ នៃក្រុងអង្គរធំ ប្រាសាទភ្នំបាខែង ប្រាសាទតានៃ ប្រាសាទបន្ទាយក្តី ប្រាសាទតាព្រហ្ម ប្រាសាទបាតជុំ ប្រាសាទបន្ទាយសំរ៉ែ ប្រាសាទព្រះគោ ប្រាសាទបាគង ប្រាសាទប្រែរូប ប្រាសាទភ្នំក្រោម ស្ពានហាលខាងកើតប្រាសាទបេងមាលា តំបន់រុនតាឯកតេជោសែន និងតាមដងស្ទឹងសៀមរាបដែរ៕

អាជ្ញាធរជាតិអប្សរា សម្ពោធស្ថានីយគ្រប់គ្រងទឹក ដោយស្វ័យប្រវត្តិ នៅតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២៤

នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៤ អាជ្ញាធរជាតិអប្សរា និងសហជីពអន្តរសង្កាត់នៃជ្រលងប៊ីយ៉ែវ (SIAVB) ប្រទេសបារាំង បានរៀបចំដាក់សម្ពោធជាផ្លូវការនូវស្ថានីយគ្រប់គ្រងទឹកចំនួន៦ស្ថានីយ ដែលស្ថិតនៅតំបន់រមណីយដ្ឋានអង្គរ។ ស្ថានីយនេះនឹងជួយដល់ការងារគ្រប់គ្រងទឹកឱ្យបានកាន់តែល្អប្រសើរ និងឆាប់រហ័ស កាត់បន្ថយកម្លាំងពលកម្មមួយផ្នែកធំ។



ឯកឧត្តមបណ្ឌិត ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា ព្រមទាំងតំណាងនៃសហជីពអន្តរសង្កាត់ នៃជ្រលងប៊ីយ៉ែវ ប្រទេសបារាំង និងសហការី បានដាក់សម្ពោធជាផ្លូវការនូវស្ថានីយគ្រប់គ្រងទឹក មួយកន្លែងនៅស្ថានីយបន្ទាយស្រី។ នេះជាស្ថានីយមួយក្នុងចំណោម៦ ដែលផ្តល់ដោយស្ថាប័ន SIAVB ដើម្បីអភិវឌ្ឍន៍ការងារគ្រប់គ្រងទឹកនៅតំបន់រមណីយដ្ឋានអង្គរ ដោយស្ថានីយទាំងនោះ ប្រើប្រាស់ឧបករណ៍ប្រព័ន្ធបច្ចេកវិទ្យាទំនើប និងបញ្ជូនព័ត៌មានឆាប់រហ័សតាមប្រព័ន្ធកុំព្យូទ័រ ទូរសព្ទ ទាក់ទងនឹងវាស់កម្ពស់ទឹកភ្លៀង វាស់សំណើម វាស់ល្បឿនខ្យល់ វាស់ទិសដៅខ្យល់ និងវាស់កាំរស្មីព្រះអាទិត្យ ជាដើម។ល។ ស្ថានីយទាំង៦រួមមាន ស្ថានីយភ្នំគូលែន ស្ថានីយបន្ទាយស្រី ស្ថានីយចៅស្រីវិបុល ស្ថានីយក្រាំងក្រូច ស្ថានីយភ្នំក្រោម និងស្ថានីយវត្តស្លាតវជ័យ។

សូមបញ្ជាក់ថា អាជ្ញាធរជាតិអប្សរា និងសហជីពអន្តរសង្កាត់ជ្រលងប៊ីយ៉ែវ បានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការវិមជ្ឈការនៅក្នុងគម្រោងប្រព័ន្ធជំនួយស្វ័យប្រវត្តិក្នុងការគ្រប់គ្រងទឹកក្នុងតំបន់សៀមរាបអង្គរ (SDGERA) កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២។ នៅខែវិច្ឆិកា ឆ្នាំ២០២៣ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា អមដំណើរដោយឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេស បានអញ្ជើញទៅពិនិត្យ និងសម្ពោធការដំឡើងសាកល្បងស្ថានីយគ្រប់គ្រងទឹកស្វ័យប្រវត្តិ ដែលសហជីពអន្តរសង្កាត់នៃជ្រលងប៊ីយ៉ែវ នឹងត្រូវយកមកដំឡើងនៅរមណីយដ្ឋានអង្គរចំនួន៦ស្ថានីយ នាទីស្នាក់ការរបស់សហជីព នាប្រទេសបារាំង៕

កិច្ចប្រជុំបច្ចេកទេសលើកទី៣៩ នៃគណៈកម្មាធិការអន្តរជាតិអាយស៊ីស៊ី-អង្គរ និងសំបូរព្រៃគុក ចាប់ផ្តើមដំណើរការ

ផ្សាយនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៤នេះ កិច្ចប្រជុំបច្ចេកទេសលើកទី៣៩ នៃគណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ និងសំបូរព្រៃគុក បានចាប់ផ្តើមហើយ ដោយមានថ្នាក់ដឹកនាំ និងអ្នកជំនាញការជាតិ-អន្តរជាតិប្រមាណជិត៣០០នាក់ចូលរួម។ កិច្ចប្រជុំនេះប្រព្រឹត្តិទៅឡើងក្រោមវត្តមានដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តម សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា ភ្ញៀវជាតិ-អន្តរជាតិ ដែលមានសហប្រធានបារាំង និងជប៉ុន ជាអ្នកសម្របសម្រួលកិច្ចប្រជុំ។

កិច្ចប្រជុំបច្ចេកទេសលើកទី៣៩ នៃគណៈកម្មាធិការអន្តរជាតិអាយស៊ីស៊ី-អង្គរ និងសំបូរព្រៃគុក ធ្វើឡើងរយៈពេល ២ថ្ងៃ គឺថ្ងៃទី១១ និងទី១២ ខែធ្នូ ដោយផ្តោតលើការងារពិនិត្យ និងតាមដានការងារនៅតាមការដ្ឋានជួសជុល និងគម្រោងមួយចំនួនទាក់ទងនឹងតំបន់អង្គរ និងសំបូរព្រៃគុក។ ដោយឡែកនៅថ្ងៃទី១៣ នឹងមានកិច្ចប្រជុំពេញអង្គលើកទី៣១ ដែលធ្វើឡើងនៅសណ្ឋាគារ សូហ្វីតែល អង្គរភូគីត្រា៕

សេចក្តីជូនដំណឹង ស្តីពីការរៀបចំពិធីបើក "បុណ្យរំលឹកគុណអង្គរ" លើកទី៤ ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៖ ៤៧៩៤/២៤ រប.សជណ

សេចក្តីជូនដំណឹង
ស្តីពី
ការរៀបចំពិធីបើក "បុណ្យរំលឹកគុណអង្គរ" លើកទី៤ ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់ក្រសួង/ស្ថាប័ន ជាតិ-អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិ និងសាធារណៈជនទាំងអស់ ឱ្យបានជ្រាបថា ដើម្បីចូលរួមអបអរសាទរខួប៣២ឆ្នាំនៃការចុះរមណីយដ្ឋានអង្គរ ទៅក្នុងបញ្ជីនៃសម្បត្តិបេតិកភណ្ឌពិភពលោក នាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២ អាជ្ញាធរជាតិអប្សរា នឹងរៀបចំប្រារព្ធពិធី "**បុណ្យរំលឹកគុណអង្គរ**" លើកទី៤ នៅក្នុងរមណីយដ្ឋានអង្គរ ចាប់ពីថ្ងៃទី១៤-១៦ ខែធ្នូ ឆ្នាំ២០២៤ តទៅ។ សម្រាប់ព្រឹត្តិការណ៍បើកពិធីបុណ្យដ៏មានអត្ថន័យនេះ នឹងប្រព្រឹត្តទៅនាព្រឹកថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៤ ចាប់ពីម៉ោង ៦:០០ នាទីព្រឹកតទៅ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត**។

ក្នុងន័យដើម្បីឱ្យពិធីប្រព្រឹត្តទៅដោយរលូន និងជោគជ័យ អាជ្ញាធរជាតិអប្សរានឹងបិទការចូលទស្សនាប្រាសាទអង្គរវត្ត តាមច្រកស្ពានហាលខាងលិច នៅព្រឹកថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៤ រហូតដល់ពិធីចប់រួចរាល់។ ក្នុងអំឡុងពេលនេះ ភ្ញៀវទេសចរជាតិ-អន្តរជាតិ អាចចូល-ចេញទស្សនាប្រាសាទអង្គរវត្ត ដោយប្រើប្រាស់ស្ពានបណ្តែតទឹកជាបណ្តោះអាសន្នជំនួសវិញ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមក្រសួង/ស្ថាប័ន ជាតិ-អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរណ៍ជាតិ-អន្តរជាតិ និងសាធារណៈជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ១១កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
សៀមរាប ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០២៤
អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបាគង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576
APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

គណៈកម្មាធិការអន្តរជាតិអាយស៊ីស៊ី-អង្គរ និងសំបូរព្រៃគុក បានបើកកិច្ចប្រជុំពេញអង្គលើកទី៣១ នៅខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៤

គណៈកម្មាធិការអន្តរជាតិអាយស៊ីស៊ី-អង្គរ និងសំបូរព្រៃគុក បានបើកកិច្ចប្រជុំពេញអង្គលើកទី៣១ នាខេត្តសៀមរាប នៅថ្ងៃទី១៣ខែធ្នូ ឆ្នាំ២០២៤ ក្រោមអធិបតីភាពសហប្រធានគណៈកម្មាធិការ ឯកឧត្តម Ueno Atsushi ឯកអគ្គរាជទូតជប៉ុន និងឯកឧត្តម Jacques Pellet ឯកអគ្គរដ្ឋទូតបារាំង និងវត្តមានដ៏ខ្ពង់ខ្ពស់ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិអប្សរា។ កិច្ចប្រជុំក៏មានការអញ្ជើញចូលរួមពីភ្ញៀវកិត្តិយស លោក Lazare Eloundou Assomo ប្រធានមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូ៕

ជប៉ុនផ្ដល់ជំនួយ៩០ម៉ឺនដុល្លារបន្ថែម សម្រាប់ការជួសជុលប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៤

នៅក្នុងកិច្ចប្រជុំពេញអង្គនៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ និងសំបូរព្រៃគុក ហៅកាត់ថា អាយស៊ីស៊ី-អង្គរ និងសំបូរព្រៃគុក នាថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៤ លោក Kawase Taro ប្រធានផ្នែកកិច្ចសហប្រតិបត្តិការវប្បធម៌ពហុភាគី នៃក្រសួងការបរទេសជប៉ុន បានប្រកាសពីការផ្ដល់ជំនួយថវិកាចំនួន ៩០ម៉ឺនដុល្លារអាមេរិកបន្ថែម ដល់កិច្ចការអភិរក្ស និងជួសជុលប្រាសាទបាយ័ន ចាប់ឆ្នាំ២០២៥ ដល់ឆ្នាំ២០២៨៕

ព្រឹត្តិការណ៍ «បុណ្យរំលឹកគុណអង្គរ» លើកទី៤ ឆ្នាំ២០២៤ បានប្រកាសបើកជាផ្លូវការហើយ

ផ្សាយនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៤

ពិធី«បុណ្យរំលឹកគុណអង្គរ» លើកទី៤ បានប្រកាសបើកជាផ្លូវការហើយ នៅព្រឹកថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៤នេះ នាបរិវេណខាងមុខប្រាសាទអង្គរវត្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** តំណាងដ៏ខ្ពង់ខ្ពស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា **សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា **ឯកឧត្តម ហង់ ពៅ** អគ្គនាយក អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា រដ្ឋបាលខេត្តសៀមរាប ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត តំណាងបណ្តាប្រទេសជាមិត្ត តំណាងមន្ទីរអង្គភាពពាក់ព័ន្ធជុំវិញខេត្ត ប្រជាពលរដ្ឋ រួមទាំងសិស្សានុសិស្សប្រមាណ២,០០០អង្គ/នាក់។

ពិធី«បុណ្យរំលឹកគុណអង្គរ» លើកទី៤នេះ បានរៀបចំពិធីបួងសួង រាប់បាត្រព្រះសង្ឃចំនួន១៣២អង្គ កម្មវិធីបែបសាសនាជាច្រើន ការតាំងពិព័រណ៌បង្ហាញសមិទ្ធផលនៃអាជ្ញាធរជាតិអប្សរា រួមជាមួយដៃគូអន្តរជាតិនានា ចាប់ពីថ្ងៃទី១៤ ដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៤ ព្រឹត្តិការណ៍សម្តែងសិល្បៈរាត្រីចងចាំ និងកម្មវិធីអមជាច្រើនទៀត ដែលផ្តល់ឱកាសឱ្យសាធារណជនបានទស្សនា និងឈ្វេងយល់ដោយសេរី។

ពិធីដង្ហែព្រះពុទ្ធចំនួន៩អង្គ ពីមុខប្រាសាទអង្គរវត្ត ប្រទក្សិណជុំវិញប្រាសាទបាយ័ន និងតម្កល់ទុកនៅពេទឧបោសថព្រះអង្គខោក ក្នុងព្រឹត្តិការណ៍បុណ្យរំលឹកគុណអង្គរ លើកទី៤ នាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៤ ពិធីមានព្រះសង្ឃចូលរួមជាង ៤00អង្គ ព្រមទាំងពុទ្ធបរិស័ទជាច្រើនរូបទៀត

ផ្សាយនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៤

លិខិតជូនពររបស់ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិកគ្រប់លំដាប់ថ្នាក់នៃអាជ្ញាធរជាតិអប្សរា គោរពជូនពរសម្តេចកិត្តិព្រឹទ្ធបណ្ឌិតប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា ក្នុងឱកាសដ៏មហានក្ខត្តឫក្សប្រពៃថ្លៃថ្លា នៃពិធីចម្រើនជន្មាយុគម្រប់៧០ឆ្នាំ ឈានចូល ៧១ឆ្នាំ

ផ្សាយនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ ៤៧៦/៤ អ.ឃជ
/២៤

សារលិខិតជូនពរ

សូមគោរពជូន
សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា
ក្នុងឱកាសចម្រើនជន្មាយុគម្រប់៧០ឆ្នាំ ឈានចូល៧១ឆ្នាំ

សម្តេចកិត្តិព្រឹទ្ធបណ្ឌិតជាទីគោរពដ៏ខ្ពង់ខ្ពស់!

ក្នុងឱកាសបុណ្យខួបកំណើតគម្រប់៧០ឆ្នាំ ឈានចូល៧១ឆ្នាំ របស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ១៥កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៤នេះ តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃអាជ្ញាធរជាតិអប្សរា និងក្នុងនាមខ្លួនខ្ញុំបាទផ្ទាល់ យើងខ្ញុំសូមគោរពជូនពរបវរមហាប្រសើរជូនចំពោះ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** សូមមានសុខភាពល្អបរិបូរណ៍ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ និងមានសុភមង្គលជាត្រចះត្រចង់។

ឆ្លៀតក្នុងឱកាសដ៏វិសេសថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមគោរពកោតសរសើរដោយស្មោះចំពោះ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដែលជាកុលធីតាខ្មែរដ៏ឆ្នើមមួយរូប ជាភរិយា **សម្តេចតេជោ** ដ៏ប្រពៃ ជាមាតាដ៏ល្អ ជាជីដូនដែលមានព្រហ្មវិហារធម៌ មានស្នាដៃដ៏ប៉ិនប្រសប់ និងគំនិតប្រាជ្ញាដ៏ឧត្តុង្គឧត្តមឈ្លាសវៃ ក្នុងការដឹកនាំកាកបាទក្រហមកម្ពុជា ដើម្បីបំពេញបេសកកម្មមនុស្សធម៌ដ៏ថ្លៃថ្លាប្រកបដោយគុណធម៌ សប្បុរសធម៌ និងបានរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការយកចិត្តទុកដាក់ដោះស្រាយទុក្ខលំបាកជូនប្រជាពលរដ្ឋរងគ្រោះដោយគ្រោះមហន្តរាយ និងគ្រោះធម្មជាតិ គ្រប់ទីកន្លែងនៅទូទាំងប្រទេស។ ទន្ទឹមនឹងនេះ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជាថ្នាក់ដឹកនាំ ស្ត្រីដ៏ឆ្នើមមួយរូប ដែលបានបំពេញតួនាទីដ៏សំខាន់ជាមួយរាជរដ្ឋាភិបាល ក្នុងការពុះពារ កសាង និងអភិវឌ្ឍន៍ជាតិមាតុភូមិ ព្រមទាំងបានខិតខំលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងតម្លៃគ្រួសារខ្មែរឱ្យបានខ្ពង់ខ្ពស់រុងរឿង។

សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដែលជាភរិយាដ៏ឧត្តុង្គឧត្តមនៃ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រីទាំងអស់ ទទួលបាននូវពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខគ្រប់ប្រការ និងសូមប្រកបតែសុខភាពល្អបរិបូរណ៍ អាយុយឺនយូរ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ ដើម្បីអភិវឌ្ឍមាតុភូមិកម្ពុជាក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមក្នុងការដឹកនាំកាកបាទក្រហមកម្ពុជា ឱ្យកាន់តែរីកចម្រើនឈានឆ្ពោះទៅកេរ្តិ៍ភាពសម្បូរសប្បាយជានិច្ចនិរន្តរ៍។

សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** មេត្តាទទួលនូវគារវកិច្ចដ៏ស្មោះស្ម័គ្រ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃពុធ ១១កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០២៤
អគ្គនាយក

ហង់ ពៅ

APSARA National Authority
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576
Address: Bang Kong Village, Ampil Commune, Prasat Bakong District, Siem Reap Province

សិស្សានុសិស្ស ចំនួន១២០០នាក់ ធ្វើព្យុហយាត្រាក្នុងព្រឹត្តិការណ៍ «រំលឹកគុណអង្គរ»

ផ្សាយនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៤

នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៤ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានអញ្ជើញជាអធិបតីក្នុងពិធីព្យុហយាត្រានៃព្រឹត្តិការណ៍«រំលឹកគុណអង្គរ»មានការចូលរួមពីសិស្សានុសិស្ស ចំនួន១២០០នាក់ ដែលចាប់ផ្តើមចេញពីមុខប្រាសាទអង្គរវត្ត ឆ្ពោះទៅខ្លោងទ្វារទន្លេអុំនៃក្រុងអង្គរធំ និងឆ្ពោះទៅក្រុងសៀមរាប ។

កម្មវិធីដង្ហែក្បួនព្យុហយាត្រា ដើម្បីអបអរសាទរពិធីបុណ្យ«រំលឹកគុណអង្គរ» ដ៏មានសារសំខាន់សម្តែង ចំណាប់អារម្មណ៍ចំពោះពាក្យស្លោកគោល អរគុណអង្គរ និងអរគុណសន្តិភាព ភ្ជាប់ដោយខ្លឹមសារថែរក្សាបរិស្ថាន និងផ្សេងៗ។

ព្យុហយាត្រានេះ ដើម្បីផ្សព្វផ្សាយឱ្យសាធារណជន ក៏ដូចជា ប្រជាពលរដ្ឋខ្មែរ ភ្ញៀវទេសចរជាតិ អន្តរជាតិ មានការរំលឹកគុណដល់ប្រាសាទអង្គរវត្ត ដែលជាសម្បត្តិបេតិកភណ្ឌពិភពលោកមិនអាចកាត់ថ្លៃបាន ដែលបុព្វបុរសខ្មែរគ្រប់ជំនាន់បានបន្សល់ទុកឱ្យកូនខ្មែរជំនាន់ក្រោយ៕

ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិ មកទស្សនាស្តង់ពិព័រណ៍ របស់អាជ្ញាធរជាតិអប្សរា នៅបរិវេណខាងមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៤

នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៤នេះ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ បានចូលមកទស្សនាស្តង់ពិព័រណ៍ស្តីពី៖ សមិទ្ធផលការងាររយៈពេល៣២ឆ្នាំ របស់អាជ្ញាធរជាតិអប្សរា និងស្តង់ពិព័រណ៍ផ្សេងៗទៀត នៅបរិវេណខាងមុខប្រាសាទអង្គរវត្ត ក្នុងពិធីបុណ្យរំលឹកគុណអង្គរ។

សូមបញ្ជាក់ថា ពិធីបុណ្យរំលឹកគុណអង្គរឆ្នាំ២០២៤នេះ ត្រូវបានប្រារព្ធឡើងរយៈពេល០៣ថ្ងៃ ចាប់ពីថ្ងៃទី១៤ រហូតដល់ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤ ដោយផ្នែកពិព័រណ៍ស្តីពីសមិទ្ធផលរបស់អាជ្ញាធរជាតិអប្សរា បានរៀបចំតាំងបង្ហាញពីថ្ងៃទី១៤ ដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៤៕

ពិធីសមាធិព្រះសង្ឃចំនួន២១ព្រះអង្គ នៅខាងមុខប្រាសាទភ្នំបាខែង

ផ្សាយនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៤

ពិធីសមាធិដើម្បីរំលឹកគុណដល់បុព្វការីជនគ្រប់ជំនាន់ត្រូវប្រព្រឹត្តទៅក្រោមការដឹកនាំបង្រៀនដោយ **សម្តេចព្រះព្រហ្មរតនមុនី ពិន សែម** គណៈមហានិកាយ ជាឧត្តមទីប្រឹក្សាគណៈសង្ឃនាយក ជាសមាជិកថេរសភាព្រះពុទ្ធសាសនានៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះគ្រូចៅអធិការវត្តរាជបូណ៌ ខេត្តសៀមរាប ដោយធ្វើបទនមស្ការ សមាទានកាន់យកនូវព្រះត្រ័យសរណគមន៍ និងនិច្ចសីល ធ្វើសមាធិ និងឧទ្ទិសកុសលផ្សាយមេត្តាចិត្ត៕

ទស្សនីយភាពសិល្បៈ
នៅក្នុងព្រឹត្តិការណ៍បុណ្យរំលឹកគុណអង្គរ

ផ្សាយនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៤

នៅរាត្រីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៤នេះ មានសាធារណជនយ៉ាងច្រើនកុះករមកទស្សនាទស្សនីយភាពការសម្តែងសិល្បៈល្ខោនយីកេមហាជន នៅព្រះលានជល់ដំរីនៃក្រុងអង្គរធំ និងការសម្តែងសិល្បៈល្ខោនស្បែកធំ នៅបរិវេណអតីតទីស្នាក់ការនគរបាលបេតិកភណ្ឌខាងមុខប្រាសាទអង្គរវត្ត ក្នុងព្រឹត្តិការណ៍នៃពិធីបុណ្យ រំលឹកគុណអង្គរ៕

ពិធីស្រង់ព្រះសុគន្ធវារីចំពោះព្រះពុទ្ធរូប ៩អង្គ នៅរោងឧបោសថព្រះអង្គចេក នារសៀលថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤ ដឹកនាំដោយសម្តេចព្រះព្រហ្មរតនមុនី ពិន សែម គណៈមហានិកាយជាឧត្តមទីប្រឹក្សាគណៈសង្ឃនាយក ជាសមាជិកថេរសភាព្រះពុទ្ធសាសនា នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះគ្រូចៅអធិការវត្តរាជបូណ៌ ខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤

សេចក្តីប្រកាសព័ត៌មាន ពាក់ព័ន្ធនឹងការលើកឡើង របស់អ្នករាយការណ៍ពិសេស ទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្សនៃក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដែលបានសម្តែងការព្រួយបារម្ភលើការតាំងទីលំនៅថ្មីដោយបង្ខំ របស់ប្រជាជនរស់នៅតំបន់អង្គរដើម្បីកិច្ចអភិរក្ស។ ចំពោះករណីលើកឡើងនេះ អាជ្ញាធរជាតិអប្សរាសូមធ្វើការបញ្ជាក់ជូនដូចខាងក្រោម៖

ផ្សាយនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
A P S A R A

លេខ៖ ៩០៨ /២៤ ក.ប.ស.ឯក

សេចក្តីប្រកាសព័ត៌មាន

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់សាធារណមតិ មេត្តាជ្រាបថា កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៤ អ្នករាយការណ៍ពិសេសទទួលបន្ទុកស្ថានភាពសិទ្ធិមនុស្សនៃក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានចេញសេចក្តីប្រកាសព័ត៌មានសម្តែងការព្រួយបារម្ភលើការតាំងទីលំនៅថ្មីដោយបង្ខំ របស់ប្រជាជនរស់នៅតំបន់អង្គរ ដើម្បីកិច្ចអភិរក្ស។

ពាក់ព័ន្ធនឹងការលើកឡើងរបស់អ្នកជំនាញការខាងលើ អាជ្ញាធរជាតិអប្សរាសូមធ្វើការបញ្ជាក់ជូនដូចខាងក្រោម៖

១- អាជ្ញាធរជាតិអប្សរា ជានិច្ចកាលមែងបំពេញកិច្ចការងារក្នុងការលើកកម្ពស់ និងការគោរពសិទ្ធិមនុស្សស្របតាមរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលកម្ពុជា។ ក្នុងរយៈកាល៣០ឆ្នាំកន្លងមកនេះ អាជ្ញាធរជាតិអប្សរាតែងតែយកចិត្តទុកដាក់ខ្ពស់លើកិច្ចការអភិវឌ្ឍន៍ប្រកបដោយចីរភាពសហគមន៍ និងការរស់នៅរបស់ប្រជាពលរដ្ឋចំនួន១១២ភូមិ ដែលរស់នៅយូរលង់ណាស់មកហើយ ក្នុងតំបន់រមណីយដ្ឋានអង្គរ។ បច្ចុប្បន្ន បុគ្គលិកចំនួន៧៤% ដែលកំពុងបំពេញការងារនៅក្នុងអាជ្ញាធរជាតិអប្សរា គឺជាប្រជាពលរដ្ឋរស់នៅក្នុងតំបន់អង្គរ។

២- ក្នុងនាមជាស្ថាប័នទទួលបន្ទុកកិច្ចការអភិរក្ស និងគ្រប់គ្រងរមណីយដ្ឋានអង្គរ អាជ្ញាធរជាតិអប្សរាជានិច្ចកាលមានកាតព្វកិច្ចគោរព និងអនុវត្តទៅតាមខ្លឹមសារចែងក្នុងលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធកិច្ចការពារបេតិកភណ្ឌវប្បធម៌ ជាពិសេសគោលការណ៍ប្រតិបត្តិសម្រាប់ការអនុវត្តអនុសញ្ញាស្តីពីបេតិកភណ្ឌពិភពលោក។

៣- អាជ្ញាធរជាតិអប្សរាមានការសោកស្តាយជាខ្លាំង ដោយអ្នករាយការណ៍ពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្សបានទទួលនូវរបាយការណ៍មួយចំនួន ដែលមិនបានឆ្លុះបញ្ចាំង ក៏ដូចជាមិនបានស្វែងយល់ព័ត៌មានពិត និងសភាពជាក់ស្តែង នៅក្នុងរមណីយដ្ឋានអង្គរ និងតំបន់ពាក់ព័ន្ធ។

៤- អាជ្ញាធរជាតិអប្សរា ស្របតាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ជាពិសេសចំពោះប្រជាជន ដែលបានតាំងទីលំនៅមិនសមស្របមួយចំនួនក្នុងតំបន់ការពារ ហើយដែលបានស្ម័គ្រចិត្តទៅតាំងទីលំនៅថ្មី តាមរយៈការផ្តល់នូវកិច្ចគាំពារ ដូចជាគោលការណ៍ទទួលកម្មសិទ្ធិដីធ្លីស្របច្បាប់ គោលនយោបាយគាំពារសង្គមរយៈពេល១០ឆ្នាំ និងការគាំពារជាច្រើនផ្សេងទៀត ដើម្បីលើកកម្ពស់សេដ្ឋកិច្ចសង្គម ដែលជាគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

៥- ជាមួយគ្នានេះ បញ្ហាដែលបានលើកឡើង ត្រូវបានយកមកពិភាក្សាយ៉ាងលម្អិត ពីអ្នកជំនាញការជាតិ និងអន្តរជាតិក្នុងកិច្ចប្រជុំបច្ចេកទេសនាពេលកន្លងមក និងជាពិសេសក្នុងកិច្ចប្រជុំលើកទី៣៩ និងពេញអង្គលើកទី៣១ នៃអាយស៊ីស៊ី-អង្គរសំបូរព្រៃគុក ប្រព្រឹត្តទៅពីថ្ងៃទី១១-១៣ ខែធ្នូ ឆ្នាំ២០២៤ ដើម្បីផ្តល់ជាតុចូលបន្ថែមលើការគ្នោគុណ្យភាពរវាងកិច្ចអភិរក្ស និងការអភិវឌ្ឍន៍សហគមន៍ប្រជាជន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណមតិជាទូទៅ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ១កេត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
សៀមរាប ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤
អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្កោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពារតំបន់រមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

ទស្សនីយភាពសិល្បៈល្ខោនខោល ក្នុងព្រឹត្តិការណ៍បុណ្យរំលឹកគុណអង្គរ

ផ្សាយនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤

ទស្សនីយភាពសិល្បៈល្ខោនខោល នៅរាត្រីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤ ត្រូវជាថ្ងៃទី៣នៃព្រឹត្តិការណ៍បុណ្យរំលឹកគុណអង្គរ នៅព្រះលានជល់ដំរីនៃក្រុងអង្គរធំ មានសាធារណជនមកទស្សនាយ៉ាងច្រើនកុះករ៕

Press Release: APSARA National Authority would like to inform the public that on December 13th, 2024, the Special Rapporteurs of the Human Rights Council of United Nations issued a press release expressing concern over the forced resettlement of people living in the Angkor area for conservation purposes.

Concerning the above rapporteur´s remarks, APSARA National Authority would like to clarify as follows:

ផ្សាយនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៤

KINGDOM OF CAMBODIA
NATION RELIGION KING

អាជ្ញាធរជាតិអប្សរា
A P S A R A

N°.908/24 DA.SR

Press Release

APSARA National Authority would like to inform the public that on December 13th, 2024, the Special Rapporteurs of the Human Rights Council of United Nations issued a press release expressing concern over the forced resettlement of people living in the Angkor area for conservation purposes.

Concerning the above rapporteur's remarks, APSARA National Authority would like to clarify as follows:

1- APSARA National Authority has always been committed to promoting and respecting human rights in accordance with the Constitution, which is the supreme law of Cambodia. Over the past 30 years, APSARA National Authority has always given close attention to the sustainable development of the community and the lives of the people of 112 villages who have long lived in the Angkor site. They were recognized, since the 1992 inscription of Angkor on the World Heritage site by UNESCO, as legally living within the 400 square kilometers of the protected site. Currently, 74% of the staff working for APSARA National Authority are people living in the Angkor area.

2- As the institution in charge of the conservation and management of the Angkor World Heritage site, APSARA National Authority is always obliged to respect and implement the contents of various legal documents related to the protection of cultural heritage, especially the Operational Guidelines for the Implementation of the UNESCO World Heritage Convention for the protection of the World Cultural and Natural Heritage.

3- APSARA National Authority is deeply saddened by the fact that the Special Rapporteurs of the Human Rights Council received a number of reports that did not reflect or understand the factual information and actual reality in the Angkor site and related areas.

4- APSARA National Authority, in accordance with the principles set by the Royal Government of Cambodia, has paid special attention to the people who have settled inappropriately in the protected areas and who have voluntarily resettled by providing social security policy such as land title, social supporting programs for 10 years, and many other supports to promote the socio-economic development, which is the policy of the Royal Government of Cambodia.

5- The issue raised by the rapporteurs IS UNFORTUNATELY OUTDATED, since this had been discussed in the recent ICC-Angkor/Sambor Prei Kuk Session, especially in the 39th Technical Session and 31st Plenary Session, held from December 11th-13th, 2024, WITH THE OBJECTIVE TO CLARIFY THE ROYAL GOVERNMENT INTEGRATED APPROACH AIMING AT PROVIDING additional input on maintaining a balance between conservation and community development AND WELLBEING.

The above information is for general public information.

Siem Reap, 16th December 2024
APSARA National Authority

PHNOM PENH:
#4, Russian Blvd, Sangkat Meatapheap,
Khan 7 Makara
Tel/Fax: (855-23) 215 771/215 776

Authority for the Protection and Management of Angkor and the Region of Siem Reap
info@apsaraauthority.gov.kh
http://www.apsaraauthority.gov.kh

SIEM REAP:
Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province
Tel/Fax: (855-63) 765 577/765 576

ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិ ទស្សនាប្រាសាទបាយ័ន នាព្រឹកថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា បញ្ចប់ការងារជួសជុលរួតទី៣ នៅជ្រុងនិរតីនៃប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤

ក្រុមអ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរា ដែលអនុវត្តគម្រោងជួសជុលរួតទី៣ នៅជ្រុងនិរតីនៃប្រាសាទបាយ័ន ដោយប្រើរយៈពេលជាង៤ខែ បញ្ចប់ដោយជោគជ័យ។

កញ្ញា ម៉េង សុវណ្ណលីលីន ស្ថាបត្យករ និងជាប្រធានការដ្ឋាន ឱ្យដឹងថា គម្រោងជួសជុលដំណាក់កាលទី៣ នៅរួតទី៣នៃជ្រុងនិរតី របស់ប្រាសាទបាយ័ន បានធ្វើឱ្យបង្កាន់ដៃនាគ ធ្នឹម និងកម្រាលថ្ម ដែលខូចខាត ប្រសើរឡើងវិញហើយ។ កាលពីឆ្នាំ២០២១ ក្រុមអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរាធ្លាប់បានជួសជុលផ្នែកខ្លះនៃជ្រុងនិរតីរបស់ប្រាសាទបាយ័ន ជាដំណាក់កាលទី១ និងកាលពីឆ្នាំ២០២៣ បានជួសជុលដំណាក់កាលទី២ នៅជ្រុងពាយ័ព្យលើទំហំ១ភាគ៤របស់ប្រាសាទបាយ័ន និងជួសជុលរចនាសម្ពន្ធខឿនផ្នែកខាងលិច។

រួតទី៣ នៅជ្រុងនិរតីនៃប្រាសាទបាយ័ន គឺជាទីតាំងសំខាន់ដែលមានភ្ញៀវទេសចរឆ្លងកាត់ឥតដាច់។ កាលពីមុនពេលជួសជុល គឺធ្នឹមដែលនៅជាប់នឹងខឿនរបស់រួតទី៣បានបែក ដែលអាចប្រឈមនឹងការធ្លាក់ កម្រាលថ្មរងការខូចខាតដោយសារឫសឈើចាក់ចូល ធ្វើឱ្យអ្នកជំនាញត្រូវយកចិត្តទុកដាក់ពង្រឹងរចនាសម្ពន្ធទាំងនោះឡើងវិញ។

ការជួសជុលបានជួយសង្គ្រោះរួតទី៣ នៃប្រាសាទបាយ័ន ឱ្យរួចផុតពីហានិភ័យនានា ព្រមទាំងទប់ស្កាត់ការខូចខាតបានទាន់ពេលវេលា ហើយបច្ចុប្បន្នរួតទី៣ មានភាពរឹងមាំឡើងវិញ និងរក្សាបានទម្រង់ដើមស្ទើរតែទាំងស្រុង៕

ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិ ទស្សនាប្រាសាទអង្គរវត្ត នាព្រឹកថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៤

គម្រោងជួសជុលព្រះលានជល់ដំរី ចំនួន២ទីតាំងនឹងត្រូវបញ្ចប់ នៅចុងខែមករា ឆ្នាំ២០២៥

ផ្សាយនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៤

នៅក្នុងបរិវេណអង្គរធំ គម្រោងជួសជុលព្រះលានជល់ដំរី ចំនួន២ទីតាំង នៅផ្នែកខាងជើងប្រវែង២២ម៉ែត្រ និងផ្នែកខាងត្បូងប្រវែង២១ម៉ែត្រ ក្រោមកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ(KOICA)តាមរយៈទីភ្នាក់ងារបេតិកភណ្ឌកូរ៉េ(KHA) គ្រោងនឹងបញ្ចប់នៅចុងខែមករា ឆ្នាំ២០២៥ ខាងមុខ។

គម្រោងជួសជុលដែលចាប់ផ្តើមដំណើរការយ៉ាងយកចិត្តទុកដាក់ តាំងពីឆ្នាំ២០១៩មក គឺជួសជុលព្រះលានជល់ដំរី ចំនួន២ទីតាំងក្នុងប្រវែងសរុបជាង៤០ម៉ែត្រហើយ រហូតមកដល់បច្ចុប្បន្នបានសម្រេចលទ្ធផលស្ទើរតែទាំងស្រុង ដោយនៅសេសសល់តែការដាប់ឆ្លាក់ថ្មថ្មីជំនួសឱ្យថ្មចាស់ដែលបាត់បង់ប៉ុណ្ណោះ។

លោក EO JINKYU ស្ថាបត្យករ និងជាអ្នកគ្រប់គ្រងគម្រោង ឱ្យដឹងថា ការងារជួសជុលព្រះលានជល់ដំរីទាំង២ទីតាំង នៅផ្នែកខាងត្បូងប្រវែងចំនួន២១ម៉ែត្រ បានបញ្ចប់ទាំងស្រុងហើយ។ ចំណែកនៅផ្នែកខាងជើងប្រវែងចំនួន២២ម៉ែត្រ ក៏បានជួសជុលរួចរាល់រចនាសម្ពន្ធផ្សេងៗ គឺនៅសេសសល់តែការដាប់ធ្លាក់សម្អាតមុខថ្មថ្មីដែលជំនួសថ្មចាស់បាត់បង់។ ការងារនេះនឹងត្រូវបញ្ចប់នៅចុងខែមករា ឆ្នាំ២០២៥ ខាងមុខនេះ។ អ្នកគ្រប់គ្រងគម្រោងដដែលបន្ថែមថា នៅទីតាំងព្រះលានជល់ដំរីប្រវែង២២ម៉ែត្រ នៅផ្នែកខាងជើង គឺបង្កាន់ដៃនាគបានបាត់បង់ទាំងស្រុង ដែលខុសពីផ្នែកខាងត្បូងដែលនៅសេសសល់ និងបានជួសជុលរៀបផ្គុំឡើងវិញទៅតាមលំនាំដើម។

លោក EO JINKYU បញ្ជាក់ថា ស្ថានភាពព្រះលានជល់ដំរីទាំង២ទីតាំង មុនពេលជួសជុលមានហានិភ័យខ្ពស់ ពិសេសផ្នែកខាងជើងបានទ្រេតប្រហែល៨៥ដឺក្រេ។ តាមរយៈកំណាយស្រាវជ្រាវរកឃើញថា គ្រឹះចុះខ្សោយ និងធ្លាប់បានជួសជុលម្តងមកហើយកាលពីសម័យមុន និងនៅសម័យបារាំង។
ការខូចខាតបណ្តាលមកពីទឹកហូរច្រោះ និងផ្នែកខ្លះធ្លាប់បានជួសជុលមិនសូវមានគុណភាពផង។ ដូច្នេះ ការងារជួសជុលត្រូវធ្វើឡើងយ៉ាងប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់យ៉ាងត្រឹមត្រូវតាមបច្ចេកទេសបុរាណដើម្បីរក្សាបាននូវភាពរឹងមាំយូរអង្វែងនៃរចនាសម្ពន្ធនៃព្រះលានជល់ដំរីជាបន្តទៀត៕

រូបភាពប្រចាំសប្តាហ៍÷
ប្រាសាទព្រហ្មកិល
សំណង់ថ្មភក់
កសាងនៅចុងសតវត្សរ៍ទី១២
ដែលជា «ហោបន់ស្រន់»
របស់មន្ទីរព្យាបាលរោគបុរាណ
ផ្សាយនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា មានសេចក្តីសោកស្តាយ និងសោកសៅបំផុត អំពីការទទួលមរណភាព របស់ឯកឧត្តម សាស្ត្រាចារ្យ Federico MAYOR ZARAGOZA

ផ្សាយនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៤

ឯកឧត្តម សាស្ត្រាចារ្យ Federico MAYOR ZARAGOZA គឺជាអតីតអគ្គនាយកនៃអង្គការយូណេស្កូ ដែលបានចូលរួមចំណែកយ៉ាងខ្លាំងក្លាក្នុងការស្តារនិងលើកកម្ពស់កិត្យានុភាពវប្បធម៌កម្ពុជាក្នុងឆាកអន្តរជាតិ។ បើទោះជាកម្ពុជាស្ថិតក្នុងកាលៈទេសៈមានសង្គ្រាមផង និងចរចារស្វែងរកសន្តិភាពផង ឯកឧត្តម សាស្ត្រាចារ្យ បានសម្រេចចិត្តដង្ហែតាមសេចក្តីអំពាវនាវរបស់ព្រះបរមរតនកោដ្ឋ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ដើម្បីផ្តើមយុទ្ធនាការអន្តរជាតិសង្គ្រោះអង្គរ តាំងពីមុនការដាក់បញ្ចូលរមណីយដ្ឋានអង្គរទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូ នាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២ មកម្លេះ។ យុទ្ធនាការជាប្រវត្តិសាស្ត្រនេះ ក្រោយមកបានក្លាយជាយន្តការអន្តរជាតិដើម្បីកិច្ចអភិរក្ស និងអភិវឌ្ឍន៍ដោយចីរភាពរមណីយដ្ឋានអង្គរ ក្នុងឆ្នាំ១៩៩៣ ហើយដែលបានបន្តមកទល់បច្ចុប្បន្ននេះ។

ROYAUME DU CAMBODGE

NATION RELIGION ROI

Ministère de la Culture et des Beaux-Arts

គួររំលឹកផងដែរថា ឯកឧត្តមសាស្ត្រាចារ្យ ក៏ជាអ្នកផ្តួចផ្តើមបើកការិយាល័យតំណាងអង្គការយូណេស្កូនៅទីក្រុងភ្នំពេញ ដើម្បីគាំពារបន្ថែមនូវសកម្មភាពនានាក្នុងការអភិវឌ្ឍនៃកម្ពុជាផងដែរ។

ROYAUME DU CAMBODGE

NATION RELIGION ROI

Ministère de la Culture et des Beaux-Arts

អាជ្ញាធរជាតិអប្សរា រួមជាមួយអ្នកជំនាញការជាតិ និងអន្តរជាតិផ្នែកវប្បធម៌ទាំងអស់ ព្រមទាំងឥស្សរជនជាតិ និងអន្តរជាតិ ដែលបានពួតដៃគ្នាការពារតម្លៃអង្គរ និងបេតិកភណ្ឌជាតិខ្មែរ ដែលជាតម្លៃសកល សូមរំលឹកដោយការដឹងគុណដ៏ជ្រាលជ្រៅ នូវស្មារតីចងចាំចំពោះឯកឧត្តមសាស្ត្រាចារ្យ MAYOR និងសូមវិញ្ញាណក្ខន្ធលោកបានទៅកាន់ទីសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

អាជ្ញាធរជាតិអប្សរា ក៏សូមចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំបំផុតចំពោះការបាត់បង់ដោយគ្មានថ្ងៃវិលត្រឡប់វិញ ជាមួយក្រុមគ្រួសាររបស់ឯកឧត្តម សាស្ត្រាចារ្យ៕

ចម្លាក់ទ្វារបាលនៅប្រាសាទព្រះគោ ជាស្នាដៃសិល្បៈដ៏ប្រណិត នៅចុងសតវត្សរ៍ទី៩ បានទាក់ទាញអារម្មណ៍ភ្ញៀវទេសចរទស្សនាស្វែងយល់ និងថតផ្តិតរូបភាព ពេលដែលបានមកដល់ប្រាសាទនេះ

ផ្សាយនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា បញ្ចប់គម្រោងជួសជុលតួប៉ម នៅជ្រុងឦសាននៃប្រាសាទព្រះគោ ដែលមានអាយុកាលជាង១ពាន់ឆ្នាំ

ផ្សាយនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៤

តួប៉មប្រាសាទឥដ្ឋអាយុកាលជាង១ពាន់ឆ្នាំ នៅជ្រុងឦសាននៃប្រាសាទព្រះគោ ដែលធ្លាប់តែប្រឈមការខូចខាតកម្រិតខ្ពស់ បានប្រែក្លាយជាភាពរឹងមាំ និងល្អប្រសើរឡើងវិញហើយ បន្ទាប់ពីក្រុមអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរាចំណាយពេលប្រហែល៧ខែ ដើម្បីជួយសង្គ្រោះរចនាសម្ពន្ធជាច្រើនផ្នែកមក។

លោក សារាយ គឹមហួល ប្រធានក្រុមអភិរក្សតំបន់រលួស នៃនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យារបស់អាជ្ញាធរជាតិអប្សរា ឱ្យដឹងថា ក្រុមការងារជួសជុលបានពង្រឹងរចនាសម្ពន្ធរបស់ប្រាសាទឥដ្ឋអាយុកាលជាង១ពាន់ឆ្នាំនេះទាំងមូលឡើងវិញ។ ជាមួយគ្នានេះ ក៏មានការជួសជុលផ្តែរ សសរផ្ដោប ទ្វារបញ្ឆោតផ្នែកខាងលិច និងខាងជើង ព្រមទាំងដំបូល។ «នៅតាមជ្រុងនីមួយៗក៏បានពង្រឹងដោយប្រើលក្ខណៈបច្ចេកទេសបិទបាយអ ដើម្បីការពារកុំឱ្យទឹកដក់ក្នុងប្រាសាទ។ ក្រុមការងារក៏ប្រើបច្ចេកទេសនៃការជួសជុលនៅតាមរន្ធទឹក ដែលមានស្នាមប្រេះ ដោយបិទរន្ធទឹកជាថ្មី ដើម្បីកុំឱ្យទឹកហូរចូលទៅក្នុងប្រាសាទ»។

ប្រធានក្រុមអភិរក្សដដែលបានឱ្យដឹងទៀតថា ក្រុមការងារក៏បានរើឥដ្ឋដែលពុកផុយ ឬក៏ឥដ្ឋដែលអាចបង្កឱ្យមានគ្រោះថ្នាក់ចេញ ហើយដាក់ឥដ្ឋថ្មីមួយចំនួនមកជំនួសនៅផ្នែកខាងក្នុង ហើយនៅផ្នែកខាងក្រៅ គឺប្រើឥដ្ឋចាស់ ដើម្បីបង្កើនភាពមាំនៃតួប្រាសាទ ព្រមទាំងរក្សាសោភ័ណភាពបែបបុរាណផង។

តួប៉មនៅជ្រុងឦសាននៃប្រាសាទព្រះគោ ទទួលរងការខូចខាតជាចម្បងគឺ បណ្តាលមកពីបញ្ហាទឹកភ្លៀងហូរចូលទៅក្នុងតួប្រាសាទធ្វើឱ្យមានប្រតិកម្មជាមួយអាចម៍ប្រចៀវបង្កើតទៅជាជាតិអាស៊ីតម្យ៉ាង។ កត្តាអាយុកាលចំណាស់របស់សំណង់ និងអាកាសធាតុ ក៏បានរួមចំណែកធ្វើឱ្យសំណង់ប្រាសាទខូចខាត ដូចជាធ្វើឱ្យឥដ្ឋនៅផ្នែកខាងក្នុងជាច្រើនមានពណ៌ខ្មៅហើយពុកផុយ ដែលទឹកភ្លៀងអាចហូរចូលបានយ៉ាងងាយធ្វើឱ្យរុក្ខជាតិជាច្រើនដុះលូតលាស់ផងដែរ។ ក្រុមអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរាបានចាប់ផ្តើមជួសជុលតួប៉មប្រាសាទឥដ្ឋនៅជ្រុងឦសាននៃប្រាសាទព្រះគោនេះ តាំងតែពីខែឧសភា ឆ្នាំ២០២៤ ហើយបច្ចុប្បន្នការងារដ៏ពិបាកនេះ បានទទួលជោគជ័យ និងបញ្ចប់ជាស្ថាពរ។

អាជ្ញាធរជាតិអប្សរា រួមជាមួយវិស័យឯកជន ផ្តល់ចង្ក្រានបង្កើនថាមពល កាត់បន្ថយការបំពុលបរិស្ថាន ដល់ពលរដ្ឋរស់នៅឃុំបាគង ស្រុកប្រាសាទបាគង

ផ្សាយនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៤ អាជ្ញាធរជាតិអប្សរា រួមជាមួយក្រុមហ៊ុន Guangzhou Iceberg Environmental Consulting Services Co Ltd (ជាំងស៊ូ អៃបឺក អិនវ៉ាយរុន មិនថល ខុនសូលធីសឺវីស)បានប្រគល់ជូនចង្ក្រានបង្កើនថាមពល កាត់បន្ថយការបំពុលបរិស្ថាន ដល់ប្រជាពលរដ្ឋចំនួន៦ភូមិ ក្នុងឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ ពិធីខាងលើ មានការអញ្ជើញចូលរួមពី**ឯកឧត្តម គឹម សុធិន** អគ្គនាយករងអាជ្ញាធរជាតិអប្សរា តំណាង**ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា **ឯកឧត្តម សុខ លក្ខិណា** ទីប្រឹក្សាអាជ្ញាធរជាតិអប្សរា លោក សាខុន ប៉ូរិន ប្រធានក្រុមហ៊ុន Guangzhou Iceberg Environmental Consulting Services Co Ltd លោក សូរ ប្លាតុង អភិបាលស្រុកប្រាសាទបាគង រួមជាមួយភ្ញៀវកិត្តិយស និងបងប្អូនប្រជាពលរដ្ឋជិត១,០០០គ្រួសារ នៅក្នុងឃុំបាគង។

នេះមិនមែនជាលើកទីមួយឡើយ ដែលអាជ្ញាធរជាតិអប្សរា បានសហការជាមួយវិស័យឯកជន ដើម្បីផ្តល់ជូនចង្ក្រានបង្កើនថាមពល កាត់បន្ថយការបំពុលបរិស្ថាន ដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។ សកម្មភាពទាំងនេះ គឺមិនត្រឹមតែបង្ហាញពីការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំចំពោះប្រជាពលរដ្ឋក្នុងមូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ ព្រមទាំងកាត់បន្ថយការបំពុលបរិស្ថានក្នុងសហគមន៍ផងដែរ ព្រោះថាចង្ក្រានដែលមានមាកសញ្ញាព្រៃមាន់ គឺមានលក្ខណៈបច្ចេកទេសក្នុងការកាត់បន្ថយ ដល់ការប្រើប្រាស់បរិមាណអុស និងការបំភាយកាបូនក្នុងកំរិតមួយទាបចូលទៅក្នុងបរិយាកាសជាដើម៕

អាជ្ញាធរជាតិអប្សរា បញ្ចប់ការជួសជុលបណ្ណាល័យ ជ្រុងអាគ្នេយ៍នៃប្រាសាទបាគង

ផ្សាយនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៤

នៅកំឡុងខែធ្នូ ឆ្នាំ២០២៤នេះ អាជ្ញាធរជាតិអប្សរា បញ្ចប់ការងារជួសជុលបណ្ណាល័យខាងជើងនៅជ្រុងអាគ្នេយ៍នៃប្រាសាទបាគង។

លោក សារាយ គឹមហ្វល ប្រធានអភិរក្សតំបន់រលួស ឱ្យដឹងថា បណ្ណាល័យខាងជើងជ្រុងអាគ្នេយ៍របស់ប្រាសាទបាគង រងការខូចខាតខ្លាំងនៅឡើន មានដីចាក់បង្គរ មានផ្នែកខ្លះឥដ្ឋបានពុកផុយ។ ជាពិសេសនៅផ្នែកដំបូល ឥដ្ឋមានសភាពពុកផុយខ្លាំង។ នៅតាមជ្រុងនីមួយៗនៃជញ្ជាំងបណ្ណាល័យបានប្រេះហែក ដែលបណ្តាលមកពីសំណង់មានអាយុកាលជាង១ពាន់ឆ្នាំ បញ្ហាទឹក និងរុក្ខជាតិ ទាមទារការជួសជុលពង្រឹង ទប់ស្កាត់ការខូចខាតជាបន្តទៀត។ អ្នកជំនាញរូបនេះ បញ្ជាក់ថា នេះជាដំណាក់កាលទី៣ នៃការជួសជុលបញ្ចប់តួបណ្ណាល័យនៅជ្រុងអាគ្នេយ៍ នៅជ្រុងខាងត្បូង និងខាងកើត។

ដើម្បីសង្គ្រោះតួបណ្ណាល័យនេះឱ្យមានភាពរឹងមាំ ក្រុមការងារបានរើឥដ្ឋផ្នែកខ្លះដែលពុកផុយ ចុះលេខបញ្ជីឥដ្ឋ និងរើឥដ្ឋនោះម្តងមួយដុំៗទៅតាមបច្ចេកទេស ដើម្បីសម្អាតកំណកដី ឫសស្មៅ និងឫសរុក្ខជាតិ និងរៀបពង្រឹងឥដ្ឋនៅទីតាំងដើមឡើងវិញ និងជួសជុលបិទទីតាំងដែលមានទឹកហូរជ្រាបចូលក្នុងប្រាសាទ រួមទាំងជម្រកសត្វល្អិតផង។
ក្រោយពីបញ្ចប់ការជួសជុលរចនាសម្ពន្ធទាំងមូលរបស់បណ្ណាល័យខាងជើងជ្រុងអាគ្នេយ៍នៃប្រាសាទបាគង នៅដំណាក់កាលទី៣ តួបណ្ណាល័យទទួលបានភាពរឹងមាំឡើងវិញហើយ។ មិនតែប៉ុណ្ណោះ ក្រុមការងារនៅតែបន្តការថែទាំ អភិរក្សតាមដានជាប្រចាំ ដូចជាការសម្អាតស្មៅ ឬរុក្ខជាតិ និងទឹកដក់តាមប្រាសាទដែលជាកង្វល់របស់អ្នកអភិរក្ស៕

អាជ្ញាធរជាតិអប្សរា ជួបពិភាក្សាការងារ ជាមួយស្ថាប័ន ASI

ផ្សាយនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៤

នាព្រឹកថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៤ ឯកឧត្តម គឹម សុធិន អគ្គនាយករងអាជ្ញាធរជាតិអប្សរា ព្រមទាំងសហការី បានទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោក Bhima Azmira ប្រធានស្ថាប័ន Archaeological Survey of India (ASI) ដើម្បីពិភាក្សាលើលទ្ធភាពក្នុងការបន្តកិច្ចសហប្រតិបត្តិការ គម្រោងអភិរក្ស និងជួសជុលប្រាសាទតាព្រហ្ម និងប្រាសាទក្តីសូរ (កុដិស្វរៈ) នាពេលអនាគត។ ក្នុងជំនួបពិភាក្សាគ្នានេះ ភាគីទាំងពីរក៏បានរំឮកពីសមិទ្ធផលសំខាន់ៗមួយចំនួន ក្នុងកិច្ចអភិរក្សរមណីយដ្ឋានអង្គរ ដែលស្ថាប័នទាំងពីរបានសហការរួមគ្នានាពេលកន្លងមកផងដែរ៕

សប្តាហ៍ទី៣នៃធ្នូ ឆ្នាំ២០២៤ ក្រុមការងារសហគមន៍ បន្តចុះពិនិត្យសំណើពលរដ្ឋ នៅក្នុងរមណីយដ្ឋានអង្គរ បានចំនួន២៨ករណី និងសម្រេចអនុញ្ញាត បានចំនួន ២៥ករណី

ផ្សាយនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៤

ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងរមណីយដ្ឋានអង្គរត្រូវបានទទួលនូវការយកចិត្តទុកដាក់អំពីសំណាក់អាជ្ញាធរជាតិអប្សរា ដោយមានការអនុគ្រោះក្នុងការជួសជុលតូចតាចនូវលំនៅដ្ឋានក៏ដូចជាសំណង់ឧបសម្ព័ន្ធមាន របង ដំបូល ជញ្ជាំង សសរពុកផុយ បង្គន់អនាម័យ រោងគោ ទ្រុងមាន់ និងទ្រុងជ្រូកជាដើម ហើយរាល់ការអនុញ្ញាតជួសជុលមានសុពលភាពត្រឹមពីរខែ នៅលើទីតាំងកំពុងរស់នៅផ្ទាល់តែម្តងតាមរយៈការចុះពិនិត្យ និងសម្រេចជាប្រចាំដោយក្រុមការងារសហគមន៍នាយកដ្ឋានគ្រប់គ្រងដីធ្លីបេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា។ ជាក់ស្តែងក្នុងសប្តាហ៍ទី៣នៃខែធ្នូ ក្រុមការងារសហគមន៍បានចុះ ពិនិត្យសំណើបានចំនួន២៨ករណី និងសម្រេចអនុញ្ញាតបានចំនួន ២៥ករណី ទៅតាមបណ្តាលស្រុក/ក្រុងទាំង៧ ដូចខាងក្រោម៖

- ស្រុកបន្ទាយស្រីអនុញ្ញាតបាន ៥ករណី
- ស្រុកពួកអនុញ្ញាតបាន ២ករណី
- ក្រុងសៀមរាបអនុញ្ញាតបាន ១៥ករណី
- ស្រុកអង្គរធំអនុញ្ញាតបាន ៣ករណី

សូមជម្រាបថា រាល់ការដាក់ពាក្យស្នើសុំច្បាប់ និងការអនុញ្ញាត គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ។ ជាមួយគ្នានេះ ក្រុមការងារសង្កេតឃើញថា ក៏មានអ្នកដែលទទួលបានការអនុញ្ញាតហើយ ប៉ុន្តែពុំបានអនុវត្តត្រឹមត្រូវ ស្របនឹងការអនុញ្ញាតនោះឡើយ។ ដូច្នេះអាជ្ញាធរជាតិអប្សរា សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតឱ្យជួសជុលលំនៅដ្ឋានត្រូវអនុវត្តឲ្យស្របតាមចំណុចបច្ចេកទេសដែលមានការទទួលដឹងលឺ ពីអាជ្ញាធរមូលដ្ឋាន និងទទួលស្គាល់ដោយអាជ្ញាធរជាតិអប្សរា៕

សកម្មភាពក្រុមការងារ សម្អាតអនាម័យបន្តសម្អាតបរិស្ថាន នៅតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៤

ក្រុមការងារសម្អាតអនាម័យបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា បានបន្តសកម្មភាពជាប្រចាំ ដើម្បីសម្អាតបរិស្ថាននៅតំបន់រមណីយដ្ឋានអង្គរ។ ការងារនេះធ្វើឡើងក្នុងន័យដើម្បីថែរក្សាសោភ័ណភាព អនាម័យ បរិស្ថាននៅតំបន់រមណីយដ្ឋានអង្គរឱ្យមានភាពស្រស់ស្អាតជាប្រចាំ ដើម្បីទាក់ទាញភ្ញៀវទេសចរ និងស័ក្តិសមជាតំបន់បេតិកភណ្ឌដ៏ពេញនិយមសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ៕

រូបភាពប្រចាំសប្តាហ៍៖ ស្នាមញញឹមនៃកំពូលព្រហ្មមុខបួន នាប្រាសាទបាយ័ន ដែលជាផ្ចិតកណ្តាលនៃក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៤

រីករាយថ្ងៃចុងសប្តាហ៍! ទិដ្ឋភាពប្រាសាទអង្គរវត្ត នាពេលព្រឹកព្រលឹម

ផ្សាយនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៤

សារលិខិតថ្វាយព្រះពរ ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៥

ផ្សាយនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា

សារលិខិតជូនពរ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៥

ផ្សាយនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សារលិខិតជូនពរ

សារលិខិតជូនពរ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៥

ផ្សាយនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សារលិខិតជូនពរ

សារលិខិតជូនពរ លោកជំទាវបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិអប្សរា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៥

ផ្សាយនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សារលិខិតជូនពរ

សារលិខិតជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ឆ្លាក់ខារ ពលករ និងឆ្មាំទាំងអស់នៃអាជ្ញាធរជាតិអប្សរា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល គ.ស. ២០២៥

ផ្សាយនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៤

គ្រប់គ្រងការផលិតទូទៅ

ឯកឧត្តម ឡុង កុសល

អគ្គនាយករងអាជ្ញាធរជាតិអប្សរា

លោក អ៊ឹម សុខរិទ្ធី

ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ

រចនា

លោក រ៉ុង អង្គរវែល

លោក ឆោម មករា

កិច្ចការពារបេតិកភណ្ឌវប្បធម៌
ជាភារកិច្ចរបស់កូនខ្មែរគ្រប់ៗរូប

មជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា

មជ្ឈមណ្ឌលសេវាកម្មត្រូវបានបង្កើតឡើងដើម្បីកែលម្អការផ្តល់សេវាសាធារណៈតាមយន្តការច្រកចេញ-ចូលតែមួយដោយគ្មានធ្វើប្រតិភូកម្មអំណាចក្នុងគោលដៅបម្រើប្រជាជនឱ្យបានប្រសើរជាងមុនតាមរយៈការប្រមូលផ្តុំសេវាកម្មរដ្ឋបាលឱ្យនៅកន្លែងតែមួយ និងកំណត់យ៉ាងច្បាស់លាស់នូវគុណភាព នីតិវិធី ពេលវេលាប្រគល់ឯកសារ និងថ្លៃសេវា។

ទីតាំងមជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា

១- ស្នាក់ការកណ្តាលអាជ្ញាធរជាតិអប្សរា ស្ថិតនៅភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគងខេត្តសៀមរាប
២- ភូមិមណ្ឌលបី សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប (តាមបណ្តោយផ្លូវហ្សាលដឺហ្គោលឆ្ពោះទៅប្រាសាទអង្គរវត្ត)
៣- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលក្រុងសៀមរាប
៤- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកពួក
៥- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកអង្គរធំ
៦- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកបន្ទាយស្រី
៧- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកប្រាសាទបាគង
៨- និងតាមរយៈក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរាប្រចាំក្រុង-ស្រុកទាំង៥ (ចំពោះការស្នើសុំជួសជុលតូចតាច)

លេខទំនាក់ទំនង

សារអេឡិចត្រូនិច
sca_apsara@yahoo.com
លេខទូរស័ព្ទ
+៨៥៥ ៦៣ ៧៦ ៥៥ ៧៧

ម៉ោងបំពេញការងារ

ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ
ពេលព្រឹក ៖ ម៉ោង ៨:០០ព្រឹក - ម៉ោង ១២:០០ថ្ងៃត្រង់
ពេលរសៀល ៖ ម៉ោង ១៣:០០រសៀល - ម៉ោង ១៦:០០រសៀល

ផលិតដោយនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ
ឆ្នាំ២០២៤